# Lowell Public Schools

## សាលាបឋមសិក្សា និងសាលាមធ្យមសិក្សា

## សៀវភៅណែនាំសម្រាប់មាតាបិតា និងសិស្ស

# ឆ្នាំសិក្សា 2026-2027

ទំព័រនេះទុកចោលទំនេរដោយចេតនា

## តារាងមាតិកា


| | |
|---|---|
| ទំព័រហត្ថលេខារបស់មាតាបិតា/អាណាព្យាបាល និងសិស្ស | 1-2 |
| ការអនុញ្ញាតឱ្យចេញផ្សាយព័ត៌មានសិស្ស | 1-4 |
| ទម្រង់បែបបទសង្គ្រោះបន្ទាន់ផ្នែកវេជ្ជសាស្ត្រ | 1-6 |
| គណៈកម្មាធិការសាលា Lowell | 1-8 |
| នាយកដ្ឋានសាលា Lowell | 1-8 |
| សាលាបឋមសិក្សា និងសាលាមធ្យមសិក្សា | 1-10 |
| ការរំពឹងទុក | 1-11 |
| សារៈសំខាន់នៃសាលា | 1-11 |
| គោលបំណង និងគោលដៅ | 1-12 |
| ប្រតិទិនសាលារដ្ឋ Lowell ឆ្នាំ 2024-2025 | 1-13 |
| **គោលនយោបាយស្តីពីការសិក្សា** | 1-14 |
| • គោលនយោបាយស្តីពីការឡើងថ្នាក់/ត្រួតថ្នាក់ – សាលាបឋមសិក្សា | 1-14 |
| • គោលនយោបាយស្តីពីការឡើងថ្នាក់/ត្រួតថ្នាក់ – សាលាមធ្យមសិក្សា | 1-15 |
| **បញ្ហាពាក់ព័ន្ធនឹងនីតិវិធីសម្រាប់សិស្ស** | 1-16 |
| • ការមកដល់ និងការឱ្យចាកចេញពីសាលា | 1-16 |
| • សេចក្តីប្រកាសអំពីការបិទសាលា/ពន្យារពេលចូលរៀន | 1-16 |
| • ការចុះឈ្មោះ-មជ្ឈមណ្ឌលធនធានគ្រួសារ | 1-16 |
| • ការដក និងការផ្ទេរ | 1-17 |
| • កាត/កំណត់ត្រានៃនីតិវិធីសង្គ្រោះបន្ទាន់ | 1-17 |
| • វត្ថុហាមឃាត់ | 1-18 |
| • ការស្លៀកពាក់សមរម្យ | 1-18 |
| • ម្ហូប និងអាវធំ | 1-19 |
| • នីតិវិធីក្នុងការពន្លត់អគ្គិភ័យ/ជម្លៀស | 1-19 |
| • ការហាត់សមសុវត្ថិភាព | 1-19 |

- ទូដាក់សម្ភារ/តុសិស្ស 1-19
- ការបូបហាត់ប្រាណ និងការបូបស្ពាយ 1-20
- សៀវភៅបាត់ សម្ភារៈបង្រៀន ឬទ្រព្យសម្បត្តិផ្សេងទៀតរបស់សាលា 1-20
- កិច្ចការផ្ទះ 1-20
- សកម្មភាពក្រៅកម្មវិធីសិក្សា 1-20
- សេវាគាំពារសិស្ស 1-20
- ការធ្វើទស្សនៈកិច្ចសាលា 1-21
- សេវាកម្មអាហារ 1-21
- គោលនយោបាយស្តីពីការពាក់ម៉ាស LPS 1-21

**ចរិយា និងឥរិយាបថ** 2-1
- ទំនួលខុសត្រូវចំពោះសង្គម 2-1
- ទំនួលខុសត្រូវចំពោះការសិក្សា 2-1
- វិន័យសិស្ស 2-1
- ការព្យួរការសិក្សា និងការបណ្តេញចេញ 2-2
- ការល្មើសធ្ងន់ធ្ងរ 2-2
- បទល្មើសផ្សេងទៀតនៅក្នុងសាលា 2-3
- ការព្យួរការសិក្សានៅក្នុងសាលា 2-4
- ការព្យួរការសិក្សារយៈពេលខ្លី 2-4
- ការដកចេញពីសាលាជាបន្ទាន់ 2-6
- ការព្យួរការសិក្សារយៈពេលវែង និងនីតិវិធីបណ្តឹងឧទ្ធរណ៍ក្រោមច្បាប់ M.G.L. 37H ¾ 2-6
- ការល្មើសធ្ងន់ធ្ងរ៖ ការព្យួរការសិក្សារយៈពេលវែង ឬការបណ្តេញចេញ 2-9
- សវនាការដែលឈានដល់ការព្យួរការសិក្សា ឬការបណ្តេញចេញ 2-9
- នីតិវិធីបណ្តឹងឧទ្ធរណ៍សម្រាប់ការព្យួរការសិក្សា ឬបណ្តេញចេញក្រោមច្បាប់ M.G.L. 37H 2-9
- សិស្សដែលត្រូវបានចោទប្រកាន់ ឬត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋ និងនីតិវិធីបណ្តឹងឧទ្ធរណ៍ក្រោមច្បាប់ M.G.L. 37H ½ 2-9

**ការលើកលែងរបស់គណៈកម្មាធិការសាលា** 2-10
- ស្ថានភាពក្រៅបរិវេណសាលា 2-10
- ការព្យួរការសិក្សា 2-10
- ការបញ្ជូនកំណត់ត្រានៃការបណ្តេញចេញ 2-10
- នីតិវិធីទាក់ទងនឹងវិន័យសិស្សដែលមានតម្រូវការពិសេស 2-11
- ចរិយាពេលជិះឡានក្រុង 2-11

**វត្តមាន** 3-1
- ការមករៀនយឺត 3-2
- ការគេចសាលា និងការគេចមិនចូលថ្នាក់រៀន 3-2
- ការចេញពីសាលា 3-3

- សិស្សមានពិការភាព 3-3

គោលនយោបាយ និងគោលការណ៍ណែនាំទាក់ទងនឹងការឆែកឆេរ និងការរឹបអូស A-1

នីតិវិធីផ្លូវច្បាប់ និងសិទ្ធិប្តឹងឧទ្ធរណ៍ B-1
ការកំហិតសកម្មភាពរាងកាយ B-1
ការរំខានការជួបជុំនៅសាលា B-1
ការបៀតបៀន និងការធ្វើបាប C-1
បទបញ្ញាហាមចូលដោយគ្មានការអនុញ្ញាត C-7
ឱកាសអប់រំស្មើភាព F-1

- គោលនយោបាយស្តីពីការប្រឆាំងនឹងការរើសអើង F-1
- ការមិនរើសអើង F-2

ឱកាសអប់រំស្មើភាព F-2

- នីតិវិធីបណ្តឹងសាទុក្ខ F-3

បណ្តឹងតវ៉ា និងបណ្តឹងសារទុក្ខរបស់សិស្ស F-3

អ្នកសម្របសម្រួល/មន្ត្រីដែលបានជ្រើសតាំង F-4

ការនិយាយបង្អាប់៖ និយមន័យ និងលក្ខខណ្ឌតម្រូវផ្លូវច្បាប់ F-5

- ការល្មើសពីបទនិយាយបង្អាប់ – និយមន័យ និងទោសទណ្ឌ F-5
- កាតព្វកិច្ចរាយការណ៍ពីការនិយាយបង្អាប់ F-5

គោលនយោបាយស្តីពីគ្រឿងញៀន/គ្រឿងស្រវឹង F-6

- ការបង្រៀនអំពីគ្រឿងស្រវឹង ថ្នាំជក់ និងគ្រឿងញៀន F-7

អង្គភាពសុខាភិបាលសាលា G-1

ការអប់រំពិសេស H-1

- នីតិវិធីទាក់ទងនឹងវិន័យសិស្សដែលមានតម្រូវការពិសេស ឬផែនការ H-1
  504 H-1
- ការត្រួតពិនិត្យការកំណត់បាតុភាព (300.523) H-1
- កម្មវិធីសាលាពេលថ្ងៃ និងកម្មវិធីជំនួស J-1
- គោលនយោបាយស្តីពីការប្រើប្រាស់ដែលអាចទទួលយកបាន J-2
- ការប្រើប្រាស់មិនត្រឹមត្រូវ J-2
- J-3
  ផលវិបាកនៃការល្មើសគោលនយោបាយស្តីពីការប្រើប្រាស់ដែលអាច
  ទទួលយកបាន

ការជូនដំណឹងមាតាបិតាទាក់ទងនឹងការអប់រំផ្លូវភេទ J-4

ការជូនដំណឹងមាតាបិតាទាក់ទងនឹង J-5
ការពិនិត្យសុខភាពផ្លូវចិត្ត

បទប្បញ្ញត្តិស្តីពីកំណត់ត្រាសិស្ស M-1

ទំព័រនេះទុកចោលទំនេរដោយចេតនា

## ទំព័រហត្ថលេខារបស់មាតាបិតា/អាណាព្យាបាល និងសិស្ស

សៀវភៅណែនាំសម្រាប់មាតាបិតា/សិស្សមាននៅលើអនឡាញនៅលើគេហទំព័រ៖
http://www.lowell.k12.ma.us

តាមរយៈការចុះហត្ថលេខាខាងក្រោម ខ្ញុំសូមទទួលស្គាល់ថា ខ្ញុំបានចូលមើលសៀវភៅណែនាំរបស់សាលា ហើយខ្ញុំសូមទទួលស្គាល់ថាកូនរបស់ខ្ញុំមានទំនួលខុសត្រូវក្នុងការប្រកាន់ខ្ជាប់នូវគោលនយោបាយទាំងនេះ ហើយអាចប្រឈមនឹងផលវិបាកចំពោះការមិនគោរពតាមច្បាប់។

តាមរយៈការចុះហត្ថលេខាខាងក្រោម ខ្ញុំក៏សូមទទួលស្គាល់ថា
ក្នុងការទទួលបានសិទ្ធិចូលមើលសៀវភៅណែនាំមាតាបិតា/អាណាព្យាបាល និងសិស្សតាមអនឡាញ
ខ្ញុំឥឡូវនេះទទួលបាន
និងមានសិទ្ធិចូលមើលច្បាប់ចម្លងនៃគោលនយោបាយថ្មីរបស់សាលាមណ្ឌលស្ដីពីការបៀតបៀន/ការបៀតបៀនផ្លូវភេទ ចាប់ផ្ដើមពីទំព័រទី 44។

ឈ្មោះសិស្ស (ជាអក្សរពុម្ព)៖________________________________________

លេខសម្គាល់៖ ______________

ឈ្មោះមាតាបិតា/អាណាព្យាបាល៖ __________________________________

អាសយដ្ឋាន៖__________________________________________________

អាផាតមិន # _______ ហ្ស៊ីបកូដ៖ ____________

លេខទូរសព្ទផ្ទះ៖ ___________________________________________

លេខកន្លែងធ្វើការ៖ ________________ទូរសព្ទចល័ត៖ _________

លេខទូរសព្ទពេលអាសន្ន៖ ______________________________________

ឈ្មោះទំនាក់ទំនងពេលអាសន្ន៖ ______________________________

ទំនាក់ទំនង៖ (ពោលគឺ ជីដូនជីតា ពូ និងមិត្តភក្តិ។ល។) ____________________

បញ្ជាក់ថាតើបុគ្គលទំនាក់ទំនងពេលអាសន្នអាចមកយកសិស្សបានដែរឬទេ៖ ____បាទ/ចាស ____ទេ

អាសយដ្ឋានអ៊ីមែលមាតាបិតា៖ ______________________________

តើអ្នកចង់បានសំបុត្រ និងឯកសារផ្ញើតាមរយៈ៖_____សេវាប្រៃសណីយ ____អ៊ីមែល

☐ ខ្ញុំមិនមានសិទ្ធិចូលមើលសៀវភៅណែនាំតាមអនឡាញទេ។ ខ្ញុំស្នើសុំច្បាប់ចម្លងជាក្រដាស។

ហត្ថលេខាមាតាបិតា/អាណាព្យាបាល៖ ______________________ កាលបរិច្ឆេទ៖ __

ហត្ថលេខាសិស្ស៖ ______________________ កាលបរិច្ឆេទ៖ __

***ត្រូវបំពេញដោយការិយាល័យដោយតម្កល់ទុកច្បាប់ចម្លងក្នុងសំណុំឯកសារប៉ុណ្ណោះ។***

______________________

កាលបរិច្ឆេទដែលប្រគល់ច្បាប់ចម្លងជាក្រដាសជូនមាតាបិតា/អាណាព្យាបាល។

ទំព័រនេះទុកចោលទំនេរដោយចេតនា

## ព័ត៌មានសិស្ស ការចេញផ្សាយរូបថត និងវីដេអូ

សូមគោរពមាតាបិតា/អាណាព្យាបាលៈ

ពេញមួយឆ្នាំសិក្សា សាលារដ្ឋ Lowell សូមសម្តែងនូវគោរពចំពោះលទ្ធផលសិក្សាផ្សេងៗរបស់សិស្សយើង។ ព័ត៌មានរបស់សិស្សអាចរួមបញ្ចូលឈ្មោះរបស់សិស្ស ការពិពណ៌នាអំពីលទ្ធផលសិក្សាជាក់ស្តែងនិង/ឬរង្វាន់ការសិក្សាឬអត្តពលកម្ម កម្រិតថ្នាក់របស់សិស្ស ពិន្ទុតេស្តសិក្សា រូបថតនិងវីដេអូ ការងាររបស់សិស្ស។ល។ នេះមិនមែនជាបញ្ជីលម្អិតទេ។

លើសពីនេះទៀត ក្នុងអំឡុងពេលព្រឹត្តិការណ៍សាលា រូបភាពរបស់សិស្សអាចត្រូវបានតាំងបង្ហាញ ថតរូប និង/ឬថតវីដេអូ។ ព័ត៌មានសិស្សនេះអាចត្រូវបានបោះពុម្ពផ្សាយ តាំងបង្ហាញ និង/ឬចម្លង និង/ឬចេញផ្សាយទៅកាន់ប្រព័ន្ធផ្សព្វផ្សាយ (រួមទាំងប៉ុន្តែមិនកំណត់ត្រឹមចំពោះ កាសែត ទូរទស្សន៍ខ្សែកាប/ទូរទស្សន៍ បណ្តាញសង្គម និងអ៊ីនធឺណិត) សម្រាប់ការតាំងបង្ហាញជាសាធារណៈ និង/ឬបោះពុម្ពផ្សាយ/ប្រើប្រាស់នៅក្នុងកាសែតសាលា/មណ្ឌលសិក្សាធិការ នៅលើគេហទំព័រសាលា/មណ្ឌលសិក្សាធិការ និង/ឬដោយភាគីទីបីផ្សេងទៀត។

អនុលោមតាមបទប្បញ្ញត្តិនៃក្រសួងអប់រំរដ្ឋ Massachusetts លេខ 603 CMR 23.00 យើងមានកំណត់លើព័ត៌មានអ្វីខ្លះដែលយើងអាចចែករំលែកទាក់ទងនឹងលទ្ធផលសិក្សារបស់កូនអ្នក ដោយមិនចាំបាច់ទទួលបានការយល់ព្រមជាលាយលក្ខណ៍អក្សរពីអ្នក និងកូនរបស់អ្នកជាមុនឡើយ។

តាមរយៈការចុះហត្ថលេខាលើលិខិតអនុញ្ញាតចេញផ្សាយនេះ ហើយធីកប្រអប់ "បាទ/ចាស" ខាងក្រោម ក្នុងនាមជាមាតាបិតា/អាណាព្យាបាលស្របច្បាប់ និង/ឬសិស្ស (បើសិស្សជាអាណាព្យាបាលស្របច្បាប់ ឬត្រូវបានលើកលែងឲ្យរួចពីកាតព្វកិច្ច) អ្នកសូមទទួលស្គាល់ថា អ្នក និង/ឬសិស្សមានសិទ្ធិស្របច្បាប់ក្នុងការចុះហត្ថលេខាលើលិខិតអនុញ្ញាតចេញផ្សាយនេះ។ អ្នក និង/ឬសិស្សក៏សូមទទួលស្គាល់ថា អ្នក និង/ឬសិស្សមានសិទ្ធិស្របច្បាប់ក្នុងការផ្តល់ឱ្យសាលាសាធារណៈរដ្ឋ Lowell ឬបុគ្គលិក ឬភ្នាក់ងាររបស់ខ្លួននូវសិទ្ធិអំណាចក្នុងការចេញផ្សាយព័ត៌មានរបស់សិស្ស។ លើសពីនេះទៀត តាមរយៈការចុះហត្ថលេខាខាងក្រោម អ្នក និង/ឬសិស្សសូមទទួលស្គាល់ថា អ្នក និង/ឬសិស្សបានយល់ព្រមដោយចេតនា និងដោយស្ម័គ្រចិត្តដើម្បីអនុញ្ញាតឱ្យសាលាសាធារណៈរដ្ឋ Lowell ឬបុគ្គលិក ឬភ្នាក់ងាររបស់ខ្លួនបញ្ចេញព័ត៌មានរបស់សិស្ស

តាមរយៈការចុះហត្ថលេខាលើលិខិតអនុញ្ញាតចេញផ្សាយនេះ ហើយធីកប្រអប់ "បាទ/ចាស" ខាងក្រោម អ្នក និង/ឬសិស្សក៏យល់ព្រមឲ្យរួចពីកាតព្វកិច្ច និងដោះបន្ទុកសាលារដ្ឋ Lowell និង/ឬបុគ្គលិក និង/ឬភ្នាក់ងាររបស់ខ្លួន និងទីក្រុង Lowell រួចពីទំនួលខុសត្រូវណាមួយ និងទាំងអស់ ឬការទាមទារឱ្យទទួលខុសត្រូវ ឬការទាមទារការខូចខាតគ្រប់រូបភាព ទាំងផ្លូវច្បាប់ និងសមធម៌ ដែលអាចកើតឡើងពីការចេញផ្សាយព័ត៌មានរបស់សិស្ស និង/ឬការប្រើប្រាស់ខុសគោលដៅដោយចេតនា ឬក្នុងរូបភាពផ្សេងដោយភាគីទីបី ឬបុគ្គល ឬជនផ្សេងទៀត។ ជាពិសេសចំពោះរូបថត និងវីដេអូដែលអ្នក និង/ឬសិស្សក៏យល់ព្រមឲ្យរួចពីកាតព្វកិច្ច និងដោះបន្ទុកសាលារដ្ឋ Lowell និង/ឬបុគ្គលិក និង/ឬភ្នាក់ងាររបស់ខ្លួន និងទីក្រុង Lowell រួចផុតពីទំនួលខុសត្រូវណាមួយដែលអាចកើតឡើងដោយសារការបង្ខូចទ្រង់ទ្រាយ ការធ្វើឱ្យព្រិល ការកែប្រែ ការបំភាន់ភ្នែក ឬប្រើប្រាស់ក្នុងទម្រង់ផ្សំ ទោះដោយចេតនា ឬតាមវិធីផ្សេង ហើយអ្នក និង/ឬសិស្សយល់ថា អ្នក និង/ឬសិស្សបោះបង់សិទ្ធិទាំងអស់ចំពោះប្រាក់កម្រៃណាមួយសម្រាប់ការប្រើប្រាស់
និង/ឬការប្រើប្រាស់ជាបន្តបន្ទាប់នៃរូបថត និង/ឬវីដេអូ ហើយយល់ថា រូបភាពដែលបានបង្ហោះនៅលើអ៊ីនធឺណិតអាចត្រូវបានជនដទៃមើល និងទាញយកបាន។

☐ ☐ បាទ/ចាស ខ្ញុំសូមផ្តល់ការអនុញ្ញាត ☐ ☐ ទេ ខ្ញុំមិនផ្តល់ការអនុញ្ញាតទេ។

ឈ្មោះសិស្ស៖ ________________________ សាលា/គ្រូ៖ ________________

សូមសរសេរជាអក្សរពុម្ព

ហត្ថលេខារបស់សិស្ស៖ ________________________ កាលបរិច្ឆេទ៖ ___

ហត្ថលេខារបស់មាតាបិតា/អាណាព្យាបាល៖ ________________ កាលបរិច្ឆេទ៖ ___

ហត្ថលេខារបស់មាតាបិតា/អាណាព្យាបាល៖ ________________ កាលបរិច្ឆេទ៖ ___

ទំព័រនេះទុកចោលទំនេរដោយចេតនា

# ទម្រង់បែបបទសង្គ្រោះបន្ទាន់ផ្នែកវេជ្ជសាស្ត្រ

សិស្ស៖ ______________________________ កាលបរិច្ឆេទកំណើត៖ _________ថ្នាក់ទី៖ _____
HR _______

អាសយដ្ឋាន ___________________________________________________ទូរសព្ទនៅផ្ទះ
____________________________________________

ឪពុកម្ដាយ/អាណាព្យាបាល _________________________________________
លេខទូរសព្ទនៅផ្ទះ៖ ___________________________________________

លេខទូរសព្ទកន្លែងការងាររបស់ឪពុកម្ដាយ/អាណាព្យាបាល
_________________លេខទូរសព្ទដៃរបស់ឪពុកម្ដាយ/អាណាព្យាបាល ____________________

លេខទូរសព្ទកន្លែងការងាររបស់ឪពុកម្ដាយ/អាណាព្យាបាល _________________
លេខទូរសព្ទដៃរបស់ឪពុកម្ដាយ/អាណាព្យាបាល _____________________

គ្រូពេទ្យរបស់សិស្ស____________________________ លេខទូរសព្ទ
_____________________________

**រាយឈ្មោះមនុស្សពេញវ័យចំនួន 3 នាក់ក្នុងតំបន់មូលដ្ឋាន (ក្រៅពីឪពុកម្ដាយ/អាណាព្យាបាល) ដែលនឹងទទួលការថែទាំកូនរបស់អ្នកភ្លាមៗ ឬមកយកកូនរបស់អ្នកនៅសាលារៀន ក្នុងករណីមានជំងឺ ឬមានអាសន្ន៖**

ឈ្មោះ៖ ______________________________ ទូរសព្ទ៖ ____________________
ឈ្មោះ៖ ______________________________ ទូរសព្ទ៖ ____________________
ឈ្មោះ៖ ______________________________ ទូរសព្ទ៖ ____________________

គូសរង្វង់ជម្រើស**ទាំងអស់**នៃលក្ខខណ្ឌសុខភាពបច្ចុប្បន្ន ឬសកម្ម ដែលអនុវត្តចំពោះកូនរបស់អ្នក៖

ADD ADHD ការថប់បារម្ភ ជំងឺហឺត ជំងឺអូទីសឹម/PDD ជំងឺពិការខួរក្បាល ជំងឺធ្លាក់ទឹកចិត្ត ជំងឺទឹកនោមផ្អែម ជំងឺបេះដូង

ប្រតិកម្មជាតិស្ករឡាក់តូសក្នុងទឹកដោះ ជំងឺឈឺក្បាលប្រកាំង ផ្សេងទៀត (សូមរាយ)

___________________________

បញ្ហាភ្នែក (សូមបញ្ជាក់) វ៉ែនតា ____ កញ្ចក់កែវភ្នែក ______ កន្លែងអង្គុយដែលពេញចិត្ត ___

បញ្ហាត្រចៀក (សូមបញ្ជាក់) ឆ្វេង ____ ស្តាំ ____ ឧបករណ៍ជំនួយការស្តាប់៖ ឆ្វេង ____ ស្តាំ____
កន្លែងអង្គុយដែលពេញចិត្ត ___

អាលែកហ្ស៊ី (សូមរាយ)________________________________________________

តើកូនរបស់អ្នកមានវេជ្ជបញ្ជាថ្នាំ **Epi pen** សម្រាប់ការព្យាបាលអាលែកហ្ស៊ីដែលបានរាយខាងលើដែរឬទេ? បាទ/ចាស ទេ

រាយឈ្មោះថ្នាំ និងដូសដែលកូនអ្នកលេបជាប្រចាំ ឬតាមតម្រូវការ៖

________________________________________________

__________________________________________

តើកូនរបស់អ្នកមានការធានារ៉ាប់រងសុខភាពដែរឬទេ? បាទ/ចាស ទេ MassHealth? បាទ/ចាស ទេ

ខ្ញុំសូមផ្តល់ការអនុញ្ញាតឱ្យគិលានុបដ្ឋាកសាលាចែករំលែកព័ត៌មានទាក់ទងនឹងស្ថានភាពសុខភាពរបស់កូនខ្ញុំជាមួយបុគ្គលិកសាលាសមស្របតាមតម្រូវការ ដើម្បីបំពេញតម្រូវការសុខភាព និងសុវត្ថិភាពរបស់កូនខ្ញុំ។ បាទ/ចាស ទេ

ក្នុងករណីមានអាសន្ន កូនរបស់អ្នកនឹងត្រូវបញ្ជូនទៅមន្ទីរពេទ្យតាម EMS។

ខ្ញុំសូមអនុញ្ញាតឱ្យគិលានុបដ្ឋាកសាលាទាក់ទងទៅគ្រូពេទ្យរបស់កូនខ្ញុំក្នុងករណីចាំបាច់។

ហត្ថលេខារបស់មាតាបិតា/អាណាព្យាបាល
___________________________កាលបរិច្ឆេទ៖____________

ទំព័រនេះទុកចោលទំនេរដោយចេតនា

## គណៈកម្មាធិការសាលា Lowell

Erik R. Gitschier, ចៅហ្វាយក្រុង - ប្រធាន

Dave Conway, អនុប្រធាន

Fred Bahou

Dominic Lay

Eileen DelRoss

Danielle McFadden

Connie A. Martin

## នាយកដ្ឋានសាលារៀន Lowell

Lowell Public Schools
155 Merrimack Street
Lowell, MA 01852

Liam Skinner, អគ្គនាយកសាលា

James P. Hall, ជំនួយការ អគ្គនាយកផ្នែកប្រតិបត្តិការ

Wendy Crocker Roberge, ជំនួយការអគ្គនាយកផ្នែកដឹកនាំសាលា

Oneida Fox Roye, ជំនួយការអគ្គនាយកផ្នែកសិក្សា និងកិច្ចការបង្រៀន

Alice Brown-Legrand, ជំនួយការអគ្គនាយកផ្នែកសេវាគាំទ្រសិស្ស

Derek Pinto  ជំនួយការអគ្គនាយកផ្នែកហិរញ្ញវត្ថុ

ទំព័រនេះទុកចោលទំនេរដោយចេតនា

# សាលាបឋមសិក្សា និងសាលាមធ្យមសិក្សា

| សាលា | រដ្ឋបាល | លេខទូរសព្ទ |
|---|---|---|
| Bailey | Kimberly Clements | 978-937-7644 |
| Bartlett Community Partnership | Dr. Mathew McLean | 978-937-8968 |
| Butler | Jaime Moody | 978-937-8973 |
| Early Childhood Center @ Cardinal O' Connell | Kerri Wilcox | 978-446-7000 |
| Daley | Brendan Asquith | 978-937-8981 |
| Dr. Janice Adie Day School | Christine Adams | 978-674-2400 |
| Greenhalge | Brendan Case | 978-937-7670 |
| Laura Lee | Kristin Mckay | 978-937-7655 |
| Leblanc | Carolyn Cuneo | 978-970-5467 |
| Lincoln | Kerien Driscoll | 978-937-2846 |
| McAuliffe | David Anderson | 978-937-2838 |
| McAvinnue | Michael Domina | 978-937-2871 |
| Moody | Roberta Keefe | 978-937-7673 |
| Morey | Dr. Kathleen McLaughlin | 978-937-7662 |
| Murkland | Kevin Andriolo | 978-937-2826 |
| Pawtucketville Memorial | Paula Jones | 978-937-7667 |
| Pyne Arts Magnet | Lori Lang | 978-937-7639 |
| Reilly | Ron Fusco | 978-937-7652 |
| Riverside (BRIDGE) | Brian Twomey | 978-453-1115 |
| Robinson | Bridget Dowling | 978-937-8974 |
| Rogers STEM | Dr. Gregory Passeri | 978-674-2040 |
| Shaughnessy | Dr. Jason McCrevan | 978-937-7657 |
| Stoklosa | James Cardaci | 978-275-6330 |
| Sullivan | Sean Carabatsos | 978-937-8993 |

| | | |
|---|---|---|
| Wang | Andrea Gobbi | 978-937-7683 |
| Washington | Jennifer Lilley | 978-937-7635 |

## ការរំពឹងទុក

សុភវិនិច្ឆ័យ និងច្បាប់នានានៃរដ្ឋ Massachusetts តម្រូវឱ្យគណៈកម្មាធិការសាលាក្រុង Lowell អនុវត្តសំណុំនៃនីតិវិធី គោលនយោបាយ និងវិធានដើម្បីគ្រប់គ្រងចរិយារបស់សិស្សនៅក្នុងសាលារដ្ឋ Lowell។ វិធាន និងបទប្បញ្ញត្តិទាំងនេះមានគោលបំណងការពារសិស្ស និងផ្តល់នូវបរិយាកាសសុវត្ថិភាព និងសណ្តាប់ធ្នាប់ ដែលពួកគេអាចរៀនសូត្រ និងរីកចម្រើន។ វិធានទាំងនេះមិនមានលក្ខណៈទាមទារ ពិបាក ឬមិនសមហេតុផលនោះទេ។ វាផ្អែកលើសុជីវធម៌ និងការគោរពដើម្បីផលប្រយោជន៍ទូទៅសម្រាប់អ្នកទាំងអស់។

**ជូនចំពោះសិស្សរបស់យើង៖** យើងសូមស្នើសុំឱ្យអ្នកចូលរួមសហការ។ សូមអានសៀវភៅណែនាំនេះដោយយកចិត្តទុកដាក់។ ស្វែងយល់ពីអ្វីដែលអ្នករំពឹងទុក - ពោលគឺអ្វីដែលត្រូវ និងអ្វីដែលខុស។ តាមរយៈចំណេះដឹងនេះ អ្នកអាចធ្វើការសម្រេចចិត្តបានល្អអំពីចរិយារបស់អ្នកនៅក្នុងសាលា។

**ជូនចំពោះមាតាបិតា ឬអាណាព្យាបាលសិស្សរបស់យើង៖** យើងស្នើឱ្យអ្នកគាំទ្រវិធាន និងបទប្បញ្ញត្តិទាំងនេះ។ ពិនិត្យមើលវិធាន និងបទប្បញ្ញត្តិទាំងនេះជាមួយកូនរបស់អ្នក ហើយស្វែងយល់ថាសាលារៀនគឺជាសហគមន៍មួយ ហើយប្រសិនបើសមាជិកទាំងអស់នៃសហគមន៍នេះ (សិស្ស និងបុគ្គលិក) មានសុជីវធម៌ ការគោរព និងចេះគិតគូរ នោះសាលារៀននឹងក្លាយជាបទពិសោធន៍ដ៏រីករាយ មានផលិតភាព និងមានអត្ថន័យ។

យើងសូមលើកទឹកចិត្តឱ្យអ្នកទាក់ទងគ្រូរបស់កូនៗអ្នក និងអ្នកគ្រប់គ្រងអគារពាក់ព័ន្ធនឹងសំណួរ ឬកង្វល់ផ្សេងៗដែលអ្នកអាចមាន។ ការចូលរួមក្នុងកិច្ចប្រជុំមាតាបិតា/គ្រូ កម្មវិធីសាលា សកម្មភាពគ្រួសារដែលឧបត្ថម្ភដោយសាលា និងធ្វើការដោយសហការជាមួយបុគ្គលិកសាលានឹងបង្កើនបទពិសោធន៍អប់រំរបស់កូនអ្នក។

## សេចក្តីថ្លែងការណ៍ទូទៅស្តីពីចរិយា និងឥរិយាបថ

សៀវភៅណែនាំនេះមិនលម្អិត ឬគ្រប់ជ្រុងជ្រោយ ដោយរួមបញ្ចូលរាល់ស្ថានភាព ឥរិយាបថ និងផលវិបាកដែលអាចកើតមានទាំងអស់នៃឥរិយាបថទាំងនេះ ដែលនាំឱ្យមានការប្រព្រឹត្តល្មើសលើគោលនយោបាយ នីតិវិធី ឬច្បាប់រដ្ឋ ឬច្បាប់សហព័ន្ធទេ។ នេះគឺជាក្របខណ្ឌសមស្របដែលបុគ្គលមានទំនួលខុសត្រូវអាចកសាងសហគមន៍អ្នកសិក្សាបាន។ រដ្ឋបាលសាលារក្សាសិទ្ធិក្នុងការចាត់វិធានការណាមួយដែលយល់ឃើញថាចាំបាច់ និងសមស្រប

ថាតើត្រូវដោះស្រាយជាពិសេសនៅក្នុងសាលាឬអត់។

## សារៈសំខាន់នៃសាលា

សាលាបឋមសិក្សា និងមធ្យមសិក្សាគឺជាបរិយាកាសអប់រំដែលកំណត់ដោះត់បមសិលើបញ្ហាបុគ្គលិកលក្ខណៈពិសេសប្លែកពីគេក៏ដូចជាតម្រូវការអភិវឌ្ឍន៍ និងបញ្ហារបស់សិស្សខ្លួន។ នៅក្នុងសាលាបឋមសិក្សា និងមធ្យមសិក្សា តម្រូវការអភិវឌ្ឍន៍ និងតម្រូវការផ្នែកបញ្ហាទាំងនេះត្រូវបានបំពេញតាមរយៈកម្មវិធីសិក្សាផ្តោតលើសិស្ស ដែលកូនសិស្សអាចរីកចម្រើនក្នុងបរិយាកាសដ៏កក់ក្តៅ និងមានការយកចិត្តទុកដាក់ខ្ពស់។ នៅទីក្រុង Lowell ឆ្នាំសិក្សាបឋមសិក្សាដែលផ្តោតលើការថែទាំកុមាររួមមានថ្នាក់ Pk-4។ ឆ្នាំសិក្សាមធ្យមសិក្សារួមមានថ្នាក់ទី 5 ដល់ទី 8 ដែលក្មេងជំទង់វ័យក្មេងទទួលបានជំនួយដ៏សំខាន់ដែលពួកគេត្រូវការដើម្បីទទួលបាន៖

- ភាពជឿជាក់លើខ្លួនឯងយូរអង្វែង
- ទម្លាប់ចេះបត់បែន និងចេះឆ្លល់
- ទំនាក់ទំនងអាចទុកចិត្តបាន និងជិតស្និទ្ធជាមួយមនុស្ស
- ការយល់ពីភាពជាកម្មសិទ្ធិនៅក្នុងក្រុមដ៏មានតម្លៃ
- ការយល់ពីប្រយោជន៍តាមវិធីណាមួយក្រៅពីខ្លួន
- ការយល់ពីទំនួលខុសត្រូវ
- ឱកាសអនុវត្តការងារជាក្រុម

## គោលបំណង និងគោលដៅ

គោលបំណង និងគោលដៅរបស់សាលារដ្ឋ Lowell គ្របដណ្តប់លើការអភិវឌ្ឍទាំងមូលរបស់សិស្សសាលាមធ្យមសិក្សា។ ដើម្បីសម្រេចបាននូវគោលដៅទាំងនេះ វាជារឿងសំខាន់ដែលបុគ្គលិកសាលា សិស្ស និងឪពុកម្តាយធ្វើការរួមគ្នាដើម្បី៖

1. ជួយសិស្សអភិវឌ្ឍសមត្ថភាពគិត
2. បំពាក់បំប៉នសិស្សនូវជំនាញសិក្សាដ៏រឹងមាំ
3. ជួយសិស្សអភិវឌ្ឍសមត្ថភាពទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព
4. ជួយសិស្សឱ្យមានភាពច្នៃប្រឌិត
5. ជួយសិស្សឱ្យយល់ពីសេចក្តីថ្លៃថ្នូរ និងតម្លៃផ្ទាល់ខ្លួន
6. ជួយសិស្សឲ្យបង្កើតវិន័យខ្លួនឯង
7. ជួយសិស្សឱ្យស្វែងយល់តម្រូវការដើម្បីផ្តួចផ្តើមការផ្លាស់ប្តូរ និងសម្របខ្លួនទៅនឹងការផ្លាស់ប្តូរពេញមួយជីវិតរបស់ពួកគេ
8. ជួយសិស្សឱ្យរៀនស្វែងរកភាពរីករាយក្នុងជីវិត
9. ជំរុញការយល់ដឹង និងការគោរពចំពោះភាពខុសគ្នារបស់មនុស្ស និងគំនិត
10. ជួយសិស្សឱ្យយល់ពីទំនួលខុសត្រូវចំពោះសង្គម និងដឹងពីតម្រូវការរបស់អ្នកដទៃ
11. ជំរុញឲ្យមានជំនឿលើលទ្ធិប្រជាធិបតេយ្យតាមរយៈការយល់ដឹងអត្ថន័យរបស់វា និងរបៀបដែលមនុស្សអាចធ្វើឱ្យវាដំណើរការបាន
12. រៀបចំសិស្សត្រៀមធ្វើការសម្រេចចិត្តវិជ្ជាជីវៈ
13. លើកកម្ពស់សុខភាពផ្លូវចិត្ត និងផ្លូវកាយ
14. ជំរុញចំណង់ចង់បន្តការសិក្សាពេញមួយជីវិត
15. អភិវឌ្ឍឥរិយាបថ និងអាកប្បកិរិយាដែលនាំទៅរកការធ្វើការសម្រេចចិត្តល្អ

**Lowell Public Schools 2026-2027 School Year Calendar**

អគ្គនាយកប្រតិបត្តិ សាលារៀនសាធារណៈ **Lowell** - ទីក្រុង **Lowell** រដ្ឋ **Massachusetts**

## ប្រតិទិនឆ្នាំសិក្សា ២០២៦-២០២៧

| | |
|---|---|
| ថ្ងៃចន្ទ ទី៣១ ខែសីហា ឆ្នាំ២០២៦ | បុគ្គលិកត្រឡប់មកសាលាវិញ - ទិវាណែនាំសម្រាប់បុគ្គលិក |
| ថ្ងៃអង្គារ ទី១ ខែកញ្ញា ឆ្នាំ២០២៦ | មិនមានការសិក្សា ការបោះឆ្នោតបឋមក្នុងតំបន់ - ថ្ងៃបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់បុគ្គលិក |
| ថ្ងៃពុធ ទី២ ខែកញ្ញា ឆ្នាំ២០២៦ | ថ្ងៃចូលរៀនថ្ងៃដំបូង - ថ្នាក់ទី ១ ដល់ទី ១២ |
| ថ្ងៃសុក្រ ទី៤ ខែកញ្ញា ឆ្នាំ២០២៦ | គ្មានការសិក្សា ទិវាពលកម្ម |
| ថ្ងៃចន្ទ ទី៧ ខែកញ្ញា ឆ្នាំ២០២៦ * | មិនមានការសិក្សា– ទិវាពលកម្ម |
| ថ្ងៃអង្គារ ទី៨ ខែកញ្ញា ឆ្នាំ២០២៦ | ថ្ងៃចូលរៀនដំបូង - ថ្នាក់មុនមត្តេយ្យ **(Pre-K)** និងថ្នាក់មត្តេយ្យ |
| ថ្ងៃពុធ ទី៧ ខែតុលា ឆ្នាំ២០២៦ | ចេញមុនម៉ោងសម្រាប់ថ្នាក់ **K-12** (ថ្នាក់ **PK** មិនមានរៀនទេ) |
| ថ្ងៃចន្ទ ទី១២ ខែតុលា ឆ្នាំ២០២៦ * | គ្មានការសិក្សា - ទិវាជនជាតិដើមភាគតិច |
| ថ្ងៃអង្គារ ទី៣ ខែវិច្ឆិកា ឆ្នាំ២០២៦ | ថ្ងៃបោះឆ្នោត - សាលារៀននៅតែបើកដំណើរការធម្មតា |
| ថ្ងៃពុធ ទី១១ ខែវិច្ឆិកា ឆ្នាំ២០២៦ | គ្មានការសិក្សា - ការប្រារព្ធទិវាអតីតយុទ្ធជន |
| ថ្ងៃពុធ ទី២៥ ខែវិច្ឆិកា ឆ្នាំ២០២៦ | ការអនុញ្ញាតឱ្យត្រឡប់ទៅផ្ទះមុនម៉ោង – វិស្សមកាលបុណ្យ **Thanksgiving** (ថ្នាក់មត្តេយ្យសិក្សា/**PK** មិនមានការរៀនសូត្រ) |
| ថ្ងៃព្រហស្បតិ៍ ទី២៦ ខែវិច្ឆិកា ឆ្នាំ២០២៦* | មិនមានការសិក្សា - ទិវាអរព្រះគុណ **(Thanksgiving Day)** |
| ថ្ងៃសុក្រ ទី២៧ ខែវិច្ឆិកា ឆ្នាំ២០២៦ * | គ្មានការសិក្សា - វិស្សមកាលបុណ្យ **Thanksgiving** |
| ថ្ងៃចន្ទ ទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៦ | សាលាបើកដំណើរការឡើងវិញ |
| ថ្ងៃពុធ ទី២ ខែធ្នូ ឆ្នាំ២០២៦ | ចេញមុនម៉ោងសម្រាប់ថ្នាក់ **K-12** (ថ្នាក់ **PK** មិនមានរៀនទេ) |

| | |
|---|---|
| ថ្ងៃពុធ ទី២៣ ខែធ្នូ ឆ្នាំ២០២៦ | វិស្សមកាលរដូវរងាចាប់ផ្តើមនៅពេលថ្ងៃត្រូវបានបញ្ចប់ |
| ថ្ងៃព្រហស្បតិ៍ ទី២៤ ខែធ្នូ ឆ្នាំ២០២៦* | ថ្ងៃមុនបុណ្យណូអែល |
| ថ្ងៃសុក្រ ទី២៥ ខែធ្នូ ឆ្នាំ២០២៦* | ថ្ងៃបុណ្យណូអែល |
| ថ្ងៃព្រហស្បតិ៍ ទី៣១ ខែធ្នូ ឆ្នាំ២០២៦* | រាត្រីមុនថ្ងៃចូលឆ្នាំថ្មី |
| ថ្ងៃសុក្រ ទី១ ខែមករា ឆ្នាំ២០២៧* | ថ្ងៃចូលឆ្នាំថ្មី |
| ថ្ងៃចន្ទ ទី៤ ខែមករា ឆ្នាំ២០២៧ | សាលាបើកដំណើរការឡើងវិញ |
| ថ្ងៃពុធ ទី១៣ ខែមករា ឆ្នាំ២០២៧ | ចេញមុនម៉ោងសម្រាប់ថ្នាក់ **K-12** (ថ្នាក់ **PK** មិនមានរៀនទេ) |
| ថ្ងៃចន្ទ ទី១៨ ខែមករា ឆ្នាំ២០២៧ * | គ្មានការសិក្សា - ថ្ងៃ **Martin Luther King, Jr.** |
| ថ្ងៃពុធ ទី៣ ខែកុម្ភៈ ឆ្នាំ២០២៧ | ចេញមុនម៉ោងសម្រាប់ថ្នាក់ **K-12** (ថ្នាក់ **PK** មិនមានរៀនទេ) |

| | |
|---|---|
| ថ្ងៃសុក្រ ទី១២ ខែកុម្ភៈ ឆ្នាំ២០២៧ | វិស្សមកាលពាក់កណ្ដាលរដូវរងាចាប់ផ្ដើមនៅពេលបញ្ចប់ការសិក្សា |
| ថ្ងៃចន្ទ ទី១៥ ខែកុម្ភៈ ឆ្នាំ២០២៧ * | ទិវាប្រធានាធិបតី [វិស្សមកាលពាក់កណ្ដាលរដូវរងា៖ ថ្ងៃចន្ទ ទី១៥ ខែកុម្ភៈ - ថ្ងៃសុក្រ ទី១៩ ខែកុម្ភៈ ឆ្នាំ២០២៧] |
| ថ្ងៃចន្ទ ទី២២ ខែកុម្ភៈ ឆ្នាំ២០២៧ | សាលាបើកដំណើរការឡើងវិញ |
| ថ្ងៃពុធ ទី៣ ខែមិនា ឆ្នាំ២០២៧ | ចេញមុនម៉ោងសម្រាប់ថ្នាក់ **K-12** (ថ្នាក់ **PK** មិនមានរៀនទេ) |
| ថ្ងៃសុក្រ ទី២៦ ខែមីនា ឆ្នាំ២០២៧ * | គ្មានការសិក្សា **–** ថ្ងៃសុក្រល្អ **(Good Friday)** |
| ថ្ងៃសុក្រ ទី១៦ ខែមេសា ឆ្នាំ២០២៧ | វិស្សមកាលរដូវផ្ការីកចាប់ផ្ដើមនៅពេលបញ្ចប់ការសិក្សា |
| ថ្ងៃចន្ទ ទី១៩ ខែមេសា ឆ្នាំ២០២៧ * | **Patriot's Day -** [វិស្សមកាលរដូវផ្ការីក៖ ថ្ងៃចន្ទ ទី១៩ ខែមេសា – ថ្ងៃសុក្រ ទី២៣ ខែមេសា ឆ្នាំ២០២៧] |
| ថ្ងៃចន្ទ ទី២៦ ខែមេសា ឆ្នាំ២០២៧ | សាលាបើកដំណើរការឡើងវិញ |
| ថ្ងៃពុធ ទី១២ ខែឧសភា ឆ្នាំ២០២៧ | ចេញមុនម៉ោងសម្រាប់ថ្នាក់ **K-12** (ថ្នាក់ **PK** មិនមានរៀនទេ) |

| | |
|---|---|
| ថ្ងៃចន្ទ ទី៣១ ខែឧសភា ឆ្នាំ២០២៧* | គ្មានការសិក្សា – ទិវាឧទ្ទិសដល់វីរជនយោធា **(Memorial Day)** |
| ថ្ងៃពុធ ទី១៦ ខែមិថុនា ឆ្នាំ២០២៧ | ថ្ងៃសិក្សាទី ១៨០ - ការអនុញ្ញាតឱ្យចេញមុនម៉ោងសម្រាប់ថ្នាក់ **K-12** នៅថ្ងៃចុងក្រោយនៃឆ្នាំសិក្សា (ថ្នាក់ **PK** មិនមានការរៀនទេ) |
| ថ្ងៃសុក្រ ទី១៨ ខែមិថុនា ឆ្នាំ២០២៧* | ទិវា **Juneteenth** |
| ថ្ងៃព្រហស្បតិ៍ ទី២៨ ខែមិថុនា ឆ្នាំ២០២៧ | ថ្ងៃសិក្សាទី ១៨៥ [រួមបញ្ចូលថ្ងៃឈប់សម្រាកដោយសារព្រិលធ្លាក់ចំនួន ៥ ថ្ងៃ] |

ប្រតិទិនឆ្នាំសិក្សា ២០២៦-២០២៧ នេះ អនុម័តដោយគណៈកម្មាធិការសាលា **Lowell** នៅក្នុងកិច្ចប្រជុំរបស់ពួកគេ។ *ការិយាល័យកណ្ដាល និង មជ្ឈមណ្ឌល ធនធានសម្រាប់គ្រួសារ (FRC) នឹងបិទទ្វារ សំរាប់ថ្ងៃឈប់សម្រាក។

ចំនួនថ្ងៃសិក្សាក្នុងមួយខែមានដូចខាងក្រោម:

| ខែ | ថ្ងៃ | ខែ | ថ្ងៃ | ខែ | ថ្ងៃ | ខែ | ថ្ងៃ |
|---|---|---|---|---|---|---|---|
| សីហា | 0 | វិច្ឆិកា | ១៨ | កុម្ភៈ | ១៥ | ឧសភា | ២០ |
| កញ្ញា | ១៩ | ធ្នូ | ១៧ | មិនា | ២២ | មិថុនា | ១២ |
| តុលា | ២១ | មករា | ១៩ | មេសា | ១៧ | | |

# គោលនយោបាយស្តីពីការសិក្សា

## គោលនយោបាយឡើងថ្នាក់/ត្រួតថ្នាក់—សាលាបឋមសិក្សា

វឌ្ឍនភាពរបស់សិស្ស គោលនយោបាយស្តីពីការឡើងថ្នាក់ និងត្រួតថ្នាក់ - សាលាបឋមសិក្សា

បុគ្គលិកផ្នែករដ្ឋបាល និងបុគ្គលិកផ្នែកបង្រៀនខិតខំបង្កើតផែនការបង្រៀន និងការរៀបចំការបង្រៀន ដែលផ្តល់ឱកាសអតិបរមាសម្រាប់ឱ្យសិស្សរីកចម្រើនក្នុងសាលារៀន ស្របតាមតម្រូវការ និងសមត្ថភាពរបស់ពួកគេផ្ទាល់ ដោយមិនមានការមាក់ងាយពីការធ្លាក់ ឬការត្រួតថ្នាក់។ សិស្សទាំងអស់មានសិទ្ធិឡើងថ្នាក់នៅពេលបញ្ចប់ការសិក្សាកាលពីឆ្នាំមុនដោយជោគជ័យ។ ការដាក់ពិន្ទុ និងការឡើងថ្នាក់នឹងផ្អែកលើភាពរីកចម្រើន លទ្ធផល សមត្ថភាពរបស់សិស្ស និងការវិនិច្ឆ័យប្រកបដោយវិជ្ជាជីវៈរបស់គ្រូ និងនាយកសាលា។

សូមចំណាំថា មានកត្តាជាច្រើនត្រូវបានពិចារណាក្នុងការផ្តល់អនុសាសន៍អំពីការឡើងថ្នាក់ ឬការត្រួតថ្នាក់ដោយគ្រូ និងនាយកសាលា នៅពេលផ្តល់អនុសាសន៍អំពីការឡើងថ្នាក់ ឬត្រួតថ្នាក់សម្រាប់សិស្សបឋមសិក្សា។ ការពិនិត្យហ្មត់ចត់លើកំណត់ត្រារបស់កូនសិស្ស នឹងធ្វើឡើងដោយមានការជូនដំណឹងជាក់លាក់អំពីអវត្តមាន ការមករៀនយឺត វឌ្ឍនភាពសិក្សា លទ្ធផលសិក្សា ការត្រៀមខ្លួនក្នុងការអភិវឌ្ឍ និងសូចនាករដែលអាចអនុវត្តបានផ្សេងទៀតនៃសក្តានុពលរបស់សិស្សសម្រាប់ភាពជោគជ័យនៅពេលឡើងថ្នាក់បន្ទាប់។

ក្នុងករណីណាក៏ដោយដែលមានអនុសាសន៍អំពីការឡើងថ្នាក់ដោយគ្រូ និងនាយកសាលា ហើយឪពុកម្តាយមានការខ្វែងគំនិតគ្នា សាលារដ្ឋ Lowell ទទួលស្គាល់សិទ្ធិរបស់ឪពុកម្តាយក្នុងការស្នើសុំឱ្យកូនរបស់ពួកគាត់ត្រួតថ្នាក់។ រាល់សំណើរបស់ឪពុកម្តាយក្នុងការឲ្យកូនរបស់ពួកគាត់ត្រួតថ្នាក់សម្រាប់ឆ្នាំខាងមុខនេះត្រូវតែធ្វើឡើងជាលាយលក្ខណ៍អក្សរទៅកាន់អគ្គនាយកសាលា និងពន្យល់អំពីហេតុផលរបស់ឪពុកម្តាយសម្រាប់ការត្រួតថ្នាក់។ ក្នុងករណីណាមួយនៃការអនុញ្ញាតឲ្យចូលរៀន ការដំឡើងថ្នាក់ និង/ឬការដាក់ចូលថ្នាក់ ការសម្រេចចិត្តចុងក្រោយនឹងអាស្រ័យលើអគ្គនាយកសាលា លើកលែងតែករណីទាំងនោះដែលតម្រូវឱ្យមានការបោះឆ្នោតពីគណៈកម្មាធិការសាលា។

**គោលនយោបាយឡើងថ្នាក់/ត្រួតថ្នាក់—សាលាមធ្យមសិក្សា**

បុគ្គលិកផ្នែករដ្ឋបាល
និងបុគ្គលិកផ្នែកបង្រៀននឹងផ្តល់នូវបរិយាកាសអប់រំដែលមានលក្ខណៈប្រកួតប្រជែងដើម្បីបង្កើនឱកាសសម្រាប់សិស្សម្នាក់ៗឲ្យរីកចម្រើននៅថ្នាក់មធ្យមសិក្សាតាមតម្រូវការ និងសមត្ថភាពផ្ទាល់ខ្លួន ដោយមិនមានការមាក់ងាយពីការធ្លាក់ ឬការត្រួតថ្នាក់។

**អ្នកសិក្សា**

ដើម្បីឡើងថ្នាក់បន្ទាប់ សិស្សមធ្យមសិក្សាត្រូវទទួលបានពិន្ទុ៖

1. ភាសាអង់គ្លេស និងគណិតវិទ្យា៖
    - ពិន្ទុជាប់ជាស្ថាពរ 65 ឬល្អប្រសើរជាងនេះក្នុងមុខវិជ្ជាភាសាអង់គ្លេស។
    - ពិន្ទុជាប់ជាស្ថាពរ 65 ឬល្អប្រសើរជាងនេះក្នុងមុខវិជ្ជាគណិតវិទ្យាទាំងអស់។
    - សិស្សដែលបានពិន្ទុចុងក្រោយពី 60 ទៅ 64 នឹងត្រួតថ្នាក់ជាបណ្តោះអាសន្ន ហើយដោយមានការអនុញ្ញាតពីនាយកសាលា ត្រូវតែចូលរៀននៅសាលារដូវក្តៅដើម្បីឡើងថ្នាក់។
    - សិស្សដែលបានពិន្ទុចុងក្រោយក្រោម 60 នឹងត្រួតថ្នាក់។

2. មុខវិជ្ជាសិក្សាស្នូលផ្សេងទៀត៖ អំណាន សំណេរ សង្គមវិទ្យា វិទ្យាសាស្ត្រ
    - ពិន្ទុមធ្យមភាគបង្គរចុងក្រោយសរុប 65 ឬនិទ្ទេសល្អប្រសើរនៅក្នុងមុខវិជ្ជាសិក្សាទាំងអស់។
    - សិស្សដែលរកបានពិន្ទុមធ្យមភាគបង្គរចុងក្រោយចាប់ពី 60 ដល់ 64 នឹងត្រួតថ្នាក់បណ្តោះអាសន្ន។
    - សិស្សដែលបានពិន្ទុចុងក្រោយក្រោម 60 នឹងត្រួតថ្នាក់។

3. សិល្បៈសម្ព័ន្ធ៖
    - ពិន្ទុមធ្យមភាគបង្គរចុងក្រោយសរុប 65 ឬនិទ្ទេសល្អប្រសើរនៅក្នុងមុខវិជ្ជាសិល្បៈសម្ព័ន្ធផ្សេងទៀតទាំងអស់។
    - សិស្សដែលរកបានពិន្ទុមធ្យមភាគបង្គរចុងក្រោយចាប់ពី 60 ដល់ 64 នឹងត្រួតថ្នាក់បណ្តោះអាសន្ន។

- សិស្សដែលបានពិន្ទុចុងក្រោយក្រោម 60 នឹងត្រួតថ្នាក់។

**ការដាក់ពិន្ទុ**

- រយៈពេលដាក់ពិន្ទុលើកទី[1] – អាចឲ្យពិន្ទុមិនក្រោម 60 នៅក្នុងមុខវិជ្ជាណាមួយ។
- រយៈពេលដាក់ពិន្ទុជាបន្តបន្ទាប់ – អាចឲ្យពិន្ទុមិនក្រោម 55 នៅក្នុងមុខវិជ្ជាណាមួយ។

**វត្តមាន**

- អវត្តមានចំនួនបួន (4) ដងឬច្រើនជាងនេះដោយមានច្បាប់ ឬគ្មានច្បាប់នៅក្នុងមួយរយៈពេលដាក់ពិន្ទុអាចបណ្តាលឱ្យមានសវនាការស្តីពីវត្តមាននៅសាលាតាមការសម្រេចចិត្តរបស់នាយកសាលា។
- ការអវត្តមានដោយគ្មានច្បាប់ចាប់ពី 16 ទៅ 25 ថ្ងៃសម្រាប់ឆ្នាំសិក្សានឹងបណ្តាលឱ្យត្រួតថ្នាក់/ឡើងថ្នាក់បណ្តោះអាសន្ននៅក្នុងសាលាមធ្យមសិក្សា ហើយអាចបណ្តាលឱ្យត្រួតថ្នាក់នៅក្នុងសាលាបឋមសិក្សា។
- ការអវត្តមានដោយគ្មានច្បាប់លើសពី 25 ថ្ងៃនឹងបណ្តាលឲ្យត្រួតថ្នាក់។

**ការត្រួតថ្នាក់/ការឡើងថ្នាក់បណ្តោះអាសន្ន**

- សាលារដូវក្តៅ នៅពេលដែលបានរៀបចំគម្រោងថវិកា និងដោយមានការអនុម័តពីនាយកសាលា គឺជាលក្ខខណ្ឌតម្រូវសម្រាប់សិស្សដែលបំពេញបានតាមលក្ខខណ្ឌនៃថ្នាក់ និងអវត្តមាន។ ផែនការអន្តរាគមន៍សម្រាប់ការធ្លាក់នឹងត្រូវបានបង្កើតឡើងនៅកម្រិតសាលាសម្រាប់សិស្សដែលប្រឈមនឹងការធ្លាក់ថ្នាក់មួយ ឬច្រើនជំនួសឱ្យសាលារដូវក្តៅ។
- កូនសិស្សអាចរៀនមិនលើសពីពីរ (2) មុខវិជ្ជានៅសាលារដូវក្តៅ។
- កូនសិស្សអាចអវត្តមានលើសពីបី (3) ដង ក្នុងអំឡុងពេលកម្មវិធីសាលារដូវក្តៅ។

## បញ្ហាពាក់ព័ន្ធនឹងនីតិវិធីសម្រាប់សិស្ស

**ការមកដល់ និងការចេញពីសាលា**

សិស្ស និងក្រុមគ្រួសារនឹងអនុវត្តតាមពិធីការស្តីពីសុខភាព និងសុវត្ថិភាពជាក់លាក់របស់សាលាសម្រាប់ការមកដល់ និងការចេញពីសាលា ដើម្បីធានាបាននូវសុខភាព និងសុវត្ថិភាពរបស់មនុស្សគ្រប់រូប។

- ការមកដល់សាលា៖ ការមកដល់របស់សិស្សមិនគួរលឿនជាង 15 នាទីមុនថ្ងៃចូលរៀនឡើយ។
- ការចេញពីសាលា៖ នៅពេលចេញពីសាលានៅថ្ងៃបិទសាលា សិស្សត្រូវចាកចេញភ្លាមៗ លុះត្រាតែពួកគេត្រូវបានឃាត់ដោយគ្រូ ឬអ្នកគ្រប់គ្រង ឬកំពុងចូលរួមក្នុងសកម្មភាពរបស់សាលាដែលស្ថិតក្រោមការគ្រប់គ្រង។

**សេចក្តីប្រកាសស្តីពីការបិទសាលា/ពន្យារពេលចូលរៀន**

នៅថ្ងៃដែលមានព្យុះភ្លៀង សេចក្តីប្រកាសអំពីការបិទសាលា ឬពន្យារពេលចូលរៀន នឹងធ្វើឡើងតាមរយៈ ConnectEd call home ហើយបង្ហោះនៅលើគេហទំព័ររបស់សាលារដ្ឋ Lowell។ សេចក្តីប្រកាសក៏នឹងត្រូវបានផ្សព្វផ្សាយជាសាធារណៈនៅលើស្ថានីយវិទ្យុក្នុងស្រុក WCAP – 980 AM ដែលចាក់ផ្សាយតាមទូរទស្សន៍ប៉ុស្តិ៍លេខ 4, 5, 7 និង 25 ហើយត្រូវបានបង្ហោះលើបណ្តាញទំនាក់ទំនងសង្គម។ មិនត្រូវទូរសព្ទទៅប៉ូលិស ឬការិយាល័យពន្លត់អគ្គិភ័យឡើយ។ ឪពុកម្តាយទទួលខុសត្រូវកំណត់ថាតើលក្ខខណ្ឌក្នុងអំឡុងពេលអាកាសធាតុមិនល្អគឺដូចជាថាកូនរបស់ពួកគេមិនគួរទៅសាលារៀននៅថ្ងៃដែលសាលាកំពុងបើករៀនដែរឬទេ។ នេះមិនត្រូវបានចាត់ទុកថាជាអវត្តមានដោយគ្មានច្បាប់នោះទេ។ ក្នុងករណីមានការពន្យារពេលចូលរៀន នឹងមានព័ត៌មានជាក់លាក់អំពីពេលវេលានៃការពន្យារពេលចូលរៀន។ ជាឧទាហរណ៍ ប្រសិនបើមានការពន្យារពេលមួយម៉ោង (60 នាទី) នោះសាលានឹងចាប់ផ្តើមមួយម៉ោងក្រោយជាងម៉ោងកំណត់ធម្មតា។ រថយន្តក្រុងរបស់សាលានឹងមកទទួលកូនសិស្សមួយម៉ោងក្រោយម៉ោងទៅទទួលធម្មតា។ មិនមានបម្រើអាហារពេលព្រឹកនៅសាលាទេ។ ការចេញពីសាលានឹងធ្វើឡើងតាមម៉ោងធម្មតា។

**ការចុះឈ្មោះ—មជ្ឈមណ្ឌលធនធានគ្រួសារ**

សិស្សទាំងអស់ដែលចូលរៀនក្នុងប្រព័ន្ធសាលារដ្ឋ Lowell ជាលើកដំបូងត្រូវតែចុះឈ្មោះនៅមជ្ឈមណ្ឌលធនធានគ្រួសារដើម្បីទទួលបានកិច្ចការសាលា។

មជ្ឈមណ្ឌលធនធានគ្រួសារដែលមានទីតាំងនៅផ្លូវ 151 Merrimack បើកពេញមួយឆ្នាំ។ ម៉ោងធ្វើការគឺពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ពីម៉ោង 8:00 ព្រឹក ដល់ 4:00 ល្ងាច។ (8-3 អំឡុងរដូវក្តៅ) ដោយសារគ្រួសារជួបវិបត្តិ COVID-19 ត្រូវតែទូរសព្ទមកមុន ឬប្រើទម្រង់បែបបទអនឡាញដែលមាននៅលើគេហទំព័ររបស់យើង ដើម្បីកំណត់ពេលណាត់ជួប ប្រសិនបើពួកគេចង់ទទួលសេវាដោយផ្ទាល់។
សូមបន្តពិនិត្យមើលទំព័រដើមរបស់មណ្ឌលសិក្សាធិការសម្រាប់ម៉ោងបម្រើសេវាកម្ម និងពិធីការដែលបានធ្វើបច្ចុប្បន្នភាពដើម្បីឆ្លើយតបទៅនឹងវិបត្តិ COVID-19។ សេវាកម្មជាច្រើន រួមទាំងការចុះឈ្មោះ អាចបំពេញបានតាមអនឡាញ ហើយអាចរកបាននៅលើគេហទំព័រមជ្ឈមណ្ឌលធនធានគ្រួសារ (https://www.lowell.k12.ma.us/frc)

ដើម្បីចុះឈ្មោះសិស្សទៅសាលារដ្ឋ Lowell គ្រួសារនឹងត្រូវបានស្នើសុំឯកសារចុះឈ្មោះដូចខាងក្រោម៖

- សំបុត្រកំណើតរបស់កូនសិស្ស
- កំណត់ត្រាអាណាព្យាបាលរបស់កូនសិស្ស
- ការចាក់វ៉ាក់សាំងរបស់កូនសិស្ស
- លិខិតបញ្ជាក់ទីលំនៅនៅទីក្រុង Lowell (វិក្កយបត្រហ្គាស ភ្លើង ឬទូរទស្សន៍ខ្សែកាប ឬកិច្ចសន្យាជួលផ្ទះ ឬលិខិតបញ្ជាក់ប្រាក់កម្ចីទិញផ្ទះនាពេលបច្ចុប្បន្ន។ មានបច្ចុប្បន្នភាពត្រូវបានកំណត់ដូចក្នុងរយៈពេល 30 ថ្ងៃកន្លងមក។)
- អត្តសញ្ញាណបណ្ណមានបិទរូបថតរបស់មាតាបិតា
- IEP (ប្រសិនបើកូនសិស្សទទួលបានសេវាកម្មអប់រំពិសេស)
- ផែនការ 504 (ប្រសិនបើកូនសិស្សទទួលបានការសម្របសម្រួល 504)
- សិស្សវិទ្យាល័យត្រូវតែបង្ហាញព្រឹត្តិប័ត្រពិន្ទុ។ ព្រឹត្តិប័ត្រពិន្ទុដែលបាត់ ឬមិនពេញលេញនឹងពន្យារពេលការចូលរៀននៅវិទ្យាល័យ។

*ដើម្បីរក្សាកំណត់ត្រារបស់នាយកដ្ឋានសាលាឲ្យបានត្រឹមត្រូវ និងមានបច្ចុប្បន្នភាព មាតាបិតាសិស្សត្រូវតែរាយការណ៍អំពីការផ្លាស់ប្តូរអាសយដ្ឋាន និងលេខទូរសព្ទទៅកាន់សាលារបស់សិស្សជាបន្ទាន់។ ប្រសិនបើមានការផ្លាស់ប្តូរអាសយដ្ឋាន ឯកសារចាំបាច់ត្រូវតែផ្តល់ជូនសាលាផងដែរ ឧ. ច្បាប់ចម្លងនៃកិច្ចសន្យាជួលផ្ទះ វិក្កយបត្រភ្លើង វិក្កយបត្រហ្គាសដែលបង្ហាញពីអាសយដ្ឋានថ្មី។*

ប្រសិនបើអ្នកកំពុងរស់នៅជាមួយអ្នករស់នៅទីក្រុង Lowell ហើយមិនអាចផ្តល់លិខិតបញ្ជាក់ទីលំនៅបាន អ្នកនឹងត្រូវធ្វើលិខិតបញ្ជាក់របស់ភាគីទីបី។ អ្នកទាំងពីរ (ឪពុកម្តាយ/អាណាព្យាបាលរបស់កូន និងអ្នករស់នៅទីក្រុង Lowell ដែលអ្នកកំពុងរស់នៅជាមួយ) ត្រូវតែបំពេញទម្រង់បែបបទ និងមានការបញ្ជាក់។ អ្នករស់នៅទីក្រុង Lowell នឹងត្រូវមានអត្តសញ្ញាណបណ្ណមានបិទរូបថត និងវិក្កយបត្រសេវាសាធារណៈបច្ចុប្បន្ន។

សូមធ្វើការសន្ទនាជាមួយយើង ប្រសិនបើអ្នកមិនអាចបង្ហាញឯកសារគ្រប់គ្រាន់ ឬប្រសិនបើលំនៅដ្ឋានរបស់អ្នកមិនមានសុវត្ថិភាព ដោយសារអ្នកអាចមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់សេវាកម្ម McKinney-Vento។

សិស្សទាំងអស់ដែលចូលរៀនក្នុងប្រព័ន្ធសាលារដ្ឋ Lowell ជាលើកដំបូង សិស្សទាំងអស់ដែលបានផ្លាស់ទីលំនៅក្នុងទីក្រុង Lowell ហើយសិស្សទាំងអស់ដែលមានបំណងផ្ទេរពីសាលារដ្ឋមួយទៅសាលារដ្ឋមួយទៀតនៅក្នុងប្រព័ន្ធសាលារដ្ឋ Lowell ត្រូវចុះឈ្មោះនៅមជ្ឈមណ្ឌលធនធានគ្រួសារ ដើម្បីទទួលបានកិច្ចការសាលា។ មជ្ឈមណ្ឌលធនធានគ្រួសារដែលមានទីតាំងនៅផ្លូវ 151 Merrimack បើកពេញមួយឆ្នាំ។ ម៉ោងធ្វើការគឺពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ ពីម៉ោង 8:00 ព្រឹក ដល់ 4:00 ល្ងាច។ ក៏មានការណាត់ជួបក្រោយម៉ោងរៀនតាមការស្នើសុំផងដែរ។

**ការដក និងការផ្ទេរ**

មាតាបិតា/អាណាព្យាបាល ឬទីភ្នាក់ងារដែលមានសិទ្ធិឃុំគ្រងតាមផ្លូវច្បាប់ (ឧ. ក្រសួងកុមារ និងគ្រួសារ) ត្រូវតែធានាថា សិស្សដែលដក/ផ្ទេរពីសាលារដ្ឋ Lowell ពិតជាបានចុះឈ្មោះចូលរៀននៅសាលាមួយផ្សេងទៀត មុនពេលសិស្សត្រូវបានអនុញ្ញាតឲ្យចេញពីសាលារដ្ឋ Lowell។

1. មានតែមាតាបិតា/អាណាព្យាបាល ឬទីភ្នាក់ងារដែលមានសិទ្ធិឃុំគ្រងតាមផ្លូវច្បាប់ប៉ុណ្ណោះ ដែលអាចស្នើសុំឱ្យដក/ផ្ទេរសិស្សចេញពីសាលាសាធារណៈរដ្ឋ Lowell បាន។

2. មាតាបិតា/អាណាព្យាបាល ឬភ្នាក់ងារដែលមានសិទ្ធិឃុំគ្រងតាមផ្លូវច្បាប់

ត្រូវតែជូនដំណឹងទៅការិយាល័យរបស់សាលាជាមុន ឬឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ទាក់ទងនឹងការដក/ផ្ទេរកូនទៅសាលាផ្សេង។

3. មាតាបិតា/អាណាព្យាបាល ឬទីភ្នាក់ងារដែលមានសិទ្ធិឃុំគ្រងតាមផ្លូវច្បាប់ត្រូវតែផ្តល់ជូនការិយាល័យរបស់សាលានូវ៖
    a. ទម្រង់បែបបទដក/ផ្ទេរសិស្សដែលបានបំពេញ/ចុះហត្ថលេខាពីសាលាបច្ចុប្បន្នរបស់កូនសិស្ស។ (ទម្រង់បែបបទដក/ផ្ទេរសិស្សអាចទៅយកពីសាលាដែលសិស្សកំពុងចូលរៀន ហើយត្រូវតែបំពេញ ហើយប្រគល់ត្រលប់ទៅការិយាល័យរបស់សាលាដដែលនោះវិញ)។
    b. ទម្រង់បែបបទអនុញ្ញាតចេញផ្សាយកំណត់ត្រាដែលបានបំពេញ/ចុះហត្ថលេខា។ (ទម្រង់បែបបទអនុញ្ញាតចេញផ្សាយកំណត់ត្រាអាចទៅយកពីសាលាដែលសិស្សកំពុងចូលរៀន ហើយត្រូវតែបំពេញ ហើយប្រគល់ត្រលប់ទៅការិយាល័យរបស់សាលាដដែលនោះវិញ)។
4. មាតាបិតា/អាណាព្យាបាលរបស់សិស្សដែលចាកចេញពីសហរដ្ឋអាមេរិកត្រូវតែផ្តល់ឯកសារផ្លូវការដល់សាលារដ្ឋ Lowell ដែលបញ្ជាក់ថាសិស្សនឹងចាកចេញ ឬបានចាកចេញពីប្រទេស (ឧទាហរណ៍ សំបុត្រយន្តហោះ ទិដ្ឋាការមានបោះត្រា ឯកសារលិខិតស្នាមកុងស៊ុល)។

## កាត/កំណត់ត្រានៃនីតិវិធីសង្គ្រោះបន្ទាន់

កាត/កំណត់ត្រានៃនីតិវិធីសង្គ្រោះបន្ទាន់ត្រូវបានរក្សាទុកក្នុងឯកសារនៅសាលាក្នុងករណីមានឧបទ្ទវហេតុ ឬជំងឺក្នុងអំឡុងពេលថ្ងៃសិក្សា។ ជារៀងរាល់ឆ្នាំ កាតថ្មីត្រូវចេញជូនសិស្សម្នាក់ៗ។ វាជាការសំខាន់ដែលរាល់ការផ្លាស់ប្តូរព័ត៌មាន ត្រូវបញ្ជូនបន្តទៅនាយកសាលាភ្លាមៗ។ យើងត្រូវតែមានលេខទូរសព្ទត្រឹមត្រូវសម្រាប់មាតាបិតា/អាណាព្យាបាលរបស់សិស្សគ្រប់រូបគ្រប់ពេល និងយ៉ាងហោចណាស់លេខទូរសព្ទទំនាក់ទំនងបន្ទាន់ចំនួនពីរខ្សែ។

**វត្ថុហាមឃាត់**

វត្ថុដូចខាងក្រោមត្រូវបានចាត់ទុកថារំខានដល់ការសិក្សាអប់រំនៅក្នុងសាលារដ្ឋ Lowell ហើយមិនត្រូវបានអនុញ្ញាតនៅក្នុងសាលា៖

- ទូរសព្ទដៃ និងឧបករណ៍ទំនាក់ទំនងដូចជា Apple watch
- វីដេអូហ្គេម
- វិទ្យុ, iPod និងឧបករណ៍ប្រភេទអាយកូមផ្សេងទៀត
- ឧបករណ៍ចង្អុលឡាស៊ែរកាន់នឹងដៃ
- ប៉ៀ
- ផលិតផលថ្នាំជក់ (រួមទាំងបំពង់ជក់ប្រភេទទឹក)
- បារីអេឡិចត្រូនិក (វ៉េប)
- ដែកកេះ/ឈើគូស (ការកាន់កាប់នឹងនាំឱ្យមានការផ្អាកទុកភ្លាមៗ)
- ក្តារជិះស្គី/ស្កុតទ័រ/ស្បែកជើងជិះស្គី/ស្បែកជើងរំអិល/ក្តារជិះរំអិល
- វត្ថុ ឬឧបករណ៍ផ្សេងទៀតដែលចាត់ទុកថាមិនសមរម្យដោយនាយកសាលា

សិស្សដែលបង្ហាញ និង/ឬប្រើប្រាស់ឧបករណ៍ទាំងនេះនឹងត្រូវរឹបអូសឧបករណ៍ទាំងនោះ ហើយអាចទទួលរងការដាក់វិន័យ រួមទាំងការព្យួរការសិក្សាផងដែរ។ ទោះបីជាសាលានឹងរឹបអូសទុកឧបករណ៍ទាំងនេះក៏ដោយ ក៏ការទទួលខុសត្រូវចុងក្រោយចំពោះការបាត់បង់ ឬការខូចខាតនៅតែជាបន្ទុករបស់សិស្សដែលបាននាំយកវត្ថុហាមឃាត់ទាំងនេះចូលសាលារៀនដដែល។ **មាតាបិតា ឬអាណាព្យាបាលត្រូវតែមកសាលារៀន ដើម្បីមកយកវត្ថុទាំងនេះ**។ ប៉ៀ ផលិតផលថ្នាំជក់ ដែកកេះ និងឈើគូសនឹងមិនត្រូវបានប្រគល់ជូនវិញទេ។ រាល់វត្ថុដែលរឹបអូសទាំងអស់ត្រូវតែទារយកវិញនៅថ្ងៃចុងក្រោយនៃឆ្នាំសិក្សា វត្ថុណាមួយដែលមិនបានទារយកវិញនឹងត្រូវចាត់ចែងយកបោះចោលក្នុងរយៈពេលមួយសប្តាហ៍បន្ទាប់ពីការបញ្ចប់ជាផ្លូវការនៃឆ្នាំសិក្សា។

**កាសឆ្នុកត្រចៀក/កាសស្តាប់ត្រចៀក**

សិស្សត្រូវតែអាចស្តាប់ឧបករណ៍ទំនាក់ទំនង និងការណែនាំពីបុគ្គលិកគ្រប់ពេលវេលាដើម្បីធានាសុវត្ថិភាព។ ដោយហេតុផលនេះ សិស្សមិនត្រូវបានអនុញ្ញាតឱ្យពាក់កាសឆ្នុកត្រចៀកនៅក្នុងសាលាឡើយ។ កាសឆ្នុកត្រចៀកនឹងត្រូវបានរឹបអូស ហើយមិនប្រគល់ឲ្យវិញទេ រហូតដល់ចុងបញ្ចប់នៃឆ្នាំសិក្សា ឬរហូតដល់ឪពុកម្តាយ ឬអាណាព្យាបាលទៅយកវត្ថុទាំងនេះ។

ការលើកលែងតែមួយគត់ចំពោះបម្រាមនេះអនុវត្តចំពោះគ្រូបង្រៀនដែលអនុញ្ញាតឱ្យប្រើកាសឆ្នុកត្រចៀកក្នុងថ្នាក់រៀនសម្រាប់គោលបំណងសិក្សាអប់រំ ប៉ុន្តែត្រូវទុកកាសឆ្នុកត្រចៀកវិញមុនពេលចេញពីថ្នាក់រៀន។

**ការស្លៀកពាក់សមរម្យ**

យើងរំពឹងថាសិស្សទាំងអស់នៅក្នុងសាលារដ្ឋ Lowell នឹងស្លៀកពាក់សមរម្យនៅពេលកំពុងរៀននៅសាលា។ លើសពីនេះ សិស្សត្រូវតែអនុវត្តតាមលក្ខខណ្ឌតម្រូវផ្នែកសុខភាព និងសុវត្ថិភាពបច្ចុប្បន្ន។ ដោយអនុលោមតាមលក្ខខណ្ឌពីមុន ការស្លៀកពាក់ដែលមានទំនោរទៅរកការរំខានដល់ការសិក្សា ឬបង្កគ្រោះថ្នាក់ដល់សុវត្ថិភាពក្នុងថ្នាក់ត្រូវបានហាមឃាត់។ ក្នុងស្មារតីនៃការថែរក្សាបរិយាកាសរៀនដែលមានសុវត្ថិភាព និងសណ្តាប់ធ្នាប់ សិស្សត្រូវបានហាមឃាត់មិនឱ្យស្លៀកសម្លៀកបំពាក់ណាមួយ ឬស្ពាយកាបូប ឬពាក់គ្រឿងលម្អផ្សេងទៀតណាដែលអាសអាភាស ដែលជំរុញឱ្យមានអំពើហិង្សា ឬការស្អប់ខ្ពើមចំពោះបុគ្គល ឬក្រុមណាមួយ ឬធ្វើឱ្យប៉ះពាល់ដល់ជំនឿរបស់អ្នកដទៃ។  ក៏ហាមឃាត់ការពាក់គ្រឿងលម្អ គ្រឿងអលង្ការ ឬច្រវាក់ដែលអាចប្រើជាអាវុធបាន។

សិស្សដែលបំពានគោលនយោបាយនេះនឹងត្រូវបានណែនាំឱ្យដោះចេញនូវវត្ថុដែលធ្វើឱ្យប៉ះពាល់អារម្មណ៍ ឬមិនមានសុវត្ថិភាព មុនពេលត្រូវបានអនុញ្ញាតឱ្យបន្តរៀននៅក្នុងសាលា។ សិស្សក៏ត្រូវបានហាមមិនឱ្យស្លៀកសម្លៀកបំពាក់ណាដែលរារាំងការកំណត់អត្តសញ្ញាណដែរ។ សិស្សដែលបដិសេធមិនគោរពតាមគោលនយោបាយនេះនឹងប្រព្រឹត្តល្មើសនឹងវិន័យសាលា និងត្រូវទទួលទោសតាមច្បាប់។

សិស្សមិនត្រូវបានអនុញ្ញាតឱ្យស្លៀកពាក់ដូចខាងក្រោម៖

- សម្លៀកបំពាក់ណាក៏ដោយដែលរារាំងការកំណត់អត្តសញ្ញាណ។ សម្លៀកបំពាក់នេះរួមបញ្ចូល ប៉ុន្តែមិនកំណត់ត្រឹមចំពោះ៖ មួក ក្រណាត់ កន្សែងបង់ក មួករលក ក្រមា មួកមានកន្ទុយ មួកក្រណាត់រុំក្បាល។ (ករណីលើកលែងនឹងត្រូវធ្វើឡើងសម្រាប់ហេតុផលសាសនា ឬវេជ្ជសាស្ត្រដែលមានចុះឯកសារ ឬពិការភាពដែលបានកំណត់។)
- សម្លៀកបំពាក់ វត្ថុ និមិត្តសញ្ញាដែលទាក់ទងនឹងក្រុមក្មេងទំនើង ឬស្នាមសាក់របស់ក្រុមក្មេងទំនើងដែលអាចមើលឃើញ
- សម្លៀកបំពាក់ ឬគ្រឿងអលង្ការដែលទាក់ទងនឹងគ្រឿងញៀន គ្រឿងស្រវឹង ឬមានអត្ថន័យផ្លូវភេទ
- សម្លៀកបំពាក់ធំហួសខ្នាត ឬយារធ្លាក់
- វ៉ែនតា
- គ្រឿងអលង្ការដែលអាចបង្កស្នាមរបួស

- សម្លៀកបំពាក់ផ្សេងទៀតណាដែលធ្វើឲ្យបែកអារម្មណ៍ រំខាន បំភិតបំភ័យ ឬបង្ករឿងអាចយល់ឃើញថាមិនសមរម្យដោយនាយកសាលា ឬអ្នកទទួលសិទ្ធិរបស់គាត់។

**មួក និងអាវធំ**

បន្ថែមពីលើការស្លៀកពាក់ត្រឹមត្រូវខាងលើ សិស្សមិនត្រូវបានអនុញ្ញាតឱ្យពាក់មួក និងអាវធំក្នុងថ្នាក់រៀន ផ្លូវដើរ ឬកន្លែងជួបជុំនៅសាលាសាធារណៈឡើយ។ ការកែប្រែគោលនយោបាយស្លៀកពាក់ គោលនយោបាយស្តីពីមួក និងគោលនយោបាយស្តីពីអាវធំអាចត្រូវបានចេញដោយនាយកសាលា នៅពេលដែលចាំបាច់ដោយលក្ខខណ្ឌបន្ថែម ដូចជាហេតុផលវេជ្ជសាស្ត្រ ឬសាសនា និងអាកាសធាតុក្តៅ/ត្រជាក់ខ្លាំង។ សិស្សត្រូវដាក់មួកទាំងអស់នៅក្នុងទូដែលបានកំណត់របស់ខ្លួនមុនពេលចូលរៀន។ សិស្សដែលបានរកឃើញពាក់មួកនឹងត្រូវរឹបអូសរហូតដល់ដំណាច់ឆ្នាំ ឬរហូតដល់ឪពុកម្តាយ/អាណាព្យាបាលមកយកវត្ថុទាំងនេះវិញ។ បទល្មើសជាបន្តបន្ទាប់អាចបណ្តាលឱ្យមានវិធានការវិន័យបន្ថែមទៀត និងការរឹបអូសរយៈពេលវែង។

**នីតិវិធីពន្លត់អគ្គិភ័យ/ជម្លៀស**

សិស្សគ្រប់រូបត្រូវតែដឹងថា នៅពេលដែលសំឡេងរោទ៍អគ្គិភ័យបន្លឺឡើង ការជូនដំណឹងនេះត្រូវចាត់ទុកថាធ្ងន់ធ្ងរ។ ដូច្នេះហើយ សិស្សម្នាក់ៗត្រូវតែធ្វើតាមការណែនាំភ្លាម និងដោយស្ងៀមស្ងាត់។ សិស្សត្រូវតែដើរឆ្លងកាត់ចេញពីអគារឲ្យលឿន ប៉ុន្តែតាមលំដាប់ដែលមានសណ្តាប់ធ្នាប់ល្អ។ ការរំខានដល់ការហាត់សមពន្លត់អគ្គិភ័យគឺជាបទល្មើសដ៏ធំមួយ ហើយអាចបណ្តាលឱ្យមានការផ្អាកការសិក្សា ឬការបណ្តេញចេញពីសាលា។

ក្នុងករណីមានអាសន្នដែលបង្កគ្រោះថ្នាក់ដល់សុវត្ថិភាពសិស្ស សិស្សសាលានឹងត្រូវបានជម្លៀសទៅកាន់កន្លែងដែលបានកំណត់ទុកជាមុន។ ព័ត៌មាននេះមាននៅក្នុងឯកសារនៅការិយាល័យសាលា ក៏ដូចជានៅការិយាល័យកណ្តាល។

**ការហាត់សមសុវត្ថិភាព**

ដើម្បីជួយធានាសុវត្ថិភាពសិស្ស និងលោកគ្រូអ្នកគ្រូ ការហាត់សមសុវត្ថិភាពដោយមានការសម្របសម្រួលជាមួយនគរបាលមូលដ្ឋាន និងក្រសួងពន្លត់អគ្គិភ័យ ត្រូវបានធ្វើឡើងជាទៀងទាត់ក្នុងអំឡុងពេលឆ្នាំសិក្សា។ ការហាត់សមទាំងនេះរួមមាន ការហាត់សមពន្លត់អគ្គិភ័យ ការហាត់សមជម្លៀស ការហាត់សមជម្លៀសការដឹកជញ្ជូន ការបិទខ្ទប់ និងការឆ្លើយតបដោយផ្អែកលើជម្រើស។

ការរំខានដល់ការហាត់សមសុវត្ថិភាពគឺជាបទល្មើសដ៏ធំមួយ ហើយអាចបណ្ដាលឱ្យមានការផ្អាកការសិក្សា ឬការបណ្ដេញចេញពីសាលា។

**ទូដាក់សម្ភារៈ/តុសិស្ស**

ការចាក់សោមិនត្រូវបានអនុញ្ញាតនៅក្នុងសាលាបឋមសិក្សាទេ។ នៅក្នុងសាលាមធ្យមសិក្សា អាចប្រើបានតែសោរបស់សាលាដែលត្រូវបានអនុម័តប៉ុណ្ណោះ។ សោផ្សេងក្រៅពីការអនុញ្ញាតដោយអ្នកគ្រប់គ្រងសាលានឹងត្រូវដកចេញ ឬកាត់ដោយបុគ្គលិកសាលា។

ត្រូវតែយកសម្ភារចេញពីទូ និងតុទាំងអស់នៅចុងឆ្នាំសិក្សា និង/ឬពេលផ្សេងទៀតតាមតម្រូវការរបស់មន្ត្រីសាលា។ សម្ភារមួយចំនួនប្រហែលជាមិនរក្សាទុកនៅក្នុងទូ ឬតុបានទេ។ សម្ភារទាំងនេះរួមមាន ប៉ុន្តែមិនកំណត់ត្រឹមចំពោះវត្ថុដូចជា៖ អាវុធ ឬសារធាតុគីមីគ្រោះថ្នាក់ សម្ភារ ប្រដាប់ប្រដារឬឧបករណ៍ គ្រឿងញៀនខុសច្បាប់ឬសារធាតុមានការគ្រប់គ្រង ថ្នាំមើលទៅដូចគ្រឿងញៀន ឧបករណ៍ប្រើប្រាស់គ្រឿងញៀន ភេសជ្ជៈមានជាតិអាល់កុល ទ្រព្យសម្បត្តិដែលលួចគេ ឬវត្ថុផ្សេងទៀតដែលអាចបណ្ដាលឱ្យមានស្ថានភាពគ្មានអនាម័យ ឬស្មោកគ្រោក។ ចំណីអាហារ ឬសម្ភារដែលអាចស្អុយរលួយបានផ្សេងទៀត មិនត្រូវទុកក្នុងទូពេញមួយយប់ឡើយ។ សិស្សត្រូវប្រើតែទូដែលចាត់ចែងឱ្យពួកគេប្រើដោយរដ្ឋបាលសាលាប៉ុណ្ណោះ។ ការត្រួតពិនិត្យ ឬការឆែកឆេររកក្នុងគ្រាអាសន្ន ឬដែលមិនមានការជូនដំណឹងអាចត្រូវបានអនុវត្តដោយមន្ត្រីសាលា និងបុគ្គលិកសមស្របផ្សេងទៀត (ដូចជាអ្នកពន្លត់អគ្គិភ័យ ប៉ូលិស) ដើម្បីការពារសិស្ស និងផ្ដល់នូវបរិយាកាសសុវត្ថិភាព និងសណ្ដាប់ធ្នាប់។

សេចក្ដីជូនដំណឹងពិសេស - នាយកដ្ឋានសាលា Lowell រក្សាសិទ្ធិក្នុងការសហការជាមួយមន្ត្រីអនុវត្តច្បាប់ ដើម្បីនាំយកសត្វឆ្កែដែលបានបង្ហាត់ឲ្យរកគ្រឿងញៀន និងសារធាតុហាមឃាត់ផ្សេងទៀតក្នុងស្ថានភាពអាសន្ន។

**ការបួបហាត់ប្រាណ និងការបួបស្លាយ**
នាយកដ្ឋានរបស់សាលារក្សាសិទ្ធិក្នុងការឆែកឆេរការបួបហាត់ប្រាណ
និងការបួបស្ពាយទាំងអស់ដែលនាំយកចូលលើបរិវេណសាលានៅពេលណាក៏បាន។
សិទ្ធិឆែកឆេររកនេះក៏អនុវត្តចំពោះភ្ញៀវទាំងអស់ដែលទៅសាលារដ្ឋណាមួយនៅក្នុងទីក្រុង Lowell ផងដែរ។

**សៀវភៅបាត់ សម្ភារៈបង្រៀន ឬទ្រព្យសម្បត្តិសាលាផ្សេងទៀត**
សៀវភៅ បច្ចេកវិទ្យាសម្រាប់ការបង្រៀន (កុំព្យូទ័រ/iPad គ្រឿងលម្អ ។ល។) សម្ភារៈបង្រៀន ឯកសណ្ឋាន។ល។
នៅពេលផ្តល់ឱ្យសិស្សរួច បន្ទាប់មកទៀតគឺត្រូវបានឲ្យខ្ចីប្រើ។ សិស្សត្រូវទទួលខុសត្រូវទាំងស្រុងចំពោះការរក្សា
និងការពារសម្ភារទាំងនោះ។ ប្រសិនបើបាត់បង់សម្ភារ ឬត្រូវចោរលួច សិស្សត្រូវបង់ប្រាក់សងគ្រប់ចំនួន។
ការសងប្រាក់ក៏ត្រូវតែធ្វើឡើងចំពោះសម្ភារៈ និងទ្រព្យសម្បត្តិដែលខូចខាតផងដែរ។
ការសងប្រាក់ទាំងអស់ត្រូវតែធ្វើឡើងមិនលើសពីថ្ងៃរៀនចុងក្រោយរបស់សាលាក្នុងខែមិថុនានៃឆ្នាំសិក្សានោះឡើយ។

ប្រសិនបើសម្ភារទាំងនោះមិនត្រូវបានប្រគល់សងវិញ ឬសំណងមិនត្រូវបានធ្វើឡើង
សិស្សអាចត្រូវបានហាមឃាត់មិនឱ្យចូលរួមក្នុងកម្មវិធី ឬសកម្មភាពរបស់សាលាឡើយ។

សិស្សនឹងត្រូវបានលើកលែងពីការសងប្រាក់វិញសម្រាប់សៀវភៅសិក្សាដែលចោរលួច
ប្រសិនបើសិស្សរាយការណ៍ថាសៀវភៅសិក្សារបស់គាត់ត្រូវចោរលួចក្នុងរយៈពេល 24 ម៉ោងបន្ទាប់ពីលួចបាត់
ហើយឬអ្នកទទួលសិទ្ធិបានស៊ើបអង្កេតបណ្តឹងដោយទទួលបានលទ្ធផលពេញចិត្ត។

**កិច្ចការផ្ទះ**
កិច្ចការផ្ទះគឺជាឧបករណ៍ដែលត្រូវប្រើសម្រាប់ពង្រឹងការរៀនសូត្រ
និង/ឬសម្រាប់ការពិនិត្យឡើងវិញនូវសម្ភារដែលបានបង្ហាញពីមុនដល់សិស្ស និង/ឬសម្រាប់ការសិក្សាឯករាជ្យ
និងកិច្ចការស្រាវជ្រាវ។ កិច្ចការផ្ទះត្រូវបានដាក់ឱ្យជាប្រចាំ យ៉ាងហោចណាស់ 4 យប់ប្រចាំសប្តាហ៍ – ពីថ្ងៃចន្ទ
ដល់ថ្ងៃព្រហស្បតិ៍។ ខាងក្រោមគឺជាកម្រិតថ្នាក់ និងចំនួនម៉ោង ដែលសិស្សគួរចំណាយលើកិច្ចការផ្ទះរៀងរាល់យប់។
កិច្ចការផ្ទះក៏អាចដាក់នៅថ្ងៃសុក្រ រួមជាមួយនឹងកិច្ចការរយៈពេលវែងពិសេស ដូចជារបាយការណ៍សៀវភៅ
និងគម្រោងថ្នាក់ផងដែរ។

| | |
|---|---|
| ថ្នាក់ទី 1 | ចំនួនម៉ោងធ្វើកិច្ចការផ្ទះនៅពេលយប់ដែលបានស្នើគឺ **20 - 30 នាទី** |
| ថ្នាក់ទី 2 | ចំនួនម៉ោងធ្វើកិច្ចការផ្ទះនៅពេលយប់ដែលបានស្នើគឺ **25 - 45 នាទី** |
| ថ្នាក់ទី 3 / 4 | ចំនួនម៉ោងធ្វើកិច្ចការផ្ទះនៅពេលយប់ដែលបានស្នើគឺ **40 - 60 នាទី** |

ថ្នាក់ទី 5 ចំនួនម៉ោងធ្វើកិច្ចការផ្ទះនៅពេលយប់ដែលបានស្នើគឺ **45 - 60 នាទី**

ថ្នាក់ទី 6 ចំនួនម៉ោងធ្វើកិច្ចការផ្ទះនៅពេលយប់ដែលបានស្នើគឺ **45 - 75 នាទី**

ថ្នាក់ទី 7 / 8 ចំនួនម៉ោងធ្វើកិច្ចការផ្ទះនៅពេលយប់ដែលបានស្នើគឺ **60 - 120 នាទី**

យើងសូមស្នើសុំឱ្យមានកិច្ចសហការរបស់អ្នកក្នុងនាមជាមាតាបិតា ក្នុងការតាមដានចំនួនម៉ោងដែលកូនរបស់អ្នកចំណាយលើកិច្ចការផ្ទះ ក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនូវការសិក្សារបស់សិស្ស។

**សកម្មភាពក្រៅកម្មវិធីសិក្សា**

សកម្មភាពក្រៅកម្មវិធីសិក្សាជាច្រើន អាស្រ័យលើសម្ភារសិក្សា និងបុគ្គលិក មាននៅក្នុងសាលារដ្ឋ Lowell។ សិស្សត្រូវបានលើកទឹកចិត្តឱ្យចូលរួមក្នុងកម្មវិធីដែលត្រូវបានផ្តល់ជូនទាំងនេះ ដើម្បីបង្កើនកម្មវិធីអប់រំសរុប។ សិស្សនៅក្នុងសកម្មភាពដែលទាក់ទងនឹងសាលាណាមួយដែលជាប់ពាក់ព័ន្ធនឹងឥរិយាបថដែលជាការរំលោភបំពានយ៉ាងខ្លាំងលើចរិយារបស់សិស្សនឹងត្រូវទទួលទោសតាមវិន័យ។

**សេវាគាំពារសិស្ស**

កម្មវិធីណែនាំ និងប្រឹក្សាមានមុខងារដើម្បីជួយសិស្សទាំងអស់៖

- វាយតម្លៃ និងស្វែងយល់ពីសមត្ថភាព ភាពវៃឆ្លាត ចំណាប់អារម្មណ៍ និងតម្រូវការអប់រំរបស់ពួកគេ
- បង្កើនការយល់ដឹងរបស់ពួកគេអំពីឱកាស និងលក្ខខណ្ឌតម្រូវនៃការងារ និងការអប់រំ
- ជួយពួកគេឱ្យប្រើប្រាស់ឱកាសទាំងនេះឱ្យបានល្អបំផុត តាមរយៈការបង្កើត និងការសម្រេចបាននូវការកែតម្រូវឥរិយាបទក្នុងសង្គមផ្ទាល់ខ្លួន
- ផ្តល់ព័ត៌មានដែលមានប្រយោជន៍ដល់បុគ្គលិកសាលា មាតាបិតា និងសហគមន៍ក្នុងការធ្វើផែនការ និងវាយតម្លៃកម្មវិធីសរុបរបស់សាលា

**ការទស្សនាសាលា**

មាតាបិតា/អាណាព្យាបាលត្រូវបានស្វាគមន៍ក្នុងការជួបជាមួយអ្នកគ្រប់គ្រង និងគ្រូនៃសាលារដ្ឋ Lowell។ ដើម្បីបំពេញតាមតម្រូវការរបស់ភាគីទាំងអស់ ការណាត់ជួបគឺត្រូវបានទាមទារ ហើយអាចធ្វើឡើងដោយទាក់ទងទៅសាលារបស់កូនអ្នក។ ភ្ញៀវទាំងអស់ដែលចូលអគារត្រូវតែរាយការណ៍ទៅការិយាល័យកណ្តាល និងទទួលបានកាតភ្ញៀវ។ ភ្ញៀវទាំងអស់ទៅកាន់មណ្ឌល LPS ត្រូវបានរំពឹងថានឹងអនុវត្តតាមក្រមប្រតិបត្តិ។ នឹងផ្តល់ជូនជម្រើសសម្រាប់ការប្រជុំដោយផ្ទាល់ ឬតាមអនឡាញ។ នៅពេលចូលទៅក្នុងអគារសិក្សា ភ្ញៀវទាំងអស់ត្រូវតែគោរពតាមការណែនាំដែលបានបិទប្រកាសសម្រាប់ការរក្សាគម្លាតពីគ្នា

និងការប្រើប្រាស់បរិក្ខារការពារខ្លួន (ឧ. ម៉ាស់)។
ការខកខានមិនបានគោរពតាមច្បាប់អាចបណ្តាលឱ្យមានការស្នើសុំឱ្យចេញពីបរិវេណសាលា។

**សេវាកម្មអាហារ**
ជាផ្នែកនៃច្បាប់ស្តីពីកុមារសុខភាពល្អ និងគ្មានការអត់ឃ្លានឆ្នាំ 2010 សាលារដ្ឋ Lowell ផ្តល់ជូនអាហារពេលព្រឹក និងអាហារថ្ងៃត្រង់ដោយឥតគិតថ្លៃដល់សិស្សទាំងអស់ក្នុងអំឡុងពេលសិក្សាដោយផ្ទាល់ និងពីចម្ងាយ។ សម្រាប់សាលារៀនដែលមានន័យថា មិនមានផ្តល់ជូនអាហារថ្ងៃត្រង់ទៀត ឬសុំឱ្យមាតាបិតាបង់ប្រាក់សម្រាប់ចំណែករបស់ខ្លួន។
សូមមើលគេហទំព័រសេវាកម្មអាហារសម្រាប់ព័ត៌មានថ្មីៗបំផុតអំពីរបៀបចូលមើលអាហារ។

**អ្វីដែលមាតាបិតាត្រូវដឹង**
សម្រាប់សាលាទាំងនោះដែលផ្តល់អាហារពេលព្រឹកដោយផ្ទាល់នៅក្នុងថ្នាក់រៀន កូនរបស់អ្នកអាចយកអាហារពេលព្រឹកដែលផ្តល់ជូនបាន។ សម្រាប់សាលារៀនផ្សេងទៀត កុមារអាចទៅអាហារដ្ឋាន ឬទេះអាហារពេលព្រឹកនៅពេលព្រឹក ហើយញ៉ាំអាហារពេលព្រឹកបាន។ សម្រាប់អាហារថ្ងៃត្រង់ សិស្សអាចចូលជួរយកអាហារថ្ងៃត្រង់ និងទទួលទាន។
សិស្សទាំងអស់នឹងនៅតែត្រូវការកត់ត្រាអាហាររបស់ពួកគេនៅពេលចុះឈ្មោះដដែល។

**តើអាហារពេលព្រឹក និងអាហារថ្ងៃត្រង់មានផ្តល់មុខម្ហូបអ្វីខ្លះ? តើជម្រើសរបស់កូនខ្ញុំមានអ្វីខ្លះ?**
ក្នុងអំឡុងពេលអាហារពេលព្រឹក យើងផ្តល់ជូនគ្រាប់ធញ្ញជាតិពីរគ្រាប់ (ឬគ្រាប់ធញ្ញជាតិមួយគ្រាប់ និងប្រូតេអ៊ីនមួយមុខ) ផ្លែឈើពីរមុខ និងទឹកដោះគោមួយ។ អ្វីទាំងអស់ដែលកូនរបស់អ្នកត្រូវធ្វើគឺយកយ៉ាងហោចណាស់ 3 មុខ (មួយមុខមានផ្លែឈើ) ដើម្បីចាត់ទុកថាជាអាហារឥតគិតថ្លៃ។ ក្នុងអំឡុងពេលអាហារថ្ងៃត្រង់ យើងផ្តល់ជូនគ្រាប់ធញ្ញជាតិ ប្រូតេអ៊ីន បន្លែ ផ្លែឈើ និងទឹកដោះគោ។ អ្វីទាំងអស់ដែលកូនរបស់អ្នកត្រូវធ្វើគឺយកយ៉ាងតិច 3 មុខផ្សេងៗគ្នាដែលផ្តល់ជូន (មួយមុខមានផ្លែឈើ ឬបន្លែ) ដើម្បីចាត់ទុកថាជាអាហារឥតគិតថ្លៃ។ សូមឆែកគេហទំព័រ LPS ដើម្បីមើលមុខម្ហូប៖ https://lowellk12ma.nutrislice.com/menu/

**ចុះបើកូនខ្ញុំចង់បានតែទឹកដោះគោ ឬតែមួយមុខ?** យើងត្រូវបានទូទាត់ប្រាក់ដោយ USDA សម្រាប់អាហារពេញលេញតែប៉ុណ្ណោះ។ ប្រសិនបើកូនរបស់អ្នកចង់បានតែទឹកដោះគោ ឬតែមួយមុខ មុខម្ហូបទាំងនោះអាចរកបានសម្រាប់ការទិញជាសាច់ប្រាក់ជាលក្ខណៈបុគ្គល ឧទាហរណ៍ទឹកដោះគោមានតម្លៃ 35

សេន។ ដើម្បីទទួលបានឥតគិតថ្លៃ កូនរបស់អ្នកត្រូវទទួលទានអាហារពេញលេញដែលមានបីមុខផ្សេងៗគ្នា (មួយមុខមានផ្លែឈើ ឬបន្លែ)។

**សំណួរណាមួយ** - ក្រុមការងារផ្នែកអាហារ និងអាហារូបត្ថម្ភរបស់អ្នកមានវត្តមាននៅទីនេះ ដើម្បីឆ្លើយសំណួររបស់អ្នកទាំងអស់។ សូមទាក់ទងការិយាល័យអាហារូបត្ថម្ភរបស់សាលារដ្ឋ Lowell តាមលេខ 978-674-2049។

# ចរិយា និងឥរិយាបថ

វិធានដែលមានចែងក្នុងសៀវភៅណែនាំនេះគឺសម្រាប់ការពារសិទ្ធិផ្ទាល់ខ្លួន។ វិធានទាំងនេះផ្អែកលើសុជីវធម៌ និងការគោរពជាធម្មតាចំពោះអ្នកដទៃ និងរួមបញ្ចូលទំនួលខុសត្រូវចំពោះសង្គម ក៏ដូចជាចំពោះការសិក្សា។ វិធានទាំងនេះមិនលម្អិត ឬគ្រប់ជ្រុងជ្រោយដើម្បីរួមបញ្ចូលនូវស្ថានភាព ឥរិយាបថ និងផលវិបាកដែលអាចកើតមានទាំងអស់នៃឥរិយាបថដែលបំពានលើគោលនយោបាយ នីតិវិធី ឬច្បាប់រដ្ឋ ឬច្បាប់សហព័ន្ធឡើយ។

### ទំនួលខុសត្រូវចំពោះសង្គម

ទំនួលខុសត្រូវចំពោះសង្គមរបស់សិស្សរួមមានភាពជាពលរដ្ឋល្អ។ នៅក្នុងសាលារៀន ភាពជាពលរដ្ឋល្អគឺផ្អែកលើការគោរព និងការចេះគិតគូរដល់សិទ្ធិរបស់អ្នកដទៃ។ សិស្សទាំងអស់នៅក្នុងសាលារដ្ឋ Lowell ត្រូវបានរំពឹងថានឹងប្រកាន់ចរិយាដែលគោរពសិទ្ធិ និងឯកសិទ្ធិរបស់អ្នកដទៃ។ ភាពជាពលរដ្ឋល្អ រួមមានទំនួលខុសត្រូវរបស់សិស្សក្នុងការៈ

- គោរពអាជ្ញាធរ
- យល់ និងប្រកាន់ខ្ជាប់នូវវិធានរបស់សាលា ព្រមទាំងគោលការណ៍ណែនាំអំពីសុខភាព និងសុវត្ថិភាព/ការរំពឹងទុក
- ទទួលខុសត្រូវទាំងស្រុងចំពោះទង្វើរបស់ពួកគេផ្ទាល់ និងចំពោះលទ្ធផលនៃទង្វើទាំងនោះ
- គោរពសិទ្ធិ និងជំនឿរបស់អ្នកដទៃ
- គោរព និងអនុវត្តតាមច្បាប់សហព័ន្ធ រដ្ឋ និងមូលដ្ឋាន
- គោរពទ្រព្យសម្បត្តិអ្នកដទៃ ទាំងឯកជន និងសាធារណៈ

### ទំនួលខុសត្រូវចំពោះការសិក្សា

ទំនួលខុសត្រូវចំពោះការសិក្សារបស់សិស្សនៅក្នុងសាលា និងការរៀនពីចម្ងាយគឺផ្អែកលើការសិក្សា និងការខិតខំ។ ដើម្បីចូលរួមដោយជោគជ័យក្នុងកម្មវិធីសិក្សា សិស្សត្រូវៈ

- ទៅសាលាទាន់ម៉ោង
- ចូលរៀនជារៀងរាល់ថ្ងៃ
- ត្រៀមខ្លួនសម្រាប់រៀនក្នុងថ្នាក់
- ស្តាប់ និងចូលរួមក្នុងថ្នាក់
- បំពេញកិច្ចការថ្នាក់ និងកិច្ចការផ្ទះទាំងអស់

- សិក្សាដើម្បីប្រឡង
- បង្ហាញពីការខិតខំប្រឹងប្រែងប្រកបដោយប្រសិទ្ធភាព

**វិន័យសិស្ស**

វិន័យ ជាតម្រូវការដើម្បីដាក់ដែនកំណត់ និងការគ្រប់គ្រងក្នុងន័យស្ថាបនា ដើម្បីអភិវឌ្ឍឥរិយាបថវិជ្ជមានចំពោះកូនសិស្សទាំងអស់ គឺជាធាតុផ្សំដ៏សំខាន់នៅក្នុងបទពិសោធន៍សិក្សាសរុបរបស់សិស្សគ្រប់រូប។ គោលដៅនៃវិន័យគឺដើម្បីជួយសិស្សឱ្យអភិវឌ្ឍជំនាញធ្វើការសម្រេចចិត្តដ៏ឈ្លាសវៃ ដូច្នេះពួកគេអាចរៀនធ្វើការជ្រើសរើសប្រកបដោយការទទួលខុសត្រូវក្នុងការទំនាក់ទំនងជាមួយអ្នកដទៃ។ ដើម្បីដោះស្រាយបញ្ហាវិន័យសិស្ស យុទ្ធសាស្រ្តដាក់វិន័យជាបន្តបន្ទាប់ត្រូវបានប្រើប្រាស់ដោយគ្រូ និងអ្នកគ្រប់គ្រងប្រព័ន្ធសាលាសាធារណៈរដ្ឋ Lowell ហើយអាចរួមបញ្ចូលតាមការសម្រេចរបស់នាយកសាលា ឬជំនួយការ ហើយអាស្រ័យលើលក្ខណៈនៃការបំពានវិន័យណាមួយនៃយុទ្ធសាស្រ្តខាងក្រោម និង/ឬបន្សំនៃយុទ្ធសាស្រ្តដាក់វិន័យខាងក្រោម៖

- ការប្រឹក្សាដែលចាប់ផ្តើមពីកម្រិតថ្នាក់រៀនរវាងគ្រូ និងសិស្ស ហើយប្រសិនបើមិនមានផលិតភាពទេនោះ បន្តទៅបុគ្គលិកសង្គមកិច្ច ទីប្រឹក្សាណែនាំ ឬនាយកសាលា និង/ឬជំនួយការ
- ការឃុំឃាំង៖ នៅការិយាល័យ ក្រោយពេលចូលរៀន និង/ឬចុងសប្តាហ៍
- ការចាត់តាំងទៅមជ្ឈមណ្ឌលកែប្រែឥរិយាបថ (BMC) ឬការផ្អាកការសិក្សា ប្រសិនបើមាននៅសាលា
- ការព្យួរការសិក្សា ដែលអាចធ្វើឡើងដោយនាយកសាលា ឬជំនួយការរហូតដល់ 5 ថ្ងៃសម្រាប់កំហុសធ្ងន់ធ្ងរ ហើយវាអាចបន្តរហូតដល់ 10 ថ្ងៃដោយមានការអនុម័តពីអគ្គនាយកសាលា ឬប្រធានមន្ត្រីសាលា។
- ការចាត់តាំងទៅកម្មវិធីជំនួសដែលអាចត្រូវបានណែនាំដោយនាយកសាលា
- ការបណ្តេញចេញពីសាលារៀនដែលអាចធ្វើឡើងដោយនាយកសាលា ឬដោយគណៈកម្មាធិការសាលា

**ការផ្អាក និងការបណ្តេញចេញ**

សិស្សគ្រប់រូបដែលបានចុះឈ្មោះចូលរៀននៅសាលាសាធារណៈរដ្ឋ Lowell មានសិទ្ធិពេញលេញ និងដោយសមធម៌ចំពោះសិទ្ធិ ឯកសិទ្ធិ សុវត្ថិភាព និងសន្តិសុខទាំងអស់ដែលមានសម្រាប់សិស្សដទៃទៀតទាំងអស់។ គ្មានសិស្សណាម្នាក់អាចបណ្តាលឱ្យសិស្សផ្សេងទៀតទទួលរងនូវការបៀតបៀនក្នុងរូបភាពណាមួយ រួមទាំងប៉ុន្តែមិនកំណត់ត្រឹមចំពោះ ការបៀតបៀនដោយផ្អែកលើលក្ខណៈខុសគ្នាជាក់ស្តែងឬតាមការយល់ឃើញ រួមទាំងពូជសាសន៍ ពណ៌សម្បុរ សាសនា ពូជពង្ស ដើមកំណើតជាតិសាសន៍ ភេទ ស្ថានភាពសេដ្ឋកិច្ចសង្គម

ភាពគ្មានផ្ទះសម្បែង ស្ថានភាពនៃការសិក្សា អត្តសញ្ញាណយេនឌ័រឬការបង្ហាញអំពីយេនឌ័រ រូបរាងកាយ ស្ថានភាពមានផ្ទៃពោះឬស្ថានភាពជាមាតាបិតា ទំនោរផ្លូវភេទ ផ្លូវចិត្ត ផ្លូវកាយ ពិការភាពខាងការលូតលាស់ ឬសតិអារម្មណ៍ ឬដោយផ្សារភ្ជាប់ជាមួយនឹងបុគ្គលដែលមាន ឬត្រូវបានគេយល់ថាមានលក្ខណៈមួយ ឬច្រើននៃលក្ខណៈទាំងនេះ។ លើសពីនេះ សិស្សមិនត្រូវទទួលរងនូវការគំរាមកំហែង ការបំភិតបំភ័យ ការវាយដំ ការទាត់ធាក់ ឬអំពើហិង្សាផ្សេងៗឡើយ។ ការបំពានបែបនេះគឺជាកម្មវត្ថុនៃការព្យួរការសិក្សាជាបន្ទាន់ និង/ឬការបណ្តេញចេញ ស្របតាមសៀវភៅណែនាំសិស្សនេះ។ វិធានដែលទាក់ទងនឹងឥរិយាបថរបស់សិស្សគឺនៅជាធរមានពេញលេញ និងមានប្រសិទ្ធភាពសម្រាប់ព្រឹត្តិការណ៍សាលាណាមួយ រួមទាំងអ្វីដែលធ្វើឡើងមុន ឬក្រោយម៉ោងសិក្សា។ ព្រឹត្តិការណ៍ទាំងនេះរួមមាន ប៉ុន្តែមិនកំណត់ត្រឹមសកម្មភាពរបស់ក្រុមឬក្លឹប ទស្សនៈកិច្ចសិក្សា និងការធ្វើដំណើរទៅសាលារៀន។ វិធានអនុវត្តចំពោះអ្នកចូលរួម ក៏ដូចជាភ្ញៀវ។

**ក្រមវិន័យ**

ក្រមវិន័យនឹងត្រូវបានអានឲ្យមានភាពស៊ីសង្វាក់គ្នាជាមួយជំពូកទី 222 នៃច្បាប់ឆ្នាំ 2012 និងច្បាប់ទូទៅដូចខាងក្រោម៖ M.G.L. ជំពូកទី 71 ផ្នែក 37H ¾; M.G.L. ជំពូកទី 71 ផ្នែក 37H; M.G.L. ជំពូកទី 71 ផ្នែក 37H ½; M.G.L. ជំពូកទី 76 ផ្នែក 16 &17។

**ការរាយបទល្មើសធ្ងន់ធ្ងរ**

រាល់បទល្មើសធ្ងន់ធ្ងរជានាការព្យួរការសិក្សាតាមឆន្ទានុសិទ្ធិ របស់ នាយកសាលា ឬជំនួយការនាយកសាលា លើកលែងតែការព្យួរការសិក្សា ឬការបណ្តេញចេញពីសាលាដោយអនុលោមតាម M.G.L. ជំពូកទី 71 ផ្នែក 37H; M.G.L. ជំពូកទី 71 ផ្នែក 37H ½ ដែលស្ថិតនៅក្នុងសិទ្ធិអំណាចផ្តាច់មុខរបស់នាយកសាលាតែប៉ុណ្ណោះ។ អាស្រ័យលើភាពធ្ងន់ធ្ងរនៃបទល្មើស ឬភាពញឹកញាប់នៃការប្រព្រឹត្តបទល្មើស នាយកសាលាអាចបញ្ជូនបញ្ហានេះដើម្បីចាត់វិធានការបន្ត ដែលអាចរាប់បញ្ចូលទាំងសវនាការស្តីពីការបណ្តេញចេញនៅចំពោះមុខនាយកសាលា ឬគណៈកម្មាធិការសាលា ឬការបញ្ជូនទៅកាន់កម្មវិធីអប់រំជំនួស។ បទល្មើសធ្ងន់ធ្ងរ និង/ឬបទល្មើសស្រាលនៃផ្នែកវិន័យអាចបណ្តាលឱ្យមានការដកសិស្សចេញពីការសិក្សា ឬកម្មវិធីឯកទេសផ្សេងទៀត (បណ្ឌិត្យសភា ក្លឹប កីឡា។ល។) រួមជាមួយនឹងសកម្មភាពវិន័យសមស្របផ្សេងទៀត រួមមាន ប៉ុន្តែមិនកំណត់ត្រឹមចំពោះការបណ្តេញចេញពីសាលាជាដើម។

បទល្មើសដែលបានរាយខាងក្រោមត្រូវបានចាត់ទុកថាជាការរំលោភបំពានធ្ងន់ធ្ងរ

ហើយអាចបណ្តាលឱ្យមានការព្យួរការសិក្សា/សវនាការអំពីការបណ្តេញចេញ៖

1. ការជួយ ឬជំរុញឱ្យមានលទ្ធភាពចូលសាលាដោយគ្មានការអនុញ្ញាត
2. សកម្មភាពណាមួយដែលមានទំនោរទៅរកគ្រោះថ្នាក់ដល់សុខភាព និងសុវត្ថិភាពរបស់ជនល្មើស សិស្សផ្សេងទៀត ឬបុគ្គលិករាំងដំណើរការរបស់គ្រូ-ការសិក្សា ឬរំខានដល់ដំណើរការ និងសណ្តាប់ធ្នាប់របស់សាលា។
3. ការវាយដំ និង/ឬទាត់ធាក់សិស្ស
4. ការវាយដំ និង/ឬទាត់ធាក់បុគ្គលិកសាលា
5. ការធ្វើបាប
6. រាល់ទង្វើជាក់ស្តែង ឬទង្វើចេតនានៃភាពលម្អៀងពូជសាសន៍ និង/ការរើសអើង
7. ការបណ្តាលឱ្យខូចខាតទ្រព្យសម្បត្តិផ្ទាល់ខ្លួន ឬខាតទ្រព្យសម្បត្តិសាធារណៈ
8. ការក្លែងបន្លំ និង/ឬចេតនាប្រើប្រាស់ និង/ឬចម្លងកិច្ចការសិក្សារបស់អ្នកដទៃ ហើយបង្ហាញថាវាជារបស់ផ្ទាល់ខ្លួន ការលួចចម្លង
9. គ្រឿងញៀន និង/ឬគ្រឿងស្រវឹង៖ ការលក់ និង/ឬការកាន់កាប់ និង/ឬផ្ទេរ និង/ឬមានគ្រឿងញៀនខុសច្បាប់ និង/ឬគ្រឿងស្រវឹង និង/ឬស្ថិតក្រោមឥទ្ធិពល
10. ការវាយតប់គ្នា
11. ការបៀតបៀន រួមទាំងការបំពានដោយពាក្យសំដី និងការនិយាយលេងសើចមិនសមរម្យ រួមទាំងការនិយាយពាក្យសំដីមិនសមរម្យ និង/ឬប្រកាន់កាន់ពូជសាសន៍ វប្បធម៌ សាសនា /ប្រមាថមើលងាយនៅសាលា ឬអំឡុងពេលសកម្មភាពសាលា (រួមទាំងកិច្ចការក្នុងថ្នាក់) និង/ឬដែលធ្វើឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ដំណើរការអប់រំ ឬដំណើរការ និងសណ្តាប់ធ្នាប់របស់សាលា។

11. ការបៀតបៀន (ផ្លូវភេទ) រួមទាំងការបំពានពាក្យសំដី និងការនិយាយលេងសើចមិនសមរម្យ ឬការប្រើប្រាស់សម្ភារដែលធ្វើឱ្យប៉ះពាល់អារម្មណ៍នៅក្នុងកិច្ចការក្នុងថ្នាក់
12. ការនិយាយបង្អាប់
13. ការប្រើប្រាស់ថ្នាំណាមួយមិនត្រឹមត្រូវ និង/ឬដោយគ្មានការអនុញ្ញាត
14. ការប្រើប្រាស់កម្មវិធីសុសហ្វវែរ/ហាតវែរកុំព្យូទ័រដោយមិនត្រឹមត្រូវ/ខុសគោលដៅ
15. ការបំពានផែនការសុវត្ថិភាពនៃការអន្តរាគមន៍
16. ការចាកចេញពីទីធ្លាសាលាក្នុងម៉ោងសិក្សា
17. ការប្រើប្រាស់ខុសនូវបរិក្ខារពន្លត់អគ្គិភ័យ ឧបករណ៍ប្រកាសអាសន្នអគ្គិភ័យ និងការហៅទៅលេខ 911
18. ការមិនអនុលោមតាមច្បាប់សាលាអំឡុងពេលហាត់សមសុវត្ថិភាព

19. ផ្សេងទៀត-បទល្មើសណាមួយដែលមិនបានរាយ-រួមទាំងបទល្មើសធ្ងន់ធ្ងរ និងច្រំដែល
20. ការកាន់កាប់ និង/ឬការប្រើប្រាស់អាវុធគ្រោះថ្នាក់ រួមទាំងមាន ប៉ុន្តែមិនកំណត់ត្រឹមចំពោះកាំភ្លើង ឬកាំបិត។
21. ការកាន់កាប់ និង/ឬការប្រើប្រាស់ឧបករណ៍ណាមួយ ដែលជាវត្ថុចម្លងតាមអាវុធគ្រោះថ្នាក់ រួមទាំង ប៉ុន្តែមិនកំណត់ត្រឹមចំពោះកាំភ្លើង ឬកាំបិត
22. ការកាន់កាប់ឧបករណ៍ដុតចំហេះណាមួយ រួមទាំងប៉ុន្តែមិនកំណត់ត្រឹមចំពោះ ដែកកេះ និងឈើគូស
23. ពាក្យប្រមាថ ការប្រើពាក្យប្រមាថ ក្នុងលក្ខណៈណាមួយដើម្បីរួមបញ្ចូលបទបង្ហាញផ្ទាល់មាត់ និងឯកសារ និងឈានទៅដល់កម្មវិធី និងការសម្តែង និងព្រឹត្តិការណ៍ផ្សេងទៀត។
24. ការផ្គើន/ការមិនគោរពសិទ្ធិអំណាចរបស់អ្នកមើលការខុសត្រូវ គ្រូបង្រៀន ឬអ្នកគ្រប់គ្រងម្តងហើយម្តងទៀតដោយចេតនា
25. បទល្មើសលើឡានក្រុងសាលា
26. បទល្មើសលួច (ជាង $250 ដុល្លារគឺជាបទឧក្រិដ្ឋ)
27. ការរុករើឯកសារសាលា ឬផ្តល់ព័ត៌មានមិនពិត
28. ការគំរាមសិស្សដទៃទៀត
29. ការចូលដោយគ្មានការអនុញ្ញាតនៅក្នុងបរិវេណសាលារដ្ឋមួយផ្សេងទៀតដែលសិស្សមិនបានចុះឈ្មោះចូលរៀន ឬសាលារបស់សិស្សនោះនៅពេលដែលកំពុងព្យួរការសិក្សា
30. ការប្រើប្រាស់បច្ចេកវិទ្យាដោយគ្មានការអនុញ្ញាត និង/ឬខុសច្បាប់ រួមមាន ប៉ុន្តែមិនកំណត់ត្រឹមចំពោះទូរសព្ទដៃ កាមេរ៉ា ឧបករណ៍ថតសំឡេង កុំព្យូទ័រយួរដៃ អាយផេត ជាដើម ទាំងជាកម្មសិទ្ធិរបស់សាលា ឬជាកម្មសិទ្ធិឯកជននៅលើបរិវេណសាលា
31. ការបំពានច្បាប់មូលដ្ឋាន ច្បាប់រដ្ឋ ច្បាប់សហព័ន្ធ
32. ការរើសអើង/ការបៀតបៀន
33. ការបង្កើតមេឌៀសំយោគមិនសមរម្យ (deepfakes) សម្រាប់ការផ្ញើសារផ្លូវភេទ ការយាយី ការធ្វើបាបតាមអ៊ីនធឺណិតជាដើម

**បទល្មើសផ្សេងទៀតនៅសាលា**

បទល្មើសផ្សេងទៀតនៅសាលា ដែលកើតឡើងជាធម្មតា ប៉ុន្តែមិនតែងតែពាក់ព័ន្ធនឹងបទល្មើសដែលមិនត្រូវបានរាយជាបទល្មើសធ្ងន់ធ្ងរឡើយ។ បទល្មើសទាំងនេះមួយចំនួនត្រូវបានដោះស្រាយដោយនាយកសាលា ឬជំនួយការ រួមមាន ការជក់បារី ការគេចមិនចូលថ្នាក់រៀន និងការគេចសាលា។ បទល្មើសផ្សេងទៀតត្រូវបានដោះស្រាយដោយគ្រូប្រចាំថ្នាក់ រួមមាន ការមករៀនយឺត ការរំខានការរៀនសូត្រក្នុងថ្នាក់ ការមិនប្រគល់កិច្ចការ ការជជែកគ្នាក្នុងថ្នាក់

ការមិនប្រគល់របាយការណ៍វឌ្ឍនភាពសិក្សា ឬមិនយកមកនូវសម្ភារៈថ្នាក់រៀន។ សិស្សក៏ត្រូវយល់ និងប្រកាន់ខ្ជាប់នូវគោលការណ៍ណែនាំ និងការរំពឹងទុកអំពីសុខភាព និងសុវត្ថិភាពផងដែរ។ ផែនការគ្រប់គ្រងថ្នាក់រៀនស្ថិតនៅក្នុងថ្នាក់នីមួយៗ ហើយបើនៅតែមិនមានការកែលម្អ សិស្សនេះនឹងត្រូវបានបញ្ជូនទៅនាយកសាលា ឬជំនួយការនាយកដើម្បីទទួលការដាក់វិន័យបន្ថែម។ ទោះយ៉ាងណាក៏ដោយ ការលើកលែងអាចធ្វើឡើងចំពោះនីតិវិធីនេះ យោងតាមការធានា និងការអនុញ្ញាតដោយនាយកសាលា។

ផែនការសេវាអប់រំទូទាំងសាលាត្រូវបានរៀបចំឡើង ដើម្បីធានាថា ទោះជាចាត់វិធានការវិន័យបែបណាក៏ដោយ សិស្សទាំងអស់នឹងត្រូវបានផ្តល់ឱកាសឱ្យទទួលបានការអប់រំ និងធ្វើឱ្យការសិក្សារីកចម្រើនដូចៗគ្នា។

**ជនល្មើសច្បាប់សាលាដែលមិនរាងចាល** (M.G.L. ជំពូកទី 119 ផ្នែក 21)
មន្ត្រីសាលាមានសិទ្ធិអំណាចក្នុងការប្តឹងជនល្មើសច្បាប់សាលាដែលមិនរាងចាល ទៅតុលាការចំពោះកូនសិស្សដែលខកខានមិនបានគោរពតាមបទបញ្ញត្តិច្បាប់ និងច្បាប់សមហេតុផលរបស់សាលាម្តងហើយម្តងទៀត។

បទល្មើសធ្ងន់ធ្ងរ និងបទល្មើសផ្សេងទៀត ការព្យួរការសិក្សានៅក្នុងសាលា ការព្យួរការសិក្សារយៈពេលខ្លី ការដកយកចេញជាបន្ទាន់ ការព្យួរការសិក្សារយៈពេលវែង (មិនលើសពី 90 ថ្ងៃសិក្សា) (M.G.L. ជំពូកទី 71 ផ្នែក 37H ¾)

**ការព្យួរការសិក្សានៅក្នុងសាលា**
"ការព្យួរការសិក្សានៅក្នុងសាលា" មានន័យថាជាការដកសិស្សចេញពីសកម្មភាពក្នុងថ្នាក់រៀនធម្មតា ប៉ុន្តែមិនមែនចេញពីបរិវេណសាលាទេ សម្រាប់រយៈពេលសិក្សាមិនលើសពីដប់ (10) ថ្ងៃជាប់ៗគ្នា ឬមិនលើសពីដប់ (10) ថ្ងៃសិក្សាបូកបញ្ចូលគ្នាសម្រាប់បទល្មើសជាច្រើនក្នុងអំឡុងពេលឆ្នាំសិក្សា។ ការដកចេញចំពោះតែការចូលរួមក្នុងសកម្មភាពក្រៅកម្មវិធីសិក្សា ឬព្រឹត្តិការណ៍ដែលឧបត្ថម្ភដោយសាលា ឬទាំងពីរ មិនត្រូវរាប់ជាការដកចេញក្នុងការគណនាចំនួនថ្ងៃសិក្សាឡើយ។ ការព្យួរការសិក្សាក្នុងសាលារយៈពេលដប់ (10) ថ្ងៃ ឬតិចជាងនេះ ជាប់ៗគ្នា ឬបូកបញ្ចូលគ្នាក្នុងអំឡុងឆ្នាំសិក្សា មិនត្រូវចាត់ទុកថាជាការព្យួរការសិក្សារយៈពេលខ្លីក្រោមបទប្បញ្ញត្តិទាំងនេះទេ។ ប្រសិនបើសិស្សត្រូវបានព្យួរការសិក្សានៅក្នុងសាលាលើសពីដប់ (10) ថ្ងៃជាប់ៗគ្នា ឬបូកបញ្ចូលគ្នាក្នុងអំឡុងឆ្នាំសិក្សា ការព្យួរបែបនេះនឹងត្រូវចាត់ទុកថាជាការព្យួរការសិក្សារយៈពេលវែងសម្រាប់នីតិវិធីផ្លូវច្បាប់ បណ្តឹងឧទ្ធរណ៍

និងគោលបំណងរាយការណ៍។

នាយកសាលា/អ្នកទទួលសិទ្ធិអាចដាក់ការព្យួរការសិក្សានៅក្នុងសាលាសម្រាប់ការល្មើសវិន័យដរាបណានាយកសាលា/អ្នកទទួលសិទ្ធិធ្វើតាមនីតិវិធីផ្លូវច្បាប់ ដែលមានចែងក្នុងកថាខណ្ឌនេះ ហើយដរាបណាសិស្សមានឱកាសរីកចម្រើនក្នុងការសិក្សា។

នាយកសាលា/អ្នកទទួលសិទ្ធិត្រូវជូនដំណឹងដល់សិស្សអំពីការល្មើសវិន័យដែលត្រូវបានចោទប្រកាន់ និងមូលដ្ឋានសម្រាប់ការចោទប្រកាន់ ហើយផ្តល់ឱកាសដល់សិស្សដើម្បីជំទាស់ការចោទប្រកាន់ និងពន្យល់ពីកាលៈទេសៈពាក់ព័ន្ធនឹងបទចោទប្រកាន់។ ប្រសិនបើនាយកសាលា/អ្នកទទួលសិទ្ធិកំណត់ថាសិស្សបានប្រព្រឹត្តល្មើសវិន័យ នាយកសាលា/អ្នកទទួលសិទ្ធិត្រូវជូនដំណឹងដល់សិស្សអំពីរយៈពេលនៃការព្យួរការសិក្សារបស់សិស្ស ដែលមិនត្រូវលើសពី 10 ថ្ងៃបូកបញ្ចូលគ្នា ឬជាប់ៗគ្នាក្នុងឆ្នាំសិក្សាមួយ។ នៅថ្ងៃតែមួយនឹងការសម្រេចចិត្តលើការព្យួរការសិក្សា នាយកសាលា/អ្នកទទួលសិទ្ធិត្រូវខិតខំប្រឹងប្រែងធ្វើយ៉ាងណាដើម្បីជូនដំណឹងដល់មាតាបិតាដោយផ្ទាល់មាត់អំពីបទល្មើសវិន័យ មូលហេតុនៃការសន្និដ្ឋានថាសិស្សបានប្រព្រឹត្តល្មើសច្បាប់ និងរយៈពេលនៃការព្យួរការសិក្សានៅក្នុងសាលា។ នាយកសាលា/អ្នកទទួលសិទ្ធិក៏ត្រូវអញ្ជើញមាតាបិតាឱ្យចូលរួមកិច្ចប្រជុំដើម្បីពិភាក្សាអំពីលទ្ធផលសិក្សា និងឥរិយាបថរបស់សិស្ស យុទ្ធសាស្ត្រសម្រាប់ការចូលរួមរបស់សិស្ស និងការឆ្លើយតបទៅនឹងឥរិយាបថដែលអាចមាន។ ការប្រជុំបែបនេះនឹងត្រូវកំណត់ពេលនៅថ្ងៃផ្អាកការសិក្សា ប្រសិនបើអាចធ្វើទៅបាន ហើយប្រសិនបើមិនអាចធ្វើបាន ត្រូវកំណត់ពេលឆាប់តាមដែលអាចធ្វើបានបន្ទាប់ពេលនោះ។ ប្រសិនបើនាយកសាលា/អ្នកទទួលសិទ្ធិមិនអាចទាក់ទងមាតាបិតាបានទេ បន្ទាប់ពីបានព្យាយាមទាក់ទង និងកត់ត្រាការព្យាយាមយ៉ាងហោចណាស់ (2) ដងក្នុងការធ្វើដូច្នេះ ការព្យាយាមបែបនេះនឹងបង្កើតជាកិច្ចខិតខំប្រឹងប្រែងសមស្របសម្រាប់គោលបំណងនៃការជូនដំណឹងដោយផ្ទាល់មាត់ដល់មាតាបិតាអំពីការផ្អាកការសិក្សានៅក្នុងសាលា។

នាយកសាលា/អ្នកទទួលសិទ្ធិត្រូវផ្ញើការជូនដំណឹងជាលាយលក្ខណ៍អក្សរដល់សិស្ស និងមាតាបិតាអំពីការផ្អាកការសិក្សាក្នុងសាលា រួមទាំងហេតុផល និងរយៈពេលនៃការផ្អាកការសិក្សាក្នុងសាលា ហើយអញ្ជើញមាតាបិតាមកប្រជុំជាមួយនាយកសាលា/អ្នកទទួលសិទ្ធិ ប្រសិនបើការប្រជុំបែបនេះមិនទាន់ធ្វើឡើងទេ។

នាយកសាលា/អ្នកទទួលសិទ្ធិត្រូវផ្តល់ការជូនដំណឹងបែបនេះនៅថ្ងៃព្យួរការសិក្សាដោយប្រគល់ផ្ទាល់ដៃ លិខិតអនុសិទ្ធិ សេវាប្រៃសណីយ៍ថ្នាក់ទីមួយ អ៊ីមែលទៅកាន់អាសយដ្ឋានដែលផ្តល់ដោយមាតាបិតាសម្រាប់ការទំនាក់ទំនងជាមួយសាលា ឬតាមវិធីប្រគល់ផ្សេងទៀតដែលយល់ព្រមដោយនាយកសាលា/អ្នកទទួលសិទ្ធិ និងឪពុកម្តាយ។ មិនមានសិទ្ធិប្តឹងឧទ្ធរណ៍ចំពោះការព្យួរការសិក្សាទៅកាន់អគ្គនាយកសាលាឡើយ។

**ការផ្អាកការសិក្សារយៈពេលខ្លី**

"ការផ្អាកការសិក្សារយៈពេលខ្លី" សំដៅលើការដកសិស្សចេញពីបរិវេណសាលា និងសកម្មភាពក្នុងថ្នាក់រៀនធម្មតាសម្រាប់រយៈពេលដប់ (10) ថ្ងៃសិក្សាជាប់ៗគ្នា ឬតិចជាងនេះ។ នាយកសាលា/អ្នកទទួលសិទ្ធិអាចអនុញ្ញាតឱ្យសិស្សធ្វើការព្យួរការសិក្សារយៈពេលខ្លីនៅក្នុងសាលាតាមឆន្ទានុសិទ្ធិរបស់គាត់។ ការដកចេញចំពោះតែការចូលរួមក្នុងសកម្មភាពក្រៅកម្មវិធីសិក្សា ឬព្រឹត្តិការណ៍ដែលឧបត្ថម្ភដោយសាលា ឬទាំងពីរ មិនត្រូវរាប់ជាការដកចេញក្នុងការគណនាចំនួនថ្ងៃសិក្សាឡើយ។

នាយកសាលា/អ្នកទទួលសិទ្ធិមិនអាចព្យួរការសិក្សាដោយសារបទល្មើសវិន័យ ដោយមិនចាំបាច់ជូនដំណឹងលើកដំបូងដល់សិស្ស និងមាតាបិតាដោយផ្ទាល់មាត់ និងជាលាយលក្ខណ៍អក្សរ ហើយផ្តល់ឱកាសដល់សិស្សមានសវនាការអំពីការចោទប្រកាន់ និងផ្តល់ឲ្យមាតាបិតានូវឱកាសចូលរួមក្នុងសវនាការបែបនេះ។ នាយកសាលា/អ្នកទទួលសិទ្ធិត្រូវផ្តល់ការជូនដំណឹងដោយផ្ទាល់មាត់ និងជាលាយលក្ខណ៍អក្សរដល់សិស្ស និងមាតាបិតាជាភាសាអង់គ្លេស និងជាភាសាកំណើតដែលនិយាយនៅផ្ទះ ប្រសិនបើក្រៅពីភាសាអង់គ្លេស ឬមធ្យោបាយទំនាក់ទំនងផ្សេងទៀតដែលសមស្រប។ សេចក្តីជូនដំណឹងត្រូវកំណត់ជាភាសាសាមញ្ញងាយយល់៖

(a) បទល្មើសវិន័យ

(b) មូលដ្ឋានសម្រាប់ការចោទប្រកាន់

(c) ផលវិបាកដែលអាចកើតមាន រួមទាំងរយៈពេលនៃការព្យួរការសិក្សារបស់សិស្ស

(d) ឱកាសសម្រាប់សិស្ស ដើម្បីមានសវនាការជាមួយនាយកសាលា/អ្នកទទួលសិទ្ធិទាក់ទងនឹងការផ្អាកការសិក្សាដែលបានស្នើឡើង រួមទាំងឱកាសជំទាស់ការចោទប្រកាន់ និងបង្ហាញការពន្យល់របស់សិស្សអំពីបទចោទប្រកាន់ និងសម្រាប់មាតាបិតាចូលរួមក្នុងសវនាការ

(e) កាលបរិច្ឆេទ ពេលវេលា និងទីកន្លែងនៃសវនាការ និង

(f) សិទ្ធិរបស់សិស្ស និងមាតាបិតារបស់សិស្សក្នុងការទទួលបានសេវាបកប្រែផ្ទាល់មាត់នៅសវនាការ ប្រសិនបើចាំបាច់ត្រូវចូលរួម។

នាយកសាលា/អ្នកទទួលសិទ្ធិត្រូវខិតខំប្រឹងប្រែងធ្វើយ៉ាងណា ដើម្បីជូនដំណឹងដល់មាតាបិតាដោយផ្ទាល់មាត់អំពីឱកាសចូលរួមសវនាការ។ ដើម្បីដំណើរការសវនាការដោយគ្មានវត្តមានមាតាបិតា នាយកសាលា/អ្នកទទួលសិទ្ធិត្រូវតែអាចចងក្រងឯកសារអំពីកិច្ចខិតខំប្រឹងប្រែងសមស្របដើម្បីរួមបញ្ចូលមាតាបិតា។ នាយកសាលា/អ្នកទទួលសិទ្ធិត្រូវបានសន្មតថាបានខិតខំប្រឹងប្រែងសមស្រប ប្រសិនបើនាយកសាលា/អ្នកទទួលសិទ្ធិបានផ្ញើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរ និងបានចងក្រងឯកសារអំពីការព្យាយាមយ៉ាងហោចណាស់ពីរ (2) ដងក្នុងការទាក់ទងមាតាបិតាតាមរបៀបមួយ ដែលមាតាបិតាបានបញ្ជាក់សម្រាប់ការជូនដំណឹងជាបន្ទាន់។ ការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅកាន់មាតាបិតាអាចធ្វើឡើងដោយដោយប្រគល់ផ្ទាល់ដៃ លិខិតអនុសិទ្ធិ សេវាប្រៃសណីយ៍ថ្នាក់ទីមួយ អ៊ីមែលទៅកាន់អាសយដ្ឋានដែលផ្តល់ដោយមាតាបិតាសម្រាប់ការទំនាក់ទំនងជាមួយសាលា

ឬតាមវិធីប្រគល់ផ្សេងទៀតដែលយល់ព្រមដោយនាយកសាលា/អ្នកទទួលសិទ្ធិ និងឪពុកម្តាយ។

គោលបំណងនៃសវនាការជាមួយនាយកសាលា/អ្នកទទួលសិទ្ធិគឺដើម្បីស្តាប់ និងពិចារណាព័ត៌មានទាក់ទងនឹងបទចោទប្រកាន់ដែលសិស្សអាចត្រូវបានព្យួរការសិក្សា ផ្តល់ឱកាសដល់សិស្សក្នុងការជំទាស់ការចោទប្រកាន់ និងពន្យល់ពីកាលៈទេសៈពាក់ព័ន្ធនឹងបទចោទប្រកាន់ កំណត់ថាតើសិស្សប្រព្រឹត្តល្មើសវិន័យដែរឬទេ ហើយបើដូច្នោះមែន ត្រូវតែទទួលខុសត្រូវចំពោះផលវិបាកដែលកើតឡើងពីការរំលោភបំពាន។ យ៉ាងហោចណាស់ នាយកសាលា/អ្នកទទួលសិទ្ធិត្រូវពិភាក្សាអំពីបទល្មើសវិន័យ មូលដ្ឋានសម្រាប់ការចោទប្រកាន់ និងព័ត៌មានពាក់ព័ន្ធផ្សេងទៀត។ សិស្សក៏នឹងមានឱកាសបង្ហាញព័ត៌មាន រួមទាំងអង្គហេតុនៃស្ថានសម្រាលទោស ដែលនាយកសាលា/អ្នកទទួលសិទ្ធិគួរពិចារណាក្នុងការកំណត់ថាតើដំណោះស្រាយ និងផលវិបាកផ្សេងទៀតអាចសមស្របដែរឬទេ។ នាយកសាលា/អ្នកទទួលសិទ្ធិត្រូវផ្តល់ឱកាសដល់មាតាបិតា បើមានវត្តមាន ដើម្បីពិភាក្សាអំពីចរិយារបស់សិស្ស និងផ្តល់ព័ត៌មាន រួមទាំងស្ថានសម្រាលទោស ដែលនាយកសាលា/អ្នកទទួលសិទ្ធិគួរពិចារណាក្នុងការកំណត់ផលវិបាកសម្រាប់សិស្ស។

ក្នុងគ្រប់ករណីនៃការប្រព្រឹត្តកំហុសរបស់សិស្ស ដែលការព្យួរការសិក្សាអាចធ្វើឡើង នាយកសាលា/អ្នកទទួលសិទ្ធិត្រូវប្រើឆន្ទានុសិទ្ធិក្នុងការសម្រេចចិត្តលើលទ្ធផលនៃបទល្មើស ពិចារណាវិធីដើម្បីជំរុញការចូលរួមរបស់សិស្សក្នុងការរៀនសូត្រឡើងវិញ និងចៀសវាងការប្រើប្រាស់ការព្យួរការសិក្សារយៈពេលវែងជាផលវិបាក រហូតដល់មានការសាកល្បងជម្រើសផ្សេងទៀត។ ជម្រើសផ្សេងទៀតអាចរួមមានការប្រើប្រាស់យុទ្ធសាស្ត្រ និងកម្មវិធីផ្អែកលើភស្តុតាង ដូចជាការសម្របសម្រួល ការដោះស្រាយជម្លោះ យុត្តិធម៌ស្តារឡើងវិញ និងការអន្តរាគមន៍ និងការគាំទ្រជាវិជ្ជមាន។

ដោយផ្អែកលើព័ត៌មានដែលមាន រួមទាំងស្ថានសម្រាលទោស នាយកសាលា/អ្នកទទួលសិទ្ធិត្រូវកំណត់ថាតើសិស្សបានប្រព្រឹត្តល្មើសវិន័យឬអត់ ហើយប្រសិនបើដូច្នេះមែន តើត្រូវអនុវត្តដំណោះស្រាយ ឬផលវិបាកអ្វីខ្លះ។

នាយកសាលា/អ្នកទទួលសិទ្ធិត្រូវជូនដំណឹងដល់សិស្ស និងមាតាបិតាអំពីការសម្រេចចិត្ត និងហេតុផលនៃការសម្រេចចិត្តនេះ ហើយប្រសិនបើសិស្សត្រូវបានផ្អាកការសិក្សា ប្រភេទ និងរយៈពេលនៃការព្យួរការសិក្សា និងឱកាសធ្វើសងកិច្ចការសាលា

និងការងារសាលាផ្សេងទៀតតាមតម្រូវការដើម្បីទទួលបានភាពរីកចម្រើនក្នុងការសិក្សាក្នុងអំឡុងពេលដកចេញ។ ការសម្រេចចិត្តត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ហើយអាចស្ថិតក្នុងទម្រង់នៃការធ្វើបច្ចុប្បន្នភាពចំពោះសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរច្បាប់ដើម។ មិនមានសិទ្ធិប្តឹងឧទ្ធរណ៍ចំពោះការព្យួរការសិក្សារយៈពេលខ្លីទៅកាន់អគ្គនាយកសាលាឡើយ។

ប្រសិនបើកូនសិស្សស្ថិតនៅក្នុងកម្មវិធីមុនមត្តេយ្យសាលារដ្ឋ ឬនៅក្នុងថ្នាក់ត្រៀមមត្តេយ្យសិក្សាដល់ថ្នាក់ទី 3 នាយកសាលាត្រូវផ្ញើច្បាប់ចម្លងនៃការសម្រេចចិត្តជាលាយលក្ខណ៍អក្សរទៅកាន់អគ្គនាយកសាលា និងពន្យល់ពីមូលហេតុនៃការដាក់ការព្យួរការសិក្សាក្រៅសាលា មុនពេលការផ្អាកការសិក្សារយៈពេលខ្លីចូលជាធរមាន។

## ផែនការសេវាកម្មអប់រំសាលារៀន

ផែនការសេវាកម្មអប់រំរបស់សាលាសាធារណៈ Lowell គួសបញ្ជាក់ពីសេវាកម្មអប់រំដែលមានសម្រាប់សិស្សដែលត្រូវបានបណ្តេញចេញពីសាលាជាលទ្ធផលនៃការព្យួរវិន័យ ឬការបណ្តេញចេញ។ ស្របតាមច្បាប់ទូទៅរបស់រដ្ឋ Massachusetts ជំពូកទី 76 មាត្រា 21 និង 603 CMR 53.13 ស្រុកនេះប្តេជ្ញាធានាថាសិស្សានុសិស្សបន្តទទួលបានឱកាសសិក្សា និងអាចទទួលបានវឌ្ឍនភាពសិក្សាក្នុងអំឡុងពេលនៃការបណ្តេញចេញ។ ផែនការសេវាកម្មអប់រំផ្តល់ជូនសិស្សដែលមានសិទ្ធិទទួលបានសេវាកម្មបង្រៀនដែលត្រូវបានរចនាឡើងដើម្បីគាំទ្រដល់ការចូលរួមជាបន្តបន្ទាប់នៅក្នុងកម្មវិធីសិក្សា ការបញ្ចប់កិច្ចការផ្ទះ និងវឌ្ឍនភាពឆ្ពោះទៅរកការបំពេញតាមការរំពឹងទុកកម្រិតថ្នាក់ និងតម្រូវការបញ្ចប់ការសិក្សា ដែលអាចអនុវត្តបាន។ សេវាកម្មអាចរួមបញ្ចូល ប៉ុន្តែមិនកំណត់ចំពោះ កិច្ចការផ្ទះដែលតម្រឹមទៅនឹងការបង្រៀនក្នុងថ្នាក់រៀន ការរៀនតាមអ៊ីនធឺណិត ឬតាមអ៊ីនធឺណិត ការបង្រៀនតាមអ៊ីនធឺណិត កម្មវិធីអប់រំជំនួស ឬការគាំទ្រការបង្រៀនផ្សេងទៀតដែលកំណត់ដោយស្រុក។ ព័ត៌មានទាក់ទងនឹងផែនការសេវាកម្មអប់រំ សេវាកម្មដែលមាន និងនីតិវិធីសម្រាប់ការចូលប្រើ សេវាកម្មទាំងនេះនឹងត្រូវបានផ្តល់ជូនសិស្ស និងឪពុកម្តាយ/អាណាព្យាបាល នៅពេលដែលមានការដកចេញពីវិន័យ។ ស្រុកលើកទឹកចិត្តគ្រួសារឱ្យធ្វើការសហការជាមួយបុគ្គលិកសាលា ដើម្បីធានាបាននូវនិរន្តរភាពនៃការរៀនសូត្រ និងការផ្លាស់ប្តូរទៅសាលារៀនវិញដោយជោគជ័យ បន្ទាប់ពីរយៈពេលនៃការដកចេញ។

**ការដកចេញពីសលាជាបន្ទាន់**

នាយកសាលា/អ្នកទទួលសិទ្ធិអាចដកសិស្សចេញពីសាលាជាបណ្ដោះអាសន្ន នៅពេលដែលសិស្សម្នាក់ត្រូវបានចោទប្រកាន់ពីបទល្មើសវិន័យ ហើយការបន្តវត្តមានរបស់សិស្សនោះបង្កគ្រោះថ្នាក់ដល់មនុស្ស ឬទ្រព្យសម្បត្តិ ឬធ្វើឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សណ្ដាប់ធ្នាប់របស់សាលា និងតាមការវិនិច្ឆ័យរបស់នាយកសាលា/អ្នកទទួលសិទ្ធិ ហើយមិនមានជម្រើសផ្សេងទៀតដែលអាចកាត់បន្ថយគ្រោះថ្នាក់ ឬការរំខានបានទេ។ នាយកសាលា/អ្នកទទួលសិទ្ធិត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអគ្គនាយកសាលាភ្លាមអំពីការដកចេញ និងហេតុផលនៃការដកចេញនេះ ហើយពិពណ៌នាអំពីគ្រោះថ្នាក់ដែលបង្កឡើងដោយសិស្សនោះ។ ការដកចេញជាបណ្ដោះអាសន្នមិនត្រូវលើសពីពីរ (2) ថ្ងៃសិក្សាឡើយ បន្ទាប់ពីថ្ងៃដកចេញពីសាលាជាបន្ទាន់ ក្នុងអំឡុងពេលនោះ នាយកសាលា/អ្នកទទួលសិទ្ធិត្រូវ៖

(a) ខិតខំប្រឹងប្រែងភ្លាមៗនិងសមស្របដើម្បីជូនដំណឹងដោយផ្ទាល់មាត់ដល់សិស្ស និងមាតាបិតារបស់សិស្សអំពីការដកចេញជាបន្ទាន់ ហេតុផលសម្រាប់តម្រូវការដកចេញជាបន្ទាន់ ហើយដែលបំពេញ និងអនុលោមតាមសេចក្ដីជូនដំណឹង និងលក្ខខណ្ឌតម្រូវខាងនីតិវិធីផ្លូវច្បាប់នៃការផ្អាកការសិក្សារយៈពេលខ្លី។

(b) ផ្ដល់ការជូនដំណឹងជាលាយលក្ខណ៍អក្សរដល់សិស្ស និងមាតាបិតាដែលបំពេញ និងអនុលោមតាមសេចក្ដីជូនដំណឹង និងលក្ខខណ្ឌតម្រូវខាងនីតិវិធីផ្លូវច្បាប់នៃការផ្អាកការសិក្សារយៈពេលខ្លី។

(c) ផ្ដល់ឱ្យសិស្សនូវឱកាសមានសវនាការជាមួយនាយកសាលា/អ្នកទទួលសិទ្ធិដែលអនុលោមតាមលក្ខខណ្ឌតម្រូវនៃការជូនដំណឹងអំពីការព្យួរការសិក្សារយៈពេលខ្លី និងរយៈពេលវែង ហើយមាតាបិតាមានឱកាសចូលរួមសវនាការ មុនពេលផុតកំណត់នៃសវនាការទាំងពីរ (2 ) ថ្ងៃសិក្សា លុះត្រាតែការពន្យារពេលសវនាការត្រូវបានយល់ព្រម ដោយនាយកសាលា/អ្នកទទួលសិទ្ធិ សិស្ស និងមាតាបិតា។

(d) ធ្វើការសម្រេចចិត្តដោយផ្ទាល់មាត់នៅថ្ងៃតែមួយនឹងសវនាការ ហើយជាលាយលក្ខណ៍អក្សរមិនលើសពីថ្ងៃសិក្សាបន្ទាប់ ដែលបំពេញ និងអនុលោមតាមសេចក្ដីជូនដំណឹង និងលក្ខខណ្ឌតម្រូវខាងនីតិវិធីផ្លូវច្បាប់នៃការព្យួរការសិក្សារយៈពេលខ្លី និងរយៈពេលវែង។

នាយកសាលា/អ្នកទទួលសិទ្ធិមិនអាចដកសិស្សចេញពីសាលាជាបន្ទាន់សម្រាប់បទល្មើសវិន័យបានទេ រហូតទាល់តែមានការរៀបចំគ្រប់គ្រាន់សម្រាប់សុវត្ថិភាព និងការធ្វើដំណើររបស់សិស្ស។

ក្នុងគ្រប់ករណីនៃការប្រព្រឹត្តកំហុសរបស់សិស្ស ដែលអាចឈានទៅដល់ការព្យួរការសិក្សា នាយកសាលា/អ្នកទទួលសិទ្ធិត្រូវប្រើឆន្ទានុសិទ្ធិក្នុងការសម្រេចចិត្តលើលទ្ធផលនៃបទល្មើស ពិចារណាវិធីដើម្បីជំរុញការចូលរួមរបស់សិស្សក្នុងការរៀនសូត្រឡើងវិញ និងចៀសវាងការប្រើប្រាស់ការព្យួរការសិក្សារយៈពេលវែងជាផលវិបាក រហូតដល់មានការសាកល្បងជម្រើសផ្សេងទៀត។ ជម្រើសផ្សេងទៀតអាចរួមមានការប្រើប្រាស់យុទ្ធសាស្រ្ត និងកម្មវិធីផ្អែកលើភស្តុតាង ដូចជាការសម្របសម្រួល ការដោះស្រាយជម្លោះ យុត្តិធម៌ស្តារឡើងវិញ និងការអន្តរាគមន៍ និងការគាំទ្រជាវិជ្ជមាន។

**ការព្យួរការសិក្សារយៈពេលវែង និងនីតិវិធីបណ្តឹងសាទុក្ខក្រោមច្បាប់ M.G.L. 37H 3/4**

"ការព្យួរការសិក្សារយៈពេលវែង" សំដៅលើការដកសិស្សចេញពីបរិវេណសាលា និងសកម្មភាពក្នុងថ្នាក់រៀនទៀងទាត់លើសពីដប់ (10) ថ្ងៃសិក្សាជាប់ៗគ្នា ឬលើសពីដប់ (10) ថ្ងៃសិក្សាបូកបញ្ចូលគ្នាសម្រាប់បទល្មើសវិន័យជាច្រើនដងក្នុងឆ្នាំសិក្សាណាមួយ។ នាយកសាលា/អ្នកទទួលសិទ្ធិអាចអនុញ្ញាតឱ្យសិស្សធ្វើការព្យួរការសិក្សារយៈពេលវែងនៅក្នុងសាលាតាមឆន្ទានុសិទ្ធិរបស់គាត់។ ការដកចេញចំពោះតែការចូលរួមក្នុងសកម្មភាពក្រៅកម្មវិធីសិក្សា ឬព្រឹត្តិការណ៍ដែលឧបត្ថម្ភដោយសាលា ឬទាំងពីរ មិនត្រូវរាប់ជាការដកចេញក្នុងការគណនាចំនួនថ្ងៃសិក្សាឡើយ។ លើកលែងតែសិស្សដែលត្រូវបានចោទប្រកាន់ពីបទល្មើសវិន័យដែលមានចែងក្នុងផ្នែករង (a) ឬ (b) នៃ G.L. c. 71, §37 H ឬនៅក្នុងផ្នែក 37H ½ នៃ G.L. c. 71គ្មានសិស្សណាម្នាក់អាចត្រូវបានព្យួរការសិក្សារយៈពេលវែងសម្រាប់បទល្មើសវិន័យមួយ ឬច្រើនសម្រាប់រយៈពេលសិក្សាលើសពីកៅសិប (90) ថ្ងៃក្នុងឆ្នាំសិក្សាមួយ ដោយចាប់ផ្តើមពីថ្ងៃដំបូងដែលសិស្សត្រូវបានដកចេញពីសាលាឡើយ។ គ្មានការព្យួរការសិក្សារយៈពេលវែងត្រូវបន្តលើសពីចុងឆ្នាំសិក្សាដែលធ្វើការព្យួរបែបនេះឡើយ។

គោលបំណងនៃសវនាការគឺដូចគ្នានឹងគោលបំណងនៃសវនាការអំពីការផ្អាកការសិក្សារយៈពេលខ្លីដែរ។ យ៉ាងហោចណាស់ បន្ថែមពីលើសិទ្ធិដែលផ្តល់ឱ្យសិស្សក្នុងសវនាការអំពីការព្យួរការសិក្សារយៈពេលខ្លី សិស្សត្រូវមានសិទ្ធិដូចខាងក្រោម៖

- មុនសវនាការ មានឱកាសពិនិត្យមើលកំណត់ត្រារបស់សិស្ស និងឯកសារ ដែលនាយកសាលា/អ្នកទទួលសិទ្ធិអាចពឹងផ្អែកលើ សម្រាប់ធ្វើការសម្រេចចិត្តក្នុងការព្យួរការសិក្សារបស់សិស្សឬអត់
- សិទ្ធិត្រូវបានតំណាងដោយអ្នកប្រឹក្សា ឬអ្នកតំណាងតាមជម្រើសរបស់សិស្ស ដោយជាបន្ទុកចំណាយរបស់សិស្ស/មាតាបិតា
- សិទ្ធិបង្កើតសាក្សីជំនួសគាត់ និងបង្ហាញការពន្យល់របស់សិស្សអំពីបទចោទប្រកាន់ ប៉ុន្តែសិស្សប្រហែលជាមិនត្រូវបានបង្ខំឱ្យធ្វើដូច្នេះទេ
- សិទ្ធិពិនិត្យសាក្សីដែលបង្ហាញដោយមណ្ឌលសិក្សាធិការ
- សិទ្ធិស្នើសុំឱ្យមានការកត់ត្រាសវនាការដោយនាយកសាលា/អ្នកទទួលសិទ្ធិ និងទទួលបានច្បាប់ចម្លងនៃខ្សែអាត់សំឡេងតាមការស្នើសុំ។ ប្រសិនបើសិស្ស ឬមាតាបិតាស្នើសុំខ្សែអាត់សំឡេង នាយកសាលា/អ្នកទទួលសិទ្ធិត្រូវជូនដំណឹងដល់អ្នកចូលរួមទាំងអស់មុខសវនាការថា ខ្សែអាត់សំឡេងនឹងត្រូវបានថត ហើយច្បាប់ចម្លងមួយនឹងត្រូវបានផ្តល់ជូនសិស្ស និងមាតាបិតាតាមការស្នើសុំ។

នាយកសាលា/អ្នកទទួលសិទ្ធិត្រូវផ្តល់ឱកាសដល់មាតាបិតា បើមានវត្តមាន ដើម្បីពិភាក្សាអំពីចរិយារបស់សិស្ស និងផ្តល់ព័ត៌មាន រួមទាំងស្ថានសម្រាលទោស ដែលនាយកសាលា/អ្នកទទួលសិទ្ធិគួរពិចារណាក្នុងការកំណត់ផលវិបាកសម្រាប់សិស្ស។

ដោយផ្អែកលើភស្តុតាង នាយកសាលា/អ្នកទទួលសិទ្ធិត្រូវកំណត់ថាតើសិស្សបានប្រព្រឹត្តល្មើសវិន័យឬអត់ ហើយប្រសិនបើប្រព្រឹត្តមែន បន្ទាប់ពីពិចារណាលើស្ថានសម្រាលទោស និងជម្រើសនៃការព្យួរការសិក្សាហើយ តើត្រូវប្រើដំណោះស្រាយ ឬនឹងត្រូវផ្តល់ផលវិបាកអ្វី ជំនួសឲ្យ ឬបន្ថែមលើការផ្អាកការសិក្សារយៈពេលវែង។ នាយកសាលា/អ្នកទទួលសិទ្ធិត្រូវផ្ញើសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរទៅកាន់សិស្ស និងមាតាបិតាដោយប្រគល់ផ្ទាល់ដៃ លិខិតអនុសិទ្ធិ សេវាប្រៃសណីយ៍ថ្នាក់ទីមួយ អ៊ីមែលទៅកាន់អាសយដ្ឋានដែលផ្តល់ដោយមាតាបិតាសម្រាប់ការទំនាក់ទំនងជាមួយសាលា

ឬតាមវិធីប្រគល់ផ្សេងទៀតដែលយល់ព្រមដោយនាយកសាលា/អ្នកទទួលសិទ្ធិ និងឪពុកម្តាយ។ ប្រសិនបើនាយកសាលា/អ្នកទទួលសិទ្ធិសម្រេចចិត្តផ្អាកការសិក្សារបស់សិស្ស សេចក្តីសម្រេចជាលាយលក្ខណ៍អក្សរត្រូវអនុលោមតាម 603 CMR 53.08(3)(d)(1-5) ដែលចែងដូចខាងក្រោម៖

1. កំណត់បទល្មើសវិន័យ កាលបរិច្ឆេទដែលសវនាការត្រូវបានធ្វើឡើង និងអ្នកចូលរួមនៅក្នុងសវនាការ
2. កំណត់ពីអង្គហេតុ និងការសន្និដ្ឋានសំខាន់ៗដែលសម្រេចបានដោយនាយកសាលា/អ្នកទទួលសិទ្ធិ
3. កំណត់រយៈពេល និងកាលបរិច្ឆេទមានប្រសិទ្ធភាពនៃការព្យួរការសិក្សាក៏ដូចជាកាលបរិច្ឆេទនៃការត្រលប់ចូលរៀនវិញ
4. រួមបញ្ចូលការជូនដំណឹងអំពីឱកាសរបស់សិស្សក្នុងការទទួលបានសេវាអប់រំ ដើម្បីធ្វើឱ្យមានការរីកចម្រើនក្នុងការសិក្សាក្នុងអំឡុងពេលនៃការដកចេញពីសាលារៀនដូចដែលបានចែងនៅក្នុងច្បាប់ 603 CMR 53.13(4)(a)
5. ជូនដំណឹងដល់សិស្សអំពីសិទ្ធិប្តឹងតវ៉ាចំពោះការសម្រេចចិត្តរបស់នាយកសាលា/អ្នកទទួលសិទ្ធិទៅកាន់អគ្គនាយកសាលា ឬអ្នកទទួលសិទ្ធិ ប៉ុន្តែលុះត្រាតែនាយកសាលា/អ្នកទទួលសិទ្ធិបានដាក់ការព្យួរការសិក្សារយៈពេលវែង។ សេចក្តីជូនដំណឹងអំពីសិទ្ធិនៃបណ្តឹងឧទ្ធរណ៍ត្រូវធ្វើឡើងជាភាសាអង់គ្លេស និងជាភាសាកំណើតដែលប្រើនៅផ្ទះ ប្រសិនបើមិនមែនជាភាសាអង់គ្លេស ឬមធ្យោបាយទំនាក់ទំនងផ្សេងទៀតដែលសមស្រប ហើយត្រូវរួមបញ្ចូលព័ត៌មានខាងក្រោមដែលមានចែងជាភាសាសាមញ្ញងាយយល់៖

    i. ដំណើរការសម្រាប់ការប្តឹងឧទ្ធរណ៍ជំទាស់នឹងការសម្រេចចិត្ត រួមទាំងថាសិស្ស ឬមាតាបិតាត្រូវដាក់លិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីបណ្តឹងឧទ្ធរណ៍ជាមួយអគ្គនាយកក្នុងរយៈពេលប្រាំ (5) ថ្ងៃប្រតិទិនគិតចាប់ពីកាលបរិច្ឆេទមានប្រសិទ្ធភាពនៃការព្យួរការសិក្សារយៈពេលវែង លុះត្រាក្នុងរយៈពេលប្រាំ (5) ថ្ងៃប្រតិទិន សិស្ស ឬមាតាបិតាអាចស្នើសុំ និងទទួលបានពីអគ្គនាយកសាលានូវការពន្យារពេលដាក់លិខិតជូនដំណឹងជាលាយលក្ខណ៍អក្សររហូតដល់ប្រាំពីរ (7) ថ្ងៃបន្ថែម ហើយថា
    ii. ការផ្អាកការសិក្សារយៈពេលវែងនឹងនៅតែមានប្រសិទ្ធភាព លើកលែងតែអគ្គនាយកសាលាសម្រេចបដិសេធការសម្រេចរបស់នាយកសាលា/អ្នកទទួល

សិទ្ធិលើបណ្តឹងឧទ្ធរណ៍។

ក្នុងគ្រប់ករណីនៃការប្រព្រឹត្តកំហុសរបស់សិស្ស ដែលការព្យួរការសិក្សាអាចធ្វើឡើង នាយកសាលា/អ្នកទទួលសិទ្ធិត្រូវប្រើឆន្ទានុសិទ្ធិក្នុងការសម្រេចចិត្តលើលទ្ធផលនៃបទល្មើស ពិចារណាវិធីដើម្បីជំរុញការចូលរួមរបស់សិស្សក្នុងការរៀនសូត្រឡើងវិញ និងចៀសវាងការប្រើប្រាស់ការព្យួរការសិក្សារយៈពេលវែងជាផលវិបាក រហូតដល់មានការសាកល្បងជម្រើសផ្សេងទៀត។ ជម្រើសផ្សេងទៀតអាចរួមមានការប្រើប្រាស់យុទ្ធសាស្រ្ត និងកម្មវិធីផ្អែកលើភស្តុតាង ដូចជាការសម្របសម្រួល ការដោះស្រាយជម្លោះ យុត្តិធម៌ស្តារឡើងវិញ ព្រមទាំងការអន្តរាគមន៍ និងការគាំទ្រជាវិជ្ជមាន។

ប្រសិនបើសិស្សស្ថិតនៅក្នុងកម្មវិធីត្រៀមមត្តេយ្យសិក្សារដ្ឋ ឬនៅក្នុងថ្នាក់មត្តេយ្យដល់ថ្នាក់ទី 3 នាយកសាលាត្រូវធ្វើច្បាប់ចម្លងនៃសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរទៅកាន់អគ្គនាយកសាលា ហើយពន្យល់ពីមូលហេតុនៃការព្យួរការសិក្សាក្រៅសាលា មិនថារយៈពេលខ្លី ឬរយៈពេលវែង មុនពេលការផ្អាកការសិក្សាចូលជាធរមាន។

សិស្សដែលត្រូវបានព្យួរការសិក្សារយៈពេលវែងបន្ទាប់ពីសវនាការជាមួយនាយកសាលា/អ្នកទទួលសិទ្ធិ មានសិទ្ធិប្តឹងឧទ្ធរណ៍ជំទាស់នឹងការសម្រេចចិត្តរបស់នាយកសាលា/អ្នកទទួលសិទ្ធិ ទៅកាន់អគ្គនាយកសាលា/អ្នកទទួលសិទ្ធិ

សិស្ស ឬមាតាបិតាត្រូវដាក់សេចក្តីជូនដំណឹងអំពីការប្តឹងឧទ្ធរណ៍ជាមួយអគ្គនាយកសាលា/អ្នកទទួលសិទ្ធិ ក្នុងរយៈពេលប្រាំ (5) ថ្ងៃប្រតិទិនគិតចាប់ពីកាលបរិច្ឆេទដែលមានប្រសិទ្ធភាពនៃការព្យួរការសិក្សារយៈពេលវែង លើកលែងតែមានការស្នើសុំពន្យារពេលបន្ថែម (សូមមើលចំណុច 5- ខាងលើ។) ប្រសិនបើមិនបានដាក់ពាក្យបណ្តឹងឧទ្ធរណ៍ទាន់ពេលវេលាទេ អគ្គនាយកសាលា/អ្នកទទួលសិទ្ធិ អាចបដិសេធបណ្តឹងឧទ្ធរណ៍ ឬអាចអនុញ្ញាតឱ្យប្តឹងឧទ្ធរណ៍តាមឆន្ទានុសិទ្ធិរបស់គាត់ ប្រសិនបើមានហេតុផលសមស្រប ។ អគ្គនាយកសាលា/អ្នកទទួលសិទ្ធិ ត្រូវបើកសវនាការក្នុងរយៈពេលបី (3) ថ្ងៃនៃថ្ងៃសិក្សាដែលសិស្សស្នើសុំ លើកលែងតែសិស្ស ឬមាតាបិតាស្នើសុំពន្យារពេលរហូតដល់ប្រាំពីរ (7) ថ្ងៃបន្ថែម ក្នុងករណីនេះ អគ្គនាយកសាលា/អ្នកទទួលសិទ្ធិ ត្រូវផ្តល់ការពន្យារពេល។

អគ្គនាយកសាលា/អ្នកទទួលសិទ្ធិ នឹងខិតខំប្រឹងប្រែងស្មោះត្រង់ ដើម្បីរួមបញ្ចូលមាតាបិតានៅក្នុងសវនាការ។ អគ្គនាយកសាលា/អ្នកទទួលសិទ្ធិ នឹងត្រូវសន្មតថាបានខិតខំប្រឹងប្រែងដោយស្មោះត្រង់

ប្រសិនបើគាត់បានខិតខំប្រឹងប្រែងស្វែងរកថ្ងៃ និងពេលវេលាសម្រាប់សវនាការដែលនឹងអនុញ្ញាតឱ្យមាតាបិតា និងអគ្គនាយកសាលា/អ្នកទទួលសិទ្ធិ ចូលរួម។ អគ្គនាយកសាលា/អ្នកទទួលសិទ្ធិ ត្រូវផ្ញើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរទៅមាតាបិតាអំពីកាលបរិច្ឆេទ ពេលវេលា និងទីតាំងនៃសវនាការ។

អគ្គនាយកសាលា/អ្នកទទួលសិទ្ធិ នឹងធ្វើសវនាការដើម្បីកំណត់ថាតើសិស្សបានប្រព្រឹត្តបទល្មើសវិន័យដែលសិស្សត្រូវបានចោទប្រកាន់ដែរឬទេ ហើយប្រសិនបើប្រព្រឹត្តមែន តើលទ្ធផលនឹងទៅជាយ៉ាងណា។ អគ្គនាយកសាលា/អ្នកទទួលសិទ្ធិ នឹងរៀបចំសម្រាប់ការថតអាត់សំឡេងសវនាការ ដែលច្បាប់ចម្លងនឹងត្រូវផ្តល់ជូនសិស្ស ឬមាតាបិតាតាមការស្នើសុំ។ អគ្គនាយកសាលា/អ្នកទទួលសិទ្ធិ ត្រូវជូនដំណឹងដល់អ្នកចូលរួមទាំងអស់នៅមុខសវនាការថា ការថតអាត់សំឡេងនឹងត្រូវបានថតពីសវនាការ ហើយច្បាប់ចម្លងនឹងត្រូវបានផ្តល់ជូនសិស្ស និងមាតាបិតាតាមការស្នើសុំ។ សិស្សត្រូវមានសិទ្ធិទាំងអស់ដែលបានផ្តល់ឱ្យសិស្សនៅសវនាការរបស់នាយកសាលា/អ្នកទទួលសិទ្ធិសម្រាប់ការព្យួរការសិក្សារយៈពេលវែង។

អគ្គនាយកសាលា/អ្នកទទួលសិទ្ធិ ត្រូវចេញសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរក្នុងរយៈពេលប្រាំ (5) ថ្ងៃនៃថ្ងៃបើកសវនាការ តាមការទាមទារដោយច្បាប់ 603 CMR 53.08(3)(d)(1-4) ដោយបញ្ជាក់ដូចខាងក្រោម៖

1) បទល្មើសវិន័យ កាលបរិច្ឆេទ និងអ្នកចូលរួមដែលមានវត្តមានក្នុងសវនាការ
2) អង្គហេតុសំខាន់ៗ និងការសន្និដ្ឋាន
3) រយៈពេល និងកាលបរិច្ឆេទដែលមានប្រសិទ្ធភាពនៃការព្យួរការសិក្សា និងការត្រលប់ចូលរៀនវិញ និង
4) លិខិតជូនដំណឹងអំពីឱកាសរបស់សិស្សក្នុងការទទួលបានសេវាអប់រំអំឡុងពេលត្រូវបានដកចេញ។

ប្រសិនបើអគ្គនាយកសាលា/អ្នកទទួលសិទ្ធិ កំណត់ថាសិស្សបានប្រព្រឹត្តល្មើសវិន័យ អគ្គនាយកសាលា/អ្នកទទួលសិទ្ធិ អាចដាក់ផលវិបាកដូចគ្នា ឬតិចជាងនាយកសាលា/អ្នកទទួលសិទ្ធិ ប៉ុន្តែមិនត្រូវដាក់ការព្យួរការសិក្សាធំជាងការកំណត់ដោយការសម្រេចចិត្តរបស់នាយកសាលា/អ្នកទទួលសិទ្ធិឡើយ។

ការសម្រេចចិត្តរបស់អគ្គនាយកសាលា/អ្នកទទួលសិទ្ធិ នឹងក្លាយជាការសម្រេចចិត្តចុងក្រោយរបស់មណ្ឌលសិក្សាធិការ សាលារដ្ឋស្វយ័ត ឬសាលាអនឡាញ ទាក់ទងនឹងការផ្អាកការសិក្សា។

**បទល្មើសធ្ងន់ធ្ងរ – ការផ្អាកការសិក្សារយៈពេលវែង ឬការបណ្ដេញចេញ**
(M.G.L. ជំពូកទី 71 ផ្នែក 37H)

បទល្មើសខាងក្រោមអាចបណ្ដាលឱ្យមានសវនាការនៅចំពោះមុខនាយកសាលា ដើម្បីកំណត់ថាតើសិស្សគួរត្រូវបានព្យួរការសិក្សា ឬបណ្ដេញចេញដែរឬទេ៖

**I. ការវាយដំ និង/ឬទាត់ធាក់បុគ្គលិកសាលា**

សិស្សណាក៏ដោយដែលវាយដំនាយកសាលា ជំនួយការនាយកសាលា គ្រូ អ្នកជំនួយការគ្រូ ឬបុគ្គលិកអប់រំផ្សេងទៀតនៅក្នុងបរិវេណសាលា ឬនៅក្នុងព្រឹត្តិការណ៍ដែលឧបត្ថម្ភដោយសាលា រួមទាំងការប្រកួតកីឡាអត្តពលកម្ម អាចនឹងត្រូវដាក់ពិន័យព្យួរការសិក្សា ឬបណ្ដេញចេញពីសាលា ឬមណ្ឌលសិក្សាធិការដោយនាយកសាលា។ (វិធាននេះក៏ទាក់ទងនឹងឡានក្រុងសាលាដែរ។) *ការគំរាមកំហែងដោយហិង្សាលើបុគ្គលិកសាលាអាច/អាចត្រូវបានចាត់ថ្នាក់ជាការវាយដំ។

**II. ការកាន់កាប់ ឬប្រើប្រាស់អាវុធគ្រោះថ្នាក់ ឬវត្ថុចម្លងតាមអាវុធគ្រោះថ្នាក់ រួមទាំង ប៉ុន្តែមិនកំណត់ត្រឹមចំពោះកាំភ្លើង ឬកាំបិត**

សិស្សណាក៏ដោយដែលត្រូវបានគេរកឃើញនៅក្នុងបរិវេណសាលា ឬនៅក្នុងព្រឹត្តិការណ៍ដែលឧបត្ថម្ភដោយសាលា ឬដែលទាក់ទងនឹងសាលា រួមទាំងការប្រកួតកីឡាអត្តពលកម្ម មានកាន់កាប់អាវុធគ្រោះថ្នាក់ ឬវត្ថុចម្លងសមស្រប រួមទាំង ប៉ុន្តែមិនកំណត់ត្រឹមចំពោះកាំភ្លើង ឬកាំបិត អាចនឹងត្រូវផ្អាកការសិក្សា ឬការបណ្ដេញចេញពីសាលា ឬមណ្ឌលសិក្សាធិការដោយនាយកសាលា។

**III. ការលក់ និង/ឬការកាន់កាប់ និង/ឬការផ្ទេរសារធាតុដែលមានការគ្រប់គ្រង**

សិស្សណាក៏ដោយដែលត្រូវបានសាលារកឃើញនៅក្នុងបរិវេណសាលា ឬនៅក្នុងព្រឹត្តិការណ៍ដែលឧបត្ថម្ភដោយសាលា ឬដែលទាក់ទងនឹងសាលារៀន រួមទាំងការប្រកួតកីឡាអត្តពលកម្ម ថាមានកាន់កាប់សារធាតុដែលមានការគ្រប់គ្រង ដូចដែលបានកំណត់ក្នុងជំពូកកៅសិបបួន C រួមទាំង ប៉ុន្តែមិនកំណត់ត្រឹមចំពោះកញ្ឆា កូកាអ៊ីន និងហេរ៉ូអ៊ីន អាចនឹងត្រូវនាយកសាលាព្យួរការសិក្សា ឬបណ្តេញចេញពីសាលា ឬមណ្ឌលសិក្សាធិការ។

**សវនាការដែលនាំទៅដល់ការព្យួរការសិក្សា ឬការបណ្តេញចេញ (នីតិវិធីផ្លូវច្បាប់)**

សិស្សណាក៏ដោយដែលត្រូវបានចោទប្រកាន់ពីបទល្មើសលើចំណុចណាមួយដែលបានរៀបរាប់ខាងលើនឹងទទួលបានការ ដំណឹងជាលាយលក្ខណ៍អក្សរអំពីឱកាសសវនាការ ទោះយ៉ាងណាក៏ដោយ ដរាបណាសិស្សអាចមានតំណាងរួមជាមួយនឹងឱកាសដើម្បីបង្ហាញភស្តុតាង និងសាក្សីនៅក្នុងសវនាការខាងលើនៅចំពោះមុខនាយកសាលា។ បន្ទាប់ពីសវនាការខាងលើ តាមឆន្ទានុសិទ្ធិរបស់ខ្លួន នាយកសាលាអាចសម្រេចផ្អាកការសិក្សាជាជាងបណ្តេញសិស្សដែលត្រូវបានកំណត់ដោយនាយកសាលាថាបានបំពានលើចំណុចណាមួយដែលបានរៀបរាប់ខាងលើ។

**នីតិវិធីបណ្តឹងឧទ្ធរណ៍ពីបទផ្អាកការសិក្សា ឬបណ្តេញចេញក្រោមច្បាប់ M.G.L. 37H**

សិស្សណាក៏ដោយដែលត្រូវបានព្យួរការសិក្សា ឬបណ្តេញចេញពីមណ្ឌលសិក្សាធិការដោយអនុលោមតាម 37H មានសិទ្ធិប្តឹងឧទ្ធរណ៍ទៅអគ្គនាយកសាលា។ សិស្សដែលត្រូវបានព្យួរការសិក្សា ឬបណ្តេញចេញត្រូវមានរយៈពេល**ដប់ថ្ងៃ** គិតចាប់ពីកាលបរិច្ឆេទព្យួរការសិក្សា ឬបណ្តេញចេញត្រូវជូនដំណឹងទៅកាន់អគ្គនាយកសាលាអំពីបណ្តឹងឧទ្ធរណ៍របស់គាត់។ សិស្សមានសិទ្ធិការពារខ្លួននៅក្នុងសវនាការនៅចំពោះមុខអគ្គនាយកសាលា ប្រសិនបើសិស្សជ្រើសរើសធ្វើដូច្នេះ។ កម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍មិនកំណត់ត្រឹមតែចំពោះការសម្រេចតាមការពិតថាតើសិស្សបានរំលោភលើបទប្បញ្ញត្តិណាមួយនៃផ្នែកនេះឬអត់នោះទេ។

**សិស្សដែលត្រូវបានចោទប្រកាន់ ឬត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋ និងនីតិវិធីបណ្តឹងឧទ្ធរណ៍ក្រោមច្បាប់ M.G.L. 37H1/2**

**(M.G.L. ជំពូកទី 71 ផ្នែក 37H1/2)**

នៅពេលចេញឯកសារ និង/ឬការកាត់ទោសបទឧក្រិដ្ឋចោទប្រកាន់សិស្សពីបទឧក្រិដ្ឋ ឬនៅពេលចេញពាក្យបណ្តឹងពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងសិស្ស នាយកសាលាអាចបណ្តេញចេញ ឬជ្រើសរើសព្យួរការសិក្សារបស់សិស្សនោះក្នុងរយៈពេលដែលកំណត់សមស្របដោយនាយកសាលា

ប្រសិនបើនាយកសាលាកំណត់ថាការបន្តវត្តមានរបស់សិស្សនៅក្នុងសាលានឹងមាន*ផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ*លើសុខុមាលភាពទូទៅរបស់សាលា។ សិស្សត្រូវទទួលបានការជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការចោទប្រកាន់ និងមូលហេតុនៃការផ្អាកការសិក្សានេះ មុនពេលការព្យួរបែបនេះចូលជាធរមាន។

សិស្ស ឬមាតាបិតា/អាណាព្យាបាលរបស់សិស្សមានសិទ្ធិប្ដឹងឧទ្ធរណ៍ចំពោះការព្យួរការសិក្សា ឬបណ្ដេញចេញទៅកាន់អគ្គនាយកសាលា ហើយអាចនាំយកមេធាវីមកបាន ប្រសិនបើសិស្សជ្រើសរើសធ្វើដូច្នេះ។ មាតាបិតា/អាណាព្យាបាលរបស់សិស្ស ឬសិស្សត្រូវជូនដំណឹងទៅអគ្គនាយកសាលាជាលាយលក្ខណ៍អក្សរអំពីសំណើសុំបណ្ដឹងឧទ្ធរណ៍របស់គាត់មិនលើសពី **ប្រាំថ្ងៃប្រតិទិន** បន្ទាប់ពីកាលបរិច្ឆេទនៃការផ្អាកការសិក្សាចូលជាធរមាន។ អគ្គនាយកសាលាត្រូវបើកសវនាការជាមួយសិស្ស និងឪពុកម្ដាយ ឬអាណាព្យាបាលរបស់សិស្សក្នុងរយៈពេលបីថ្ងៃតាមប្រតិទិនសម្រាប់ការស្នើសុំបណ្ដឹងឧទ្ធរណ៍របស់សិស្ស។

**ការលើកលែងរបស់គណៈកម្មាធិការសាលា** (អាស្រ័យលើ និងត្រូវតែអានស្របតាមច្បាប់ **M.G.L. ជំពូកទី 71 ផ្នែក 37H ¾)**
**(M.G.L. ជំពូកទី 76 ផ្នែក 16 &17)**
នាយកសាលា ឬគណៈកម្មាធិសាលាអាចដាក់វិន័យសិស្សដោយស្របច្បាប់ចំពោះកំហុស បើទោះបីជាកំហុសនេះមិនត្រូវបានពិពណ៌នាជាក់លាក់នៅក្នុងច្បាប់វិន័យទាំងនេះក៏ដោយ។ ចំណាត់ការបែបនេះនឹងអនុលោមតាមលក្ខខណ្ឌតម្រូវខាងនីតិវិធីផ្លូវច្បាប់ ហើយមិនត្រូវអនុវត្តតាមអំពើចិត្ត ឬដោយចេតនាឡើយ។ នេះក៏អាចអនុវត្តចំពោះសកម្មភាពដែលនៅក្រៅសាលារៀនផងដែរ ហើយថាជនល្មើសបានដឹងថាទង្វើរបស់គាត់ខុសធ្ងន់ធ្ងរ និងផ្ទុយពីគោលនយោបាយរបស់សាលា។

ចំណាំ៖ <u>Nicholas B. v. គណៈកម្មាធិការសាលា Worcester</u>៖
តុលាការបានតម្កល់ចំណាត់ការរបស់គណៈកម្មាធិការសាលា Worcester ក្នុងនោះនៅពេលសិស្សជាប់ពាក់ព័ន្ធនឹងឧបទ្ទវហេតុក្រោយពីម៉ោងរៀននៅក្រៅបរិវេណសាលាដោយបានរៀបចំគម្រោងនៅក្នុងសាលា សិស្សម្នាក់នោះឬសិស្សច្រើននាក់នោះនៅតែត្រូវទទួលវិន័យសាលា។ តុលាការបានសម្រេចថា សិស្សបានដឹងថាទង្វើហិង្សារបស់ខ្លួនគឺខុសធ្ងន់ធ្ងរ និងផ្ទុយពីគោលនយោបាយរបស់សាលា បើទោះបីជាក្រមវិន័យមិនបានចែងពីសកម្មភាពនៅក្រៅបរិវេណសាលាក៏ដោយ។

**ស្ថានភាពក្រៅបរិវេណសាលា**

វិន័យទាក់ទងនឹងឥរិយាបថរបស់សិស្សក៏ចូលជាធរមានពេញលេញ និងមានប្រសិទ្ធភាពសម្រាប់សិស្ស ខណៈពេលដែលស្ថិតក្នុងស្ថានភាពក្រៅបរិវេណសាលាអំឡុងពេលម៉ោងសិក្សា និងក្រោយម៉ោងសិក្សា និងថ្ងៃមិនរៀន ជាផ្នែកនៃក្រុម ក្លឹប ទស្សនកិច្ចសិក្សា កិច្ចការ ការដឹកជញ្ជូនរបស់សាលា ឬជាអ្នកចូលរួម ឬអ្នកមើលសកម្មភាពដាក់ទណ្ឌកម្មរបស់សាលាផ្សេងទៀតនៅក្នុង ឬជុំវិញទីតាំងនៃសកម្មភាព (រួមទាំងកន្លែងចតរថយន្ត។)

វិធានការវិន័យក៏អាចធ្វើឡើងសម្រាប់***ឥរិយាបថក្នុង ឬក្រៅបរិវេណសាលា*** រួមមាន ប៉ុន្តែមិនកំណត់ត្រឹមចំពោះ ការបង្ហោះតាមទូរសព្ទដៃ និង/ឬរូបថត ការផ្ញើសារ និងការបង្ហោះតាមអ៊ីនធឺណិត និង/ឬរូបថតដែលអាចទាយទុកជាមុនបានក្នុងការទទួលបានការយកចិត្តទុកដាក់ពីអ្នកគ្រប់គ្រងសាលា និងបង្កើតហានិភ័យនៃការរំខានយ៉ាងខ្លាំង និងធ្ងន់ធ្ងរដល់ការងារ និងវិន័យរបស់សាលា។

**ការព្យួរការសិក្សា**
សិស្សដែលត្រូវបានព្យួរការសិក្សាមិនត្រូវបានអនុញ្ញាតឲ្យមានវត្តមានស្ថិតនៅលើបរិវេណសាលា ឬត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុង ឬជាភ្ញៀវ ឬជាអ្នកចូលរួមនៅក្នុងកម្មវិធី ការប្រារព្ធកម្មវិធីរបស់ធីសាលា និងសកម្មភាពក្រៅកម្មវិធីសិក្សាឡើយ។

សិស្សដែលត្រូវបានព្យួរការសិក្សានឹងត្រូវបានផ្តល់ឱកាសឱ្យទទួលបានសេវាអប់រំ និងធ្វើឱ្យដំណើរការសិក្សាស្របតាមផែនការសេវាអប់រំទូទាំងសាលា។ សិស្សមានទំនួលខុសត្រូវក្នុងការបំពេញការងារក្នុងរយៈពេលដែលបានបញ្ជាក់ដោយផែនការសេវាកម្ម។

**ការបញ្ជូនកំណត់ត្រានៃការបណ្តេញចេញ**
នៅពេលដែលសិស្សម្នាក់ត្រូវបានបណ្តេញចេញ ឬព្យួរការសិក្សាក្រោមបទប្បញ្ញត្តិនៃផ្នែកនេះ គ្មានសាលារៀន ឬមណ្ឌលសិក្សាធិការណាមួយក្នុងសហធនរដ្ឋនេះ ត្រូវបានតម្រូវឱ្យទទួលយកសិស្សនោះ ឬផ្តល់សេវាអប់រំដល់សិស្សនោះឡើយ។ ប្រសិនបើសិស្សនោះដាក់ពាក្យសុំចូលរៀននៅសាលា ឬមណ្ឌលសិក្សាធិការផ្សេង អគ្គនាយកមណ្ឌលសិក្សាធិកាដែលសិស្សនោះដាក់ពាក្យសុំ អាចស្នើសុំ ហើយត្រូវទទួលពីអគ្គនាយកសាលាដែលបណ្តេញសិស្សនោះនូវសេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរអំពីហេតុផលនៃការបណ្តេញចេញ៖

- សិស្សត្រូវតែបំពេញកិច្ចការទាំងអស់ដែលបានដាក់ឱ្យ។

- សិស្សមានទំនួលខុសត្រូវក្នុងការប្រគល់កិច្ចការទាំងអស់ឲ្យគ្រូដែលសមស្រប។
- សិស្សណាក៏ដោយដែលចាកចេញពីបន្ទប់ដោយគ្មានការអនុញ្ញាត ឬចាកចេញដោយមានការអនុញ្ញាត ប៉ុន្តែមិនត្រលប់ទៅបន្ទប់ព្យួរការសិក្សាវិញ នឹងត្រូវផ្អាកការសិក្សាដោយស្វ័យប្រវត្តិ ហើយត្រូវត្រលប់ទៅជាមួយឪពុកម្តាយវិញនៅថ្ងៃសិក្សាបន្ទាប់ ដើម្បីជួបជាមួយនាយកសាលា។ សិស្សនឹងបំពេញការពិន័យក្នុងអគារដើមដំបូង។

**នីតិវិធីទាក់ទងនឹងវិន័យសិស្សដែលមានតម្រូវការពិសេស**

គោលការណ៍ជាមូលដ្ឋាននៃផ្នែកនេះគឺថា សិស្សដែលមានតម្រូវការពិសេសមិនត្រូវបានបដិសេធលទ្ធភាពទទួលបានកម្មវិធីអប់រំ និងសេវាកម្មរបស់ពួកគេ ដោយសារតែការផ្អាកការសិក្សាសម្រាប់ឥរិយាបថដែលទាក់ទងដោយផ្ទាល់ទៅនឹងតម្រូវការពិសេស ឬពិការភាពរបស់ពួកគេ ឬលទ្ធផលនៃកម្មវិធីអប់រំពិសេសដែលមិនសមរម្យឡើយ។

សិស្សម្នាក់ត្រូវបានចាត់ទុកថាជាសិស្សដែលមានតម្រូវការពិសេស ប្រសិនបើមានចំណុចណាមួយក្នុងចំណោមចំណុចដូចខាងក្រោម៖

- សិស្សកំពុងទទួលបានសេវាកម្មតាមរយៈផែនការអប់រំបុគ្គល
- មណ្ឌលសិក្សាធិការកំពុងធ្វើការវាយតម្លៃដំបូងនាពេលបច្ចុប្បន្ន
- បច្ចុប្បន្នសិស្សមានសិទ្ធិទទួលបានការសម្របសម្រួលនៅក្រោមផែនការផ្នែកទី 504
- មាតាបិតារបស់សិស្សបានលើកឡើងពីការព្រួយបារម្ភថាសិស្សមានពិការភាព និង/ឬមានត្រូវការពិសេស
- តម្រូវការជាលាយលក្ខណ៍អក្សរ និង/ឬបានស្នើសុំការវាយតម្លៃ ឬប្រសិនបើ
- បុគ្គលិកមណ្ឌលសិក្សាធិកាបានសម្តែងការព្រួយបារម្ភថា សិស្សអាចមានពិការភាព និងសេវាដែលចាំបាច់មុនពេលមានចំណាត់ការវិន័យ។

ប្រសិនបើមុនពេលមានចំណាត់ការវិន័យ មណ្ឌលសិក្សាធិការដឹងថា សិស្សអាចជាសិស្សពិការ មិនថាដឹងពីបុគ្គលិក ឬមាតាបិតានោះទេ មណ្ឌលសិក្សាធិការត្រូវតែបង្កើតការការពារទាំងអស់សម្រាប់សិស្សរហូតដល់ និងលើកលែងតែសិស្សនោះ ពេលក្រោយមកទៀតត្រូវបានកំណត់ថាមិនមានសិទ្ធិ។ ក្នុងករណីទាំងនេះ ដែលសិទ្ធិទទួលបានមិនទាន់ត្រូវបានកំណត់ មណ្ឌលសិក្សាធិការត្រូវធ្វើការបញ្ជូនសិស្សទៅទទួលការវាយតម្លៃការអប់រំពិសេសភ្លាមៗ។

ការផ្អាកការសិក្សារបស់សិស្សដែលមានតម្រូវការពិសេសបែបនេះ

ត្រូវបានកំណត់ថាជាសកម្មភាពណាមួយដែលនាំឱ្យមានការដកសិស្សនេះចេញពីកម្មវិធីអប់រំរបស់ពួកគេ រួមទាំងការបណ្តេញចេញលែងឱ្យប្រើមធ្យោបាយដឹកជញ្ជូនដែលបានកំណត់ និងពេលវេលានៅក្នុងកម្មវិធីព្យួរការសិក្សានៅក្នុងអគារ។ ផែនការអប់រំបុគ្គលអាចកំណត់ថាតើសិស្សអាចអនុលោមតាមក្រមវិន័យរបស់សាលាបានឬអត់។

**ចរិយាពេលជិះឡានក្រុង**

សិស្សទាំងអស់ដែលជិះឡានក្រុងត្រូវបានរំពឹងថានឹងឡើងឡានក្រុងនៅចុងថ្ងៃសិក្សា លុះត្រាតែមានការដោះសារដោយមានលិខិតរបស់មាតាបិតា ហើយត្រូវបានរំពឹងថានឹងគោរពតាមវិន័យដែលបានកំណត់ខាងលើ។ សិស្សដែលបដិសេធមិនគោរពតាមការណែនាំរបស់អ្នកបើកបររថយន្តក្រុងភ្លាមៗ ឬអ្នកដែលមិនព្រមគោរពតាមបទបញ្ញត្តិ ក្នុងចំណោមសកម្មភាពវិន័យផ្សេងទៀត អាចបាត់បង់សិទ្ធិជិះរថយន្តក្រុង។

សិស្សត្រូវគោរពវិន័យរបស់រថយន្តក្រុងទាំងអស់រួមមាន៖

- មកទាន់ពេលនៅចំណតឡានក្រុងដែលបានកំណត់។
- ប្រព្រឹត្តិទង្វើប្រកបដោយសុវត្ថិភាពពេលកំពុងរង់ចាំ។
- ធ្វើដំណើរឆ្ពោះទៅកាន់ឡានក្រុងលុះត្រាតែឡានក្រុងបានចតទាំងស្រុង។
- ឡើងឡានក្រុងតាមរបៀបដែលគោរពអ្នកជិះផ្សេងទៀត។

ច្បាប់របស់ឡានក្រុងពេលជិះឡានក្រុងសាលា៖

- សិស្សត្រូវដាក់ដៃ ជើង និងក្បាលរបស់ខ្លួននៅខាងក្នុងឡានក្រុង។
- សិស្សត្រូវតែជួយថែរក្សារថយន្តក្រុងឱ្យមានសុវត្ថិភាព និងអនាម័យ។

- សិស្សត្រូវតែទុកដាក់ឧបករណ៍ឡានក្រុងឱ្យបានល្អ។
- សិស្សត្រូវទុកសៀវភៅ កញ្ចប់ អាវធំ និងវត្ថុផ្សេងទៀតទាំងអស់ចេញពីច្រកដើរ។
- សិស្សត្រូវតែមានសុជីវធម៌ចំពោះសិស្សដទៃទៀត និងចំពោះអ្នកបើកបរឡានក្រុង។
- សិស្សត្រូវតែជួយមើលថែរក្សាសុវត្ថិភាព និងផាសុកភាពរបស់កុមារតូចៗ។
- សិស្សត្រូវតែបន្តនៅលើឡានក្រុង លុះត្រាតែអ្នកបើកបររថយន្តក្រុងបានស្នើសុំឱ្យចាកចេញក្នុងករណីមានអាសន្នតាមផ្លូវ។ សិស្សត្រូវតែស្ងប់ស្ងាត់ពេលទៅដល់ចំណតឆ្លងកាត់ផ្លូវដែក។
- សិស្សត្រូវអង្គុយកន្លែងដែលគេប្រាប់ឱ្យអង្គុយ។
- សិស្សត្រូវតែមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរឱ្យចេញពីឡានក្រុងក្រៅពីនៅផ្ទះ ឬនៅសាលា។
- សិស្សមិនត្រូវស្រែក ឬបង្កការភាន់ច្រឡំដែលមិនចាំបាច់ឡើយ។
- សិស្សមិនត្រូវបើក និងបិទបង្អួចឡានក្រុងឡើយ។
- សិស្សមិនត្រូវរុករើឡានក្រុង ឬបរិក្ខារណាមួយរបស់ឡានក្រុងឡើយ។ (ការរុករើបរិក្ខារនឹងត្រូវបង់សងប្រាក់ដោយអ្នកល្មើស។)
- សិស្សមិនត្រូវទុកសៀវភៅ អាហារថ្ងៃត្រង់ ឬសម្ភារផ្សេងទៀតនៅលើក្រុងឡើយ។
- សិស្សមិនត្រូវចាកចេញ ឬប្តូរកៅអីឡើយ ខណៈពេលដែលរថយន្តក្រុងកំពុងបើក។
- សិស្សមិនត្រូវបោះអ្វីចេញពីបង្អួចឡានក្រុងឡើយ។
- សិស្សមិនត្រូវប្រឡែងគ្នាលេងរញ៉េរញ៉ៃឡើយ។
- សិស្សមិនត្រូវប្រើភាសាមិនសមរម្យឡើយ។
- សិស្សមិនត្រូវជក់បារីឡើយ។

# **វត្តមាន**

គណៈកម្មាធិការសាលា អ្នកគ្រប់គ្រងសាលា និងគ្រូចាត់ទុកវត្តមានទៀងទាត់ជាការចាំបាច់សម្រាប់ភាពជោគជ័យនៅក្នុងសាលា។ សិស្សគ្រប់រូបត្រូវចូលរៀនឱ្យបានទៀងទាត់ និងទាន់ម៉ោង។ ដោយអនុលោមតាមលក្ខខណ្ឌតម្រូវរបស់រដ្ឋ ប្រព័ន្ធសាលារដ្ឋ Lowell ទទួលស្គាល់ថា **អវត្តមានត្រូវបានចាត់ទុកថាមានច្បាប់ ប្រសិនបើវាបណ្ដាលមកពីហេតុផលមួយ ឬច្រើនដែលមានឯកសារលិខិតស្នាមដូចខាងក្រោម៖**

- ការព្យួរការសិក្សា
- ជំងឺ
- ការសម្រាកព្យាបាលនៅមន្ទីរពេទ្យ
- ពិការភាពរបស់កុមារគឺរាំងកុមារមិនឱ្យចូលរៀននៅសាលា ដូចដែលបានកំណត់ដោយគ្រូពេទ្យ
- មរណភាពរបស់សមាជិកគ្រួសារ
- ការបង្ហាញខ្លួននៅតុលាការ
- ថ្ងៃបុណ្យសាសនា/ការប្រារព្ធពិធីសាសនា
- កំណត់ត្រាការចាក់វ៉ាក់សាំងមិនគ្រប់ដូស ឬហួសកាលបរិច្ឆេទ
- លិខិតបញ្ជាក់របស់គ្រូពេទ្យដែលបញ្ជាក់ពីស្ថានភាពសុខភាពដែលរារាំងមិនឱ្យចូលរៀនបាន
- តម្រូវឱ្យធ្វើចត្តាឡីស័ក្ត

**នីតិវិធីនៅពេលសិស្សអវត្តមាន៖**

- មាតាបិតា ឬអាណាព្យាបាលនឹងទូរសព្ទទៅសាលានៅថ្ងៃចូលរៀន នៅថ្ងៃអវត្តមាន ហើយជូនដំណឹងដល់សាលាអំពីអវត្តមានរបស់សិស្ស។
- សិស្សនឹងយកលិខិតពីមាតាបិតា ឬអាណាព្យាបាលដែលបញ្ជាក់ពីហេតុផល និងកាលបរិច្ឆេទនៃការអវត្តមានមិនលើសពីថ្ងៃទីពីរបន្ទាប់ពីអវត្តមាន។
- ប្រសិនបើសិស្សអវត្តមាន សិស្សមានទំនួលខុសត្រូវក្នុងការធ្វើកិច្ចការសង ដោយសារតែអវត្តមានក្នុងអំឡុងពេលដែលបានបង្ហាញនៅក្នុងផែនការសេវាកម្មអប់រំទូទាំងសាលា។ ប្រសិនបើកិច្ចការសាលាមិនបានធ្វើសងទេ សិស្សអាចបាត់បង់ពិន្ទុសម្រាប់កិច្ចការដែលមិនទាន់បានបញ្ចប់។

- គ្រូត្រូវតែផ្តល់កិច្ចការធ្វើសងស្របតាមផែនការសេវាកម្មអប់រំទូទាំងសាលា។ ស្ថានភាពសម្រាលទោសដែលអាចធ្វើឱ្យមានការលំបាកក្នុងការបញ្ចប់កិច្ចការក្នុងរយៈពេលដែលបានកំណត់ក្នុងផែនការ ដូចជាការសម្រាកព្យាបាលនៅមន្ទីរពេទ្យ គួរតែពិភាក្សាជាមួយនាយកសាលា។
- អវត្តមាននឹងត្រូវបានចាត់ទុកថាគ្មានច្បាប់ ប្រសិនបើជំហានខាងលើមិនត្រូវបានអនុវត្ត។
- ប្រសិនបើសិស្សអវត្តមានច្រើនដងពេក ឬមានទម្លាប់អវត្តមានច្រើនដងក្នុងរយៈពេលយូរ នាយកសាលា ឬអ្នកទទួលសិទ្ធិត្រូវបានអនុញ្ញាតឱ្យស្នើសុំឯកសារបន្ថែម រួមទាំងលិខិតរបស់គ្រូពេទ្យផងដែរ។

**ការរៀនពីចម្ងាយ**

នៅពេលសិស្សចូលរួមក្នុងការរៀនពីចម្ងាយ វត្តមាននេះនឹងត្រូវបានកំណត់ដោយការចូលរួមរបស់សិស្សរៀនមេរៀនតាមអនឡាញ មេរៀនផ្ទាល់ និងការបញ្ចប់កិច្ចការ។ សិស្សត្រូវបានរំពឹងថានឹងមានវត្តមានទៀងទាត់ក្នុងអំឡុងពេលសិក្សាពីចម្ងាយស្របតាមការរំពឹងទុកដែលកំណត់ដោយសាលា/មណ្ឌលសិក្សាធិការ។ ប្រសិនបើគ្រួសារកំពុងជួបប្រទះបញ្ហាប្រឈមដោយសារបច្ចេកវិទ្យា ឬកាលវិភាគ ពួកគេគួរតែទាក់ទងទៅសាលារបស់ពួកគេ (អ្នកគ្រប់គ្រង និងគ្រូ)។

**សូមប្រឹងប្រែងឲ្យអស់ពីសមត្ថភាពក្នុងការរៀបចំកាលវិភាគដែលពាក់ព័ន្ធនឹងកូនរបស់អ្នកមុន ឬក្រោយម៉ោងសិក្សា។**

**កាតព្វកិច្ចរបស់សាលាពេលសិស្សអវត្តមាន៖**

យោងតាមជំពូកទី 222 ច្បាប់ឆ្នាំ 2012 ច្បាប់ទាក់ទងនឹងការចូលរៀនរបស់សិស្សទៅសេវាអប់រំ និងការមិនដាក់បញ្ចូលក្នុងសាលារៀន សាលារដ្ឋ Lowell បានបង្កើតផែនការអន្តរាគមន៍វត្តមានរបស់សាលារដ្ឋ Lowell។ តាមផែនការ អ្នកគួរតែរំពឹងនូវអ្វីដូចខាងក្រោម៖

- ការហៅទូរសព្ទដោយស្វ័យប្រវត្តិបន្ទាប់ពីរាល់អវត្តមាន
- នៅថ្ងៃ ឬមុនអវត្តមានលើកទី 3 ក្នុងត្រីមាសនីមួយៗ កិច្ចប្រជុំតាមប្រព័ន្ធទូរសព្ទ ឬការប្រជុំនឹងត្រូវកំណត់ពេលជាមួយមាតាបិតា ដើម្បីបង្កើតកិច្ចព្រមព្រៀងស្តីពីវត្តមាន

- នៅថ្ងៃ ឬបន្ទាប់ពីអវត្តមានលើកទី 4 ក្នុងត្រីមាសនីមួយៗ លិខិតព្រមានអំពីវត្តមាននឹងផ្ញើទៅមាតាបិតាតាមរយៈអ៊ីមែល ឬសេវាបញ្ញើសំបុត្រសហរដ្ឋអាមេរិក ដើម្បីជូនដំណឹងដល់ពួកគេអំពីសារៈសំខាន់ និងផលប៉ះពាល់លើនិទ្ទេសរបស់កូនពួកគេ

- ជារៀងរាល់ត្រីមាស មាតាបិតានឹងត្រូវបានជូនដំណឹងអំពីអវត្តមានរបស់កូនពួកគេនៅលើកាតរបាយការណ៍របស់ពួកគេ
- នៅថ្ងៃ ឬមុនអវត្តមានលើកទី 5 មាតាបិតាអាចរំពឹងថានឹងទទួលបានការចុះមកដល់ផ្ទះពីសមាជិកក្រុមការងារផ្នែកវត្តមានម្នាក់ ឬពីរនាក់នៃសាលារបស់កូនអ្នក និង/ឬមានការអញ្ជើញឱ្យចូលរួមកិច្ចប្រជុំដែលធ្វើឡើងនៅសាលា
- នៅថ្ងៃ ឬមុនការអវត្តមានលើកទី 6 អ្នកអាចត្រូវបានបញ្ជូនទៅកិច្ចប្រជុំអន្តរាគមន៍វត្តមាន និង
- យោងតាមច្បាប់ នៅថ្ងៃ ឬប្រហែលអវត្តមានលើកទី 9 សាលាអាចដាក់ពាក្យ កុមារដែលត្រូវការជំនួយ (CRA) និង/ឬការខកខានក្នុងការអនុវត្តតាមលក្ខខណ្ឌវត្តមានរបស់សាលាទៅកាន់តុលាការអនីតិជន Middlesex។

សូមជ្រាបថា នាយកដ្ឋានបឋមសិក្សា និងមធ្យមសិក្សាតម្រូវឱ្យគ្រប់ប្រព័ន្ធសាលារៀនទាំងអស់មានពេល 180 ថ្ងៃសិក្សាក្នុងមួយឆ្នាំសិក្សា។ ប្រតិទិនផ្លូវការរបស់សាលានៅខាងដើមនៃសៀវភៅណែនាំនេះអាចមានប្រាំ (5) ថ្ងៃនៃថ្ងៃធ្លាក់ទឹកកកដែលរាប់បញ្ចូលនៅក្នុងប្រតិទិន។ ប្រសិនបើប្រព័ន្ធសាលារៀនមានការបិទសាលាលើសពីប្រាំដងដែលមិនបានគ្រោងទុក នោះថ្ងៃបន្ថែមនឹងត្រូវបានបន្ថែមទៅចុងឆ្នាំសិក្សា ដើម្បីឱ្យប្រព័ន្ធសាលារៀនអនុលោមតាមលក្ខខណ្ឌតម្រូវ 180 ថ្ងៃ។

ថ្ងៃបន្ថែមទាំងនេះរាប់ជាថ្ងៃសិក្សាធម្មតា។ សិស្សត្រូវបានតម្រូវឱ្យមានវត្តមានក្នុងថ្ងៃនេះ ហើយគ្មានការលើកលែងណាមួយនឹងត្រូវបានផ្តល់ឱ្យសម្រាប់សិស្សដែលមានគម្រោងធ្វើដំណើរនៅរដូវក្តៅឡើយ។

## ការបង្រៀននៅផ្ទះ ឬមន្ទីរពេទ្យ

សិស្សសាលារដ្ឋ Lowell ដែលដោយសារហេតុផលវេជ្ជសាស្ត្រដែលបានកត់ត្រាទុក ត្រូវបានកំណត់ឱ្យនៅក្នុងផ្ទះ ឬនៅក្នុងមន្ទីរពេទ្យរយៈពេលដប់បួន (14) ថ្ងៃសិក្សា ឬច្រើនជាងនេះក្នុងឆ្នាំសិក្សា មានសិទ្ធិទទួលបានសេវាអប់រំនៅផ្ទះ/មន្ទីរពេទ្យ ដូចដែលបានពិពណ៌នានៅក្រោម 603 CMR 28.03(3)(c)។ សិស្សដែលមានជំងឺរ៉ាំរ៉ៃដែលមានការស្នាក់នៅផ្ទះ/មន្ទីរពេទ្យដដែលៗតិចជាង 14 ថ្ងៃសិក្សាជាប់ៗគ្នា នៅពេលដែលការកើតឡើងវិញបែបនេះបានបូកបញ្ចូលគ្នា ឬត្រូវបានគេរំពឹងថានឹងបូកបញ្ចូលគ្នាលើសពី 14 ថ្ងៃសិក្សាក្នុងឆ្នាំសិក្សា ក៏មានសិទ្ធិទទួលបានការថែទាំនៅផ្ទះ ឬ...

សេវាអប់រំនៅមន្ទីរពេទ្យ ប្រសិនបើពួកគេត្រូវបានស្នើសុំ ហើយតម្រូវការវេជ្ជសាស្ត្រត្រូវបានកត់ត្រាដោយគ្រូពេទ្យ។ នៅក្នុងបរិបទនេះ "សិស្សសាលារដ្ឋ Lowell" មានន័យថា សិស្សដែលបានចុះឈ្មោះចូលរៀននៅសាលារដ្ឋ Lowell ឬសិស្សដែលកំពុងត្រូវបានអប់រំដោយមូលនិធិសាធារណៈនៅក្នុងសាលាអប់រំពិសេសសម្រាប់ថ្ងៃ ឬសម្រាប់ស្នាក់នៅដែលសហការអប់រំ ឬសាលាឯកជនដែលត្រូវបានអនុម័ត។ 603 CMR 28.03(3)(c)

នៅពេលដែលគ្រូពេទ្យផ្ទាល់ខ្លួនរបស់សិស្សកំណត់ថាស្ថានភាពសុខភាពរបស់សិស្សនឹងត្រូវការសម្រាកព្យាបាលនៅមន្ទីរពេទ្យ ឬការថែទាំនៅផ្ទះយ៉ាងហោចណាស់ 14 ថ្ងៃសិក្សា គ្រូពេទ្យត្រូវតែជូនដំណឹងដល់ស្រុកសាលាដែលទទួលខុសត្រូវចំពោះសិស្ស ដើម្បីចាប់ផ្តើមដំណើរការបង្រៀននៅផ្ទះ/មន្ទីរពេទ្យ។ គ្រូពេទ្យរបស់សិស្សត្រូវតែបំពេញទម្រង់បែបបទ 28R/3 (ការបញ្ជាក់របស់គ្រូពេទ្យ) របស់នាយកដ្ឋានអប់រំបឋមសិក្សា និងមធ្យមសិក្សា ហើយដាក់ជូននាយកអគាររបស់សិស្ស ឬអ្នកគ្រប់គ្រងកម្មវិធីសមស្របផ្សេងទៀត។ យ៉ាងហោចណាស់ ការបញ្ជាក់ដែលចុះហត្ថលេខារបស់គ្រូពេទ្យត្រូវតែរួមបញ្ចូលព័ត៌មានទាក់ទងនឹង៖

- កាលបរិច្ឆេទដែលសិស្សត្រូវបានបញ្ជូនទៅមន្ទីរពេទ្យ ឬត្រូវបានឃុំខ្លួននៅផ្ទះ។

- មូលហេតុផ្នែកវេជ្ជសាស្ត្រសម្រាប់ការឃុំឃាំងនេះ;

· រយៈពេលដែលរំពឹងទុកនៃការឃុំឃាំង និង

· តម្រូវការផ្នែកវេជ្ជសាស្ត្ររបស់សិស្សដែលគួរត្រូវពិចារណាក្នុងការរៀបចំផែនការសេវាអប់រំនៅផ្ទះ ឬមន្ទីរពេទ្យ

ទម្រង់បែបបទបញ្ជាក់ការចូលរៀនរបស់គ្រូពេទ្យដែលបានបំពេញរួច គួរតែដាក់ជូននាយកសាលានៅកម្រិតបឋមសិក្សា ឬអ្នកប្រឹក្សាណែនាំរបស់សិស្សរបស់អ្នកនៅកម្រិតមធ្យមសិក្សា និងវិទ្យាល័យ។ ទម្រង់បែបបទនេះអាចរកបាននៅការិយាល័យសេវាកម្មគាំទ្រសិស្ស ការិយាល័យនៅផ្ទះ និងតាមអ៊ីនធឺណិតនៅ lowell.k12.ma.us។ សូមមើលតំណភ្ជាប់ខាងក្រោមសម្រាប់ទម្រង់បែបបទបញ្ជាក់ការចូលរៀនរបស់គ្រូពេទ្យ DESE និងការណែនាំអំពីសំណួរ និងចម្លើយលម្អិតទាក់ទងនឹងការណែនាំនៅផ្ទះ/មន្ទីរពេទ្យ។ បទប្បញ្ញត្តិរបស់រដ្ឋ Massachusetts ដែលតម្រូវឱ្យមានសេវាអប់រំនៅផ្ទះ ឬមន្ទីរពេទ្យគឺ 603 CMR 28.03(3)(c)។ ការណែនាំអំពីសំណួរ និងចម្លើយរបស់ DESE សម្រាប់ការបង្រៀននៅផ្ទះ/មន្ទីរពេទ្យ។

**<u>វិស្សមកាលជាលក្ខណៈគ្រួសារមិនត្រូវបានចាត់ទុកថាជាអវត្តមានដោយមានច្បាប់ឡើយ</u>។**

វាជាគោលនយោបាយនៃប្រព័ន្ធសាលារដ្ឋ Lowell ដែលសិស្សដែលមានអវត្តមាន 15 ថ្ងៃជាប់ៗគ្នានឹងត្រូវចាត់ទុកថាមិនមែនជាសមាជិក ហើយត្រូវដកចេញពីបញ្ជីឈ្មោះរបស់សាលា។

សិស្សដែលមានអាយុក្រោម 16 ឆ្នាំត្រូវតែត្រលប់ទៅសាលារដ្ឋ Lowell ឬទៅសាលាផ្សេងទៀតវិញនៅក្នុងសហគមន៍លំនៅដ្ឋានថ្មី។ សិស្សទាំងឡាយដែលត្រលប់ទៅសាលារដ្ឋ Lowell វិញនៅថ្នាក់មត្តេយ្យដល់ថ្នាក់ទី 8 ត្រូវតែចុះឈ្មោះនៅមជ្ឈមណ្ឌលធនធានគ្រួសារ (FRC) ដើម្បីចូលរៀនវិញ។ សិស្សទាំងអស់នោះនឹងត្រូវស្ថិតនៅក្រោមគោលនយោបាយ និងនីតិវិធីដែលមានស្រាប់ ដែលអនុវត្តចំពោះសិស្សថ្មីដែលចូលរៀននៅសាលារដ្ឋ Lowell។

**ការមករៀនយឺត**

ការមករៀនយឺតគឺជាឧបសគ្គដល់ដំណើរការអប់រំ និងជាអ្វីមួយដែលត្រូវចៀសវាងដើម្បីភាពជោគជ័យនាពេលអនាគតនៅក្នុងកម្លាំងការងារ។ *សូមប្រឹងប្រែងឲ្យអស់ពីសមត្ថភាពក្នុងការកំណត់ពេលណាត់ជួបសម្រាប់សិស្សមុន ឬក្រោយម៉ោងសិក្សា។*

សិស្សដែលមករៀនយឺតត្រូវតែចូលមកចុះឈ្មោះនៅការិយាល័យកណ្ដាល នៅពេលចូលសាលា ហើយប្រាប់ពីហេតុផលនៃការមកយឺត ដែលនឹងត្រូវកត់ត្រាឯកសារនៅក្នុងការិយាល័យសាលា។ សម្រាប់**ការមកយឺតលើសពីប្រាំ (5) ថ្ងៃក្នុងរយៈពេលដាក់ពិន្ទុ** មន្ត្រីសាលាត្រូវបានអនុញ្ញាតឱ្យទាក់ទងទៅមាតាបិតា។ ការទម្លាប់មករៀនយឺតអាចបណ្ដាលឱ្យមានចំណាត់ការដាក់វិន័យ។

**ការគេចសាលា និងការគេចមិនចូលថ្នាក់រៀន**

សិស្សណាក៏ដោយដែលគេចមិនចូលរៀននៅក្នុងថ្នាក់ និង/ឬអវត្តមានពីសាលាដោយគ្មានច្បាប់ (ដោយមាន ឬគ្មានការយល់ព្រមពីមាតាបិតា) ត្រូវបានចាត់ទុកថាជាសិស្សគេចសាលា។ មុនពេលដែលសិស្សគេចសាលានឹងត្រូវបានអនុញ្ញាតឱ្យចូលថ្នាក់រៀន សិស្សដែលអមដំណើរដោយឪពុកម្ដាយ ឬអាណាព្យាបាលរបស់គាត់ត្រូវតែមានកិច្ចប្រជុំជាមួយនាយកសាលា ឬអ្នកទទួលសិទ្ធិ។ ផែនការដោះស្រាយកិច្ចការដែលមិនបានធ្វើ និងពេលវេលានឹងត្រូវបានបង្កើតឡើងដោយសាលាជាមួយនឹងកិច្ចការដែលមិនបានធ្វើនឹងត្រូវធ្វើសងក្នុងរយៈពេល 3 ថ្ងៃ ដើម្បីទទួលបានពិន្ទុ។

សិស្សគេចសាលាអាចនឹងត្រូវឃាត់ខ្លួន និង/ឬអាចបញ្ជូនទៅកាន់ការិយាល័យវត្តមាន ដើម្បីធ្វើអន្តរាគមន៍។ សូមចំណាំថា ទាក់ទងនឹងសិស្សដែលមានអាយុចាប់ពី 16 ឆ្នាំចុះក្រោម ច្បាប់ទូទៅនៃរដ្ឋ Massachusetts ជំពូកទី 76 ផ្នែកទី 2 ស្ដីពីការខកខានក្នុងការបង្ខំឱ្យចូលសាលាចែងថា "មនុស្សគ្រប់រូបដែលគ្រប់គ្រងលើកុមារត្រូវបង្ខំឱ្យគាត់ចូលរៀនតាមច្បាប់តម្រូវ ហើយប្រសិនបើគាត់មិនអាចធ្វើដូច្នេះបានក្នុងប្រាំពីរ (7) ថ្ងៃ ឬដប់បួន (14) ថ្ងៃកន្លះ នៅក្នុងរយៈពេលណាមួយនៃប្រាំមួយខែ" អាចប្រឈមមុខនឹងការកាត់ទោសដោយការិយាល័យមេធាវីមណ្ឌលនៅក្នុងករណីគេចសាលាជាប់ដែលអាចបណ្ដាលឱ្យមានការផាកពិន័យ។ លើសពីនេះ សាលារដ្ឋ Lowell អាចស្វែងរកពាក្យបណ្ដឹងពីបទគេចសាលា CRA (កុមារដែលត្រូវការជំនួយ) តាមរយៈប្រព័ន្ធតុលាការសម្រាប់កុមារអាយុក្រោមដប់ប្រាំមួយឆ្នាំ ដែលខកខានមិនបានចូលសាលាលើសពីប្រាំបី (8) ថ្ងៃក្នុងមួយត្រីមាសដោយគ្មានច្បាប់ត្រឹមត្រូវ។

មន្ត្រីផ្នែកវត្តមាននឹងធ្វើការចុះសួរដល់ផ្ទះ និងសាលារៀនទាក់ទងនឹងអវត្តមានច្រើនហួសហេតុ ការមករៀនយឺត និងការគេចសាលាច្រើនដងហួសហេតុ ហើយនឹងធ្វើការស៊ើបអង្កេត

និងផ្តល់អនុសាសន៍ក្នុងគ្រប់ករណីសាលាទាំងអស់នៅក្នុងតុលាការអនីតិជន និងគ្រប់ករណីទាំងអស់នៃជនល្មើស និងសិស្សគេចសាលា។

**ការចេញពីសាលា**

សាលាផ្តល់ពេលវេលាសិក្សាដ៏មានតម្លៃ។ សូមជ្រាបថា ការឲ្យសិស្សចេញពីសាលាប៉ះពាល់ដល់ពេលវេលាសិក្សារបស់សិស្ស និងកុមារដទៃទៀត។ ការទម្លាប់ចេញពីសាលាមុនម៉ោងអាចបណ្តាលឱ្យមានចំណាត់ការដាក់វិន័យ។ មាតាបិតាត្រូវបានជំរុញឱ្យធ្វើការណាត់ជួបចាំបាច់សម្រាប់សិស្សក្រោយម៉ោងសិក្សា ដើម្បីកាត់បន្ថយតម្រូវការចេញពីសាលាជាអប្បរមា។

សិស្សដែលមានបំណងចង់សុំចេញពីសាលាត្រូវយកមកនូវលិខិតដែលចុះហត្ថលេខាដោយមាតាបិតាទៅកាន់ការិយាល័យកណ្តាលនៅព្រឹកថ្ងៃចេញពីសាលាដោយបញ្ជាក់៖

- ឈ្មោះសិស្ស
- ថ្ងៃ/កាលបរិច្ឆេទ/ឆ្នាំនៃការចេញពីសាលា ហេតុផលនៃការចេញពីសាលា
- ឈ្មោះមាតាបិតា/អាណាព្យាបាល
- ហត្ថលេខា
- លេខទូរសព្ទដែលគេអាចទាក់ទងមាតាបិតាបាន ដើម្បីផ្ទៀងផ្ទាត់ការចេញពីសាលា
- ឈ្មោះអ្នកដែលនឹងត្រូវមកយកសិស្សចេញពីសាលា

**សូមចំណាំ៖** គ្មានសិស្សណាម្នាក់នឹងត្រូវបានអនុញ្ញាតឲ្យចេញពីសាលាទេ ប្រសិនសាលាមិនអាចទាក់ទងមាតាបិតាសិស្សបាន។ សមាជិកគ្រួសារដែលចូលមកទទួលសិស្សចេញពីសាលាដោយមាការផ្ទៀងផ្ទាត់ពីមុនត្រូវតែបង្ហាញអត្តសញ្ញាណដែលមានសុពលភាព។

ប្រសិនបើមានភាពអាសន្នកើតឡើង ហើយមិនបានផ្ញើលិខិតមកនោះទេ មាតាបិតា/អាណាព្យាបាលត្រូវមកសាលា ហើយបង្ហាញអត្តសញ្ញាណបណ្ណមានសុពលភាព ដើម្បីអនុញ្ញាតឲ្យសិស្សចេញពីសាលា។ ប្រសិនបើមិនអាចមកសាលាផ្ទាល់បាន សូមផ្ញើទូរសារដែលបានចុះហត្ថលេខាដោយមាតាបិតាដែលផ្តល់ព័ត៌មានចាំបាច់ទាំងអស់អាចត្រូវបានទូរសារទៅការិយាល័យកណ្តាលដោយមានការហៅទូរសព្ទតាមដានបន្តទៅមាតាបិតា/អាណាព្យាបាល។

**គ្មានការឲ្យចេញពីសាលាជាបន្ទាន់នឹងត្រូវបានយល់ព្រមដោយអ្នកទំនាក់ទំនងតាមទូរសព្ទប៉ុណ្ណោះឡើយ។**

**សិស្សមានពិការភាព**

កុមារមិនត្រូវបានសន្មតថាមិនអាចចូលសាលាបានតែម្នាក់ឯងឡើយ ដោយសារតែគាត់មានសិទ្ធិទទួលបានសេវាអប់រំពិសេស ឬការសម្របសម្រួលតាមរយៈផែនការផ្នែកទី 504។ កុមារណាក៏ដោយដែលមានផែនការអប់រំបុគ្គល (I.E.P) ឬផែនការផ្នែកទី 504 ត្រូវបានរំពឹងថានឹងចូលរៀនជាទៀងទាត់ លុះត្រាតែមានលិខិតស្នាមអំពីបញ្ហាសុខភាពនៅលើផែនការដែលរារាំងការចូលរៀន។

# គោលនយោបាយ និងគោលការណ៍ណែនាំទាក់ទងនឹងការឆែកឆេរ និងការរឹបអូស

មាតាបិតា/អាណាព្យាបាល និងសិស្សទាំងអស់ត្រូវតែយល់ថា តុលាការកំពូលនៃសហរដ្ឋអាមេរិកបានសម្រេចថា៖

1. ដីកាមិនត្រូវបានទាមទារទេ
មុនពេលអ្នកគ្រប់គ្រងសាលាធ្វើការឆែកឆេរសិស្សដែលសង្ស័យថាបានបំពានច្បាប់សាលា ឬលក្ខន្តិកៈព្រហ្មទណ្ឌ។
2. មូលហេតុដែលទំនងគឺមិនត្រូវបានទាមទារ មុនពេលសិស្សអាចនឹងត្រូវបានឆែកឆេរ ជាជាងមុននឹងធ្វើការឆែកឆេរ គ្រូត្រូវតែមាន "ហេតុផលសមស្របសម្រាប់ការសង្ស័យថា
ការឆែកឆេរនេះនឹងបង្ហាញភស្តុតាងដែលបញ្ជាក់ថាសិស្សបានបំពាន ឬកំពុងបំពានច្បាប់ ឬច្បាប់សាលា។"
3. ការឆែកឆេរនេះត្រូវតែមានមូលហេតុសមស្រប ក៏ដូចជាការចាប់ផ្តើមធ្វើការឆែកឆេររកផងដែរ៖

ដូចជា៖

- នាយកសាលា ជំនួយការនាយកសាលា ឬអ្នកទទួលសិទ្ធិអាចធ្វើការឆែកឆេរសិស្សនៅក្នុងបរិវេណសាលា ប្រសិនបើគាត់មានមូលហេតុ ឬហេតុផលដែលជឿថាសិស្សកាន់កាប់វត្ថុណាមួយ ដែលការកាន់កាប់នោះបង្កើតជាបទល្មើសព្រហ្មទណ្ឌក្រោមច្បាប់នៃសហធនរដ្ឋ Massachusetts ឬជាការរំលោភលើគោលនយោបាយរបស់សាលា និង/ឬសៀវភៅណែនាំមាតាបិតា/អាណាព្យាបាល និងសិស្ស។ ការឆែកឆេរ នេះនឹងធ្វើឡើងនៅចំពោះមុខភាគីទីបី ដែលសុទ្ធតែជាភេទដូចគ្នាជាមួយនឹងជនសង្ស័យដែលត្រូវបានចោទប្រកាន់ លើកលែងតែក្នុងករណីមានអាសន្នសុខភាព និង/ឬសុវត្ថិភាពដែលពាក់ព័ន្ធនឹងការគំរាមកំហែងចំពោះមុខ និង/ឬគ្រោះថ្នាក់ដែលអាចកើតមាន។ ការឆែកឆេរនេះមិនត្រូវបានកំណត់ត្រឹមតែការការឆែកឆេរបុគ្គលរបស់សិស្សនោះទេ ប៉ុន្តែក៏អាចរួមបញ្ចូលនូវវត្ថុដែលមាន និង/ឬជាកម្មសិទ្ធិរបស់សិស្សផងដែរ រួមមាន ប៉ុន្តែមិនកំណត់ត្រឹមចំពោះទូដាក់សម្ភារដែលបានប្រគល់ឱ្យប្រើ និងទ្រព្យសម្បត្តិ កាបូបស្ពាយ ទ្រព្យសម្បត្តិផ្ទាល់ខ្លួន (កាបូប សៀវភៅកត់ត្រា។ល។)។

- នាយកសាលា ជំនួយការនាយកសាលា ឬអ្នកទទួលសិទ្ធិអាចធ្វើការឆែកឆេររកបរិក្ខាររបស់សាលា និងឧបករណ៍ប្រើប្រាស់ទាំងអស់នោះ រួមទាំងទូដាក់សម្ភារសម្រាប់សិស្សផងដែរ។

- នាយកដ្ឋានសាលា Lowell រក្សាសិទ្ធិក្នុងការនាំយកសត្វឆ្កែដែលបានបង្ហាត់ ដើម្បីហិតរកគ្រឿងញៀន និងរំសេវ និងគ្រឿងផ្ទុះផ្សេងទៀត។

ក្នុងគ្រប់កាលៈទេសៈទាំងអស់នៃការឆែកឆេរ និងការរឹបអូសនៅក្នុងសាលា "ផលប្រយោជន៍របស់សិស្សនឹងត្រូវបានកាត់បន្ថយមិនឱ្យលើសពីកម្រិតចាំបាច់ដើម្បីសម្រេចបាននូវគោលដៅស្របច្បាប់នៃការថែរក្សាសណ្តាប់ធ្នាប់នៅក្នុងសាលារៀន។"

ការឆែកឆេរសិស្ស និងអាចឈានដល់ការរឹបអូសពីបុគ្គលិកសាលានឹងត្រូវបានអនុវត្តឡើង ប្រសិនបើ៖

- មានមូលហេតុសមស្របសម្រាប់ការសង្ស័យថាសិស្សបានរំលោភបំពាន ឬកំពុងបំពានច្បាប់ ឬវិន័យរបស់សាលា និង
- ការឆែកឆេរនេះឯងត្រូវបានធ្វើឡើងក្នុងលក្ខណៈសមហេតុផលដែលទាក់ទងទៅនឹងគោលបំណងរបស់ខ្លួន និងមិនមានការជ្រៀតជ្រែកហួសហេតុពេកដោយគិតពីអាយុ និងភេទរបស់សិស្ស និងលក្ខណៈនៃការបំពាន។

មូលហេតុសមស្របសម្រាប់ការឆែកឆេរសិស្សអាចរួមមាន៖

- ការសង្កេតផ្ទាល់ខ្លួនរបស់បុគ្គលិកសាលា
- ការទទួលរបាយការណ៍ដោយមន្ត្រីសាលាពីគ្រូ បុគ្គលិកសាលា សិស្ស ឬប្រភពដែលអាចទុកចិត្តបានមួយចំនួនផ្សេងទៀត ឬ
- ការទទួលរបាយការណ៍ពីប្រភពអនាមិក ប្រសិនបើកាលៈទេសៈធ្វើឲ្យមន្ត្រីសាលាជឿ ឬប្រសិនបើមានព័ត៌មានឯករាជ្យបញ្ជាក់ពីវា។

ដូចដែលបានបញ្ជាក់ខាងលើ នៅពេលដែលអាចធ្វើទៅបាន ការឆែកឆេរគួរតែធ្វើឡើងក្រោមការដឹកនាំរបស់អ្នកគ្រប់គ្រងសាលា ឬបុគ្គលិកសន្តិសុខដែលមានបុគ្គលិកសាលាផ្សេងទៀតយ៉ាងហោចណាស់ម្នាក់ធ្វើជាសាក្សី ហើយនៅពេលណាដែលអាចធ្វើទៅបាន កិច្ចខិតខំប្រឹងប្រែងសមស្របត្រូវតែធ្វើឡើងដើម្បីជូនដំណឹងដល់មាតាបិតា/អាណាព្យាបាលរបស់សិស្សអំពីបំណងឆែកឆេរមុនពេលចាត់វិធានការនោះ។ ការស្វែងរកគួរតែធ្វើឡើងដោយប្រុងប្រយ័ត្នតាមដែលអាចធ្វើទៅបាន ធ្វើឱ្យប្រាកដថាចៀសវាងការឆែកឆេរដែលរំខានខ្លាំង ការឆែកឆេរព្រាវៗ

ឬការឆែកឆេរដែលពាក់ព័ន្ធនឹងការលក់ដុំនូវទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់សិស្ស។

ប្រសិនបើតាមការវិនិច្ឆ័យរបស់រដ្ឋបាលសាលា ស្ថានភាពដែលកើតឡើងពីការឆែកឆេរសិស្ស និងដីការឹបអូសនោះ សាលានឹងជូនដំណឹងដល់អាជ្ញាធរអនុវត្តច្បាប់សមស្រប។ ក្នុងករណីបែបនេះ សិស្ស និងមាតាបិតារបស់សិស្សនឹងទទួលបានការជូនដំណឹង។ សម្ភារទាំងអស់ដែលរឹបអូសបាននឹងត្រូវបិទសៀល ចុះកាលបរិច្ឆេទ និងចុះហត្ថលេខា ហើយរក្សាទុកនៅកន្លែងដែលមានសុវត្ថិភាពដោយអាជ្ញាធរសាលា។ សម្ភារណាមួយត្រូវប្រគល់ឲ្យប៉ូលិសនឹងត្រូវធ្វើដូច្នេះដោយអនុលោមតាមការការពារសុវត្ថិភាពសិស្សតាមផ្លូវច្បាប់។

## ការរំខានដល់ការជួបជុំគ្នានៅសាលា

ស្របតាមច្បាប់រដ្ឋ Massachusetts អ្នកណាដែលរំខាន ឬរំខានដល់សាលារៀន ឬការជួបជុំផ្សេងទៀតដោយចេតនា នឹងត្រូវទទួលរងនូវវិធានការវិន័យ ដូចជា ការព្យួរ បណ្តេញចេញ ការផ្ទេរ ការសាកល្បង ដកហូតសិទ្ធិ ឬការចាប់ខ្លួន។ ក្នុងករណីមានការចាប់ខ្លួន មិនចាំបាច់បង្ហាញថាចុងចោទមានបំណងជាក់លាក់ណាមួយដើម្បីរំខានដល់ដំណើរការរបស់សាលារៀននោះទេ។ តម្រូវការចេតនានៃច្បាប់ទូទៅរដ្ឋ Massachusetts ជំពូក 272 មាត្រា 40 ទាមទារតែទង្វើរបស់ចុងចោទដែលត្រូវធ្វើដោយចេតនា។ ដរាបណាទង្វើទាំងនោះមានចេតនា មិនមែនដោយសារគ្រោះថ្នាក់ ឬអចេតនាទេ តម្រូវការសម្រាប់ការចាប់ខ្លួនត្រូវបានបំពេញ (Commonwealth vs. Bohmer, 374 Mass. 368, 377; 372 NE 2nd 1381, 1978)

### នីតិវិធីផ្លូវច្បាប់ និងសិទ្ធិប្តឹងឧទ្ធរណ៍

សិស្សទាំងអស់ត្រូវតែទទួលបាននីតិវិធីផ្លូវច្បាប់ នៅពេលណាដែលមានការដកហូតសិទ្ធិទទួលបានការអប់រំរបស់ពួកគេ តាមរយៈការដកចេញពីការរៀនសូត្រក្នុងថ្នាក់ធម្មតារបស់ពួកគេ ឬពីសកម្មភាពសាលាផ្សេងទៀត រួមមាន៖ ការព្យួរការសិក្សារយៈពេលវែង ការបណ្តេញចេញ ការផ្ទេរ ការព្យួរ ឬការដកឯកសិទ្ធិ។ សិទ្ធិទទួលបាននីតិវិធីផ្លូវច្បាប់ រួមមានសិទ្ធិទទួលបានសវនាការដោយយុត្តិធម៌ មុនការបដិសេធណាមួយខាងលើ លើកលែងតែការព្យួរការសិក្សាជាបន្ទាន់ដោយអនុលោមតាមក្រមនេះ។

- **ការបណ្តេញចេញ** គឺជាការកាត់ផ្តាច់សមាជិកភាពរបស់សិស្សចេញពីសាលាទាំងស្រុង។ ការបណ្តេញចេញនឹងជាលទ្ធផលនៃចំណាត់ការដែលធ្វើឡើងដោយនាយកសាលា ដោយផ្អែកលើច្បាប់ទូទៅរបស់រដ្ឋ Massachusetts តាមជំពូកទី 71 ផ្នែក 37H & 37H1/2 ឬដោយគណៈកម្មាធិការសាលាដោយផ្អែកលើច្បាប់ទូទៅរបស់រដ្ឋ Massachusetts តាមជំពូកទី 76 ផ្នែកទី 17។ ការសម្រេចចិត្តទាក់ទងនឹងការបណ្តេញសិស្សចេញគឺធ្វើឡើងដោយគណៈកម្មាធិការសាលា Lowell ដោយប្រើនីតិវិធីបណ្តេញចេញដែលបានកត់សម្គាល់ខាងលើ។
- **ការព្យួរការសិក្សារយៈពេលវែង** គឺជាការដកចេញពីការរៀនសូត្រក្នុងថ្នាក់ធម្មតាសម្រាប់រយៈពេលជាង 10

ថ្ងៃសិក្សា។

- សិស្សទាំងអស់ត្រូវតែទទួលបាន**នីតិវិធីផ្លូវច្បាប់** នៅពេលណាដែលមានលទ្ធភាពនៃការបណ្តេញចេញលើសពី 10 ថ្ងៃ។ សិទ្ធិទទួលបាននីតិវិធីផ្លូវច្បាប់ រួមមានសិទ្ធិទទួលបានសវនាការដោយយុត្តិធម៌មុនការបណ្តេញចេញ ឬការផ្អាកការសិក្សារយៈពេលវែង
លើកលែងតែសម្រាប់ការព្យួរការសិក្សាជាបន្ទាន់ដោយអនុលោមតាមបទប្បញ្ញត្តិទាំងនេះ។

## ការកំហិតសកម្មភាពរាងកាយ

បទប្បញ្ញត្តិរបស់ក្រុមប្រឹក្សាភិបាលអប់រំ (603 CMR 46.00)
ទាក់ទងនឹងការកំហិតសកម្មភាពរាងកាយនៅក្នុងកម្មវិធីអប់រំសាធារណៈគឺសំដៅលើកកម្ពស់សុវត្ថិភាពសម្រាប់សិស្ស និងបុគ្គលិកទាំងអស់នៅក្នុងសាលា។
ការកំហិតសកម្មភាពរាងកាយនឹងត្រូវប្រើតែក្នុងស្ថានភាពអាសន្នជាមធ្យោបាយចុងក្រោយប៉ុណ្ណោះ
បន្ទាប់ពីជម្រើសដែលស្របច្បាប់ផ្សេងទៀត និងមិនសូវមានការរំខានបានបរាជ័យ ឬត្រូវបានចាត់ទុកថាមិនសមរម្យ និងដោយប្រុងប្រយ័ត្នបំផុត។ បទប្បញ្ញត្តិនេះក៏គ្រប់គ្រងការផ្អាក និងការនៅដាច់ពីគេផងដែរ។

# ការបៀតបៀន

ការបៀតបៀនសិស្សដោយសិស្សផ្សេងទៀត និយោជិត អ្នកលក់ និងភាគីទី 3 នឹងមិនត្រូវបានអត់ឱនឱ្យឡើយនៅក្នុងសាលារដ្ឋ Lowell។ ការបៀតបៀនដែលត្រូវបានចោទប្រកាន់ត្រូវតែពាក់ព័ន្ធនឹងទង្វើដែលបានកើតឡើងនៅក្នុងកម្មវិធី ឬសកម្មភាពរបស់សាលា ដូចជាថាតើការបៀតបៀនបានកើតឡើងនៅទីតាំង ឬក្នុងកាលៈទេសៈដែលសាលាកាន់កាប់ ឬគ្រប់គ្រងក្នុងបរិវេណ អនុវត្តការត្រួតពិនិត្យ ត្រួតត្រា ឬដាក់វិន័យលើទីតាំង ឬអ្នកចូលរួម ឬផ្តល់មូលនិធិ ឧបត្ថម្ភ ផ្សព្វផ្សាយ ឬគាំទ្រព្រឹត្តិការណ៍ ដែលការបៀតបៀនដែលបានចោទប្រកាន់បានកើតឡើងប្រឆាំងនឹងបុគ្គលម្នាក់នៅក្នុងសហរដ្ឋអាមេរិកដែរឬទេ។ គោលការណ៍នេះចូលជាធរមាន ខណៈពេលដែលសិស្សស្ថិតនៅលើបរិវេណសាលារៀន ទីតាំងអចលនទ្រព្យរបស់មណ្ឌលសិក្សាធិការ ឬទីតាំងអចលនទ្រព្យនៅក្នុងយុត្តាធិការនៃមណ្ឌលសិក្សាធិការ រថយន្តក្រុងសាលា ឬចូលរួម ឬពាក់ព័ន្ធក្នុងសកម្មភាពដែលឧបត្ថម្ភដោយសាលា។

ការបៀតបៀនដែលហាមឃាត់ដោយមណ្ឌលសិក្សាធិការ រួមមាន ប៉ុន្តែមិនកំណត់ត្រឹមចំពោះការបៀតបៀនដោយផ្អែកលើពូជសាសន៍ ភេទ អត្តសញ្ញាណយេនឌ័រ ជំនឿ ពណ៌សម្បុរ ដើមកំណើតជាតិសាសន៍ ទំនោរផ្លូវភេទ សាសនា ស្ថានភាពអាពាហ៍ពិពាហ៍ ឬពិការភាព។ សិស្សដែលទង្វើរបស់ខ្លួនត្រូវបានគេរកឃើញថាបំពាននឹងគោលនយោបាយនេះនឹងត្រូវទទួលរងការពិន័យរហូតដល់ និងរួមទាំងការផ្អាកការសិក្សា ឬការបណ្តេញចេញដោយអនុលោមតាមក្រមវិន័យ។ និយោជិតដែលត្រូវបានរកឃើញថាបំពានគោលនយោបាយនេះ នឹងត្រូវទទួលវិន័យរហូតដល់ និងរួមទាំងការបញ្ចប់កិច្ចសន្យាការងារ ដែលស្ថិតនៅក្រោមកាតព្វកិច្ចវិន័យតាមកិច្ចសន្យា។

**ការបៀតបៀនរបស់និយោជិតទៅលើសិស្ស** សំដៅលើការប្រព្រឹត្តជាលាយលក្ខណ៍អក្សរ ពាក្យសំដី ឬកាយវិការដើម្បីធ្វើឲ្យអាម៉ាស់ ធ្វើឲ្យទុក្ខព្រួយ ធ្វើឲ្យរំជើបរំជួល រំខាន ឬបង្កបញ្ហាដល់សិស្សនៅពេលៈ

- ការចូលរួមធ្វើទង្វើបែបនេះធ្វើឡើងដោយច្បាស់លាស់ ឬដោយប្រយោលចំពោះលក្ខខណ្ឌនៃការសិក្សារបស់សិស្ស ឬការចូលរួមរបស់សិស្សនៅក្នុងកម្មវិធី ឬសកម្មភាពរបស់សាលា ឬ
- ការចូលរួម ឬការបដិសេធទង្វើបែបនេះដោយសិស្សត្រូវបានប្រើជាមូលដ្ឋានសម្រាប់ការសម្រេចចិត្តដែលប៉ះពាល់ដ

ល់សិស្ស។

**ការបៀតបៀនរបស់សិស្សទៅលើសិស្ស** សំដៅលើការប្រព្រឹត្តទង្វើជាលាយលក្ខណ៍អក្សរ ពាក្យសំដី ឬកាយវិការដើម្បីធ្វើឲ្យអាម៉ាស់ ធ្វើឲ្យទុក្ខព្រួយ ធ្វើឲ្យរំជើបរំជួល រំខាន ឬបង្កបញ្ហាដល់សិស្សនៅពេលៈ

- ទង្វើបែបនេះមានគោលបំណង ឬឥទ្ធិពលក្នុងការជ្រៀតជ្រែកដោយមិនសមស្របក្នុងការសិក្សារបស់សិស្ស ឬបង្កើតបរិយាកាសសិក្សាដែលបំភិតបំភ័យ ឬមានអរិភាព។

ការបៀតបៀន ដូចដែលបានរៀបរាប់ខាងលើអាចរួមមាន ប៉ុន្តែមិនកំណត់ត្រឹមចំពោះ៖

- ការបៀតបៀន ឬការរំលោភបំពានជាលាយលក្ខណ៍អក្សរ ជាវាចា ឬផ្លូវកាយ (រួមទាំងការផ្ញើសារ ការសរសេរប្លក ឬវិធីសាស្ត្របច្ចេកវិទ្យាផ្សេងទៀត)
- ការលើកឡើងម្តងហើយម្តងទៀតនៃលក្ខណៈដែលបង្ខូចកេរ្តិ៍ឈ្មោះ
- ការគំរាមកំហែងដោយបង្កប់ន័យ ឬច្បាស់លាស់ទាក់ទងនឹងនិទ្ទេស លទ្ធផលរបស់សិស្សណាម្នាក់ ឬបញ្ហាសាលាផ្សេងទៀត។
- ការនិយាយលេងសើច រឿងរ៉ាវ ឬសកម្មភាពសំដៅទៅរកសិស្សនោះ។

តាមច្បាប់ អ្វីដែលជាការបៀតបៀនត្រូវបានកំណត់តាមទស្សនៈរបស់បុគ្គលមានវិចារណញ្ញាណ ដោយមានការផ្តោតលើលក្ខណៈនៃការបៀតបៀន។ បុគ្គលម្នាក់ៗគួរពិចារណាពីរបៀបដែលពាក្យសម្តី និងទង្វើរបស់ពួកគេអាចត្រូវបាន អ្នកដទៃមើលឃើញដោយសមហេតុផលថាមានលក្ខណៈបែបណា។

មណ្ឌលសិក្សាធិការនឹងធ្វើការស៊ើបអង្កេតភ្លាមៗ និងដោយសមស្របចំពោះការចោទប្រកាន់អំពីបទបៀតបៀន តាមរយៈការចាត់តាំងអ្នកសម្របសម្រួលចំណងជើង Title IX ឬបុគ្គលិកនៅក្នុងអគារ ដែលអាចរាប់បញ្ចូលទាំងនាយកសាលា ឬអ្នកទទួលសិទ្ធិរបស់ពួកគេ។ ដោយមានការពិគ្រោះយោបល់ជាមួយនាយកសាលា អគ្គនាយកនឹងណែនាំឱកាសការបណ្តុះបណ្តាលសមស្របដល់អ្នកទទួលដែលបានកំណត់ ។

## ការបៀតបៀនផ្លូវភេទ

ការបៀតបៀនផ្លូវភេទគឺជាការប្រព្រឹត្តពាក់ព័ន្ធនឹងផ្លូវភេទដែលមិនសមគួរ។ និយមន័យរួមមាន ទង្វើមិនសមគួរដោយផ្អែកលើភេទដែលមានលក្ខណៈធ្ងន់ធ្ងរ រាលដាល និងប្រមាថមើលងាយជាសត្យានុម័ត ដែលទង្វើនេះគឺជាបដិសេធយ៉ាងមានប្រសិទ្ធភាព ចំពោះលទ្ធភាពដែលបុគ្គលម្នាក់អាចទទួលបានសិទ្ធិស្មើគ្នាក្នុងកម្មវិធីអប់រំ ឬសកម្មភាពរបស់សាលា រួមទាំងការសុំរួមភេទដែលមិនសមគួរ ការស្នើសុំការអនុគ្រោះផ្អែកផ្លូវភេទ និងពាក្យសំដី កាយវិការ ឬទង្វើដែលមានលក្ខណៈផ្លូវភេទផ្សេងទៀត។ ការបៀតបៀនផ្លូវភេទរួមមាន ទង្វើរបស់និយោជិតដែលធ្វើការកំណត់លក្ខខណ្ឌអត្ថប្រយោជន៍ ឬសេវាកម្មអប់រំ ចំពោះការចូលរួមរបស់បុគ្គលម្នាក់នៅក្នុងការប្រព្រឹត្តអំពើផ្លូវភេទដែលមិនសមគួរ ដែលជារឿយៗគេហៅថាការបៀតបៀនក្រោយលក្ខខណ្ឌដោះដូរ និងការរំលោភផ្លូវភេទ ដោយសារច្បាប់ស្តីពីការប៉ះពាល់ផ្នែកឯកជនរបស់សហព័ន្ធកំណត់អំពីបទឧក្រិដ្ឋនោះ។ អំពើហិង្សាផ្លូវភេទគឺជាទម្រង់នៃការបៀតបៀនផ្លូវភេទ។ អំពើហិង្សាផ្លូវភេទដូចដែលការិយាល័យសិទ្ធិស៊ីវិល (OCR) ប្រើពាក្យនេះ ដើម្បីសំដៅលើអំពើផ្លូវភេទលើរាងកាយដែលប្រព្រឹត្តផ្ទុយនឹងឆន្ទៈរបស់បុគ្គលម្នាក់ ឬកន្លែងដែលបុគ្គលនោះមិនអាចផ្តល់ការយល់ព្រម (ឧ. ដោយសារអាយុរបស់សិស្ស ឬការប្រើប្រាស់គ្រឿងញៀន ឬគ្រឿងស្រវឹង ឬដោយសារតែបញ្ញា ឬពិការភាពផ្សេងទៀតរារាំងមិនឱ្យសិស្សមានសមត្ថភាពក្នុងការផ្តល់ការយល់ព្រម)។ ទង្វើផ្សេងៗមួយចំនួនស្ថិតនៅក្នុងប្រភេទនៃអំពើហិង្សាផ្លូវភេទ រួមមាន ការរំលោភសេពសន្ថវៈ ការរំលោភផ្លូវភេទ ការរំលោភបំពានផ្លូវភេទ និងការបង្ខិតបង្ខំផ្លូវភេទ។ ច្បាប់ទូទៅនៃរដ្ឋ Massachusetts ត្រង់ជំពូកទី 119 ផ្នែកទី 51 A តម្រូវឱ្យសាលារដ្ឋរាយការណ៍ករណីនៃការសង្ស័យថាមានការរំលោភបំពានលើកុមារ ដោយផ្ទាល់មាត់ភ្លាមៗ ហើយដាក់របាយការណ៍ក្នុងរយៈពេល 48

ម៉ោងដែលលម្អិតអំពីការរំលោភបំពានដែលសង្ស័យទៅកាន់ក្រសួងទទួលបន្ទុកផ្នែកកុមារ និងគ្រួសារ។ សម្រាប់ប្រភេទនៃអំពើហិង្សាផ្លូវភេទ បន្ថែមពីលើផ្នែក 51A គឺសំដៅលើបទល្មើស និងបញ្ហាធ្ងន់ធ្ងរផ្សេងទៀតដែលនឹងត្រូវបញ្ជូនទៅស្ថាប័នអនុវត្តច្បាប់ក្នុងតំបន់។ សាលាត្រូវតែយកចិត្តទុកដាក់ខ្ពស់ចំពោះរបាយការណ៍ទាំងអស់នៃការបៀតបៀនផ្លូវភេទដែលត្រូវនឹងនិយមន័យនៃការបៀតបៀនផ្លូវភេទ និងលក្ខខណ្ឌនៃការជូនដំណឹង និងយុត្តាធិការជាក់ស្តែងដូចបានកត់សម្គាល់ខាងលើ។ ការធ្វើឲ្យសាលាទទួលខុសត្រូវក្រោមចំណងជើង Title IX អាចកើតឡើងបានលុះត្រាតែសាលាដឹងពីការចោទប្រកាន់អំពីការបៀតបៀនផ្លូវភេទ និងឆ្លើយតបក្នុងរបៀបដែលព្រងើយកន្តើយដោយចេតនា (គ្មានមូលហេតុច្បាស់លាស់នៅក្នុងកាលៈទេសៈដែលគេស្គាល់)។

ទោះបីយើងមិនអាចលើកឡើងនូវកាលៈទេសៈបន្ថែមទាំងអស់ដែលអាចបង្កើតឱ្យមានការបៀតបៀនផ្លូវភេទក៏ដោយ ខាងក្រោមនេះគឺជាឧទាហរណ៍មួយចំនួនស្តីពីទង្វើដែលមិនសមគួរ អាចជាការបៀតបៀនផ្លូវភេទ អាស្រ័យលើស្ថានភាពជារួមម រួមទាំងភាពធ្ងន់ធ្ងរនៃការប្រព្រឹត្ត និងភាពរាលដាលរបស់វា៖

- ការបំពានផ្លូវភេទមិនសមគួរ—ថាតើវាពាក់ព័ន្ធនឹងការប៉ះពាល់រាងកាយឬអត់
- ពាក្យជៀមជាមពាក់ព័ន្ធនឹងផ្លូវភេទ ការលេងសើច ការសរសេរ ឬការនិយាយសំដៅលើទង្វើផ្លូវភេទ ការនិយាយដើមទាក់ទងនឹងជីវិតផ្លូវភេទរបស់មនុស្សម្នាក់ អត្ថាធិប្បាយអំពីរាងកាយរបស់បុគ្គល យោបល់អំពីសកម្មភាពផ្លូវភេទ ចំណុចខ្វះខាត ឬសមត្ថភាពរបស់បុគ្គលម្នាក់
- ការបង្ហាញវត្ថុ រូបភាព រូបគំនូរជីវចលស្រើបស្រាលផ្លូវភេទ
- ការមើលចុងភ្នែកដោយមិនសមគួរ ការខ្សឹបខ្សៀវ ការត្រដុសនឹងរាងកាយ កាយវិការផ្លូវភេទ ការបញ្ចេញមតិស្រើបស្រាលផ្លូវភេទ ឬប្រមាថ
- ការសាកសួរអំពីបទពិសោធន៍ផ្លូវភេទរបស់មនុស្សម្នាក់ និង
- ការពិភាក្សាអំពីសកម្មភាពផ្លូវភេទរបស់មនុស្សម្នាក់។

និយមន័យផ្លូវច្បាប់ស្តីពីការបៀតបៀនផ្លូវភេទគឺមានលក្ខណៈទូលំទូលាយ ហើយបន្ថែមពីលើឧទាហរណ៍ខាងលើ អាកប្បកិរិយាផ្លូវភេទផ្សេងទៀត ថាតើវាមានបំណងឬអត់ ដែលមិនសមគួរ និងមានឥទ្ធិពលនៃការបង្កើតបរិយាកាសអរិភាព ការប្រមាថ ការបំភិតបំភ័យចំពោះសិស្សប្រុស សិស្សស្រី ឬសិស្សភេទទីបីឬនិយោជិតក៏អាចបង្កើតជាការបៀតបៀនផ្លូវភេទផងដែរ។

ដោយសារតែមណ្ឌលសិក្សាធិការយកចិត្តទុកដាក់ខ្ពស់លើការចោទប្រកាន់ពីបទបៀតបៀន រួមទាំងការបៀតបៀនផ្លូវភេទ

យើងនឹងឆ្លើយតបភ្លាមៗចំពោះពាក្យបណ្ដឹងពីបទបៀតបៀន រួមទាំងការបៀតបៀនផ្លូវភេទ ហើយបន្ទាប់ពីការស៊ើបអង្កេតដែលកំណត់ថាទង្វើមិនសមរម្យបែបនេះបានកើតឡើង យើងនឹងចាត់វិធានការភ្លាមៗដើម្បីលុបបំបាត់ទង្វើនេះ ហើយដាក់វិធានការកែតម្រូវតាមការចាំបាច់ រួមទាំងការចាត់វិធានការតាមការសមស្រប។

សូមចំណាំថា
ទោះបីជាគោលនយោបាយនេះកំណត់គោលដៅរបស់យើងក្នុងការលើកកម្ពស់បរិយាកាសដែលគ្មានការបៀតបៀន រួមទាំងការបៀតបៀនផ្លូវភេទក៏ដោយ គោលនយោបាយនេះមិនត្រូវបានរៀបចំឡើង ឬមានបំណងដាក់កម្រិតលើសិទ្ធិអំណាចរបស់យើងក្នុងការដាក់វិន័យ ឬចាត់វិធានការដោះស្រាយចំពោះទង្វើដែលយើងចាត់ទុកថាមិនអាចទទួលយកបានឡើយ ទោះជាទង្វើដែលត្រូវនឹងនិយមន័យស្ដីពីការបៀតបៀន ឬការបៀតបៀនផ្លូវភេទក៏ដោយ។ យើងក៏ហាមឃាត់ការសងសឹកដើមបណ្ដឹងផងដែរ ដោយសារតែពួកគេបានដាក់ពាក្យបណ្ដឹងពីបទបៀតបៀន ឬបទបៀតបៀនផ្លូវភេទ ឬបានជួយ ឬចូលរួមក្នុងការស៊ើបអង្កេត ឬដំណើរការដាក់ពាក្យបណ្ដឹងពីបទបៀតបៀនផ្លូវភេទ។ សិស្ស ឬនិយោជិតដែលត្រូវបានរកឃើញថាបានសងសឹកចំពោះអ្នកផ្សេងទៀតដែលបំពានលើគោលនយោបាយនេះ នឹងត្រូវទទួលរងនូវវិធានការវិន័យរហូតដល់ និងរួមទាំងការព្យួរការសិក្សា និងការបណ្ដេញសិស្សចេញ ឬការបញ្ឈប់បុគ្គលិក។

ដើមបណ្ដឹងមិនត្រូវតែជាជនដែលត្រូវបានគេធ្វើទង្វើផ្លូវភេទដាក់នោះឡើយ។ ដើមបណ្ដឹង មិនថាមានភេទណាក៏ដោយ អាចជាសាក្សី និងធ្វើឲ្យទាស់ចិត្តចំពោះទង្វើបែបនេះ។

សេចក្ដីជូនដំណឹងអំពីការបៀតបៀនផ្លូវភេទ

បទប្បញ្ញត្តិតម្រូវឱ្យមណ្ឌលសិក្សាធិការឆ្លើយតបនៅពេលដែលមណ្ឌលសិក្សាទទួលបានការជូនដំណឹងពិតប្រាកដអំពីការបៀតបៀនផ្លូវភេទ។ មណ្ឌលសិក្សាធិការទទួលបានការជូនដំណឹងពិតប្រាកដ នៅពេលដែលការចោទប្រកាន់ត្រូវបានជូនដំណឹងដល់បុគ្គលិកសាលាណាម្នាក់។ សាលាត្រូវតែយកចិត្តទុកដាក់ខ្ពស់លើរាល់របាយការណ៍អំពីការបៀតបៀនផ្លូវភេទ ដែលត្រូវនឹងនិយមន័យស្ដីពីការបៀតបៀន និងលក្ខខណ្ឌនៃការជូនដំណឹង និងយុត្តាធិការជាក់ស្ដែង ដូចដែលបានកត់សម្គាល់ ថាតើដើមបណ្ដឹងដាក់ពាក្យបណ្ដឹងជាផ្លូវការឬអត់។

ការធ្វើឲ្យសាលាទទួលខុសត្រូវក្រោមចំណងជើង Title IX អាចកើតឡើងបានលុះត្រាតែសាលាដឹងពីការចោទប្រកាន់អំពីការបៀតបៀនផ្លូវភេទ និងឆ្លើយតបក្នុងរបៀបព្រងើយកន្តើយដោយចេតនា (គ្មានមូលហេតុច្បាស់លាស់នៅក្នុងកាលៈទេសៈដែលគេស្គាល់)។ សាលាត្រូវបានតម្រូវឱ្យស៊ើបអង្កេតរាល់ពាក្យបណ្តឹងផ្លូវការ និងឆ្លើយតបយ៉ាងមានន័យចំពោះរាល់របាយការណ៍ដែលបានដឹងអំពីការបៀតបៀនផ្លូវភេទ។

បទប្បញ្ញត្តិបង្ហាញពីសារៈសំខាន់នៃវិធានការគាំទ្រដែលត្រូវបានរៀបចំឡើងដើម្បីការពារ ឬស្តារលទ្ធភាពទទួលបានកម្មវិធីអប់រំ ឬចូលរួមសកម្មភាពរបស់សាលាឡើងវិញ ដោយមាន ឬគ្មានបណ្តឹងជាផ្លូវការ។ នៅពេលដែលរកឃើញការទទួលខុសត្រូវ បទប្បញ្ញត្តិនឹងទាមទារឱ្យមានដំណោះស្រាយដែលត្រូវបានបង្កើតឡើងដើម្បីស្តារ ឬរក្សាសិទ្ធិទទួលបានកម្មវិធី ឬចូលរួមសកម្មភាពអប់រំរបស់សាលាឡើងវិញ។

ការការពារតាមនីតិវិធីផ្លូវច្បាប់

ការការពារតាមនីតិវិធីផ្លូវច្បាប់រួមមានដូចខាងក្រោម៖

1. ការសន្មតពីភាពគ្មានទោសពេញមួយដំណើរការបណ្តឹងសាទុក្ខ ដោយមានបន្ទុកភស្តុតាងលើសាលា
2. ការហាមឃាត់គំរូអ្នកស៊ើបអង្កេតតែមួយ ជំនួសឱ្យការទាមទារឱ្យមានការសម្រេចចិត្តដាច់ដោយឡែកពីអ្នកសម្របសម្រួល ឬអ្នកស៊ើបអង្កេតតាមចំណងជើង Title IX
3. ភស្តុតាងច្បាស់លាស់ និងគួរឱ្យជឿជាក់ ឬឧត្តមានុភាពនៃភស្តុតាង ដែលស្ថិតក្រោមដែនកំណត់
4. ឱកាសធ្វើតេស្តភាពជឿជាក់របស់គូភាគី និងសាក្សីតាមរយៈការសាកសួរចម្លើយសាក្សីដែលស្ថិតនៅក្រោមការការពារ "ច្បាប់ការពារការរំលោភ"
5. ការជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការចោទប្រកាន់ និងឱកាសស្មើគ្នាក្នុងការពិនិត្យភស្តុតាង
6. អ្នកសម្របសម្រួលចំណងជើង Title IX អ្នកស៊ើបអង្កេត និងអ្នកធ្វើការសម្រេចចិត្ត ត្រូវតែមិនមានការលម្អៀង ឬមានទំនាស់ផលប្រយោជន៍
7. ឱកាសស្មើគ្នាសម្រាប់ភាគីប្តឹងសាទុក្ខ ដែលសាលាផ្តល់ការប្តឹងសាទុក្ខ
8. នៅពេលដាក់ពាក្យបណ្តឹងជាផ្លូវការ សាលាត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ភាគីដែលមានព័ត៌មានលម្អិតគ្រប់គ្រាន់ ដើម្បីអនុញ្ញាតឱ្យភាគីរៀបចំការសម្ភាសន៍ដំបូងណាមួយ និងបន្តការស៊ើបអង្កេតអង្គហេតុ។ សម្រាប់សាលាមត្តេយ្យដល់ថ្នាក់ទី 12 សវនាការគឺធ្វើក៏បានអត់ក៏បាន ប៉ុន្តែគូភាគីត្រូវតែទទួលបានការអនុញ្ញាតឱ្យដាក់សំណួរជាលាយលក្ខណ៍អក្សរ ដើម្បីជំទាស់នឹងភាពជឿជាក់របស់គ្នាទៅវិញទៅមក មុនពេលអ្នកធ្វើការសម្រេចចិត្តធ្វើការសម្រេច។ បន្ទាប់ពីការស៊ើបអង្កេត ការសម្រេចចិត្តជាលាយលក្ខណ៍អក្សរត្រូវផ្ញើទៅភាគីទាំងពីរពន្យល់ពីបទចោទប្រកាន់នីមួយៗ ថាតើអ្នកឆ្លើយត្រូវទទួលខុសត្រូវ ឬមិនទទួលខុសត្រូវ រួមទាំងអង្គហេតុ និងភស្តុតាងដែលការសន្និដ្ឋានផ្អែកលើ តាមរយៈការអនុវត្តន៍ទាំងការសន្មតនៃភស្តុតាង ឬស្តង់ដារច្បាស់លាស់ និងគួរឱ្យជឿជាក់ ទោះយ៉ាងណាក៏ដោយ សាលាអាចប្រើប្រាស់ស្តង់ដារឧត្តមានុភាពទាបបានលុះត្រាតែខ្លួនប្រើស្តង់ដារនោះសម្រាប់ការបំពានក្រមសីលធម៌ដែលមិនពាក់ព័ន្ធនឹងការបៀតបៀនផ្លូវភេទ ប៉ុន្តែអនុវត្តការដាក់ទណ្ឌកម្មវិន័យអតិបរមាដូចគ្នា។ ដរាបណាដំណើរការនេះធ្វើឡើងដោយស្ម័គ្រចិត្តសម្រាប់ភាគីទាំងអស់ បន្ទាប់ពីទទួលបានព័ត៌មានពេញលេញ

និងការយល់ព្រមជាលាយលក្ខណ៍អក្សរត្រូវបានផ្តល់ដោយភាគីទាំងពីរ សាលាអាចសម្របសម្រួលការដោះស្រាយក្រៅផ្លូវការនៃបណ្តឹងផ្លូវភេទ។

មណ្ឌលសិក្សាធិការអាចបង្កើតដំណើរការស៊ើបអង្កេតក្រៅផ្លូវការ ដែលអាចតាមសំណើរបស់ដើមបណ្តឹងត្រូវបានអនុវត្តតាមដំណើរការផ្លូវការ។

ដោយមានការពិគ្រោះជាមួយអ្នកសម្របសម្រួលចំណងជើង Title IX អគ្គនាយកសាលាត្រូវចាត់តាំងនាយកសាលានីមួយៗនៅក្នុងមណ្ឌលសិក្សាធិការ ឬអ្នកទទួលសិទ្ធិរបស់ពួកគេ (ឬនិយោជិតសមស្របផ្សេងទៀត) ឱ្យធ្វើជានីតិបុគ្គលដំបូង ដើម្បីទទួលពាក្យបណ្តឹងអំពីបទបៀតបៀនផ្លូវភេទ។ ដូចគ្នានេះដែរ ចំពោះបញ្ហាពាក់ព័ន្ធនឹងការបៀតបៀនផ្លូវភេទ មណ្ឌលសិក្សាធិការត្រូវតម្រូវឱ្យអ្នកសម្របសម្រួលចំណងជើង Title IX ទទួលបានការជូនដំណឹងឱ្យបានឆាប់តាមដែលអាចធ្វើទៅបានអំពីការដាក់ពាក្យបណ្តឹង។ គ្មានចំណុចណាមួយនៅក្នុងគោលនយោបាយនេះនឹងរារាំងបុគ្គលណាម្នាក់មិនឲ្យរាយការណ៍ពីសកម្មភាពហាមឃាត់ទៅកាន់អ្នកផ្សេងក្រៅពីអ្នកទទួលពាក្យបណ្តឹងដែលបានកំណត់ខាងលើឡើយ។
មន្រ្តីស៊ើបអង្កេតអាចទទួលបានពាក្យបណ្តឹងដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ ហើយការស៊ើបអង្កេតត្រូវធ្វើឡើងតាមរបៀបមួយ ដើម្បីរក្សាការសម្ងាត់ក្នុងកម្រិតដែលអាចអនុវត្តបានក្នុងកាលៈទេសៈ និងអនុលោមតាមច្បាប់ជាធរមាន។ ការស៊ើបអង្កេតនឹងមានភាពរហ័សរហួន ហ្មត់ចត់ និងមិនលម្អៀង ហើយនឹងរួមបញ្ចូលយ៉ាងហោចណាស់នូវការសម្ភាសន៍ឯកជនជាមួយអ្នកដែលដាក់ពាក្យបណ្តឹង និងជាមួយសាក្សី។ ដូចគ្នានេះដែរ ជនរងគ្រោះនឹងត្រូវបានសម្ភាសផងដែរ។ នៅពេលបានបញ្ចប់ការស៊ើបអង្កេតនេះ អ្នកទទួលពាក្យបណ្តឹងនឹងជូនដំណឹងដល់បុគ្គលដែលដាក់ពាក្យបណ្តឹង និងបុគ្គលដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តចំពោះលទ្ធផលនៃការស្រាវជ្រាវនោះ ទៅតាមវិសាលភាពសមស្រប។

លក្ខខណ្ឌតម្រូវនៃការរក្សាកំណត់ត្រា

សាលាត្រូវតែបង្កើត និងរក្សាកំណត់ត្រាដែលចងក្រងរាល់ពាក្យបណ្តឹងពីបទបៀតបៀនផ្លូវភេទក្រោមចំណងជើង Title IX។ នេះអាចរួមមានការសម្រុះសម្រួល យុត្តិធម៌ស្តារឡើងវិញ ឬគំរូផ្សេងទៀតនៃការដោះស្រាយវិវាទផ្សេងទៀត។ សាលាត្រូវតែរក្សាកំណត់ត្រាទាក់ទងនឹងការឆ្លើយតបរបស់សាលាចំពោះរាល់របាយការណ៍អំពីការបៀតបៀនផ្លូវភេទ ដែលដឹងថា ទោះបីជាមិនមានការប្តឹងផ្តល់ជាផ្លូវការក៏ដោយ រួមទាំងឯកសារនៃបញ្ហាជំនួយដែលបានផ្តល់ និងអនុវត្តសម្រាប់ដើមបណ្តឹង។

គោលនយោបាយនេះ ឬសេចក្តីសង្ខេបដែលមានធាតុផ្សំនៃគោលនយោបាយសំខាន់ៗ នឹងត្រូវបានមណ្ឌលសិក្សាធិការក្រុង Lowell ចែកជូនសិស្ស និងនិយោជិតរបស់ខ្លួននៅក្នុងសៀវភៅណែនាំ ហើយមាតាបិតា ឬអាណាព្យាបាលនីមួយៗត្រូវចុះហត្ថលេខាបញ្ជាក់ថាពួកគេបានទទួល និងយល់អំពីគោលនយោបាយនេះ។ សាលានីមួយៗនឹងរក្សាច្បាប់ចម្លងនៃហត្ថលេខាមាតាបិតា/អាណាព្យាបាលដែលបញ្ជាក់ពីការទទួលបានគោលនយោបាយនេះ។

អ្នកសម្របសម្រួលចំណងជើង IX របស់សាលាសាធារណៈ Lowell៖ លោកស្រី Alice Brown-LeGrand ជំនួយការអគ្គនាយកសម្រាប់សេវាកម្មគាំទ្រសិស្ស (978) 674-4334 ។ ប្រសិនបើអ្នកមានពាក្យបណ្តឹង សូមទាក់ទងការិយាល័យរបស់ Alice Brown-LeGrand ជំនួយការអគ្គនាយកសម្រាប់សេវាកម្មគាំទ្រសិស្ស (978) 674-4334។

ការិយាល័យប្រព័ន្ធដោះស្រាយបញ្ហា នាយកដ្ឋានអប់រំបឋមសិក្សា និងមធ្យមសិក្សារដ្ឋ Massachusetts
75 Pleasant St
ម៉ាល់ឌិន, MA 02148-4906
ទូរស័ព្ទ: 7810338-3700
ទូរសារ: 781-338-3710
អ៊ីម៉ែល: compliance@doe.mass.edu

សូមចំណាំថា ស្ថាប័នខាងក្រោមអាចកំណត់ពេលវេលាជាក់លាក់ក្នុងការដាក់ពាក្យបណ្តឹង។

ដើមបណ្តឹងក៏អាចដាក់ពាក្យបណ្តឹងទៅកាន់៖

> គណៈកម្មាការប្រឆាំងការរើសអើងនៃរដ្ឋ Mass., 1 Ashburton Place, បន្ទប់ 601
> Boston, MA 02108
> ទូរសព្ទ៖ 617-994-6000
> TTY: 617-994-6196
> ទូរសារ៖ 617-994-6024
> Email:assistanttochairman@state.ma.us

ការិយាល័យសិទ្ធិស៊ីវិល (ក្រសួងអប់រំសហរដ្ឋអាមេរិក)
5 Post Office Square, 8th Floor
Boston, MA 02109
ទូរសព្ទ៖ 617-289-0111
TDD: 1-800-877-8339
ទូរសារ៖ 617-289-0150
អ៊ីមែល៖ OCR.Boston@ed.gov

ការិយាល័យប្រព័ន្ធដោះស្រាយបញ្ហា នាយកដ្ឋានអប់រំបឋមសិក្សា និងមធ្យមសិក្សារដ្ឋ Massachusetts
75 Pleasant St
ម៉ាល់ឌិន, MA 02148-4906
ទូរស័ព្ទ: 7810338-3700
ទូរសារ: 781-338-3710
អ៊ីម៉ែល: compliance@doe.mass.edu

គណៈកម្មការឱកាសការងារស្មើភាពរបស់សហរដ្ឋអាមេរិក
John F. Kennedy Bldg.
475 Government Center
Boston, MA 02203
អ៊ីមែល៖ https://www.eeoc.gov/filing-charge-discrimination

**ការធ្វើបាប** ត្រូវបានកំណត់និយមន័យជាការប្រមូលហើយម្ដងទៀតដោយសិស្សម្នាក់ ឬច្រើននាក់ ឬដោយសមាជិកនៃបុគ្គលិកសាលា រួមមាន ប៉ុន្តែមិនកំណត់ត្រឹមចំពោះអ្នកអប់រំ អ្នកគ្រប់គ្រង គិលានុបដ្ឋាកសាលា បុគ្គលិកអាហារដ្ឋាន អ្នកមើលថែ អ្នកបើកឡានក្រុង គ្រូបង្វឹកអត្តពលិក ទីប្រឹក្សាសម្រាប់សកម្មភាពក្រៅកម្មវិធីសិក្សា ឬអ្នកជំនួយការផ្នែកទំនាក់ទំនង និង/ឬការនិយាយផ្ទាល់មាត់ ជាលាយលក្ខណ៍អក្សរ ឬអេឡិចត្រូនិក (រួមទាំងការធ្វើបាបតាមអ៊ីនធឺណិត) ឬទង្វើផ្លូវកាយ ឬកាយវិការ ឬការរួមផ្សំគ្នានៃទង្វើណាមួយ

ដែលសំដៅទៅកាន់ជនរងគ្រោះដែល (i) បង្កគ្រោះថ្នាក់ដល់ផ្លូវកាយ ឬផ្លូវចិត្តដល់ជនរងគ្រោះ ឬខូចខាតទ្រព្យសម្បត្តិរបស់ជនរងគ្រោះ (ii) ធ្វើឲ្យជនរងភ័យខ្លាចមានគ្រោះថ្នាក់ដល់ខ្លួនគាត់ ឬខូចខាតទ្រព្យសម្បត្តិរបស់គាត់ដោយមានមូលហេតុត្រឹមត្រូវ (iii) បង្កើតបរិយាកាសអរិភាពនៅសាលារៀនសម្រាប់ជនរងគ្រោះ (iv) ការរំលោភលើសិទ្ធិរបស់ជនរងគ្រោះនៅសាលារៀន ឬ (v) រំខានយ៉ាងខ្លាំងដល់ដំណើរការអប់រំ ឬដំណើរការ និងសណ្តាប់ធ្នាប់របស់សាលា។

"**ការធ្វើបាបតាមអ៊ីនធឺណិត**" គឺជាការធ្វើបាបតាមរយៈការប្រើប្រាស់បច្ចេកវិទ្យា ឬការទំនាក់ទំនងតាមអេឡិចត្រូនិក ដែលនឹងរួមមាន ប៉ុន្តែមិនកំណត់ត្រឹមចំពោះ ការផ្ទេរសញ្ញា អក្សរ រូបភាព សំឡេង ទិន្នន័យណាមួយ ឬការស៊ើបយកការលក្ខណៈណាមួយដែលត្រូវបានបញ្ជូនទាំងមូល ឬដោយផ្នែកដោយខ្សែ វិទ្យុ អេឡិចត្រូម៉ាញ៉េទិច រូបថត ឬប្រព័ន្ធអេឡិចត្រូនិក ឬប្រព័ន្ធអុបទិករូបថត រួមមាន ប៉ុន្តែមិនកំណត់ត្រឹមចំពោះសារអេឡិចត្រូនិក ទំនាក់ទំនងតាមអ៊ីនធឺណិត សារផ្ញើភ្លាមៗ ឬការទំនាក់ទំនងតាមទូរសារ។ ការធ្វើបាបតាមអ៊ីនធឺណិតក៏នឹងរួមបញ្ចូលផងដែរ (i) ការបង្កើតទំព័របណ្តាញ ឬប្លក់ដែលអ្នកបង្កើតសន្មតថាជាអត្តសញ្ញាណរបស់បុគ្គលផ្សេងទៀត ឬ (ii) ការក្លែងខ្លួនដោយចេតនាជាបុគ្គលម្នាក់ទៀតជាអ្នកនិពន្ធនៃខ្លឹមសារ ឬសារដែលបានបង្ហោះ ប្រសិនបើការបង្កើត ឬការក្លែងបន្លំបង្កើតលក្ខខណ្ឌណាមួយដែលបានរាប់បញ្ចូលក្នុងប្រការ (i) ទៅដល់ (v) ដោយមានរួមបញ្ចូលនិយមន័យនៃការធ្វើបាប។ ការធ្វើបាបតាមអ៊ីនធឺណិតក៏នឹងរួមបញ្ចូលផងដែរនូវការចែកចាយតាមរយៈមធ្យោបាយអេឡិចត្រូនិកអំពីការប្រាស្រ័យទាក់ទងទៅកាន់មនុស្សច្រើនជាងម្នាក់ ឬការបង្ហោះសម្ភារៈនៅលើឧបករណ៍អេឡិចត្រូនិកដែលអាចចូលប្រើបានដោយមនុស្សម្នាក់ ឬច្រើននាក់ ប្រសិនបើការចែកចាយ ឬការបង្ហោះបង្កើតលក្ខខណ្ឌណាមួយដែលបានរៀបរាប់នៅក្នុងប្រការ (i) ទៅដល់ (v) ដោយមានរួមបញ្ចូលនិយមន័យនៃការធ្វើបាប។

សិស្សមួយចំនួនអាចងាយរងគ្រោះធ្លាក់ខ្លួនក្លាយជាគោលដៅនៃការធ្វើបាប ឬការបៀតបៀនផ្អែកលើលក្ខណៈជាក់ស្តែង ឬតាមការយល់ឃើញផ្សេងគ្នា រួមទាំងពូជសាសន៍ ពណ៌សម្បុរ សាសនា ពូជពង្ស ដើមកំណើតជាតិសាសន៍ ភេទ ស្ថានភាពសេដ្ឋកិច្ចសង្គម ភាពគ្មានផ្ទះសម្បែង ស្ថានភាពសិក្សា អត្តសញ្ញាណយេនឌ័រ ឬការបង្ហាញលក្ខណៈភេទ រូបរាង ស្ថានភាពមានផ្ទៃពោះ ឬមាតាបិតា ទំនោរផ្លូវភេទ ផ្លូវចិត្ត ផ្លូវកាយ ពិការភាពខាងការលូតលាស់ ឬពិការភាពខាងសតិអារម្មណ៍ ឬដោយផ្សារភ្ជាប់ជាមួយនឹងបុគ្គលដែលមាន ឬត្រូវបានយល់ថាមានលក្ខណៈមួយ ឬច្រើននៃលក្ខណៈទាំងនេះ។

***សិស្សណាក៏ដោយដែលជឿថាគាត់ត្រូវបានទទួលរងនូវការធ្វើបាប និង/ឬការបៀតបៀន គួរតែរាយការណ៍ពីករណីនេះទៅសមាជិកណាមួយនៃបុគ្គលិកសាលា (គ្រូ អ្នកប្រឹក្សា អ្នកគ្រប់គ្រង អ្នកឯកទេសផ្នែកអន្តរាគមន៍វិបត្តិ គិលានុបដ្ឋាកសាលា។ល។) និង/ឬមាតាបិតា***

***និង/ឬមន្ត្រីអនុវត្តច្បាប់ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។*** ក្នុងករណីដែលសិស្ស/មាតាបិតាជឿថាការបៀតបៀន និង/ឬការធ្វើបាបបានបង្កើតបណ្ដឹងសាទុក្ខក្រោមចំណងជើង Title IX និង/ឬជំពូកទី 662 សិស្សក៏នឹងមានជម្រើសក្នុងការដាក់ពាក្យបណ្ដឹងជាលាយលក្ខណ៍អក្សរទៅកាន់អ្នកសម្របសម្រួលនៃចំណងជើង Title IX ឬជំពូក 622 ផងដែរ។ សូមមើលផ្នែកមុននេះស្ដីពីការបៀតបៀន និងការបៀតបៀនផ្លូវភេទ។

របាយការណ៍ (ផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ) អំពីការធ្វើបាប និង/ឬការបៀតបៀននឹងត្រូវបានស៊ើបអង្កេតភ្លាមៗ និងក្នុងលក្ខណៈមិនលម្អៀង និងរក្សាការសម្ងាត់ ដើម្បីធានាបាននូវចំណាត់ការភ្លាមៗ និងសមស្រប។ បុគ្គលណាក៏ដោយដែលត្រូវបានរកឃើញ បន្ទាប់ពីការស៊ើបអង្កេតសមស្រប ថាបានចូលរួមក្នុងការបៀតបៀន និង/ឬការធ្វើបាប (ដូចបានកំណត់ខាងលើ) នៅឬក្រៅសាលា (ដូចដែលបានកំណត់ដោយច្បាប់) នឹងត្រូវទទួលរងនូវវិធានការវិន័យរហូតដល់ និងរួមទាំងការបណ្ដេញចេញ។ គ្មានបុគ្គលណាម្នាក់នឹងត្រូវទទួលរងនូវទម្រង់នៃការបង្ខិតបង្ខំ ការបំភិតបំភ័យ ការសងសឹក ការជ្រៀតជ្រែក ឬការរើសអើងដោយសារធ្វើរបាយការណ៍ទាក់ទងនឹងការបៀតបៀន និង/ឬការធ្វើបាប និង/ឬសម្រាប់កិច្ចសហការ និង/ឬជំនួយក្នុងការស៊ើបអង្កេតឡើយ។ ទោះជាយ៉ាងណាក៏ដោយ ការចោទប្រកាន់មិនពិតពីបទបៀតបៀន និង/ឬបទធ្វើបាបដោយចេតនា នឹងនាំឱ្យមានការចាត់វិធានការវិន័យរហូតដល់ និងរួមទាំងការបណ្ដេញចេញ។

សូមចំណាំផងដែរថា ស្ថាប័នអនុវត្តច្បាប់អាចត្រូវបានជូនដំណឹងលទ្ធផលអំពីការធ្វើបាប និង/ឬការបៀតបៀន និង/ឬសម្រាប់ការចោទប្រកាន់មិនពិតដោយចេតនា ហើយជាលទ្ធផល ការចោទប្រកាន់ព្រហ្មទណ្ឌអាចធ្វើឡើង។

សម្រាប់ព័ត៌មានបន្ថែមទាក់ទងនឹងការគំរាមកំហែងនិង/ឬការឃាយអ្នកអាចទាក់ទងនាយកសាលារបស់កូន របស់អ្នក និង/ឬការិយាល័យសេវាកម្មគាំទ្រសិស្សសម្រាប់សាលាសាធារណៈLowellនៅ 978-674-4334។ ព័ត៌មានបន្ថែមអាចរកបាននៅលើគេហទំព័ររបស់នាយកដ្ឋានអប់រំបឋមសិក្សា និងមធ្យមសិក្សារដ្ឋ Massachusetts ឬគេហទំព័រសាលាសាធារណៈ Lowell ។ ប្រសិនបើអ្នកត្រូវការរាយការណ៍អំពីការគំរាមកំហែង អ្នកនឹងរកឃើញទម្រង់របាយការណ៍នៅលើគេហទំព័ររបស់ស្រុក។

ចំពោះព័ត៌មានបន្ថែមទាក់ទងនឹងការធ្វើបាប និង/ឬការបៀតបៀន អ្នកអាចទាក់ទងនាយកសាលារបស់កូនអ្នក និង/ឬការិយាល័យសមធម៌អប់រំ និងការចូលរួមសហគមន៍សម្រាប់សាលារដ្ឋ Lowell តាមរយៈលេខទូរសព្ទ 978-674-2034។ ព័ត៌មានបន្ថែមអាចរកបាននៅលើគេហទំព័ររបស់នាយកដ្ឋានបឋមសិក្សា និងមធ្យមសិក្សារដ្ឋ

Massachusetts ឬគេហទំព័រសាលារដ្ឋ Lowell។ ប្រសិនបើអ្នកត្រូវការរាយការណ៍ពីការធ្វើបាប អ្នកនឹងរកឃើញទម្រង់បែបបទរាយការណ៍នៅលើគេហទំព័ររបស់មណ្ឌលសិក្សាធិការ។

## បទបញ្ជាហាមចូលដោយគ្មានការអនុញ្ញាត

អនុលោមតាមច្បាប់ M.G.L c. ត្រង់ជំពូក 266 ផ្នែក 120 អគ្គនាយកសាលាមានសិទ្ធិស្នើសុំ និងចេញបទបញ្ជាហាមចូលដោយគ្មានការអនុញ្ញាតចំពោះបុគ្គល ឬក្រុមបុគ្គលណាមួយដែលស្របតាមលក្ខខណ្ឌតម្រូវនៃច្បាប់រដ្ឋ ដែលអាចរួមបញ្ចូល ប៉ុន្តែមិនកំណត់ត្រឹមចំពោះការធ្វើទង្វើមិនសមរម្យ ដែលបង្កឱ្យមានផលប៉ះពាល់ និង/ឬធ្វើសកម្មភាពគំរាមកំហែងដល់បុគ្គលិកសាលា ឬសិស្ស។

# ឱកាសអប់រំស្មើភាព

## គោលនយោបាយស្ដីពីការប្រឆាំងនឹងការរើសអើង

វាជាគោលនយោបាយរបស់សាលារដ្ឋ Lowell មិនឲ្យមានការរើសអើងដោយផ្អែកលើភេទ ទំនោរផ្លូវភេទ សាសនា ពណ៌សម្បុរ ឬប្រភពដើមជាតិសាសន៍នៅក្នុងកម្មវិធីអប់រំ សកម្មភាព ឬគោលនយោបាយការងារ ដូចដែលតម្រូវដោយចំណងជើង Title IX នៃវិសោធនកម្មការអប់រំឆ្នាំ 1972 និងជំពូក 622 នៃច្បាប់ឆ្នាំ 1971។ ចំណងជើង Title IX គឺជាច្បាប់សហព័ន្ធដែលហាមឃាត់ការរើសអើងសិស្ស និងនិយោជិតដោយផ្អែកលើភេទ។ ជំពូកទី 22 គឺជាច្បាប់រដ្ឋដែលរួមបញ្ចូលការហាមឃាត់ការរើសអើងដោយផ្អែកលើភេទ ទំនោរផ្លូវភេទ ឬអត្តសញ្ញាណយេនឌ័រ ប៉ុន្តែក៏ហាមឃាត់ការរើសអើងដោយផ្អែកលើពូជសាសន៍ ពណ៌សម្បុរ ដើមកំណើតជាតិសាសន៍ និងសាសនាផងដែរ។ (ជំពូក 622 និយាយអំពីសិស្សតែប៉ុណ្ណោះ។) នេះនឹងមានន័យថាសិស្សគ្រប់រូបនឹងទទួលបានឱកាសស្មើគ្នាក្នុងការចូលរៀន ទទួលបានវគ្គសិក្សា ខ្លឹមសារនៃវគ្គសិក្សា ការណែនាំ និងសកម្មភាពក្រៅកម្មវិធីសិក្សា និងកម្មវិធីកីឡា។

## នីតិវិធីបណ្ដឹងសាទុក្ខ

សិស្ស ឬនិយោជិតនៅក្នុងសាលារដ្ឋ Lowell ដែលមានអារម្មណ៍ថាខ្លួនមានបណ្ដឹងសាទុក្ខក្រោមចំណងជើង Title IX ឬជំពូក 622 ត្រូវដាក់បណ្ដឹងសាទុក្ខជាលាយលក្ខណ៍អក្សរទៅបុគ្គលដូចខាងក្រោម៖

- កម្រិត 1 នាយក/អ្នកទទួលសិទ្ធិ
- កម្រិត 2 អ្នកសម្របសម្រួលចំណងជើង Title IX/622
- កម្រិត 3 អគ្គនាយកសាលា
- កម្រិត 4 គណៈកម្មាធិការសាលា

<u>កម្រិត 1</u>៖ សិស្ស ឬនិយោជិតដែលមានអារម្មណ៍ថាមានបណ្ដឹងសាទុក្ខក្រោមចំណងជើង Title IX ឬជំពូក 622 ត្រូវបញ្ជូនវាជាលាយលក្ខណ៍អក្សរទៅកាន់នាយកសាលា/អ្នកទទួលសិទ្ធិ។ នាយកសាលា/អ្នកទទួលសិទ្ធិនឹងជួបជាមួយសិស្ស ឬនិយោជិតក្នុងរយៈពេលប្រាំថ្ងៃសិក្សា បន្ទាប់ពីទទួលបានពាក្យបណ្ដឹងក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីដោះស្រាយពាក្យបណ្ដឹង។

<u>កម្រិត 2៖</u> ប្រសិនបើនៅចុងបញ្ចប់នៃប្រាំ (5) ថ្ងៃសិក្សាបន្ទាប់ពីកិច្ចប្រជុំនោះ បណ្ដឹងសាទុក្ខមិនត្រូវបានចាត់ចែងដោយជោគជ័យទេ បណ្ដឹងសាទុក្ខជាលាយលក្ខណ៍អក្សរអាចត្រូវបានបង្ហាញទៅកាន់អ្នកសម្របសម្រួលចំណងជើង Title IX

ដែលក្នុងរយៈពេលដប់ (10) ថ្ងៃសិក្សាបន្ទាប់ពីនោះមក ជួបក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីដោះស្រាយបណ្តឹងសាទុក្ខ។

*អ្នកសម្របសម្រួល/មន្ត្រីដែលបានជ្រើសតាំង*
Title IX Latifah Phillips ប្រធានផ្នែកសមធម៌អប់រំ និងការចូលរួមរបស់សហគមន៍ (978) 674-4326
Title II  Oneida Fox Roye, ជំនួយការអង្គនាយកផ្នែកសិក្សា និងកិច្ចការបង្រៀន (978) 674-4323

អ្នកសម្របសម្រួលមណ្ឌលសាលា 504, Alice Brown-Legrand, ជំនួយការអគ្គនាយកផ្នែកសេវាគាំទ្រសិស្ស (978) 674-4326

<u>កម្រិត 3</u>៖ ប្រសិនបើនៅចុងបញ្ចប់នៃដប់ (10) ថ្ងៃសិក្សាបន្ទាប់ក្រោយពីកិច្ចប្រជុំបណ្តឹងសាទុក្ខមិនត្រូវបានដោះស្រាយតាមការចង់បានរបស់ដើមបណ្តឹង ដើមបណ្តឹងអាចបញ្ជូនបណ្តឹងសាទុក្ខជាលាយលក្ខណ៍អក្សរទៅកាន់អគ្គនាយកសាលា ដែលក្នុងរយៈពេលដប់ (10) ថ្ងៃសិក្សា បន្ទាប់មក ជួបគ្នាក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីដោះស្រាយបណ្តឹងសាទុក្ខ។

<u>កម្រិត 4</u>៖ ប្រសិនបើនៅចុងបញ្ចប់នៃដប់ (10) ថ្ងៃសិក្សាបន្ទាប់ពីកិច្ចប្រជុំជាមួយអគ្គនាយកសាលា បណ្តឹងសាទុក្ខមិនបានដោះស្រាយតាមការចង់បានរបស់ដើមបណ្តឹង ដើមបណ្តឹងអាចបញ្ជូនបណ្តឹងសាទុក្ខជាលាយលក្ខណ៍អក្សរទៅកាន់គណៈកម្មាធិការសាលា។ នៅក្រោមបណ្តឹងសាទុក្ខជំពូកទី 622 ដើមបណ្តឹងអាចដាក់ច្បាប់ចម្លងទៅការិយាល័យឱកាសអប់រំស្មើភាព។ គណៈកម្មាធិការសាលាត្រូវឆ្លើយតបភ្លាមៗ ប៉ុន្តែមិនយូរជាងសាមសិប (30) ថ្ងៃសិក្សា ជាលាយលក្ខណ៍អក្សរទៅកាន់ភាគីប្តឹង។ គណៈកម្មាធិការសាលាក៏ត្រូវផ្ញើច្បាប់ចម្លងនៃការឆ្លើយតបទៅនឹងបណ្តឹងសាទុក្ខជំពូកទី 622 ទៅកាន់ការិយាល័យឱកាសអប់រំស្មើភាពនៅក្រសួងអប់រំរដ្ឋ Massachusetts ផងដែរ។ លើសពីនេះ ដើមបណ្តឹងមានសេរីភាពក្នុងការបន្តសិទ្ធិរបស់ខ្លួនជាមួយទីភ្នាក់ងាររដ្ឋសមស្រប ឬតុលាការ/ស្ថាប័នរដ្ឋបាល ដែលនឹងមានយុត្តាធិការ រួមទាំងប៉ុន្តែមិនកំណត់ត្រឹមចំពោះខាងក្រោម៖

ការិយាល័យបណ្តឹងសាទុក្ខនៃការអប់រំពិសេស | ផ្នែកបណ្តឹងសាទុក្ខច្បាប់រដ្ឋបាល | 14 Summer Street, 4th floor, Malden,
MA 02148 | ទូរសព្ទ 781-397-4755|ទូរសារ 781-397-4770

ក្រសួងកម្មវិធីអប់រំនៃរដ្ឋ Massachusetts, សេចក្តីសម្រេចកម្មវិធី, 75 Pleasant Street, Malden MA 02148 ទូរសព្ទ
(781) 338-37000៖ ទូរសារ (781)- 338-3710៖ TTY: សេវាបញ្ជូនបន្ត (800)-439-2370។
អ៊ីមែល៖ compliance@doe.mass.edu

ក្រសួងអប់រំនៃសហរដ្ឋអាមេរិក ការិយាល័យសិទ្ធិស៊ីវិល ក្រសួងអប់រំ 5 Post Office Square, 8th Floor, Boston,
Massachusetts 02109
ទូរសព្ទ (617) 289-00112៖ ទូរសារ៖ (617-289-0150)៖ TTD: (800) 877)-8339-521-2172;.
អ៊ីមែល៖ OCR.Boston@ed.gov

## ការមិនរើសអើង

ការគោរពចំពោះសេចក្តីថ្លៃថ្នូរ និងតម្លៃរបស់បុគ្គលម្នាក់ៗ គឺមានសារៈសំខាន់បំផុតក្នុងការបង្កើតគោលនយោបាយទាំងអស់ដោយគណៈកម្មាធិការសាលា Lowell និងក្នុងការគ្រប់គ្រងគោលនយោបាយទាំងនោះដោយគណៈកម្មាធិការសាលា និងបុគ្គលិកទាំងអស់នៃសាលារដ្ឋ Lowell។ **ចំណងជើង Title II** នៃច្បាប់ស្តីពីជនពិការអាមេរិក និង **ផ្នែកទី 504** នៃច្បាប់ស្តារនីតិសម្បទាហាមឃាត់ការរើសអើងដោយផ្អែកលើពិការភាពរបស់បុគ្គលម្នាក់។

សាលារដ្ឋ Lowell ប្តេជ្ញារក្សាបរិយាកាសអប់រំ និងកន្លែងធ្វើការ ដែលបុគ្គលម្នាក់ៗមិនមានការរើសអើងដោយផ្អែកលើពិការភាពរបស់ពួកគេ។ សាលារដ្ឋ Lowell ខិតខំបង្កើតបរិយាកាសមួយដែលសិស្ស និងបុគ្គលិកទាំងអស់មានអារម្មណ៍ស្វាគមន៍។ ដើម្បីឆ្លើយតបនឹងគោលបំណងនេះ សាលារដ្ឋ Lowell នឹងមិនអត់ឱនចំពោះការ បដិសេធចំពោះលទ្ធភាពធ្វើសកម្មភាព កម្មវិធី ឬសេវាកម្មដល់ជនពិការ (ដូចដែលបានកំណត់ក្នុងផ្នែកទី 504 នៃច្បាប់ស្តារនីតិសម្បទា 29 USC ផ្នែកទី 705 (20)។

គោលនយោបាយស្តីពីការមិនរើសអើងរបស់គណៈកម្មាធិការសាលាត្រូវបន្តអនុវត្តចំពោះសិស្ស បុគ្គលិក សាធារណជនទូទៅ និងបុគ្គលដែលខ្លួនធ្វើអាជីវកម្មជាមួយ។ គោលនយោបាយស្តីពីការមិនរើសអើងរបស់គណៈកម្មាធិការសាលាត្រូវហាមឃាត់ការរើសអើង

រួមទាំងការបៀតបៀនដោយឈរលើមូលដ្ឋាននៃជាតិសាសន៍ ពណ៌សម្បុរ សាសនា ពូជពង្ស ដើមកំណើតជាតិសាសន៍ ភេទ ស្ថានភាពសេដ្ឋកិច្ចសង្គម ភាពគ្មានផ្ទះសម្បែង អត្តសញ្ញាណឬការបង្ហាញអំពីយេនឌ័រ ការមានផ្ទៃពោះ ឬលក្ខខណ្ឌទាក់ទងនឹងការមានផ្ទៃពោះ ស្ថានភាពមាតាបិតា ទំនោរផ្លូវភេទ ពិការភាព ឬដោយផ្សារភ្ជាប់ជាមួយនឹងបុគ្គលដែលមាន ឬត្រូវបានគេយល់ថាមានលក្ខណៈមួយ ឬផ្សេងទៀតនៃលក្ខណៈទាំងនេះ

**ឱកាសអប់រំស្មើភាព**

ក្នុងការទទួលស្គាល់គោលនយោបាយរបស់គណៈកម្មាធិការសាលាប្រឆាំងនឹងការរើសអើង គណៈកម្មាធិការសាលា និងបុគ្គលិកទាំងអស់នៃសាលារដ្ឋ Lowell នឹងខិតខំប្រឹងប្រែងឱ្យអស់ពីសមត្ថភាពដើម្បីអនុវត្តតាមខ្លឹមសារ និងស្មារតីនៃច្បាប់ស្តីពីឱកាសអប់រំស្មើគ្នានៃរដ្ឋ Massachusetts ដែលហាមឃាត់ការរើសអើងក្នុងការចូលរៀននៅសាលារដ្ឋ និងកម្មវិធី និងការអនុវត្តបទប្បញ្ញត្តិទាំងអស់ដែលចេញដោយនាយកដ្ឋានអប់រំបឋមសិក្សា និងមធ្យមសិក្សារដ្ឋ Massachusetts នឹងត្រូវអនុវត្តតាម។

វាជាគោលនយោបាយរបស់សាលារដ្ឋ Lowell ដែលរាប់បញ្ចូល ឬមិនរើសអើងសិស្សក្នុងការចូលរៀននៅសាលា Lowell ឬក្នុងការទទួលបានអត្ថប្រយោជន៍ ឯកសិទ្ធិ និងការសិក្សាវគ្គសិក្សានៅក្នុងសាលារដ្ឋ Lowell ដោយឈរលើមូលដ្ឋាននៃពូជសាសន៍ ពណ៌សម្បុរ សាសនា ពូជពង្ស ដើមកំណើតជាតិសាសន៍ ភេទ ស្ថានភាពសេដ្ឋកិច្ចសង្គម ភាពគ្មានផ្ទះសម្បែង អត្តសញ្ញាណយេនឌ័រឬការបង្ហាញអំពីលក្ខណៈភេទ ស្ថានភាពដែលទាក់ទងនឹងការមានផ្ទៃពោះឬស្ថានភាពមានផ្ទៃពោះ ស្ថានភាពជាមាតាបិតា ទំនោរផ្លូវភេទ ពិការភាព ឬដោយផ្សារភ្ជាប់ជាមួយនឹងបុគ្គលដែលមាន ឬត្រូវបានគេយល់ថាមានលក្ខណៈមួយ ឬផ្សេងទៀតនៃលក្ខណៈទាំងនេះនៅក្នុងកម្មវិធីអប់រំ សកម្មភាពរបស់យើង ដូចដែលរំពឹងដោយចំណងជើង Title IX នៃវិសោធនកម្មការអប់រំឆ្នាំ 1972 និងជំពូកទី 622 នៃច្បាប់ឆ្នាំ 1971 បន្ថែមពីលើច្បាប់ទូទៅនៃរដ្ឋ Massachusetts ជំពូកទី 76 ផ្នែកទី 5 និង 603 CMR 26.00 និង 603 CMR 28.00។

នេះក៏មានន័យផងដែរថា សិស្សគ្រប់រូបនឹងទទួលបានសិទ្ធិចូលរៀន/ឱកាសស្មើភាពក្នុងការចូលរៀន ការចូលរៀនវគ្គសិក្សា ខ្លឹមសារវគ្គសិក្សា ការណែនាំ អាហារូបករណ៍ រង្វាន់ ពានរង្វាន់ និងសកម្មភាពក្រៅកម្មវិធីសិក្សា និងកម្មវិធីកីឡា។

លទ្ធផលរកឃើញនៃការរើសអើងអាចបណ្ដាលឱ្យមានផលវិបាកសមស្របស្របតាមគោលនយោបាយ និងគោលការណ៍ណែនាំរបស់សាលារដ្ឋ Lowell។

**បណ្ដឹងតវ៉ា និងបណ្ដឹងសារទុក្ខរបស់សិស្ស**

គណៈកម្មាធិការសាលាទទួលស្គាល់ថាអាចមានលក្ខខណ្ឌនៅក្នុងប្រព័ន្ធសាលារៀនដែលត្រូវការការកែលម្អ ហើយថាសិស្សទាំងអស់គួរតែមានមធ្យោបាយមួយចំនួនដែលកង្វល់របស់ពួកគេ អាចត្រូវបានបង្ហាញដោយមានប្រសិទ្ធភាព យកមកពិចារណា និងដោះស្រាយដោយយុត្តិធម៌។

មធ្យោបាយបែបនេះ ប្រសិនបើមានការយល់ឃើញ និងយល់ច្បាស់ជាមុន អាចនឹងកាន់តែមានប្រសិទ្ធភាពក្នុងការរក្សាទំនាក់ទំនងប្រកបដោយសុខដុមរមនាក្នុងចំណោមសាលារៀន និងសិស្ស និងសហគមន៍។

គោលនយោបាយ "បើកចំហរ" តាមទម្លាប់នៅក្នុងប្រព័ន្ធសាលារៀននឹងអនុវត្តបន្ត។ សិស្ស និងមាតាបិតា និង/ឬអាណាព្យាបាលរបស់ពួកគេ ដែលជឿថាសិស្សបានទទួលការប្រព្រឹត្ត ដោយអយុត្តិធម៌អាចបញ្ជូនបន្តពាក្យបណ្ដឹងសាទុក្ខរបស់ពួកគេតាមរយៈបណ្ដាញសមស្រប។

រាល់ការប៉ុនប៉ងនឹងធ្វើឡើងដើម្បីស្វែងរកដំណោះស្រាយដែលពេញចិត្តចំពោះរាល់បណ្ដឹង ឬបណ្ដឹងសាទុក្ខស្របច្បាប់ទាំងអស់ប្រកបដោយមិត្តភាព និងក្រៅផ្លូវការ ប្រសិនបើអាចធ្វើទៅបាន។ រាល់បទប្បញ្ញត្តិដែលអាចអនុវត្តបានទាំងអស់នៃច្បាប់ទូទៅនៃរដ្ឋ Massachusetts ឬច្បាប់សហព័ន្ធនឹងត្រូវអនុវត្តតាមដោយមន្ត្រីសាលាក្នុងការស៊ើបអង្កេត និងពិនិត្យមើលនូវបណ្ដឹងសាទុក្ខរបស់សិស្ស និង/ឬធ្វើសវនាការ។

ក្នុងករណីសិស្ស និងមាតាបិតា និង/ឬអាណាព្យាបាលរបស់ពួកគេ ដែលជឿថាសិស្សបានទទួលការប្រព្រឹត្តដាក់ដោយអយុត្តិធម៌ ដំណើរការបណ្ដឹងឧទ្ធរណ៍នឹងត្រូវបានដឹកនាំដោយគោលនយោបាយ និងនីតិវិធីរបស់សាលារដ្ឋ Lowell និងច្បាប់ណាមួយ និង/ឬទាំងអស់ដែលមានជាធរមាន។

សម្រាប់សិស្ស និង/ឬមាតាបិតា/អាណាព្យាបាលណាក៏ដោយនៅក្នុងសាលារដ្ឋ Lowell ដែលគិតថាខ្លួនបានទទួលរងនូវការរើសអើងក្រោមចំណងជើង Title IX ឬជំពូក 622 ត្រូវដាក់បណ្តឹងជាលាយលក្ខណ៍អក្សរទៅខាងក្រោម៖

**<u>បណ្តាញរាយការណ៍</u>**

កម្រិត 1៖ នាយក/អ្នកទទួលសិទ្ធិ

កម្រិត 2៖ អ្នកសម្របសម្រួល/មន្ត្រីដែលបានជ្រើសតាំង

កម្រិត 3 អគ្គនាយកសាលា

កម្រិត 4៖ គណៈកម្មាធិការសាលា/ផ្សេងទៀត

<u>កម្រិត 1</u>៖ អ្នកគ្រប់គ្រងសាលាដែលបានចាត់តាំងនឹងជួបជាមួយសិស្ស និង/ឬបុគ្គលិកសាលាក្នុងរយៈពេលប្រាំ (5) ថ្ងៃសិក្សា បន្ទាប់ពីទទួលបានបណ្ដឹងសាទុក្ខក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីដោះស្រាយពាក្យបណ្ដឹង។ អ្នកគ្រប់គ្រងនឹងរាយការណ៍ពីលទ្ធផលរកឃើញ និងសេចក្ដីសម្រេចនៃកិច្ចប្រជុំទាំងនោះទៅកាន់នាយកសាលា/អ្នកទទួលសិទ្ធិ។

<u>កម្រិត 2</u>៖ ប្រសិនបើនៅចុងបញ្ចប់នៃថ្ងៃសិក្សាប្រាំ (5) ថ្ងៃបន្ទាប់ពីកិច្ចប្រជុំនោះ បណ្ដឹងសាទុក្ខនឹងមិនត្រូវបានដោះស្រាយដោយពេញចិត្តទេ <u>បណ្ដឹងជាលាយលក្ខណ៍អក្សរនឹងត្រូវដាក់ជូន អ្នកសម្របសម្រួល/មន្ត្រី</u>សមស្រប ដែលក្នុងរយៈពេលដប់ (10) ថ្ងៃសិក្សាបន្ទាប់ពីនោះ មកជួបក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីដោះស្រាយបណ្ដឹងសាទុក្ខ។

*អ្នកសម្របសម្រួល/មន្ត្រីដែលបានជ្រើសតាំង*

ចំណងជើង IX Alice Brown-LeGrand ជំនួយការអគ្គនាយកសម្រាប់សេវាកម្មគាំទ្រសិស្ស (978) 674-4334

ចំណងជើងទី II Alice Brown-LeGrand, ជំនួយការអគ្គនាយកសម្រាប់សេវាកម្មគាំទ្រសិស្ស (978) 674-4334

អ្នកសម្របសម្រួលថ្នាក់ស្រុក 504, Alice Brown-LeGrand, ជំនួយការអគ្គនាយកសម្រាប់សេវាកម្មគាំទ្រសិស្ស (978) 674-4334

កម្រិត 3៖ ប្រសិនបើនៅចុងបញ្ចប់នៃដប់ (10) ថ្ងៃសិក្សាបន្ទាប់ពីកិច្ចប្រជុំ បណ្ដឹងសាទុក្ខមិនត្រូវបានដោះស្រាយតាមការចង់បានរបស់ដើមបណ្ដឹងទេ ដើមបណ្ដឹងអាចបញ្ជូន <u>បណ្ដឹងសាទុក្ខជាលាយលក្ខណ៍អក្សរទៅកាន់</u> <u>អគ្គនាយកសាលា</u> ដែលក្នុងរយៈពេលដប់ (10) ថ្ងៃសិក្សា បន្ទាប់មកជួបក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីដោះស្រាយបណ្ដឹងសាទុក្ខ។

កម្រិត 4៖ ប្រសិនបើនៅចុងបញ្ចប់នៃដប់ (10) ថ្ងៃសិក្សាបន្ទាប់ពីកិច្ចប្រជុំជាមួយអគ្គនាយកសាលា បណ្ដឹងសាទុក្ខមិនបានដោះស្រាយតាមការចង់បានរបស់ដើមបណ្ដឹង ដើមបណ្ដឹងអាចបញ្ជូនបណ្ដឹងសាទុក្ខជាលាយលក្ខណ៍អក្សរទៅកាន់គណៈកម្មាធិការសាលា។

លើសពីនេះ ដើមបណ្ដឹងមានសេរីភាពក្នុងការបន្តសិទ្ធិរបស់ខ្លួនជាមួយទីភ្នាក់ងាររដ្ឋសមស្រប ឬតុលាការ/ស្ថាប័នរដ្ឋបាល ដែលនឹងមានយុត្តាធិការ រួមទាំងប៉ុន្តែមិនកំណត់ត្រឹមចំពោះខាងក្រោម៖

ការិយាល័យអប់រំពិសេសនៃរដ្ឋ Massachusetts ផ្នែកបណ្ដឹងឧទ្ធរណ៍ច្បាប់រដ្ឋបាល, 14 Summer Street, 4th Floor, Malden, MA 02148, ទូរសព្ទ (781) 397-4755 ទូរសារ (781) 397-4770។

នាយកដ្ឋានអប់រំបឋមសិក្សា និងមធ្យមសិក្សារដ្ឋ Massachusetts, ប្រព័ន្ធដំណោះស្រាយកម្មវិធី, 135 Santilli Highway, Everett, MA 02149, ទូរស័ព្ទ (781) 338-37000: ទូរសារ (781)- 338-3710: TTY: បញ្ជូនត (800)-439-2370។ អ៊ីម៉ែល: compliance@doe.mass.edu

ក្រសួងកម្មវិធីអប់រំនៃរដ្ឋ Massachusetts, សេចក្ដីសម្រេចកម្មវិធី, 75 Pleasant Street, Malden MA 02148, ទូរសព្ទ (781) 338-3000 ទូរសព្ទ (781) 338-3710, TTY សេវាបញ្ជូនបន្ត (800) 439-2370។

ក្រសួងអប់រំនៃសហរដ្ឋអាមេរិក ការិយាល័យសិទ្ធិស៊ីវិល ក្រសួងអប់រំ 5 Post Office Square, 8th Floor, Boston, Massachusetts 02109

ទូរសព្ទ (617) 289-0012 ទូរសារ (617) 289-0150, TTD (877) 521-2172.

គ្មានអ្វីហាមឃាត់ដើមបណ្ដឹងមិនឲ្យបន្តចាត់ការវត្តមានៗនៅចំពោះមុខតុលាការ
ឬទីភ្នាក់ងាររដ្ឋបាលដែលមានយុត្តាធិការសមស្របនោះឡើយ។

## ការបង្ខំធ្វើបាបៈ និយមន័យ និងលក្ខខណ្ឌតម្រូវផ្លូវច្បាប់

**ការល្មើសពាក់ព័ន្ធនឹងការបង្ខំធ្វើបាប—និយមន័យ និងទោសទណ្ឌ**

ពាក្យ "ការការបង្ខំធ្វើបាប" ដូចដែលបានប្រើនៅក្នុងផ្នែកនេះសំដៅលើទង្វើ ឬវិធីសាស្ត្រនៃការចាប់ផ្តើមនៅក្នុងអង្គភាពសិស្សនិស្សិតណាមួយ មិនថានៅលើអចលនទ្រព្យសាធារណៈ ឬឯកជន ដែលបង្កគ្រោះថ្នាក់ដោយចេតនា ឬដោយចេតនាដល់សុខភាពផ្លូវកាយ ឬផ្លូវចិត្តរបស់សិស្ស ឬមនុស្សផ្សេងទៀត។ ទង្វើបែបនេះរួមមានការវាយដំ ការទាត់ធាក់ ការបង្កើតស្លាកយីហោ ការបង្ខំឱ្យហាត់ប្រាណ ការប្រឈមនឹងអាកាសធាតុ ការបង្ខំឱ្យទទួលទានអាហារ ស្រា ភេសជ្ជៈ គ្រឿងញៀន ឬសារធាតុផ្សេងទៀត ឬការប្រព្រឹត្តដ៏ឃោរឃៅផ្សេងទៀត ឬសកម្មភាពរាងកាយដោយបង្ខំ ដែលទំនងជាធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់សុខភាពផ្លូវកាយ ឬសុវត្ថិភាពរបស់សិស្ស ឬមនុស្សផ្សេងទៀត ឬដែលធ្វើឲ្យសិស្សនោះ ឬមនុស្សផ្សេងទៀតមានភាពតានតឹងផ្លូវចិត្តខ្លាំង រួមទាំងការអត់គេង ឬសម្រាករយៈពេលយូរ ឬការនៅដាច់ដោយឡែករយៈពេលយូរ។ (ច្បាប់ទូទៅរដ្ឋ Massachusetts ជំពូកទី 269 ផ្នែក 17)

**កាតព្វកិច្ចរាយការណ៍ពីការការបង្ខំធ្វើបាប**

អ្នកណាក៏ដោយដែលដឹងថាបុគ្គលម្នាក់ទៀតជាជនរងគ្រោះនៃការបង្ខំធ្វើបាបដូចដែលបានកំណត់និយមន័យ ហើយស្ថិតនៅកន្លែងកើតហេតុនៃសកម្មភាពនោះ (ក្នុងករណីដែលបុគ្គលនោះអាចធ្វើដូច្នេះបានដោយគ្មានគ្រោះថ្នាក់ ឬហានិភ័យដល់ខ្លួនឯង និងអ្នកដទៃ) ត្រូវរាយការណ៍ពីសកម្មភាពនោះឱ្យបានឆាប់ទៅកាន់នាយកសាលា ជំនួយការនាយកសាលា ឬបុគ្គលិកសាលា។

## គោលនយោបាយស្តីពីការប្រើប្រាស់គ្រឿងស្រវឹង គ្រឿងជក់ និងគ្រឿងញៀន

នាយកដ្ឋានសាលា Lowell ទទួលស្គាល់ទំនួលខុសត្រូវចំពោះមុខច្បាប់ និងសង្គមក្នុងការបង្កើតគោលនយោបាយ និងជំរុញសកម្មភាពរដ្ឋបាលដែលលើកកម្ពស់បរិយាកាសសាលារៀនគ្មានការប្រើប្រាស់ ការកាន់កាប់ ឬការចែកចាយគ្រឿងស្រវឹង ថ្នាំជក់ បារី វ៉េប /បារីអេឡិចត្រូនិក និង/ឬសារធាតុដែលមានការគ្រប់គ្រង។

សាលារដ្ឋ Lowell ទទួលស្គាល់ថា ការប្រើប្រាស់សារធាតុញៀនគឺជាជំងឺដែលប៉ះពាល់ដល់សុខភាព ការអប់រំ និងសក្តានុពលថ្ងៃប្រឌិតរបស់ភាគីដែលរងផលប៉ះពាល់ទាំងអស់ ហើយរាល់ការខិតខំប្រឹងប្រែងនឹងត្រូវធ្វើឡើងដើម្បីកំណត់បញ្ហាដែលអាចកើតមាន និងបន្ត ហើយផ្តល់អន្តរាគមន៍តាមការយល់ឃើញសមស្រប។ ពោលគឺនាយកដ្ឋានសាលា Lowell នឹងផ្តល់ជំនួយដល់សិស្សណាម្នាក់ដែលស្ម័គ្រចិត្តស្វែងរកដំបូន្មាន ឬការព្យាបាលផ្តាច់គ្រឿងស្រវឹង ថ្នាំជក់។ ការស្វែងរកជំនួយដោយស្ម័គ្រចិត្តមិននិរាករណ៍ទំនួលខុសត្រូវរបស់សិស្សនៅក្រោមគោលនយោបាយណាមួយរបស់នាយកដ្ឋានសាលា Lowell ទេ។

បុគ្គលិកត្រូវចាត់វិធានការដូចខាងក្រោមទាក់ទងនឹងសិស្សដែលស្វែងរកព័ត៌មាន ឬជំនួយទាក់ទងនឹងគ្រឿងស្រវឹង ថ្នាំជក់ ឬការប្រើប្រាស់គ្រឿងញៀន មុនពេលមានការរំលោភលើគោលនយោបាយរបស់នាយកដ្ឋានសាលា Lowell៖

a. ពិចារណាភ្លាមៗនូវមធ្យោបាយដ៏ល្អបំផុតដែលអាចមានក្នុងការគាំទ្រសិស្សរួមទាំងការទទួលបានបុគ្គលិកសាលា ធនធានឯកជន និង/ឬធនធានសហគមន៍សមស្រប។ ប្រព័ន្ធសាលារៀនមិនអាចទទួលខុសត្រូវលើការចំណាយណាមួយសម្រាប់ជំនួយឯកជន ឬការសម្រាកព្យាបាលនៅមន្ទីរពេទ្យបានទេ។
b. ឲ្យមាតាបិតាចូលរួមគាំទ្រសិស្សឱ្យបានឆាប់តាមដែលយល់ឃើញថាសមស្រប។
c. ផ្តល់ឱ្យសិស្សដែលស្វែងរកជំនួយ ឬការព្យាបាលដោយស្ម័គ្រចិត្តនូវឱកាសធ្វើកិច្ចសាលាសង។

នាយកដ្ឋានសាលា Lowell ទទួលស្គាល់តម្រូវការក្នុងការផ្តល់តុល្យភាពរវាងការផ្តល់សេវាប្រឹក្សាគាំទ្រដល់សិស្សទាំងនោះដែលមានបញ្ហាគ្រឿងស្រវឹង ថ្នាំជក់ ឬគ្រឿងញៀន ព្រមទាំងការដោះស្រាយបញ្ហាវិន័យផងដែរ។

គោលការណ៍របស់នាយកដ្ឋានសាលា Lowell ចែងថា មិនថាបរិមាណកម្រិតណាក៏ដោយ

សិស្សមិនត្រូវប្រើប្រាស់/ប្រើ កាន់កាប់ ទិញ/លក់ ស្ថិតក្រោមឥទ្ធិពល ឬចែកភេសជ្ជៈណាមួយដែលមានជាតិអាល់កុល ផលិតផលថ្នាំជក់ណាមួយ រួមទាំងវ៉េប/បារីអេឡិចត្រូនិក កញ្ឆា ថ្នាំស្តេរ៉ូអ៊ីត ឬសារធាតុ/គ្រឿងញៀនដែលមានការគ្រប់គ្រង ឬខុសច្បាប់ ឬមើលទៅដូចសារធាតុ/ថ្នាំញៀន ឱសថ/វេជ្ជបញ្ជា (ផ្ទុយពីគោលនយោបាយឱសថរបស់សាលារដ្ឋ Lowell) និង/ឬសារធាតុងាយនឹងបង្កជាហេតុនៅលើបរិវេណសាលារៀន និង/ឬមុន ឬអំឡុងពេលមានសកម្មភាព ឬព្រឹត្តិការណ៍ដែលសាលាឧបត្ថម្ភ ឬពាក់ព័ន្ធនឹងសាលា។ សកម្មភាពបែបនេះអាចបណ្តាលឲ្យមានការរារាំងសិស្សមិនឲ្យចូលរួមសកម្មភាព និងព្រឹត្តិការណ៍នានារបស់សាលា និង/ឬក៏អាចបណ្តាលឱ្យមានចំណាត់ការដាក់វិន័យបន្ថែមទៀត រួមទាំង ប៉ុន្តែមិនកំណត់ត្រឹមចំពោះ ការបណ្តេញចេញពីសាលារដ្ឋ Lowell នោះទេ។

បុគ្គលិកត្រូវចាត់វិធានការដូចខាងក្រោមលើសិស្សណាក៏ដោយដែលបំពានគោលនយោបាយនេះ៖

a. បុគ្គលិកណាម្នាក់នៃនាយកដ្ឋានសាលា រួមទាំងអ្នកផ្តល់សេវាជាប់កិច្ចសន្យា និងបុគ្គលិករបស់ពួកគេនឹងរាយការណ៍ពីការបំពានណាមួយលើគោលនយោបាយរបស់នាយកដ្ឋានសាលា Lowell ទាក់ទងនឹងគ្រឿងស្រវឹង ថ្នាំជក់ និងគ្រឿងញៀនទៅកាន់នាយកសាលា ឬអ្នកទទួលសិទ្ធិ។
b. នាយកសាលា ឬអ្នកទទួលសិទ្ធិនឹងស៊ើបអង្កេតការចោទប្រកាន់ស្របតាមគោលនយោបាយ និងគោលការណ៍ណែនាំរបស់នាយកដ្ឋានសាលា Lowell ហើយចាត់វិធានការសមស្រប (ដែលអាចរួមបញ្ចូល ប៉ុន្តែមិនកំណត់ត្រឹមចំពោះ វិន័យ និង/ឬជម្រើសផ្សេងទៀតចំពោះចំណាត់ការដាក់វិន័យ) ស្របតាមគោលនយោបាយ និងគោលការណ៍ណែនាំខាងលើ រួមទាំង ប៉ុន្តែមិនកំណត់ត្រឹមចំពោះ ការទាក់ទងមាតាបិតារបស់សិស្សជាដើម។
c. សារធាតុណាមួយដែលរឹបអូសដោយសារល្មើសគោលនយោបាយនេះនឹងត្រូវបានរឹបអូស ហើយប៉ូលិសនឹងត្រូវបានជូនដំណឹង។ ការល្មើសគោលនយោបាយនេះអាចជាអំពើឧក្រិដ្ឋ។
d. នៅពេលសមស្រប នាយកដ្ឋានសាលា Lowell ក៏អាចជូនដំណឹងដល់ក្រសួងកុមារ និងគ្រួសារផងដែរ។ នាយកដ្ឋានសាលា Lowell ក៏រក្សាសិទ្ធិរបស់ខ្លួនក្នុងការចាត់វិធានការផ្លូវច្បាប់ស្របតាមច្បាប់រដ្ឋ និងសហព័ន្ធ ចំពោះការល្មើសគោលនយោបាយនេះផងដែរ។
e. នាយកដ្ឋានសាលា Lowell នឹងសហការជាមួយភ្នាក់ងារអនុវត្តច្បាប់ ដើម្បីធានាថាសកម្មភាពខុសច្បាប់របស់សិស្ស និងអ្នកផ្សេងទៀតត្រូវបានបង្អាក់នៅក្នុង និងជុំវិញសាលារៀនទាំងអស់។

f. នាយកដ្ឋានសាលា Lowell នឹងអនុវត្តតាមគោលនយោបាយនេះដោយមានការពិចារណាគ្រប់ជ្រុងជ្រោយចំពោះសិទ្ធិស្របច្បាប់របស់សិស្សដែលពាក់ព័ន្ធ និងសិទ្ធិ និងសុវត្ថិភាពនៃសហគមន៍សាលា។
g. នាយកសាលា ឬអ្នកទទួលសិទ្ធិនឹងផ្តល់ជំនួយដល់សិស្សដែលស្ម័គ្រចិត្តស្វែងរកដំបូន្មាន ឬការព្យាបាលផ្តាច់គ្រឿងស្រវឹង ថ្នាំជក់ឬគ្រឿង។

## ការបង្រៀនអំពីគ្រឿងស្រវឹង ថ្នាំជក់ និងគ្រឿងញៀន

អនុលោមតាមច្បាប់រដ្ឋ និងសហព័ន្ធ សាលារដ្ឋ Lowell ត្រូវផ្តល់កម្មវិធីអប់រំស្តីពីការទប់ស្កាត់គ្រឿងញៀន គ្រឿងស្រវឹង ថ្នាំជក់ទៅតាមវ័យ ការអភិវឌ្ឍសមស្របនិងផ្អែកលើតាមភស្តុតាងនៅថ្នាក់មត្តេយ្យរហូតដល់ថ្នាក់ទី 12។

កម្មវិធីទប់ស្កាត់គ្រឿងស្រវឹង ថ្នាំជក់ និងគ្រឿងញៀនត្រូវបង្កើនការយល់ដឹងរបស់សិស្សអំពីផលវិបាកផ្នែកច្បាប់ សង្គម និងសុខភាពដោយសារការប្រើប្រាស់គ្រឿងស្រវឹង ថ្នាំជក់ និងគ្រឿងញៀន។ កម្មវិធីនេះក៏ត្រូវរួមបញ្ចូលការណែនាំអំពីផលប៉ះពាល់នៃគ្រឿងស្រវឹង ថ្នាំជក់ និងគ្រឿងញៀនលើប្រព័ន្ធខ្លួនប្រាណមនុស្ស អារម្មណ៍ ផ្លូវចិត្ត និងគ្រោះថ្នាក់នៃការប្រើប្រាស់បែបនេះ ដោយសង្កត់ធ្ងន់លើការមិនប្រើប្រាស់ដោយកុមារក្នុងវ័យសិក្សា និងព័ត៌មានអំពីបច្ចេកទេសប្រកបដោយប្រសិទ្ធភាព និងការអភិវឌ្ឍជំនាញសម្រាប់ការពន្យារពេល និងចៀសវាងការប្រើប្រាស់សារធាតុ ក៏ដូចជាជំនាញសម្រាប់ដោះស្រាយ និង/ឬចៀសវាងសម្ពាធពីមិត្តភក្តិក្នុងការប្រើប្រាស់គ្រឿងស្រវឹង ថ្នាំជក់ និង/ឬគ្រឿងញៀនផងដែរ។

គោលបំណងនៃកម្មវិធីនេះ ដូចមានចែងខាងក្រោម ត្រូវបានចាក់ឫសក្នុងជំនឿរបស់គណៈកម្មាធិការសាលា Lowell ដែលថាការទប់ស្កាត់ទាមទារឱ្យមានការអប់រំ ហើយថាទិដ្ឋភាពសំខាន់បំផុតនៃគោលនយោបាយ និងគោលការណ៍ណែនាំរបស់មណ្ឌលសិក្សាគួរតែជាការអប់រំរបស់សិស្សម្នាក់ៗអំពីគ្រោះថ្នាក់ និងផលវិបាកដោយសារការប្រើប្រាស់គ្រឿងស្រវឹង ថ្នាំជក់ និងគ្រឿងញៀន ក្នុងពេលដំណាលគ្នានេះក៏អភិវឌ្ឍសមត្ថភាព និងជំនាញរបស់សិស្សដើម្បីធ្វើការសម្រេចចិត្តល្អ៖

- ដើម្បីទប់ស្កាត់ ពន្យារពេល និង/ឬកាត់បន្ថយការប្រើប្រាស់គ្រឿងស្រវឹង ថ្នាំជក់ និងគ្រឿងញៀនក្នុងចំណោមកុមារ និងយុវជន។
- ដើម្បីបង្កើតការយល់ដឹងអំពី និង/ឬបង្កើនការយល់ដឹងរបស់សិស្សអំពីផលវិបាកផ្នែកច្បាប់ សង្គម និងសុខភាពដោយសារការប្រើប្រាស់គ្រឿងស្រវឹង ថ្នាំជក់ និងគ្រឿងញៀន។
- ដើម្បីបង្កើតការយល់ដឹងអំពី និង/ឬបង្កើនការយល់ដឹងរបស់សិស្សអំពីបញ្ហាផ្ទាល់ខ្លួន សង្គម

និងសេដ្ឋកិច្ចដែលបណ្តាលមកពីការសេពគ្រឿងស្រវឹង ថ្នាំជក់ និងគ្រឿងញៀន។

- ដើម្បីបង្រៀនសិស្សនូវជំនាញគ្រប់គ្រងខ្លួនឯង ជំនាញសង្គមកិច្ច ជំនាញចរចា និងជំនាញបដិសេធ ដើម្បីជួយពួកគេធ្វើការសម្រេចចិត្តល្អ និងឆ្លាតវៃ អភិវឌ្ឍសេចក្តីក្លាហានដើម្បីឈរលើការជឿជាក់ និងចៀសវាងសម្ពាធពីមិត្តភក្តិ ដែលជាហេតុចៀសវាងការប្រើប្រាស់គ្រឿងស្រវឹង ថ្នាំជក់ និង/ឬគ្រឿងញៀនបាន។

កម្មវិធីសិក្សា និងសម្ភារបង្រៀនដែលប្រើប្រាស់ក្នុងកម្មវិធីនេះ នឹងត្រូវបានណែនាំដោយអគ្គនាយក និងអនុម័តដោយគណៈកម្មាធិការសាលា។

គោលនយោបាយនេះត្រូវបង្ហោះនៅលើគេហទំព័ររបស់មណ្ឌលសិក្សាធិការ ហើយសេចក្តីជូនដំណឹងត្រូវផ្តល់ជូនសិស្ស និងមាតាបិតាទាំងអស់ស្របតាមច្បាប់របស់រដ្ឋ។ លើសពីនេះ មណ្ឌលសិក្សាធិការត្រូវតម្កល់ច្បាប់ចម្លងនៃគោលនយោបាយនេះនៅ DESE ស្របតាមច្បាប់ និងតាមលក្ខណៈដែលបានស្នើសុំដោយ DESE។

# អង្គភាពសុខាភិបាលសាលា

**ឯកសារណែនាំមាតាបិតា/អាណាព្យាបាលអំពីក្រសួងសុខាភិបាល Lowell៖**

គិលានុបដ្ឋាកសាលាគឺជាជនទំនាក់ទំនងរវាងគ្រួសារសិស្ស និងសាលារៀនទាក់ទងនឹងបញ្ហាសុខភាព និងដើម្បីបម្រើជាធនធានសុខភាពសម្រាប់អ្នក និងកូនរបស់អ្នក។ គិលានុបដ្ឋាកសាលាបញ្ចប់ការពិនិត្យតាមកាតព្វកិច្ចរបស់រដ្ឋ និងផ្ដល់ការថែទាំថែទាំសម្រាប់ជំងឺ ឬគ្រោះថ្នាក់។ គិលានុបដ្ឋាកសាលាលើកកម្ពស់សុខុមាលភាព និងជួយក្នុងការរក្សាបរិយាកាសដែលមានសុខភាពល្អ និងមានសុវត្ថិភាពសម្រាប់សិស្ស និងបុគ្គលិក។ សូមទាក់ទងគិលានុបដ្ឋាកសាលារបស់អ្នកជាមួយនឹងបញ្ហា ឬសំណួរអំពីសុខភាពផ្សេងៗ។

**ទម្រង់បែបបទសង្គ្រោះបន្ទាន់ផ្នែកវេជ្ជសាស្ត្រ៖**

ទម្រង់បែបបទសង្គ្រោះបន្ទាន់ផ្នែកវេជ្ជសាស្ត្រត្រូវតែបំពេញ ហើយប្រគល់ជូនវិញដល់គិលានុបដ្ឋាកសាលា។ ទម្រង់បែបបទនេះផ្ដល់ព័ត៌មានអំពីរបៀបទាក់ទងមាតាបិតាក្នុងករណីមានអាសន្ន និងផ្ដល់ព័ត៌មានសុខភាពថ្មីៗអំពីកូនរបស់អ្នកពីមួយឆ្នាំទៅមួយឆ្នាំ។

ជូនដំណឹងដល់គិលានុបដ្ឋាកសាលាអំពីការផ្លាស់ប្ដូរព័ត៌មានទំនាក់ទំនងបន្ទាន់ ឬស្ថានភាពសុខភាពក្នុងអំឡុងឆ្នាំសិក្សា។ នៅក្នុងករណីមានតម្រូវការស្នើសុំការដឹកជញ្ជូនផ្នែកវេជ្ជសាស្ត្រ រាល់ការប៉ុនប៉ងនឹងធ្វើឡើងដើម្បីផ្ញើច្បាប់ចម្លងនៃទម្រង់បែបបទនេះ។ **សូមចងចាំថា ក្នុងករណីមានឧបទ្ទវហេតុ ឬជំងឺ សាលាត្រូវតែអាចទៅមាតាបិតា ឬអ្នកផ្សេងទៀតដែលនឹងទទួលខុសត្រូវចំពោះសិស្ស។**

**អាសន្នផ្នែកសុខភាព៖**

សូមជូនដំណឹងដល់គិលានុបដ្ឋាកសាលាអំពីស្ថានភាពវេជ្ជសាស្ត្រដែលអាចបង្កជាស្ថានភាពអាសន្នសម្រាប់កូនរបស់អ្នក (ឧ. ប្រតិកម្មចំពោះអាហារ សត្វល្អិតខាំ ឬថ្នាំពេទ្យ ជំងឺហឺត ទឹកនោមផ្អែម ប្រកាច់)។ គិលានុបដ្ឋាកសាលានឹងសហការជាមួយអ្នកដើម្បីបង្កើតផែនការថែទាំ ដើម្បីបំពេញតម្រូវការថែទាំសុខភាពរបស់កូនអ្នក។

**ជំងឺ៖**

កុមារ**ត្រូវតែនៅផ្ទះ** ប្រសិនបើពួកគេមានជំងឺដូចខាងក្រោម៖

- ជំងឺឆ្លងដូចជាជំងឺអុតស្វាយ គ្រុនផ្តាសាយ ឬរលាកបំពង់ក រហូតដល់វេជ្ជបណ្ឌិត ឬមន្ត្រីក្រសួងសុខាភិបាលសាធារណៈនិយាយថាមានសុវត្ថិភាពក្នុងការត្រលប់មកសាលាវិញបាន ឬកុមារបានលេបថ្នាំអង់ទីប៊ីយោទិចរយៈពេល 24 ម៉ោង។
- កន្ទួល ឬជំងឺស្បែកដែលមិនត្រូវបានធ្វើរោគវិនិច្ឆ័យដោយវេជ្ជបណ្ឌិត
- គ្រុនក្តៅដែលបណ្តាលឱ្យញាក់ បែកញើស ឬឈឺសាច់ដុំ
- កម្តៅខ្លួនលើសពី 100.0 ក្នុងរយៈពេល 24 ម៉ោងកន្លងមក
- ក្អួត/រាកក្នុងរយៈពេល 24 ម៉ោងកន្លងមក
- កើតចៃលើក្បាល
- ការជូនដំណឹងដោយគិលានុបដ្ឋាកសាលា/ក្រសួងសុខាភិបាលថា ការចាក់វ៉ាក់សាំងមិនទាន់មានថ្មី។ (សេចក្តីជូនដំណឹងអំពីការលើកលែង)

**គោលការណ៍ណែនាំអំពីវត្តមាននៅសាលាក្រោយមានជំងឺ៖**

កុមារត្រូវតែ**មិនមានគ្រុនក្តៅ** ដោយមិនលេបថ្នាំ និង**មិនមានរោគសញ្ញា** សម្រាប់រយៈពេល 24 ម៉ោងមុនពេលត្រលប់ទៅសាលារៀនវិញ។ យោងតាមគោលការណ៍ណែនាំរបស់ក្រសួងសុខាភិបាល កុមារដែលបានធ្វើរោគវិនិច្ឆ័យថាមានជំងឺរលាកបំពង់ក ជំងឺរលាកស្បែក ឬជំងឺភ្នែកក្រហមតម្រូវឱ្យប្រើប្រាស់ថ្នាំរយៈពេល 24 ម៉ោង មុនពេលត្រលប់ទៅសាលារៀនវិញ។

**លក្ខខណ្ឌតម្រូវនៃការចាក់វ៉ាក់សាំង/ធ្វើតេស្តមន្ទីរពិសោធន៍៖**

ច្បាប់ស្តីពីការចាក់វ៉ាក់សាំងនៅសាលា ជំពូកទី 76 ផ្នែកទី 15 នៃច្បាប់ទូទៅនៃរដ្ឋ Massachusetts តម្រូវថា វ៉ាក់សាំងចាក់ទាំងអស់ត្រូវតែថ្មីដើម្បីឱ្យកុមារអាចចូលសាលាស្របតាមបទប្បញ្ញត្តិរបស់ក្រសួងសុខាភិបាលសាធារណៈរដ្ឋ Massachusetts។ ច្បាប់ទូទៅរបស់រដ្ឋ Massachusetts អនុញ្ញាតឱ្យមណ្ឌលសិក្សាធិការដកកុមារណាម្នាក់ចេញពីសាលារៀន ដែលមិនបានចាក់វ៉ាក់សាំងថ្មី។

- ឯកសារបញ្ជាក់អំពីការចាក់វ៉ាក់សាំងពីគ្រូពេទ្យរបស់កូនអ្នកត្រូវបានទាមទារដើម្បីទទួលបានការអនុញ្ញាតឱ្យចូលសាលា
- កំណត់ត្រាចាក់វ៉ាក់សាំងទាំងអស់ត្រូវតែផ្តល់ជាភាសាអង់គ្លេស និងរួមបញ្ចូលកាលបរិច្ឆេទពេញទាំងអស់។
- ការចាក់វ៉ាក់សាំងត្រូវបានពិនិត្យដោយគិលានុបដ្ឋាកសាលា។ នៅក្នុងករណីខ្វះព័ត៌មាន ឬព័ត៌មានមិនត្រឹមត្រូវ ការយកចិត្តទុកដាក់ភ្លាមៗរបស់អ្នកក្នុងការដោះស្រាយកំហុស/ការខ្វះគឺជាការចាំបាច់ដើម្បីធានាការអនុលោមតាមច្បាប់រដ្ឋ។
- **លក្ខខណ្ឌតម្រូវចូលថ្នាក់ត្រៀមមត្តេយ្យ៖**

  4 ដូសវ៉ាក់សាំងរោគខាន់ស្លាក់ តេតាណូស ក្អកមាន់ (Dtap/DTP), 3 ដូសជំងឺស្វិតដៃជើង, 3 ដូសជំងឺរលាកថ្លើមប្រភេទ B, 1 ដូសកញ្ជ្រឹល ស្រឡទែន និងកញ្ជ្រឹលស្រាល (MMR), 4 ដូស Hib, 1 ដូសជំងឺអុតស្វាយ ឬកំណត់ត្រាគ្រូពេទ្យអំពីករណីជំងឺអុតស្វាយ, ការធ្វើតេស្តរកសំណ 1

- **លក្ខខណ្ឌតម្រូវចូលសាលាមត្តេយ្យ៖**

  5 ដូសវ៉ាក់សាំងរោគខាន់ស្លាក់ តេតាណូស ក្អកមាន់ (Dtap/DTP), 4 ដូសជំងឺស្វិតដៃជើង (**1 បន្ទាប់ពីថ្ងៃខួបកំណើតគម្រប់ [4] ខួប), 3 ដូសជំងឺរលាកថ្លើមប្រភេទ B,

  2 ដូសកញ្ជ្រឹល ស្រឡទែន និងកញ្ជ្រឹលស្រាល (MMR), 2 ដូសជំងឺអ៊ុតស្វាយ ឬ កំណត់ត្រាគ្រូពេទ្យអំពីករណីជំងឺអុតស្វាយ,

  ការធ្វើតេស្តរកសំណ 1

- **លក្ខខណ្ឌតម្រូវចូលរៀនថ្នាក់ទី 1-6៖**

  5 ដូសវ៉ាក់សាំងរោគខាន់ស្លាក់ តេតាណូស ក្អកមាន់ (Dtap/DTP), 4 ដូសជំងឺស្វិតដៃជើង, 3 ដូសជំងឺរលាកថ្លើមប្រភេទ B; 2 ដូសកញ្ជ្រឹល ស្រឡទែន និងកញ្ជ្រឹលស្រាល (MMR), 2 ដូសជំងឺអ៊ុតស្វាយ ឬកំណត់ត្រាគ្រូពេទ្យអំពីករណីជំងឺអុតស្វាយសម្រាប់គ្រប់ថ្នាក់។

- **លក្ខខណ្ឌតម្រូវចូលរៀនថ្នាក់ទី 7-12៖**

    ស៊េរីដូសសម្រាប់កុមារ និង 1 ដូសវ៉ាក់សាំងរោគខាន់ស្លាក់ តេតាណូស ក្អកមាន់ (Tdap), 1 ដូសវ៉ាក់សាំងការពារជំងឺរលាកស្រោមខួរ (MenACWY) ដែលត្រូវការសម្រាប់ថ្នាក់ទី 7 ដល់ទី 10 និងដូសទីពីរ (2) សម្រាប់ថ្នាក់ទី 11 និង 12 (នៅ ឬក្រោយថ្ងៃកំណើតទី 16)។

**គោលនយោបាយស្តីពីថ្នាំពេទ្យ៖**

ថ្នាំពេទ្យ (ទាំងមានវេជ្ជបញ្ជា និងគ្មានវេជ្ជបញ្ជា) មិនគួរលេបក្នុងអំឡុងពេលម៉ោងសិក្សាទេ ប្រសិនបើអាចសូមលេបថ្នាំនៅផ្ទះ។ ថ្នាំដែលត្រូវលេបបី (3) ដងក្នុងមួយថ្ងៃអាចផ្តល់ឱ្យនៅផ្ទះមុនពេលចូលរៀន ក្រោយចេញពីសាលា បន្ទាប់ពីចូលគេង។

**វេជ្ជបញ្ជារបស់គ្រូពេទ្យចេញវេជ្ជបញ្ជាត្រូវបានទាមទារសម្រាប់ថ្នាំមានវេជ្ជបញ្ជា និងគ្មានវេជ្ជបញ្ជា(មិនមានសំបុត្រពេទ្យ)ទាំងអស់។**

ដើម្បីធានាសុវត្ថិភាពកូនអ្នក ថ្នាំទាំងអស់ត្រូវដឹកបញ្ជូនដល់សាលា៖

- នៅក្នុង*ប្រអប់បិទស្លាកឱសថស្ថាន*

    សុំឱ្យឱសថស្ថានផ្តល់ដបថ្នាំដាច់ដោយឡែកសម្រាប់ផ្ទះ និងសាលារៀន

- ដោយឪពុកម្តាយ/អាណាព្យាបាលមនុស្សពេញវ័យ **មិនមែនពីកុមារ**

**ថ្នាំពេទ្យនឹងត្រូវទទួលយក<u>តែ</u>នៅក្នុងប្រអប់បិទស្លាកឱសថស្ថានប៉ុណ្ណោះ។**

***ក្នុងករណីមានការពន្យារពេលបើកសាលា***
**ថ្នាំពេទ្យដែលបានកំណត់ពេលសម្រាប់ម៉ោងចាប់ផ្តើមធម្មតានឹងមិនត្រូវបានឲ្យលេបទេ។**

ថ្នាំទាំងអស់ដែលត្រូវលេបក្នុងម៉ោងសិក្សា មិនថារយៈពេលវែង ឬរយៈពេលខ្លី តម្រូវឲ្យមានទម្រង់បែបបទដូចខាងក្រោមដាក់ក្នុងការិយាល័យសុខភាពសាលា មុនពេលថ្នាំណាមួយអាចឲ្យលេបនៅសាលា៖

- វេជ្ជបញ្ជាថ្នាំបច្ចុប្បន្ន ចុះហត្ថលេខា និងចុះកាលបរិច្ឆេទដោយគ្រូពេទ្យចេញវេជ្ជបញ្ជា
- ចុះហត្ថលេខា និងបានបំពេញការយល់ព្រមពីមាតាបិតា និងផែនការគ្រប់គ្រងថ្នាំពេទ្យ
- រូបថតបច្ចុប្បន្នរបស់សិស្សសម្រាប់គោលបំណងកំណត់អត្តសញ្ញាណ
- ថ្នាំពេទ្យនឹងត្រូវបានរាប់ដោយគិលានុបដ្ឋាកនៅចំពោះមុខមាតាបិតា/អាណាព្យាបាល/មនុស្សពេញវ័យដែលទទួលខុសត្រូវ ហើយបានចុះហត្ថលេខាលើកំណត់ហេតុថ្នាំពេទ្យ។

យោងតាមច្បាប់ស្តីពីការអនុវត្តគិលានុបដ្ឋាក និងគោលនយោបាយរបស់ក្រសួងសុខាភិបាល គិលានុបដ្ឋាកមិនត្រូវបានអនុញ្ញាតឱ្យទទួលវេជ្ជបញ្ជាពីអ្នកមិនមានអាជ្ញាបណ្ណ (ឪពុកម្តាយ ឬអាណាព្យាបាល) ឡើយ។ នេះអនុវត្តចំពោះថ្នាំពេទ្យមានវេជ្ជបញ្ជា ឬគ្មានវេជ្ជបញ្ជាទាំងអស់។

**ការទៅយកថ្នាំពេទ្យ៖**

មាតាបិតា/អាណាព្យាបាលអាចទៅយកថ្នាំពេទ្យពីគិលានុបដ្ឋាកសាលា ហើយចុះហត្ថលេខាថ្នាំទាំងនេះនៅក្នុងកំណត់ហេតុថ្នាំពេទ្យ។ រាល់ថ្នាំពេទ្យដែលមិនបានប្រើ ឈប់ប្រើ ឬហួសកាលបរិច្ឆេទ ត្រូវតែទៅយកដោយមាតាបិតា/អាណាព្យាបាលនៅចុងបញ្ចប់នៃឆ្នាំសិក្សា បើមិនដូច្នោះទេ វានឹងត្រូវបោះចោល។

**លក្ខខណ្ឌតម្រូវពិនិត្យរាងកាយ៖**

ក្នុងរយៈពេល 1 ឆ្នាំមុនពេលចូលសាលារៀន ឬក្នុងរយៈពេល 30 ថ្ងៃបន្ទាប់ពីចូលសាលា។ ការពិនិត្យរាងកាយតម្រូវសម្រាប់ថ្នាក់ត្រៀមមត្តេយ្យ ថ្នាក់មត្តេយ្យ ថ្នាក់ទី 4, 7 និង 10។

**ការកើតចៃលើក្បាល៖**

## អនុលោមតាមគោលនយោបាយគ្មានចៃ

កុមារត្រូវតែត្រូវបានព្យាបាល គ្មានចៃ និងពិនិត្យដោយគិលានុបដ្ឋាកសាលា មុនពេលត្រូវបានអនុញ្ញាតឱ្យចូលរៀន។ ការបង្ការគឺជាគន្លឹះក្នុងការគ្រប់គ្រងបញ្ហាធុញទ្រាន់នេះ។ សូមពិនិត្យសក់របស់កូនអ្នកឱ្យបានញឹកញាប់ ហើយទូរសព្ទទៅគិលានុបដ្ឋាកសាលា ប្រសិនបើអ្នកមានចម្ងល់ផ្សេងៗ។

## កម្មវិធីពិនិត្យតាមការកំណត់៖

ការពិនិត្យភ្នែក ការស្តាប់ ការពិនិត្យឥរិយាបថ និង BMI នឹងធ្វើឡើងពេញមួយឆ្នាំសិក្សា។

**ប្រសិនបើអ្នកមិនចង់ឱ្យកូនរបស់អ្នកចូលរួមក្នុងការពិនិត្យភ្នែក ត្រចៀក ការពិនិត្យឥរិយាបថ ឬ BMI ទេ សូមជូនដំណឹងដល់គិលានុបដ្ឋាកជាលាយលក្ខណ៍អក្សរ។**

**ការពិនិត្យភ្នែក និងត្រចៀក៖ ការពិនិត្យភ្នែក៖** ឆ្នាំចូលរៀន ថ្នាក់មត្តេយ្យដល់ថ្នាក់ទី 5 ថ្នាក់ទី 7 និងទី 9។
**ការពិនិត្យត្រចៀក៖** ឆ្នាំចូលរៀន ថ្នាក់មត្តេយ្យដល់ថ្នាក់ទី 3 ថ្នាក់ទី 7 និងទី 9 ។
មាតាបិតា/អាណាព្យាបាលនឹងត្រូវបានជូនដំណឹងអំពីបញ្ហាណាមួយ
ដែលតម្រូវឱ្យមានការតាមដានសុខភាពជាចាំបាច់។
**ការពិនិត្យរាងកាយ៖** រដ្ឋ Massachusetts កំណត់ឱ្យសិស្សទាំងអស់នៅថ្នាក់ទី 5 ដល់ទី 9
ត្រូវធ្វើតេស្តពិនិត្យរកមើលជំងឺ ជំងឺខ្នងកោង។ មាតាបិតា/អាណាព្យាបាលនឹងត្រូវបានជូនដំណឹងអំពីបញ្ហាណាមួយ
ដែលតម្រូវឱ្យមានការតាមដានសុខភាពជាចាំបាច់។

**កម្ពស់ និងទម្ងន់៖** សិស្សត្រូវធ្វើតេស្តពិនិត្យនៅថ្នាក់ទី 1, 4, 7 និង 10 ដើម្បីគណនា BMI។
ព័ត៌មានត្រូវបានរក្សាទុកជាសម្ងាត់។

**SBIRT៖** (ការធ្វើតេស្តពិនិត្យ អន្តរាគមន៍លឿន និងការបញ្ជូនទៅព្យាបាល) នៅខែមីនា ឆ្នាំ 2016 នីតិប្បញ្ញត្តិនៃរដ្ឋ Massachusetts បានអនុម័តច្បាប់ទាក់ទងនឹងការប្រើប្រាស់សារធាតុញៀន ការព្យាបាល ការអប់រំ និងការបង្ការ (ច្បាប់ STEP) ដែលបង្ហាញពីលក្ខខណ្ឌតម្រូវសម្រាប់សាលារដ្ឋនៅក្នុងសហធនរដ្ឋនេះ ដើម្បីចូលរួមក្នុងការធ្វើតេស្តពិនិត្យរកសារធាតុញៀន និងអប់រំ។ ការធ្វើតេស្តពិនិត្យនេះធ្វើឡើងនៅថ្នាក់ទី 7 និងទី 9

នៅក្នុងសាលារដ្ឋ Lowell។ **ព័ត៌មានដែលមានលិខិតបដិសេធនឹងត្រូវបានផ្ញើទៅផ្ទះមុនធ្វើតេស្ត SBIRT។**

**លេខសំខាន់៖**

ការិយាល័យគិលានុបដ្ឋាក Freshman Academy៖ ទូរសព្ទ៖ 978-446-7356 ទូរសារ៖ 978-446-7011

ការិយាល័យគិលានុបដ្ឋាកវិទ្យាល័យ Lowell៖ ទូរសព្ទ៖ 978-937-8958 ទូរសារ៖ 978-275-6313

សុខភាពសហគមន៍ Lowell (ទីភ្នាក់ងារខាងក្រៅ)៖ ទូរសព្ទ៖ 978-458-6642

## ការអប់រំពិសេស

ច្បាប់ស្តីពីការអប់រំជនពិការ (IDEA) អនុវត្តចំពោះមនុស្សទាំងអស់ដែលមានអាយុពីបីឆ្នាំទៅម្ភៃពីរឆ្នាំ ដែលមិនទាន់បានបញ្ចប់ការសិក្សានៅវិទ្យាល័យ និងអ្នកដែលបំពេញបានតាមគោលការណ៍ណែនាំអំពីសិទ្ធិទទួលបានសេវាកម្មអប់រំពិសេស។ នៅពេលកំណត់អត្តសញ្ញាណសិស្សដែលសង្ស័យថាមានតម្រូវការពិសេស និងមានការបញ្ជូនបន្ត ដំណើរការកម្មវិធីសិក្សា នឹងចាប់ផ្តើម។ ប្រសិនបើសិស្សត្រូវបានកំណត់ថាមានសិទ្ធិទទួលបានសេវាកម្ម ផែនការអប់រំកម្មវិធីសិក្សា (IEP) ត្រូវបានរៀបចំឡើងដើម្បីបំពេញតាមតម្រូវការរបស់សិស្ស។

**នីតិវិធីទាក់ទងនឹងវិន័យសិស្សដែលមានតម្រូវការពិសេស ឬផែនការ 504**

គោលការណ៍ជាមូលដ្ឋាននៃផ្នែកនេះគឺថា សិស្សដែលមានតម្រូវការពិសេសមិនត្រូវទទួលបានការបដិសេធនូវសិទ្ធិទទួលបានកម្មវិធីអប់រំរបស់ពួកគេឡើយ ដោយសារតែការផ្អាកការសិក្សាសម្រាប់ឥរិយាបថដែលទាក់ទងដោយផ្ទាល់ទៅនឹងតម្រូវការពិសេសរបស់ពួកគេ ឬលទ្ធផលនៃកម្មវិធីអប់រំពិសេសដែលមិនសមរម្យ។ ការព្យួរការសិក្សារបស់សិស្សបែបនេះត្រូវបានកំណត់ថាជាចំណាត់ការណាមួយដែលនាំឱ្យមានការដកសិស្សនេះចេញពីកម្មវិធីដែលបានកំណត់ក្នុងផែនការ IEP របស់ពួកគេ។

សិស្សអាចត្រូវបានដកចេញ/ផ្អាកការសិក្សាពីកម្មវិធី/សាលារបស់ពួកគេរហូតដល់ដប់ (10) ថ្ងៃសិក្សាបូកសរុប ឬជាប់ៗគ្នាក្នុងមួយឆ្នាំសិក្សា។ ការដកចេញ/ការព្យួរការសិក្សាដែលអាចអនុញ្ញាតបានរួមមានការព្យួរការសិក្សាក្នុងសាលា ការដកចេញជាបន្ទាន់ ការព្យួរការសិក្សារយៈពេលខ្លី ការព្យួរការសិក្សារយៈពេលវែង ឬការចាត់តាំងទៅឱ្យកន្លែងអប់រំជំនួសបណ្តោះអាសន្ន។ ការដកចេញ/ការព្យួរការសិក្សាទាំងអស់ត្រូវតែគោរពតាម 603 CMR 53។

នៅពេលដែលសិស្សត្រូវបានដកចេញ/ព្យួរការសិក្សាសម្រាប់រយៈពេលដប់ (10) ថ្ងៃសិក្សា (ជាប់ៗគ្នា ឬសរុបចូលគ្នា) ក្នុងឆ្នាំសិក្សា ប្រការនេះត្រូវបានចាត់ទុកថាជាការផ្លាស់ប្តូរការដាក់ចូលថ្នាក់ ហើយក្រុម IEP ត្រូវតែប្រជុំឡើងវិញដើម្បីធ្វើការត្រួតពិនិត្យការកំណត់បាតុភាពដើម្បីកំណត់ថាតើឥរិយាបថនៃការព្រួយបារម្ភ គឺជាបាតុភាពនៃពិការភាពរបស់កុមារដែរឬទេ។

ការអនុវត្តនៅក្នុងសាលារដ្ឋ Lowell គឺថាបទល្មើសចំនួនបី (3) ករណី និង/ឬមិនលើសពីប្រាំពីរ (7) ថ្ងៃនៃការដកចេញ/ការព្យួរការសិក្សា ប្រធានក្រុមអប់រំ (ETC) នឹងចេញលិខិតយល់ព្រមសម្រាប់ការវិភាគឥរិយាបថមុខងារ (FBA) ជូនមាតាបិតា/អាណាព្យាបាល/អាណាព្យាបាល។ គោលបំណងនេះគឺដើម្បីប្រមូលទិន្នន័យដើម្បីបំពេញ FBA សម្រាប់បង្កើតផែនការអន្តរាគមន៍ឥរិយាបថសមស្រប (BIP) ដើម្បីដោះស្រាយបញ្ហាឥរិយាបថរបស់សិស្ស។

មិនលើសពីដប់ (10) ថ្ងៃសិក្សានៃការសម្រេចចិត្តផ្លាស់ប្តូរទីតាំងរបស់សិស្ស អ្នកគ្រប់គ្រងសាលា មាតាបិតា/អាណាព្យាបាល និងសមាជិកពាក់ព័ន្ធនៃក្រុមផែនការ IEP ត្រូវតែប្រជុំដើម្បីធ្វើការពិនិត្យឡើងវិញ (ការកំណត់បាតុភាព)។ នៅក្នុងកិច្ចប្រជុំត្រួតពិនិត្យការកំណត់បាតុភាពនេះ ក្រុមការងារផែនការ IEP នឹងកំណត់ថាតើបទល្មើសដែលសិស្សត្រូវទទួលរងគឺ (1) បណ្តាលមកពី ឬ និងពាក់ព័ន្ធដោយផ្ទាល់ និងយ៉ាងសំខាន់ទៅនឹងពិការភាពរបស់សិស្ស ឬ (2) គឺជាលទ្ធផលផ្ទាល់នៃការបរាជ័យក្នុងការអនុវត្តផែនការ IEP ឬផ្នែកទី 504 របស់សិស្សដែរឬទេ

ក្នុងអំឡុងពេលកិច្ចប្រជុំត្រួតពិនិត្យការកំណត់បាតុភាព សមាជិកនៃក្រុមផែនការ IEP នឹងពិនិត្យឡើងវិញនូវព័ត៌មានពាក់ព័ន្ធទាំងអស់នៅក្នុងឯកសាររបស់សិស្ស រួមទាំងផែនការ IEP កញ្ចប់ព័ត៌មានណែនាំអំពីវិន័យ ប្រសិនបើមាន ការសង្កេតរបស់គ្រូ និងព័ត៌មានពាក់ព័ន្ធណាមួយដែលផ្តល់ដោយមាតាបិតា/អាណាព្យាបាល ដើម្បីកំណត់ថាតើកំហុសកើតចេញពីពិការភាពឬអត់។

ប្រសិនបើឆ្លើយ "បាទ/ចាស" ចំពោះសំណួរណាមួយ នោះឥរិយាបថគឺជាបាតុភាព ហើយអ្វីៗខាងក្រោមនេះនឹងកើតឡើង៖

- បញ្ជូនសិស្សទៅកាន់ថ្នាក់ពីមុនវិញ ហើយពិនិត្យ និង/ឬធ្វើ FBA ហើយបង្កើត និង/ឬធ្វើបច្ចុប្បន្នភាព និងអនុវត្ត BIP។

- ប្រសិនបើ BIP បានអនុវត្តរួចហើយ ក្រុមការងារនឹងពិនិត្យផែនការ និងកែប្រែតាមតម្រូវការ ដើម្បីដោះស្រាយបញ្ហាឥរិយាបថ ហើយបញ្ជូនសិស្សទៅថ្នាក់ដែលសិស្សត្រូវបានដកចេញពីមុន។

- ប្រសិនបើបទល្មើសដែលសិស្សត្រូវទទួលរងគឺជាលទ្ធផលផ្ទាល់កើតឡើងពីការខកខានមិនបានអនុវត្តផែនការ IEP ឬផ្នែកទី 504 របស់សិស្ស នោះក្រុមផែនការ IEP គួរតែចាត់វិធានការចាំបាច់ដើម្បីកែតម្រូវបញ្ហាខកខានក្នុងការអនុវត្តរួមទាំង ប៉ុន្តែមិនកំណត់ត្រឹមចំពោះការចូលរួមពាក់ព័ន្ធពីនាយកសាលា និង/ឬនាយកផ្នែកអប់រំពិសេស។

ប្រសិនបើឆ្លើយ "ទេ" ចំពោះសំណួរទាំងពីរ នោះឥរិយាបថមិនមែនជាបាតុភាព ហើយអ្វីៗខាងក្រោមនេះអាចកើតឡើង៖

- សាលាអាចបន្តប្រើប្រាស់នីតិវិធីវិន័យរបស់សាលា រួមទាំងការដកចេញ/ការផ្អាកការសិក្សា។ ក្នុងអំឡុងពេលព្យួរការសិក្សា/ការដកចេញ សាលាត្រូវតែបន្តផ្តល់ឱ្យសិស្សនូវ FAPE ហើយត្រូវតែអនុវត្តតាមលក្ខខណ្ឌតម្រូវនៃប្រការ 603 CMR 53 រួមទាំង ប៉ុន្តែមិនកំណត់ត្រឹមចំពោះឱកាសក្នុងការធ្វើកិច្ចការសង និងការងារផ្សេងទៀតតាមតម្រូវការ ដើម្បីធ្វើឲ្យការសិក្សារីកចម្រើនក្នុងអំឡុងពេលព្យួរការសិក្សា/ការដកចេញ។

ប្រសិនបើមាតាបិតា/អាណាព្យាបាលមិនយល់ស្របនឹងការសម្រេចចិត្តរបស់ក្រុមការងារទាក់ទងនឹង "ការកំណត់បាតុភាព" ទេ មាតាបិតា/អាណាព្យាបាលមានសិទ្ធិស្នើសុំឱ្យមានការពន្លឿនដំណើរការសវនាការពីការិយាល័យបណ្តឹងឧទ្ធរណ៍សម្រាប់ការអប់រំពិសេស (BSEA) បាន។

ក្រុមការងារក៏អាចសម្រេចចិត្តមិនបញ្ជូនសិស្សទៅថ្នាក់ពីមុនរបស់ពួកគេវិញ ប្រសិនបើ (1) មាតាបិតា/អាណាព្យាបាល និងមណ្ឌលសិក្សាធិការយល់ព្រមលើការដាក់ចូលថ្នាក់ផ្សេង (2) មន្ត្រីសវនាការបញ្ជាឱ្យដាក់ចូលថ្នាក់ថ្មី ឬ (3) សិស្សត្រូវបានព្យួរការសិក្សាសម្រាប់ករណីពិសេស។

នៅក្រោមករណីពិសេស បុគ្គលិកសាលាអាចដកសិស្សចេញជាឯកតោភាគី ហើយដាក់សិស្សក្នុងកន្លែងអប់រំជំនួសបណ្ដោះអាសន្នរហូតដល់ 45 ថ្ងៃសិក្សា

មិនថាឥរិយាបថត្រូវបានកំណត់ថាជាបាតុភាពនៃពិការភាពរបស់សិស្សនោះឬអត់។
ករណីពិសេសមានដូចខាងក្រោមៈ

- សិស្សកំពុងកាន់កាប់អាវុធគ្រោះថ្នាក់នៅលើបរិវេណសាលា ឬនៅក្នុងព្រឹត្តិការណ៍ដែលឧបត្ថម្ភដោយសាលា
- សិស្សកំពុងកាន់កាប់ ឬប្រើប្រាស់គ្រឿងញៀនខុសច្បាប់នៅលើបរិវេណសាលា ឬក្នុងព្រឹត្តិការណ៍ដែលឧបត្ថម្ភដោយសាលា
- សិស្សបានចូលរួមក្នុងការស្នើសុំសារធាតុគ្រប់គ្រងនៅលើបរិវេណសាលា ឬនៅក្នុងព្រឹត្តិការណ៍ដែលឧបត្ថម្ភដោយសាលា ឬ
- សិស្សបានបង្កស្នាមរបួសរាងកាយធ្ងន់ធ្ងរដល់អ្នកផ្សេងទៀតនៅសាលា ឬនៅក្នុងព្រឹត្តិការណ៍ដែលឧបត្ថម្ភដោយសាលា។

ករណីពិសេស កន្លែងអប់រំជំនួសបណ្ដោះអាសន្ន ត្រូវតែអនុញ្ញាតឱ្យសិស្សចូលរួមក្នុងកម្មវិធីសិក្សាចំណេះទូទៅ វឌ្ឍនភាពឆ្ពោះទៅរកគោលដៅនៅក្នុងផែនការ IEP និងទទួលបានការអប់រំពិសេស និងសេវាកម្មពាក់ព័ន្ធដែលមាននៅក្នុងផែនការ IEP របស់សិស្ស។ កន្លែងជំនួសបណ្ដោះអាសន្នក៏ត្រូវតែផ្ដល់សេវាកម្ម និងការកែប្រែ ដែលត្រូវបានធ្វើឡើង ដើម្បីដោះស្រាយឥរិយាបថដែលនាំឱ្យមានការដកចេញ និងដើម្បីការពារឥរិយាបថបែបនេះកុំឲ្យកើតឡើងម្តងទៀត។

នៅចុងបញ្ចប់នៃរយៈពេលសិក្សាសែសិបប្រាំ (45) ថ្ងៃ សិស្សនឹងត្រូវត្រលប់ទៅថ្នាក់ពីមុនរបស់គាត់វិញ លើកលែងតែមាតាបិតា/អាណាព្យាបាល (ឬសិស្សបើមានអាយុចាប់ពី 18 ឆ្នាំឡើងទៅ) យល់ព្រមចំពោះការពន្យារពេលចំពោះកន្លែងជំនួសបណ្ដោះអាសន្ន ឬបទបញ្ជាទទួលបានពីការិយាល័យបណ្តឹងឧទ្ធរណ៍នៃការអប់រំពិសេស ដែលអនុញ្ញាតឱ្យបន្តការដកសិស្សចេញ។ សូមចំណាំថា ប្រសិនបើមាតាបិតា/អាណាព្យាបាលមិនយល់ស្របនឹងការសេចក្តីសម្រេចចំពោះ "ករណីពិសេស" និង/ឬ "កន្លែងអប់រំជំនួសបណ្ដោះអាសន្ន" ទេ មាតាបិតា/អាណាព្យាបាលក៏អាចប្រើប្រាស់សិទ្ធិរបស់ពួកគេចំពោះសវនាការតាមនីតិវិធីច្បាប់ពី BSEA បានផងដែរ។

ទោះជាយ៉ាងណាក៏ដោយ អវត្តមានក្នុងករណីពិសេស សាលានៅតែអាចដកសិស្សចេញទៅកាន់កន្លែងជំនួសបណ្ដោះអាសន្នសម្រាប់រយៈពេលសែសិបប្រាំ (45) ថ្ងៃសិក្សាដោយមាន៖ 1) ការយល់ព្រមពីមាតាបិតា/អាណាព្យាបាល ឬ 2) ដោយទទួលបានការអនុញ្ញាតពីតុលាការ ឬមន្ត្រីសវនាការ BSEA។ ដើម្បីទទួលបានដីកាពីតុលាការ ឬមន្ត្រីសវនាការរបស់ BSEA សាលាត្រូវតែបង្ហាញថាការរក្សាថ្នាក់ចាស់របស់សិស្សទំនងជាអាចបណ្ដាលឱ្យបង្កស្នាមរបួសដល់សិស្ស ឬអ្នកដទៃ។

មាតាបិតា/អាណាព្យាបាលត្រូវមានសិទ្ធិប្ដឹងឧទ្ធរណ៍លើការសម្រេចចិត្តរបស់ក្រុមការងារកំណត់បាតុភាពការអនុវត្តការផ្លាស់ប្ដូរវិន័យនៅក្នុងថ្នាក់ និងការដាក់សិស្សនៅក្នុងកន្លែងអប់រំជំនួសបណ្ដោះអាសន្ន។ សិស្សនឹងនៅតែស្ថិតក្នុងការដាក់វិន័យដែលធ្វើឡើងដោយអាជ្ញាធរសាលា ដោយរង់ចាំការសម្រេចចិត្តលើបណ្ដឹងឧទ្ធរណ៍ ឬរហូតដល់ផុតកំណត់នៃការដាក់ទណ្ឌកម្មវិន័យ ពោលគឺកំណត់យកមួយណាកើតមុន។

មិនយូរជាងកាលបរិច្ឆេទនៃការសម្រេចចិត្តដើម្បីចាត់វិធានការវិន័យ សាលាជូនដំណឹងដល់មាតាបិតាអំពីការសម្រេចចិត្តនោះ ហើយផ្ដល់ជូនពួកគេនូវសេចក្ដីជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការការពារតាមនីតិវិធី។ តំណភ្ជាប់ទៅកាន់សេចក្ដីជូនដំណឹងនេះមានដូចខាងក្រោម៖ https://www.doe.mass.edu/sped/prb/

# កម្មវិធីសាលាពេលថ្ងៃ និងកម្មវិធីជំនួស

**កម្មវិធី BRIDGE នៅសាលា David J. McHugh Alternative Middle School**
ទទួលយកសិស្ស LPS ដែលមានអាយុចន្លោះពី 12-16 ឆ្នាំ ដែលរៀននៅថ្នាក់ទី 6 ដល់ថ្នាក់ទី 8។ សិស្សត្រូវបានបញ្ជូនទៅកម្មវិធី BRIDGE ដោយផ្អែកលើការបែងចែករបស់សាលា ប្រសិនបើពួកគេមិនទទួលបានជោគជ័យក្នុងការដាក់ចូលថ្នាក់នៅសាលាមធ្យមសិក្សាទូទៅ ហើយមានបញ្ហានៃការសិក្សា ឥរិយាបថ និងវត្តមាន។ សម្រាប់សិស្សដែលមានផែនការ IEP កិច្ចប្រជុំអំពីការដាក់ចូលថ្នាក់ត្រូវតែធ្វើឡើងមុនពេលបន្តដំណើរការ។ ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីធានាថាអាចផ្តល់សេវាសមស្រប សិស្សដែលមានផែនការ IEPs នឹងត្រូវបានវាយតម្លៃតាមករណីនីមួយៗ ដើម្បីធានាថាការចុះឈ្មោះចូលរៀនមិនលើសចំណុះ ដើម្បីបំពេញតម្រូវការរបស់សិស្ស។ សិស្សដែលត្រូវបានធ្វើរោគវិនិច្ឆ័យថាមានពិការភាពផ្នែកសតិអារម្មណ៍ និងចេះភាសាអង់គ្លេសមានកម្រិត មិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់បញ្ជូនទៅកាន់កម្មវិធី BRIDGE នោះទេ។ សិស្សត្រូវបានទទួលយកទៅក្នុងកម្មវិធីពេញមួយឆ្នាំសិក្សា តាមតម្រូវការបច្ចុប្បន្ន។ សិស្សផ្នែកអប់រំចំណេះទូទៅអាចស្ថិតនៅក្នុងកន្លែងជំនួសសម្រាប់រយៈពេល 90 ថ្ងៃសិក្សា។ ការអប់រំពិសេស និងសិស្ស 504 អាចបន្តនៅក្នុងកន្លែងជំនួសសម្រាប់រយៈពេល 45 ថ្ងៃសិក្សា។ មុនពេលបញ្ចប់នៃការដាក់ចូលថ្នាក់រយៈពេល 90/45 ថ្ងៃសិក្សា កិច្ចប្រជុំអាចធ្វើឡើងដើម្បីបន្តការនៅបន្តរបស់សិស្ស ឬកិច្ចប្រជុំនេះអាចត្រូវបានលើកលែងដោយមាតាបិតា/អាណាព្យាបាល (អនុញ្ញាតឱ្យសិស្សស្នាក់នៅដោយមិនមានកិច្ចប្រជុំបែបនេះ)។ កិច្ចប្រជុំនេះនឹងត្រូវធ្វើឡើងរៀងរាល់ 90 ថ្ងៃសិក្សាសម្រាប់សិស្សផ្នែកអប់រំចំណេះទូទៅ ឬវាអាចត្រូវបានលើកលែងដោយមាតាបិតា/អាណាព្យាបាល ដរាបណាសិស្សនៅតែបន្តស្ថិតនៅក្នុងថ្នាក់។ មិនចាំបាច់មានកិច្ចប្រជុំនេះទេ សម្រាប់ការអប់រំពិសេស/សិស្ស 504 បន្ទាប់ពីកិច្ចប្រជុំ 45 ថ្ងៃសិក្សាដំបូង ពីព្រោះផែនការ IEPs/504 របស់សិស្សទាំងនេះនឹងត្រូវបានកែប្រែ ដើម្បីឆ្លុះបញ្ចាំងពីការដាក់ចូលថ្នាក់ជាថ្នាក់ថ្មីរបស់ពួកគេនៅក្នុងផែនការ IEP/504 ហើយកិច្ចប្រជុំណាមួយនឹងត្រូវបានធ្វើឡើងស្របតាមច្បាប់អប់រំពិសេសរបស់សហព័ន្ធ និងរដ្ឋ។ <u>ការរំពឹងទុកគឺថាសិស្សនៅតែស្ថិតក្នុងកម្មវិធី Bridge សម្រាប់ឆ្នាំសិក្សាមធ្យមរបស់ពួកគេ។</u> ទោះជាយ៉ាងណាក៏ដោយ សិស្សអាចត្រលប់ទៅសាលារបស់ពួកគេវិញនៅពេលដែលពួកគេបានរីកចម្រើនគ្រប់គ្រាន់ដើម្បីទទួលបានជោគជ័យ។

**សាលា Laura Lee Therapeutic Day School**
គឺជាកម្មវិធីអប់រំពិសេសដាច់ដោយឡែកមួយយ៉ាងសំខាន់ ដែលផ្តល់សេវាកម្មជូនសិស្សថ្នាក់មត្តេយ្យដល់ថ្នាក់ទី 7។ សិស្សទាំងអស់ដែលចូលរៀននៅសាលា Laura Lee ត្រូវតែមានផែនការ IEP ដែលមានពិការភាពផ្នែកសតិអារម្មណ៍ និងបញ្ហាក្នុងការដាក់ចូលថ្នាក់នៅសាលា Public Day School។ ក្រុមការងារផ្នែកអប់រំពិសេសរបស់សាលាដែលបញ្ជូនសិស្សគឺកំណត់ពិការភាព និងតម្រូវការនៃការដាក់ចូលថ្នាក់។ សិស្សដែលចូលរៀននៅសាលា Laura Lee ត្រូវតែមានពិការភាពផ្នែកសតិអារម្មណ៍យ៉ាងសំខាន់ រួមជាមួយនឹងបញ្ហាប្រឈមផ្នែកឥរិយាបថ ដែលទាមទារបរិយាកាសសាលាកាន់តែតឹងរ៉ឹង និងបង្កើនសេវាកម្មអប់រំពិសេសដែលលើសពីអ្វីដែលអាចផ្តល់ជូនក្នុងកម្រិតបឋមសិក្សា និងមធ្យមសិក្សាធម្មតា។ លើសពីនេះ ចំនួនសិស្សទាំងអស់ក៏មានសិស្សដែលត្រលប់ទៅសាលារដ្ឋវិញបន្ទាប់ពីឈប់ពីការដាក់ចូលថ្នាក់នៅក្រោមណ្ឌលសិក្សាធិការ។ សិស្សដែលចុះឈ្មោះចូលរៀនភាគច្រើនត្រូវបានធ្វើរោគវិនិច្ឆ័យថាមានបញ្ហាធំនៃសុខភាពផ្លូវចិត្តមួយ ឬច្រើនមុខ។ សិស្សនៅថ្នាក់ទី 8 ដល់ 12 ផ្លាស់ប្តូរទៅសាលា LeBlanc Therapeutic Day School។

**សាលា LeBlanc Therapeutic Day School**
គឺជាកម្មវិធីអប់រំពិសេសដាច់ដោយឡែកមួយយ៉ាងសំខាន់ ដែលផ្តល់សេវាកម្មជូនសិស្សថ្នាក់ទី 8 ដល់ទី 12។ សិស្សទាំងអស់ដែលចូលរៀននៅសាលា LeBlanc ត្រូវតែមានផែនការ IEP ដែលមានពិការភាពផ្នែកសតិអារម្មណ៍ និងការដាក់ចូលថ្នាក់នៅសាលា Public Day School។ ក្រុមការងារផ្នែកអប់រំពិសេសរបស់សាលាដែលបញ្ជូនសិស្សគឺកំណត់ពិការភាព និងតម្រូវការនៃការដាក់ចូលថ្នាក់។ សិស្សដែលចូលរៀននៅសាលា LeBlanc ត្រូវតែមានពិការភាពផ្នែកសតិអារម្មណ៍យ៉ាងសំខាន់ រួមជាមួយនឹងបញ្ហាប្រឈមផ្នែកឥរិយាបថ ដែលទាមទារបរិយាកាសសាលាកាន់តែតឹងរ៉ឹង និងបង្កើនសេវាកម្មអប់រំពិសេសដែលលើសពីអ្វីដែលអាចផ្តល់ជូនក្នុងបរិបទមធ្យមសិក្សា/វិទ្យាល័យធម្មតា។ សិស្សដែលចុះឈ្មោះចូលរៀនភាគច្រើនត្រូវបានធ្វើរោគវិនិច្ឆ័យថាមានបញ្ហាធំនៃសុខភាពផ្លូវចិត្តមួយ ឬច្រើនមុខ។

**សាលា Janice Adie Day School** គឺជាកម្មវិធីពេញមួយថ្ងៃ ប្រាំថ្ងៃក្នុងមួយសប្តាហ៍

ដែលបម្រើសិស្សថ្នាក់ត្រៀមមត្តេយ្យដល់ថ្នាក់ទី 12 ដែលមានជំងឺអូទីសឹម។ តម្រូវការពិសេសរបស់សិស្សទាមទារកន្លែងតូចជាងមុន ដោយមានការរៀបចំកម្មវិធីផ្ទាល់ខ្លួន និងកម្មវិធីឯកទេសជាងមុន។ ការងារជាក្រុមអន្តរកម្មសិក្សារបស់យើងនៅក្នុងបរិយាកាសសិក្សាដែលពោរពេញដោយគាំទ្រ ត្រូវបានបង្កើតឡើងដើម្បីជួយសិស្សគ្រប់រូបឱ្យទទួលបានជោគជ័យក្នុងការសិក្សា សហគមន៍ និងផ្ទះតាមរយៈការសិក្សាជំនាញទូទៅ។ សិស្សត្រូវបានអនុញ្ញាតឱ្យចូលរៀននៅសាលា Lowell Day តាមរយៈដំណើរការផែនការ IEP/ក្រុមការងារ។ បន្ទប់ថ្នាក់រៀនមានដប់ (10) បន្ទប់ ដែលបន្ទប់នីមួយៗមានគ្រូ (1) នាក់ និងអ្នកជំនួយការគ្រូបី (3) នាក់។ សិស្សទាំងអស់នៅសាលា Lowell Day School នឹងចូលរួមក្នុងការវាយតម្លៃទូទាំងរដ្ឋ និងមណ្ឌលសិក្សាធិការដែលកំណត់ដោយ IEP របស់ពួកគេ។

## គោលនយោបាយស្តីពីការប្រើប្រាស់ដែលអាចទទួលយកបាន

គោលបំណងអប់រំនៃគោលនយោបាយស្តីពីការប្រើប្រាស់ដែលអាចទទួលយកបានគឺស្របជាមួយនឹងបេសកកម្ម និងចក្ខុវិស័យនៃផែនការបច្ចេកវិទ្យារបស់សាលារដ្ឋ Lowell ហើយឆ្លុះបញ្ចាំងពីតម្លៃនៃសហគមន៍អ្នកសិក្សារបស់យើង។

- គួរតែមានសិទ្ធិចូលប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានដោយស្មើភាព។
- បច្ចេកវិទ្យាគួរតែប្រើប្រាស់ដើម្បីបង្រៀន រៀន និងអនុវត្តជំនាញជំនាញគិតបែបត្រិះរិះពិចារណា។
- បច្ចេកវិទ្យានៅពេលប្រើប្រាស់ដោយការទទួលខុសត្រូវ ធ្វើឱ្យមានភាពខុសគ្នានៃការបង្រៀន និងការរៀនសូត្រ ដោយផ្តល់សិទ្ធិទទួលបានឱកាសស្មើភាពសម្រាប់ទាំងអស់គ្នា។
- បច្ចេកវិទ្យាគឺជាកត្តាចាំបាច់ក្នុងពិភពលោកបច្ចុប្បន្ន។ វាមិនមែនជាការបន្ថែមលើកម្មវិធីសិក្សាទេ ប៉ុន្តែជាយានជំនិះដែលជំរុញដោយកម្មវិធីសិក្សាជាជាង។
- បុគ្គលិកត្រូវតែទទួលបានកម្រិតមូលដ្ឋាននៃការយល់ដឹងអំពីបច្ចេកវិទ្យាព័ត៌មាន ដើម្បីឱ្យសិស្សរបស់យើងទទួលបានធនធានពេញលេញដែលបច្ចេកវិទ្យាអាចផ្តល់ឱ្យ។

**កាតព្វកិច្ច និងការរំពឹងទុក**

អ៊ីនធឺណិតផ្តល់នូវលទ្ធភាពចូលប្រើប្រាស់ធនធានអប់រំដ៏មានឥទ្ធិពល ដែលអនុញ្ញាតឱ្យសិស្សស្វែងរកព័ត៌មាននៅលើបណ្តាញគ្រប់ទីកន្លែងក្នុងពិភពលោក។ វាជាឯកសិទ្ធិ មិនមែនជាសិទ្ធិទេ។

តាមរយៈការចុះហត្ថលេខាលើឯកសារនេះ អ្នកយល់ព្រមចំពោះទំនួលខុសត្រូវដូចខាងក្រោម៖

- ការប្រើប្រាស់ឧបករណ៍ផ្ទាល់ខ្លួនដែលភ្ជាប់ជាមួយបណ្តាញសាលាត្រូវតែគោរពតាមគោលនយោបាយស្តីពីការប្រើប្រាស់ដែលអាចទទួលយកបាន។
- ប្រើប្រាស់កុំព្យូទ័រសម្រាប់គោលបំណងដែលមានការអនុញ្ញាតប៉ុណ្ណោះ

ការសរសេរប្លក់ និងការផ្ញើអ៊ីមែលគឺត្រូវប្រើជាវេទិកាសម្រាប់ការរៀន និងការទំនាក់ទំនងរបស់សិស្សប៉ុណ្ណោះ ហើយត្រូវគោរពតាមវិធាន និងលក្ខខណ្ឌតម្រូវរបស់គ្រូក្នុងថ្នាក់ និងមណ្ឌលសិក្សាធិការ។

- ប្រើតែកម្មវិធីសុសវែររក្សាសិទ្ធិស្របច្បាប់ដែលសាលារដ្ឋ Lowell បានទិញ
- អនុលោមតាមច្បាប់រដ្ឋ និងសហព័ន្ធទាំងអស់ និងច្បាប់ការពារអ៊ីនធឺណិតរបស់កុមារ (CIPA)
- ការអនុលោមទៅតាមវិធានទូទៅរបស់សាលាអំពីឥរិយាបថល្អត្រូវបានរំពឹងទុកនៅលើបណ្តាញកុំព្យូទ័ររបស់សាលា ដូចដែលវាស្ថិតនៅក្នុងថ្នាក់រៀន ឬតាមសាលធំរបស់សាលា។
- ការអនុញ្ញាតពីមាតាបិតាត្រូវបានទាមទារសម្រាប់អនីតិជន។
- ការប្រើប្រាស់តំបន់ផ្ទុកបណ្តាញដោយការទទួលខុសត្រូវ - ដូចជាទូដាក់សម្ភារៈរបស់សាលា ឯកសារ និងការទំនាក់ទំនងអាចត្រូវបានពិនិត្យដោយអ្នកគ្រប់គ្រងបណ្តាញគ្រប់ពេល។
- ការប្រើប្រាស់កុំព្យូទ័រអាចត្រូវបានត្រួតពិនិត្យដោយគ្រូ ឬបុគ្គលិកកុំព្យូទ័រគ្រប់ពេល។
- ការប្រើប្រាស់បន្ទប់កុំព្យូទ័ររបស់សាលាដោយមានការត្រួតពិនិត្យតែពីមនុស្សពេញវ័យប៉ុណ្ណោះ។

**ការប្រើប្រាស់មិនត្រឹមត្រូវ**

សកម្មភាពដែលត្រូវបានចាត់ទុកថាជាការប្រើប្រាស់មិនត្រឹមត្រូវនូវបច្ចេកវិទ្យារបស់មណ្ឌលសិក្សាធិការ រួមមាន ប៉ុន្តែមិនកំណត់ត្រឹមចំពោះ៖

- ធ្វើឲ្យរអាក់រអួលបណ្តាញដោយចេតនា
- ព្យាយាមគេចវេស ឬបំផ្លាញវិធានការសុវត្ថិភាពប្រព័ន្ធ
- ប្រើប្រាស់ទិន្នន័យ ឬឯកសាររបស់អ្នកដទៃដោយគ្មានការអនុញ្ញាត
- ប្រើឈ្មោះអ្នកប្រើ ឬពាក្យសម្ងាត់របស់អ្នកដទៃ ឬបង្ហាញពាក្យសម្ងាត់របស់អ្នកដល់សិស្សផ្សេងទៀត
- បន្លំខ្លួនជាអ្នកប្រើផ្សេងទៀត ឬធ្វើសកម្មភាពអនាមិកណាមួយ
- ទាញយកកម្មវិធីណាមួយ រួមទាំងតន្ត្រី វីដេអូ ឬរូបភាពដោយគ្មានការអនុញ្ញាតពីគ្រូ
- ផ្ញើសារភ្លាមៗ ឬចូលរួមក្នុងបន្ទប់ឆាតក្រៅពីគោលបំណងអប់រំនៅលើកុំព្យូទ័រសាលា រួមទាំង iPad របស់សាលាផងដែរ។
- បំផ្លិចបំផ្លាញ លួច ឬការកែច្នៃសមាសភាគហាតវែរ ឬសុសវែរតាមវិធីណាមួយ
- ចម្លងឯកសារ ទិន្នន័យ ឬកម្មវិធីពីអ៊ីនធឺណិតដោយគ្មានការអនុញ្ញាត
- ទាញយកឯកសារតន្ត្រីដោយខុសច្បាប់
- ប្រើឧបករណ៍ពីផ្ទះ និងដោតចូលទៅក្នុងកុំព្យូទ័ររបស់សាលាសម្រាប់សាកថ្ម ផ្ទេរឯកសារ។ល។
- ព្យាយាមចូលប្រើ ឬទាញយកគេហទំព័រណាមួយនៅលើអ៊ីនធឺណិត ដែលផលិតសម្ភារៈដែលធ្វើឱ្យប៉ះពាល់អារម្មណ៍ ឬអាសអាភាស

ឬអាចញុះញង់ឱ្យមានការស្អប់ខ្ពើមពូជសាសន៍

- ប្រើប្រាស់បណ្តាញសម្រាប់គោលបំណងធ្វើពាណិជ្ជកម្ម ចំណេញផ្នែកហិរញ្ញវត្ថុ ឬការក្លែងបន្លំ
- ប្រើពាក្យអាសអាភាស ពាក្យជេរ ឬពាក្យប្រមាថ
- ប្រើប្រាស់កុំព្យូទ័រ ឬឧបករណ៍ណាមួយដែលភ្ជាប់ជាមួយបណ្តាញសាលា ដើម្បីបៀតបៀន ប្រមាថ ឬបង្ហោះព័ត៌មានបង្ខូចកេរ្តិ៍ឈ្មោះអំពីបុគ្គល ឬស្ថាប័នផ្សេងទៀត
- បញ្ចុះបញ្ចូលនយោបាយ
- លួចចម្លង – ចម្លងស្នាដៃដែលបង្កើតឡើងដោយអ្នកដ៏ទៃ ហើយបង្ហាញថាជារបស់ផ្ទាល់ខ្លួន
- រំលោភលើសិទ្ធិអ្នកនិពន្ធ – ការផលិតឡើងវិញនូវស្នាដៃដែលត្រូវបានការពារដោយច្បាប់រក្សាសិទ្ធិដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ ឬម្ចាស់កម្មសិទ្ធិបញ្ញា
- ប្រើប្រាស់កម្មវិធី ឬគេហទំព័រណាមួយដើម្បីរំលងតម្រងមាតិការបស់សាលា
- សកម្មភាពផ្សេងទៀតដែលបំពានលើក្រមប្រតិបត្តិវិន័យ និង/ឬរំខានយ៉ាងខ្លាំងដល់ដំណើរការអប់រំដើម្បីដាក់បញ្ចូលការប្រើប្រាស់ឧបករណ៍ផ្ទាល់ខ្លួន

**ផលវិបាកនៃការល្មើសគោលនយោបាយស្តីពីការប្រើប្រាស់ដែលអាចទទួលយកបាន**

គ្រូបង្រៀន ឬអ្នកគ្រប់គ្រងបណ្តាញមានឆន្ទានុសិទ្ធិក្នុងការចាត់វិធានការសមស្រប រួមទាំង ប៉ុន្តែមិនកំណត់ត្រឹមចំពោះ៖

- ការផ្អាក/ការដកហូតសិទ្ធិចូលប្រើបណ្តាញ
- ការផ្អាក/ការដកហូតសិទ្ធិចូលប្រើកុំព្យូទ័រ
- បញ្ជូនទៅនាយកសាលា ឬជំនួយការនាយកដើម្បីចាត់វិធានការវិន័យ៖
    - សេវាសហគមន៍
    - ការឃុំខ្លួន
    - ការព្យួរផ្អាកការសិក្សានៅសាលា
    - ការបណ្តេញចេញពីសាលា
    - ចំណាត់ការផ្លូវច្បាប់/ការកាត់ទោសដោយអាជ្ញាធរ
    - ឬចំណាត់ការផ្សេងទៀតដែលចាត់ទុកថាសមស្របដោយនាយកសាលា ឬជំនួយការនាយក

# ការជូនដំណឹងមាតាបិតាទាក់ទងនឹងការអប់រំផ្លូវភេទ

អនុលោមតាមច្បាប់ទូទៅរបស់រដ្ឋ Massachusetts ជំពូកទី 71 ផ្នែកទី 32A គណៈកម្មាធិការសាលា Lowell បានអនុម័តគោលនយោបាយនេះស្ដីពីសិទ្ធិមាតាបិតា និងអាណាព្យាបាលរបស់សិស្សរបស់យើងទាក់ទងនឹងកម្មវិធីសិក្សាដែលពាក់ព័ន្ធជាចម្បងទៅនឹងការអប់រំផ្លូវភេទរបស់មនុស្ស ឬបញ្ហាផ្លូវភេទរបស់មនុស្ស។

នៅដើមឆ្នាំសិក្សានីមួយៗ មាតាបិតា/អាណាព្យាបាលសិស្សទាំងអស់នៅក្នុងសាលារបស់យើងនឹងទទួលបានការជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីវគ្គសិក្សា និងកម្មវិធីសិក្សាដែលយើងផ្ដល់ជូន ដែលភាគច្រើនពាក់ព័ន្ធជាចម្បងទៅនឹងការអប់រំផ្លូវភេទរបស់មនុស្ស ឬបញ្ហាផ្លូវភេទរបស់មនុស្ស។ នាយកសាលានីមួយៗនឹងទទួលខុសត្រូវចំពោះការធ្វើសេចក្ដីជូនដំណឹងនេះ។ មាតាបិតា/អាណាព្យាបាលរបស់សិស្សដែលចុះឈ្មោះចូលរៀនបន្ទាប់ពីឆ្នាំសិក្សាចាប់ផ្ដើម នឹងទទួលបានការជូនដំណឹងជាលាយលក្ខណ៍អក្សរនៅពេលចុះឈ្មោះ។ ប្រសិនបើមានការផ្លាស់ប្ដូរកម្មវិធីសិក្សាដែលបានគ្រោងទុកក្នុងអំឡុងឆ្នាំសិក្សា ក្នុងកម្រិតដែលអាចអនុវត្តបាន មាតាបិតា/អាណាព្យាបាលនឹងត្រូវបានជូនដំណឹងអំពីការពិតនេះទាន់ពេលវេលាមុនពេលអនុវត្ត។

ការជូនដំណឹងបែបនេះចំពោះមាតាបិតា/អាណាព្យាបាលនីមួយៗនឹងរួមបញ្ចូលការពណ៌នាសង្ខេបអំពីកម្មវិធីសិក្សាដែលមានចែងក្នុងគោលនយោបាយនេះ ហើយនឹងជូនដំណឹងដល់មាតាបិតា/អាណាព្យាបាលថា ពួកគេអាច៖

- លើកលែងកូនរបស់ពួកគេពីផ្នែកណាមួយនៃកម្មវិធីសិក្សាដែលពាក់ព័ន្ធជាចម្បងទៅនឹងការអប់រំផ្លូវភេទរបស់មនុស្ស ឬបញ្ហាផ្លូវភេទរបស់មនុស្ស ដោយមិនមានការពិន័យសិស្ស ដោយផ្ញើលិខិតទៅនាយកសាលា ដើម្បីស្នើសុំការលើកលែង។ សិស្សណាក៏ដោយដែលត្រូវបានលើកលែងដោយមានការស្នើសុំពីមាតាបិតា/អាណាព្យាបាលក្រោមគោលនយោបាយនេះ អាចត្រូវបានផ្ដល់កិច្ចការផ្សេងជំនួស។

- ពិនិត្យ និងពិនិត្យសើរើឯកសារបង្រៀនសម្រាប់កម្មវិធីសិក្សាទាំងនេះ

ដែលនឹងត្រូវបានផ្តល់ជូនដោយសមរម្យសម្រាប់មាតាបិតា/អាណាព្យាបាល និងអ្នកដទៃក្នុងវិសាលភាពដែលអាចអនុវត្តបាន។ មាតាបិតា/អាណាព្យាបាលអាចរៀបចំជាមួយនាយកសាលាដើម្បីពិនិត្យសើរើឯកសារនៅសាលា។

មាតាបិតា/អាណាព្យាបាលដែលមិនពេញចិត្តនឹងការសម្រេចចិត្តរបស់នាយកសាលាទាក់ទងនឹងការជូនដំណឹង ការទទួលបានសម្ភារបង្រៀន ឬការលើកលែងសម្រាប់សិស្សក្រោមគោលនយោបាយនេះអាចធ្វើសំណើជាលាយលក្ខណ៍អក្សរទៅកាន់អគ្គនាយកសាលាសុំឲ្យពិនិត្យសើរើបញ្ហានេះបាន។ អគ្គនាយក ឬអ្នកទទួលសិទ្ធិនឹងពិនិត្យសើរើបញ្ហានេះ ហើយផ្តល់ឱ្យមាតាបិតា/អាណាព្យាបាលនូវការសម្រេចចិត្តជាលាយលក្ខណ៍អក្សរទាន់ពេលវេលាជាពិសេសក្នុងរយៈពេលបួនសប្តាហ៍នៃការស្នើសុំ។ មាតាបិតា/អាណាព្យាបាលដែលនៅតែមិនពេញចិត្តបន្ទាប់ពីដំណើរការនេះអាចធ្វើសំណើជាលាយលក្ខណ៍អក្សរទៅកាន់ស្ទងការផ្នែកអប់រំបឋមសិក្សា និងមធ្យមសិក្សា សុំឲ្យពិនិត្យសើរើបញ្ហាដែលកំពុងមានជម្លោះបាន។

## ការជូនដំណឹងពីមាតាបិតាទាក់ទងនឹងការពិនិត្យសុខភាពផ្លូវចិត្ត

ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីលើកកម្ពស់សុខភាព និងសុខុមាលភាពរបស់សិស្សនៅក្នុងសាលារដ្ឋ Lowell សិស្សនឹងត្រូវបានផ្តល់ជូនជាទៀងទាត់នូវកម្រងសំណួរ ការស្ទង់មតិ និងកម្មវិធីត្រួតពិនិត្យដែលដោះស្រាយបញ្ហាទាក់ទងនឹងសុខភាពផ្លូវចិត្ត។

ព័ត៌មានដែលទទួលបាននឹងគាំទ្រដល់សមត្ថភាពរបស់សាលាក្នុងការផ្តល់ការគាំទ្រពេញទំហឹង និងទាន់ពេលវេលាសម្រាប់សិស្ស ប្រសិនបើពួកគេត្រូវការជំនួយណាមួយ។ មាតាបិតា និងអាណាព្យាបាល ក៏ដូចជាសិស្សអាចជ្រើសរើសដកខ្លួនចេញពីការបំពេញកម្រងសំណួរ ការស្ទង់មតិ ឬកម្មវិធីត្រួតពិនិត្យ ដែលពួកគេមិន

ចាប់អារម្មណ៍។ មាតាបិតា/អាណាព្យាបាលអាចជ្រើសរើសកូន(ច្រើននាក់) របស់ពួកគេជារៀងរាល់ឆ្នាំ នៅពេលណាក៏បានដោយទាក់ទងមន្ត្រី

សង្គមកិច្ចនៃសាលារបស់កូនពួកគេ

ឬដោយបំពេញទម្រង់បែបបទជ្រើសរើសដកខ្លួនដែលនឹងត្រូវបានផ្តល់ដោយសាលារៀន

ឬមណ្ឌលសាលាមុនពេលរដ្ឋបាលនៃការពិនិត្យសុខភាពផ្លូវចិត្តដែលបានគ្រោងទុក។

មាតាបិតា/អាណាព្យាបាលអាចចូលទៅកាន់គេហទំព័រសុខភាពផ្លូវចិត្ត/ការរៀនពីអារម្មណ៍និងសង្គមរបស់មណ្ឌលសាលា ដើម្បីពិនិត្យមើលបញ្ជីនៃការស្ទង់មតិ កម្រងសំណួរ

និងឧបករណ៍ត្រួតពិនិត្យទាំងអស់ដែលកំពុងផ្តល់ឲ្យ។

# បទប្បញ្ញត្តិស្តីពីកំណត់ត្រាសិស្ស

កំណត់ត្រាសិស្សគឺជាព័ត៌មានណាមួយអំពីសិស្សដែលត្រូវបានរក្សាទុកនៅក្នុងសាលា (និទ្ទេស ពិន្ទុប្រឡង មូលវាចារណ៍)។ វាជាផ្នែកមួយនៃ "ព្រឹត្តិប័ត្រពិន្ទុ" របស់អ្នក (ឈ្មោះ អាសយដ្ឋាន វគ្គសិក្សាដែលបានសិក្សា ពិន្ទុ និងនិទ្ទេស) និង "កំណត់ត្រាបណ្ដោះអាសន្ន" (របាយការណ៍វឌ្ឍនភាព ពិន្ទុតេស្ត ចំណាត់ថ្នាក់ សកម្មភាពក្រៅកម្មវិធីសិក្សា និងព័ត៌មានអប់រំដែលពាក់ព័ន្ធផ្សេងទៀត)។

សម្រាប់សិស្សដែលមានអាយុចាប់ពី 14 ឆ្នាំឡើងទៅ សិទ្ធិដែលបានកត់សម្គាល់ខាងក្រោមគឺជារបស់សិស្ស និងមាតាបិតារបស់គាត់។ សម្រាប់សិស្សដែលមានអាយុក្រោម 14 ឆ្នាំ សិទ្ធិដែលបានកត់សម្គាល់ខាងក្រោមគឺជារបស់មាតាបិតាតែប៉ុណ្ណោះ។

សាលារដ្ឋ Lowell មានកាតព្វកិច្ចគោរពតាមវិធាន/ច្បាប់/បទប្បញ្ញត្តិដែលកំណត់ក្នុងច្បាប់ស្តីពីសិទ្ធិ និងឯកជនភាពនៃការអប់រំគ្រួសារ (FERPA) និងបទបញ្ញត្តិរដ្ឋ Massachusetts 603 CMR 23.00 ចែងលម្អិតអំពីសិទ្ធិសិស្ស និងមាតាបិតាទាក់ទងនឹងកំណត់ត្រាសិស្ស។

ផ្នែកទី 23.10៖ ការជូនដំណឹងតម្រូវឱ្យធ្វើឡើងយ៉ាងហោចណាស់ម្តងក្នុងអំឡុងឆ្នាំសិក្សានីមួយៗ សាលាត្រូវបោះពុម្ព និងចែកជូនសិស្ស/មាតាបិតានូវសេចក្តីជូនដំណឹងប្រចាំឆ្នាំអំពីសិទ្ធិទូទៅរបស់ពួកគេទាក់ទងនឹងកំណត់ត្រាសិស្ស ដូចមាននៅក្នុងលិខិតនេះ។ តាមការស្នើសុំ សាលារដ្ឋ Lowell នឹងផ្តល់ជូនមាតាបិតា និងសិស្សនូវច្បាប់ចម្លងពេញលេញនៃបទប្បញ្ញត្តិដែលនឹងរៀបរាប់លម្អិតអំពីសិទ្ធិរបស់ពួកគេ។

**ការមើលកំណត់ត្រារបស់អ្នក**

សិស្ស និងមាតាបិតាមានសិទ្ធិមើល និងថតចម្លងអ្វីៗគ្រប់យ៉ាងនៅក្នុងកំណត់ត្រារបស់សិស្សក្នុងរយៈពេល 10 ថ្ងៃនៃការស្នើសុំ។ សាលាប្រហែលជាមិនគិតថ្លៃអ្នកលើសពីថ្លៃថតចម្លងឡើយ។

**ឯកជនភាពនៃកំណត់ត្រារបស់អ្នក**

បុគ្គលិកសាលាដែលធ្វើការដោយផ្ទាល់ជាមួយសិស្សអាចមើលកំណត់ត្រានៅពេលដែលវាចាំបាច់សម្រាប់ពួកគេបំពេញភារកិច្ចរបស់ពួកគេ។ ដោយមានករណីលើកលែងតិចតួចបំផុត គ្មាននរណាម្នាក់អាចមើលកំណត់ត្រាសិស្សដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីសិស្ស ឬមាតាបិតាបានឡើយ។

**ការបំផ្លាញកំណត់ត្រារបស់អ្នក**

អនុលោមតាមប្រការ 603 CMR 23.06 (2) ក្នុងអំឡុងឆ្នាំសិក្សាដែលសិស្សបានចុះឈ្មោះចូលរៀននៅសាលា នាយកសាលា ឬអ្នកទទួលសិទ្ធិត្រូវពិនិត្យ និងបំផ្លាញតាមពេលកំណត់នូវព័ត៌មានបំភាន់ ចាស់ ឬមិនពាក់ព័ន្ធ (រួមទាំងច្បាប់ចម្លងនៃឯកសារដើម) ដែលមាននៅក្នុងកំណត់ត្រាបណ្តោះអាសន្នក្នុងករណីសិស្សដែលមានសិទ្ធិ និងមាតាបិតារបស់គាត់ត្រូវបានជូនដំណឹងជាលាយលក្ខណ៍អក្សរ ហើយត្រូវបានផ្តល់ឱកាសឱ្យទទួលបានព័ត៌មាន ឬច្បាប់ចម្លងមុននឹងបំផ្លាញចោល។

ច្បាប់ចម្លងនៃការជូនដំណឹងបែបនេះនឹងត្រូវបានដាក់ក្នុងកំណត់ត្រាបណ្តោះអាសន្ន។

ប្រសិនបើអ្នកមិនចង់ឱ្យនាយកសាលា ឬអ្នកទទួលសិទ្ធិបំផ្លាញចោលកំណត់ត្រាបែបនេះ ឬអ្នកចង់រក្សាទុកកំណត់ត្រាដែលត្រូវបានគូសសម្គាល់សម្រាប់ការបំផ្លាញចោល នោះមាតាបិតា/អាណាព្យាបាលត្រូវតែជូនដំណឹងជាលាយលក្ខណ៍អក្សរភ្លាមៗទៅនាយកសាលា ឬអ្នកទទួលសិទ្ធិអំពីសំណើនោះ បន្ទាប់ពីទទួលបានសេចក្តីជូនដំណឹងអំពីការបំផ្លាញចោល។

**ការកែប្រែកំណត់ត្រារបស់អ្នក និងប្តឹងឧទ្ធរណ៍ប្រឆាំងនឹងការកែប្រែ**

សិស្ស ឬមាតាបិតាអាចបន្ថែមឯកសារសំណេរដែលពាក់ព័ន្ធណាមួយទៅក្នុងកំណត់ត្រាបាន។ ប្រសិនបើមានព័ត៌មាននៅក្នុងកំណត់ត្រាដែលសិស្ស ឬមាតាបិតាគិតថាមិនត្រឹមត្រូវ បំភាន់ ឬមិនពាក់ព័ន្ធ ហើយសិស្ស ឬមាតាបិតាចង់លុបវាចេញ សិស្ស ឬមាតាបិតាអាចស្នើសុំឱ្យនាយកសាលារបស់អ្នកលុបវាចេញបាន (សូមមើលបទប្បញ្ញត្តិ 603 CMR 23:08 របស់ក្រសួងអប់រំស្តីពីកំណត់ត្រាសិស្ស)។

ប្រសិនបើសំណើត្រូវបានបដិសេធ ឬប្រសិនបើសិស្ស ឬមាតាបិតាមានការជំទាស់ផ្សេងទៀតចំពោះគោលនយោបាយស្តីពីកំណត់ត្រារបស់សាលា មានដំណើរការបណ្តឹងឧទ្ធរណ៍ដែលសិស្ស ឬមាតាបិតាអាចប្រើប្រាស់បាន។ ដំណើរការនេះត្រូវបានពិពណ៌នានៅក្នុងបទប្បញ្ញត្តិ 603 CMR 23:09 របស់ក្រសួងអប់រំស្តីពីកំណត់ត្រា។

នេះគ្រាន់តែជាការសង្ខេបអំពីសិទ្ធិរបស់អ្នកក្រោមបទប្បញ្ញត្តិប៉ុណ្ណោះ។
អ្នកអាចទទួលបានច្បាប់ចម្លងនៃបទប្បញ្ញត្តិពីនាយកដ្ឋានអប់រំបឋមសិក្សា និងមធ្យមសិក្សារដ្ឋ Massachusetts ឬគេហទំព័រ (ជំពូកទី 71 ផ្នែកទី 34D និង 34EF នៃច្បាប់ទូទៅ ឆ្នាំ 1973)។

នេះគ្រាន់តែជាសេចក្តីសង្ខេបនៃសិទ្ធិរបស់អ្នកនៅក្រោមបទប្បញ្ញត្តិ.
អ្នកអាចទទួលបានច្បាប់ចម្លងនៃបទប្បញ្ញត្តិពីនាយកដ្ឋានអប់រំបឋមសិក្សា និងមធ្យមសិក្សារដ្ឋ Massachusetts ឬគេហទំព័ររបស់ពួកគេ (ជំពូកទី 71; ផ្នែក 34D និង 34EF នៃច្បាប់ទូទៅ, 1973).

**ការចេញផ្សាយកំណត់ត្រាទៅសាលាផ្សេងទៀត៖**

អនុលោមតាមប្រការ 603 CMR 23.07 (4) (g) ក្នុងអំឡុងឆ្នាំសិក្សាដែលសិស្សបានចុះឈ្មោះចូលរៀន នាយកសាលា ឬអ្នកទទួលសិទ្ធិអាចផ្តល់ជូនបុគ្គលិកសាលាដែលមានការអនុញ្ញាតរបស់សាលា ដែលសិស្សស្វែងរក ឬមានបំណងផ្ទេរសិទ្ធិចូលមើលកំណត់ត្រារបស់សិស្ស ដោយគ្មានការយល់ព្រមពីសិស្ស ឬមាតាបិតាដែលមានសិទ្ធិបាន។ កំណត់ត្រាសិស្សក៏អាចត្រូវបានបញ្ជូនបន្តដោយនាយកសាលា ឬអ្នកទទួលសិទ្ធិរបស់គាត់ទៅកាន់សាលាដែលសិស្សស្វែងរក ឬមានបំណងផ្ទេរទៅ។
ខាងលើគឺជាសេចក្តីសង្ខេបនៃសិទ្ធិរបស់អ្នកក្រោមបទប្បញ្ញត្តិកំណត់ត្រាសិស្ស។
អ្នកអាចស្នើសុំច្បាប់ចម្លងនៃបទប្បញ្ញត្តិពីមជ្ឈមណ្ឌលសេវាកម្មសិស្សនៃនាយកដ្ឋានអប់រំបឋមសិក្សា និងមធ្យមសិក្សារដ្ឋ Massachusetts (ជំពូកទី 71៖ ផ្នែកទី 34D និង 34F នៃច្បាប់ទូទៅ ឆ្នាំ 1973)។

ខាងលើគឺជាសេចក្តីសង្ខេបនៃសិទ្ធិរបស់អ្នកក្រោមបទប្បញ្ញត្តិកំណត់ត្រាសិស្ស។
អ្នកអាចស្នើសុំច្បាប់ចម្លងនៃបទប្បញ្ញត្តិពីមជ្ឈមណ្ឌលសេវាកម្មនិស្សិតនៃនាយកដ្ឋានបឋមសិក្សា និងមធ្យមសិក្សារដ្ឋ Massachusetts ( ជំពូកទី 71: ផ្នែក 34D និង 34F នៃច្បាប់ទូទៅ, 1973 )។

**សេចក្តីជូនដំណឹងដល់មាតាបិតា និងសិស្សទាំងអស់អំពីការបំផ្លាញចោលកំណត់ត្រាសិស្ស**

អនុលោមតាមបទប្បញ្ញត្តិរដ្ឋលេខ 603CMR23.06 កំណត់ត្រាបណ្តោះអាសន្នរបស់សិស្ស (ព័ត៌មានទាំងអស់ដែលមិនមាននៅក្នុងព្រឹត្តិប័ត្រពិន្ទុរបស់សិស្ស) នឹងត្រូវបំផ្លាញចោលមិនលើសពី 7 ឆ្នាំគិតចាប់ពីថ្ងៃដក ផ្ទេរ ឬបញ្ចប់ការសិក្សារបស់សិស្ស។ វាជាសិទ្ធិរបស់អ្នកក្នុងការទទួលបានកំណត់ត្រាទាំងនេះ

មុនពេលកំណត់ត្រាទាំងនេះត្រូវបានបំផ្លាញចោល។ ប្រសិនបើសិស្ស ឬមាតាបិតាចង់មានកំណត់ត្រាទាំងនេះ ពួកគេអាចទាក់ទងអ្នកប្រឹក្សាណែនាំនៅសាលារបស់សិស្ស។ ប្រសិនបើកំណត់ត្រាមិនត្រូវបានស្នើសុំក្នុងរយៈពេល 7 ឆ្នាំគិតចាប់ពីថ្ងៃដក ផ្ទេរ ឬបញ្ចប់ការសិក្សារបស់សិស្ស កំណត់ត្រាដែលរួមមាន ប៉ុន្តែមិនកំណត់ត្រឹមចំពោះ លទ្ធផលតេស្ត ចំណាត់ថ្នាក់ សកម្មភាពក្រៅកម្មវិធីសិក្សា និងការវាយតម្លៃរបស់គ្រូអាចនឹងត្រូវបំផ្លាញចោល។ **កំណត់ត្រាអចិន្ត្រៃយ៍នឹងត្រូវបានរក្សាទុកសម្រាប់រយៈពេលហុកសិប (60) ឆ្នាំ។**

**បុគ្គលដូចខាងក្រោមដែលបម្រើការងារក្នុងតួនាទីជាមាតាបិតាមានសិទ្ធិចូលមើលកំណត់ត្រារបស់សិស្ស៖**

- ឪពុករបស់សិស្ស
- ម្តាយរបស់សិស្ស
- អាណាព្យាបាលសិស្ស
- បុគ្គល ឬទីភ្នាក់ងារដែលមានសិទ្ធិស្របច្បាប់ក្នុងការធ្វើការជំនួស ឬជាមួយឪពុក ម្តាយ ឬអាណាព្យាបាលរបស់សិស្ស
- ឪពុកម្តាយដែលលែងលះគ្នា ឬរស់នៅបែកគ្នា (ជាកម្មវត្ថុនៃកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរណាមួយរវាងឪពុកម្តាយ ឬដីកាតុលាការដែលគ្រប់គ្រងសិទ្ធិរបស់មាតាបិតាដែលត្រូវជូនដំណឹងដល់សាលា)។

**សិទ្ធិចូលមើលកំណត់ត្រាសាលាសម្រាប់មាតាបិតាដែលមិនមានសិទ្ធិឃុំគ្រង**

ច្បាប់បទប្បញ្ញត្តិស្តីពីកំណត់ត្រារបស់សាលានៃរដ្ឋ Massachusetts ជំពូកទី 71 ផ្នែកទី 34H តម្រូវឱ្យមាតាបិតាដែលមិនមានសិទ្ធិឃុំគ្រងផ្តល់ការផ្ទៀងផ្ទាត់ក្នុងទម្រង់ជាដីកាតុលាការផ្នែកមតក ឬសាលក្រមទាក់ទងនឹងសិទ្ធិឃុំគ្រងកុមារ ដោយបញ្ជាក់យ៉ាងលម្អិត ថាគាត់មិនទាន់ត្រូវបានបដិសេធនៅក្នុងដីការបស់តុលាការនូវសិទ្ធិឃុំគ្រងផ្អែកលើការគំរាមកំហែងដល់សុវត្ថិភាពរបស់កុមារ ឬមាតាបិតាដែលមានសិទ្ធិឃុំគ្រង។

**មាតាបិតាដែលមិនមានសិទ្ធិឃុំគ្រងមិនអាចចូលមើលកំណត់ត្រាសាលារបស់សិស្សបានទេ នៅពេលដែល៖**

- មាតាបិតាត្រូវបានបដិសេធនូវសិទ្ធិឃុំគ្រងស្របច្បាប់ដោយសារការគំរាមកំហែងដល់សុវត្ថិភាពរបស់កុមារ ឬមាតាបិតាដែលមានសិទ្ធិឃុំគ្រង។
- មាតាបិតាត្រូវបានបដិសេធមិនឲ្យទៅសួរសុខទុក្ខកូន ឬត្រូវបានបង្គាប់ឱ្យសួរសុខទុក្ខកូនដោយក្រោមការត្រួតពិនិត្យ។
- សិទ្ធិរបស់មាតាបិតាទៅមើលកុមារ

ឬមាតាបិតាដែលមានសិទ្ធិឃុំគ្រងត្រូវបានដាក់កម្រិតដោយដីការក្សាការពារបណ្ដោះអាសន្ន ឬជាអចិន្ត្រៃយ៍ លើកលែងតែមានដីការក្សាការពារ (ឬដីកាជាបន្តបន្ទាប់ណាមួយដែលកែប្រែដីការក្សាការពារ) ជាពិសេសអនុញ្ញាតឱ្យចូលមើលព័ត៌មានសិស្សដែលបានពិពណ៌នានៅក្នុងលក្ខន្តិកៈ។

ច្បាប់ទូទៅនៃរដ្ឋ Massachusetts ជំពូកទី 71 ផ្នែកទី 34H តម្រូវឱ្យមាតាបិតាដែលមិនមានសិទ្ធិឃុំគ្រងដាក់សំណើជាលាយលក្ខណ៍អក្សរទៅកាន់សាលា **ជារៀងរាល់ឆ្នាំ**។ ចំពោះព័ត៌មានបន្ថែម សូមទាក់ទងនាយកសាលារបស់កូនអ្នក។